# អ្នកគ្មានទោសក្នុងពន្ធនាគារ ៖

**របាយការណ៍អង្គការលីកាដូ ស្តីពី**

**សិទ្ធិរបស់កុមារដែលចំរើនវ័យក្នុងពន្ធនាគារ**



# I- បុព្វកថា

មានមនុស្សមួយចំនួនដែលត្រូវតែរស់នៅក្នុងពន្ធនាគារ ទោះបីជាគេមិនដែលបានប្រព្រឹត្តិ ឬត្រូវបានចោទប្រកាន់ពីការប្រព្រឹត្តិបទឧក្រិដ្ឋណាមួយក៏ដោយ ។ របាយការណ៍នេះប្រហែលជាមិនទាន់ធ្វើអោយមានការកន្រ្តាក់អារម្មណ៏ខ្លាំងណាស់ណាទេ ដោយសារនេះគ្រាន់តែជាករណីកុមាររស់នៅក្នុងពន្ធនាគារជាមួយនិងឪពុកម្តាយជាទណ្ឌិតឬពិរុទ្ធជនតែប៉ុណ្ណោះ ។ តើកុមារដែលកំពុងត្រូវបានចិញ្ចឹមនៅក្នុងបរិវេណពន្ធនាគារទាំងនោះបានជួបប្រទះនឹងបញ្ហាអ្វីខ្លះ? ទោះបីជាចំនួនកុមារកម្ពុជាដែលកំពុងរស់នៅជាមួយឪពុក ម្តាយ ដែលស្ថិតក្រោមការឃុំឃាំងមិនមានកំរិតខ្ពស់ខុសប្រក្រតីក៏ដោយ ក៏វាជារឿងមួយមិនធម្មតាដែរចំពោះកុមារមួយចំនួនដែលត្រូវទៅតាមម្តាយនៅក្នុងពន្ធនាគារ ហើយជារឿងមិនធម្មតាដែរសំរាប់ស្រ្តីមួយចំនួនដែលសម្រាលកូនចំពេលដែលនាងកំពុងស្ថិតនៅក្នុងពន្ធនាគារនោះ ។ គេបានពិចារណាបញ្ហានេះយ៉ាងយកចិត្តទុកដាក់ជាទីបំផុតដើម្បីធានាអោយមានការអនុវត្តន៏ស្របទៅតាមសេចក្តីណែនាំជាតិ និងប្រកាសច្បាស់លាស់ ដែលមាននៅក្នុងនីតិវិធីជាបទដ្ឋានពន្ធនាគារដែលបានចេញដោយក្រសួងមហាផ្ទៃប្រទេសកម្ពុជា ។

អាស្រ័យដោយបញ្ហានេះ មិនសូវមានគេចាប់អារម្មណ៏ ហើយកន្លងមកក៏មិនដែលមានការធ្វើការស្រាវជ្រាវអោយបានជាក់លាក់នូវប្រធានបទនេះដែរ ។ ក្រៅពីមានរបាយការណ៏ជាប្រចាំពីការិយាល័យពេទ្យនិងការិយាល័យគំរោងកម្មវិធីពន្ធនាគាររបស់អង្គការលីកាដូ មិនដែលមានអង្គការជាតិឬអន្តរជាតិណាបានធ្វើការប្រមូលទិន្នន័យទាក់ទងទៅនឹងពិរុទ្ធជនឬទណ្ឌិតជាស្រ្តីឬកុមារដែលរស់នៅជាមួយពិរុទ្ធជនទណ្ឌិតទាំងនោះនៅឡើយទេ ហើយក៏នៅមិនទាន់មានអង្គការណាមួយបានបង្កើតកម្មវិធីរបស់ខ្លួនដើម្បីដោះស្រាយបញ្ហាដែលជនទាំងនោះកំពុងតែប្រឈមមុខដែរ ។ អ្នកស្រាវជ្រាវបានសង្កេតឃើញថាមានតែអង្គការលីកាដូមួយគត់ដែលផ្តល់សេវាជាប្រចាំក្នុងពេលបច្ចុប្បន្ន ដោយផ្តោតការយកចិត្តទុកដាក់ទៅលើស្រ្តីនិងកុមាររស់នៅក្នុងពន្ធនា គារ[១] ។

---

[១] *អ្នកផ្តល់ការសំភាសន៏ក៏បានរាយការណ៏ថាមានអង្គការមួយចំនួនទៀតបានចូលមកជួយដែរ ដូចជាអង្គការ អាដហុក (របាយការណ៏ពីម្តាយម្នាក់ និង ចាងហ្វាងពន្ធនាគារ ២ នាក់) ។ ចាងហ្វាងពន្ធនាគារម្នាក់និង បុគ្គលិកពន្ធនាគារ ២នាក់បានរាយការណ៏ថា អង្គការ CHHRA ក៏បានចូលមកជួយដែរ ។ ចាងហ្វាងពន្ធនាគារម្នាក់បានរាយការណ៏ថា អង្គការ LAC បានចូលមកជួយពិគ្រោះផ្នែកច្បាប់ដល់អនីតិជនតែប៉ុណ្ណោះ ។ ចាងហ្វាងពន្ធនាគារម្នាក់បានរាយការណ៏ថាអង្គការ MSF បានជួយផ្នែកសេវាសុខភាពដែរ ហើយចាងហ្វាងម្នាក់ទៀតរាយការណ៏ដែរថា UNCOHCHR ក៏បានជួយដែរ ។ ប៉ុន្តែអ្នកផ្តល់សំភាសន៏នោះបាននិយាយថាមានតែលីកាដូទេដែលផ្តល់សេវាសុខភាពជាប្រចាំ ហើយច្រើនតែបានផ្តល់នូវ*

អង្គការលីកាដូ បានផ្តល់ការព្យាបាលជំងឺ សំរាប់អ្នកទោសទាំងឡាយហើយក៏បានផ្តល់ម្ហូបអាហារបន្ថែមដល់ម្តាយនិងកូនព្រមទាំងស្ត្រីមានផ្ទៃពោះផងដែរ ។ ការិយាល័យកុមាររបស់អង្គការលីកាដូបានធ្វើការចែកចាយម្ហូបអាហារមួយខែម្តងដល់មាតាណា ដែលមានកូននៅក្នុងពន្ធនាគារនិងស្ត្រីមានផ្ទៃពោះហើយអាហារទាំងនោះរួមមានៈ ត្រីខកំប៉ុង អង្ករ ប្រេងឆា ហើយជួនកាលក៏មានទឹកដោះគោកំប៉ុង ឬម្សៅផងដែរ ។ ការផ្តល់អាហារបែបនេះជាធម្មតាធ្វើនៅក្នុងកំឡុងពេល ពី៣ ទៅ ៦ ខែក្រោយពេលសម្រាលកូនរួចហើយពេលវេលានៃការផ្តល់នេះគឺប្រែប្រួលទៅតាមកាលៈទេសៈជាក់ស្តែង ។ ជាឧទាហរណ៏ នៅពន្ធនាគារមណ្ឌលកែប្រែទី២ អ្នកស្រាវជ្រាវបានឃើញដោយផ្ទាល់ភ្នែក ដែលម្តាយទាំងអស់ដែលមានកូនតូចៗ រួមទាំងអ្នកដែលមានកូនធំៗហើយផងដែរ បានទទួលអាហារបន្ថែមពីអង្គការលីកាដូ ។ នៅតាមពន្ធនាគារដែលនៅឆ្ងាយពីភ្នំពេញការបែងចែកអាហារបន្ថែមបែបនេះត្រូវធ្វើឡើងដោយបុគ្គលិកការិយាល័យលីកាដូនៅក្នុងខេត្តនោះ ដែលទទួលបន្តពីការិយាល័យលីកាដូភ្នំពេញនៅពេលដែលឡើងមកប្រជុំប្រចាំខែ ។

ការិយាល័យពេទ្យរបស់លីកាដូ ក៏មានការផ្តល់អាហារបន្ថែមដល់អ្នកទោសដែលមានផ្ទៃពោះនិងអ្នកទោសដែលមានកូនតូចៗនៅជាមួយផងដែរ ។ ក្នុងកំឡុងពេលចុះទៅពិនិត្យសុខភាពប្រចាំខែដល់អ្នកទោសការិយាល័យពេទ្យបានផ្តល់អោយគេ ដូចជាស្ករ ចេក និង ជួនកាលអាហារផ្សេងៗទៀត ។ ការផ្តល់អាហារនៅតែបន្តធ្វើដល់អ្នកទោសប្រសិនបើគ្រូពេទ្យយល់ឃើញថាគួរបន្តហើយបរិមាណផ្តល់ទៀតសោតក៏ប្រែប្រួលអាស្រ័យទៅតាមកាលៈទេសៈជាក់ស្តែងផងដែរ ។ ការិយាល័យពេទ្យបានអោយដឹងថា គេចំណាយប្រមាណពី ១០០ ទៅ ១៥០ ដុល្លាអាមេរិកក្នុងមួយខែៗ សំរាប់អាហារបន្ថែម ដល់អ្នកទោសទាំងនោះ ។

ការិយាល័យពេទ្យក៏បានផ្តល់ការថែទាំសុខភាពជាប្រចាំដល់អ្នកទោសផងដែរ ។ នៅឆ្នាំ ២០០១ បុគ្គលិកពេទ្យរបស់អង្គការលីកាដូ បានទៅពិនិត្យព្យាបាលសុខភាពដល់អ្នកទោសប្រចាំខែនៅក្នុងពន្ធនាគារចំនួន ១២ ដែលបានផ្តល់ការពិនិត្យសុខភាពអ្នកទោសចំនួន ៤៩២៤ នាក់ ដែលរួមមានទាំង ទណ្ឌិត និង

---

*អាហារបន្ថែមដល់កុមារនិងស្ត្រីទៀតផង ។ លើសពីនេះទៅទៀតក្នុងការពិភាក្សាជាមួយបុគ្គលិកនិងអង្គការផ្សេងៗរួមមានៈ អាដហុក LAC CDP CRC Children's house CNCC SSC និង UNICEF ក៏បានបញ្ជាក់ដូច្នេះដែរ ។ អង្គការ CHHRA បានផ្តល់កាថែទាំសុខភាពដល់ពន្ធនាគារចំនួនបួនកន្លែងគឺៈតាកែវ កំពង់ធំ ពោសាត់និង ក្រុងព្រះសីហនុ ប៉ុន្តែមិនបានផ្តោតការយកចិត្តទុកដាក់ពិសេសទៅលើស្ត្រីនិងកុមារទេ ។ ហើយអង្គការនេះក៏មិនដែលបានធ្វើការសិក្សាស្រាវជ្រាវឬសរសេររបាយការណ៏លំអិតណាមួយស្តីពីស្ថានភាពរស់នៅនៃមាតា កុមារ និង ស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារនេះដែរ ។*

ពិរុទ្ធជន[២] ។ លើសពីនេះទៅទៀតក្នុងឆ្នាំ ២០០១ កន្លងទៅនេះអ្នកស៊ើបអង្កេតមកពីការិយាល័យស៊ើបអង្កេត និង គំរោងកម្មវិធីពន្ធនាគាររបស់លីកាដូ បានចូលទៅពិនិត្យមើលពន្ធនាគារស៊ីវិលចំនួន ១៩ និង ពន្ធនាគារយោធាចំនួន ១ ដោយបានចូលទៅពិនិត្យយ៉ាងហោចណាស់ ៣ ដងក្នុងមួយខែ ។ ក្នុងពេលចូលទៅពិនិត្យនេះបុគ្គលិកទាំងនោះបានសម្ភាសន៍ចំនួន ២៣២៤ដង ជាមួយពិរុទ្ធជននិងទណ្ឌិតដើម្បីត្រួតពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សនៅក្នុងពន្ធនាគារ[៣] ។ ការអនុវត្តន៏ការងារជាប្រចាំជាមួយអ្នកទោសទាំងនោះ បានធ្វើអោយបុគ្គលិកលីកាដូដឹងច្បាស់នូវស្ថានភាពយ៉ាប់យ៉ឺនរបស់មាតាកុមារនិងស្ត្រីមានផ្ទៃពោះទាំងនោះ ។ សង្ឃឹមថា ពិតមែនតែជាកុមារមួយក្រុមតូចទាក់ទងទៅនិងករណីខាងលើនេះដែលពួកគេខ្លះកើត និងរស់នៅក្នុងពន្ធនាគារនាពេលបច្ចុប្បន្ននេះ វានឹងផ្តល់ជាបុព្វហេតុនៃសេចក្តីសង្ឃឹមក្នុងការដោះស្រាយស្ថានភាពនេះមុននិងវាក្លាយទៅជាបញ្ហាធំ ។ នេះគឺជាហេតុផលមួយដែលលីកាដូជ្រើសរើសយកមកស្រាវជ្រាវ បញ្ហានៅពេលនេះ ។ ក្នុងការសរសេររបាយការណ៍ខាងក្រោមនេះ អង្គការលីកាដូសង្ឃឹមថា វាជាឱកាសផ្តល់ អោយស្ត្រី និង កុមារទាំងនោះបញ្ចេញមតិយោបល់អំពីផលប៉ះពាល់មកលើពួកគេដែលរហូតមកទល់ពេលនេះឱកាសមានតិចតួចណាស់ ឬក្រែងគេស្តាប់ឬយកចិត្តទុកដាក់ខ្លះ ។

**គោលបំណងនៃការសិក្សានេះមានដូចខាងក្រោមៈ**

- ដើម្បីកំណត់នូវវិសាលភាពនៃបញ្ហា និង ស្វែងយល់អោយបានច្បាស់នូវប្រជាសាស្ត្រទូទៅនៃអ្នកដែលទទួលរងឥទ្ធិពល ។
- ដើម្បីបង្កើនការយល់ដឹងនូវតំរូវការ និងកង្វល់ចម្បងៗរបស់មាតា[៤]កុមារ និងស្ត្រីមានផ្ទៃពោះទាំងនោះដែលកំពុងរស់នៅក្នុងពន្ធនាគារក៏ដូចជាការបង្កើនការយល់ដឹងពីផលប៉ះពាល់

---

[២] *ចំពោះពត៌មានបន្ថែមនិងស្ថិតិពីការងារការិយាល័យពេទ្យលីកាដូសូមអានរបាយការណ៍លីកាដូ "ស្តីអំពីបញ្ហាពន្ធនាគារនិងបញ្ហាសុខភាព : ខែមករា-ធ្នូឆ្នាំ ២០០១" ភ្នំពេញៈលីកាដូ ២០០២ ។*

[៣] *ចំពោះពត៌មានបន្ថែម ស្តីអំពីស្ថិតិរបស់ការិយាល័យស៊ើបអង្កេត និងពន្ធនាគារលីកាដូ សូមអានរបាយការណ៍ លីកាដូស្តីពី "បញ្ហាពន្ធនាគារ និង បញ្ហាសិទ្ធិមនុស្ស : ខែ មករា - ធ្នូ ឆ្នាំ ២០០១" ភ្នំពេញៈ លីកាដូ ២០០២ ។*

[៤] *គ្រប់ទណ្ឌិត និង ពិរុទ្ធជនដែលបានសម្ភាសន៍នៅក្នុងការសិក្សាស្រាវជ្រាវនេះ គឺជាមាតា ឬស្ត្រីមានផ្ទៃពោះ មិនមានអ្នកទោសបុរសណាមានកូននៅក្នុងពន្ធនាគារជាមួយទេក្នុងពេលបច្ចុប្បន្ននេះ ។ ហេតុនេះពាក្យ "មាតា " នឹងត្រូវឃើញមានប្រើញឹកញាប់បំផុតក្នុងឯកសារនេះ ។ ប៉ុន្តែមានកាលៈទេសៈខ្លះក៏អាចមានឪពុកជាប់ឃុំឃាំងហើយមានកូនមករស់នៅជាមួយដែរ ។ នៅក្នុងពេលធ្វើការសិក្សាស្រាវជ្រាវនេះអ្នកស្រាវជ្រាវបានព្ទថាមាន ១ករណីដែរ ដែលឪពុកជាប់*

ដល់សិទ្ធិ កុមារក្នុងការដែលពួកគេរស់នៅក្នុងពន្ធនាគារនោះ តាមរយៈការចងក្រងឯកសារ និងវិភាគស្ថានភាពជាក់ ស្តែងដែលគេកំពុងតែជួបប្រទះនោះ ។

- ដើម្បីប្រមូលចងក្រងពតិមានស្តីអំពីច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ និងគោលនយោបាយទាំងឡាយដែលទាក់ទងទៅនិងបញ្ហានោះហើយកំណត់អំពីក៏រិតដែលច្បាប់និងគោលនយោបាយទាំងនោះមានចូលពាក់ព័ន្ធផងដែរ ។
- ដើម្បីស្វែងយល់អោយបានច្បាស់ថាតើលក្ខ័ណ្ឌបច្ចុប្បន្នវាគាំទ្រនិង/ឬរំលោភលើសិទ្ធិកុមារឬទេ ដោយយោងទៅនឹងក្រុមសិទ្ធិធំៗទាំង៤របស់កុមាមានៈ (សិទ្ធិក្នុងការរស់នៅ ការពារ អភិវឌ្ឍន៍ និង សិទ្ធិក្នុងការចូលរួម) ដូចដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ។
- ដើម្បីបង្កើតអនុសាសន៏រកដំណោះស្រាយលើបញ្ហាតំរូវការនិងកង្វល់ដែលបានលើកឡើងខាងលើ ដើម្បីកុំអោយបញ្ហានេះក្លាយទៅជាបញ្ហាសង្គមកាន់តែរីកធំឡើងទៀត ។

---

*ពន្ធនាគារហើយមានកូនមករស់នៅជាមួយដែរ ។ តាមសំដីបុគ្គលិកពន្ធនាគារម្នាក់បានអោយដឹងថា បុរសនោះមានកូនអាយុប្រមាណ ៨-៩ឆ្នាំ និង កូនស្រីម្នាក់អាយុ ១១ ឆ្នាំ ធ្លាប់មករស់នៅជាមួយឪពុកក្នុងពន្ធនាគារដែរ ។ ពេលមួយមានអង្គការចូលមកពន្ធនាគារហើយបានសុំការអនុញ្ញាតពីគាត់ដើម្បីសុំកូនទាំងនោះទៅចិញ្ចឹមហើយគាត់ក៏បានយល់ព្រមអោយគេយកទៅ ។ ក្រោយពីបានចាកចេញពីពន្ធនាគារទៅរស់នៅជាមួយអង្គការកូន២ទាំងនោះបានមកលេងឪពុកគេម្តង ។ បុគ្គលិកពន្ធនាគារនោះក៏មិនបានចាំពីរយៈពេលដែលបុរសជាឪពុកត្រូវជាប់ឃុំឃាំងក្នុងពន្ធនាគារនោះដែរ ។*

# សំរាយអក្សរកាត់

| | |
|---|---|
| ADHOC | សមាគមការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា |
| CC II | មណ្ឌលកែប្រែទី ២ (ពន្ធនាគារសំរាប់ស្ត្រី និង អនីតិជននៅព្រៃសរ) |
| CDP | គម្រោងអ្នកការពារក្តីកម្ពុជា |
| CHHRA | សម្ព័ន្ធសិទ្ធិមនុស្ស និងសុខភាពកម្ពុជា |
| CNCC | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| CRC | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ |
| LAC | ជំនួយផ្នែកច្បាប់កម្ពុជា |
| LICADHO | សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស |
| MOH | ក្រសួងសុខាភិបាល |
| MOI | ក្រសួងមហាផ្ទៃ |
| MOJ | ក្រសួងយុត្តិធមិ |
| MOSALVY | ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា |
| MOWA | ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| UN | អង្គការសហប្រជាជាតិ |
| UNICEF | មូលនិធិសំរាប់កុមារអង្គការសហប្រជាជាតិ |

## II- សេចក្តីសង្ខេប

ពាក្យ **"អ្នកទោសឬអ្នកជាប់ពន្ធនាគារ"** ជាធម្មតាប្រើសំដៅទៅលើពួកឧក្រិដ្ឋជនធំៗ ដូចជាពួកចោរ ពួករំលោភផ្លូវភេទ ពួកឃាតករ និង ពួកដែលពោរពេញដោយការគំរាមកំហែងដល់សង្គមជាតិ។ ពន្ធនាគារនៅប្រទេសកម្ពុជាទាំងឡាយត្រូវបានប្រើប្រាស់សំរាប់ដាក់ជនល្មើសហឹង្សាបែបនេះប៉ុន្តែវាក៏បានក្លាយជាផ្ទះសំបែងរបស់មនុស្សមួយក្រុមដែលច្រើនតែត្រូវគេមើលរំលង ដូចជាក្រុមកុមារដែលគ្មានខុសបន្តិចសោះជាដើម ។ កុមារទាំងនេះរស់នៅក្នុងពន្ធនាគារ គឺពុំមែនដោយសារតែអំពើរបស់ពួកគេទេ គឺពីព្រោះតែម្តាយរបស់ពួកគេត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ហើយម្តាយរបស់ពួកគេត្រូវបំរើទោសឬត្រូវរងចាំការវិនិច្ឆ័យទោស ដូច្នេះកូនៗរបស់ពួកគាត់ត្រូវរស់នៅក្នុងជីវិត ដូចជនជាប់ចោទដែរ ដោយពុំបានល្មើសច្បាប់ទាល់តែសោះ ។

កុមារទាំងនេះរស់នៅក្នុងពន្ធនាគារពីព្រោះច្បាប់នៅកម្ពុជាបានអនុញ្ញាតអោយគេនៅនិងដោយសារមូលហេតុច្រើនជាអនេកព្រមទាំងគ្មានជំរើសណាក្រៅពីនេះទៀតផង។ កុមារខ្លះបានទៅតាមម្តាយនៅមណ្ឌលកែប្រែពីព្រោះពួកគេពុំមានញាតិណាម្នាក់អាចជួយចិញ្ចឹមបានឡើយ ឬ ពីព្រោះម្តាយរបស់ពួកគេ មិនជឿជាក់លើការមើលថែទាំ នៅខាងក្រៅពន្ធនាគារ ។ កុមារខ្លះទៀតនៅបៅដោះនៅឡើយ ក្នុងពេលដែលម្តាយពួកគេត្រូវចាប់ខ្លួន ហេតុនេះគេយល់ថាមិនទាន់អាចបំបែកចេញពីម្តាយបានទេដោយនៅក្មេងពេក ។ កុមារខ្លះទៀត បានកើតនៅក្នុងពន្ធនាគារ ក្នុងកំឡុងពេលដែលម្តាយរបស់ពួកគេកំពុងបំរើទោស ឬ រងចាំការវិនិច្ឆ័យទោសហើយជួនកាលកុមារខ្លះកើតនៅក្នុងពន្ធនាគារតែម្តងក៏មាន ។ មាតាកុមារទាំងនោះ ចេះតែធ្វើទំលាប់មួយជាធម្មតា ដោយពុំបានគិតពីកាលៈទេសៈយ៉ាងណាទេ គឺការគិតទុកកូនអោយរស់នៅក្នុងពន្ធនាគារជាមួយក្នុងពន្ធនាគារ ថា ជាជំរើសមួយដ៏ល្អបំផុត ។

ឆ្លងតាមការងារពិនិត្យព្យាបាលជំងឺនិង ត្រួតពិនិត្យស្ថានភាពសិទ្ធិមនុស្សក្នុងពន្ធនាគារចំនួន២០ក្នុងប្រទេសកម្ពុជាកន្លងមក បុគ្គលិកអង្គការលីកាដូបានដឹងថាមានកុមារជាច្រើនកំពុងចំរើនវ័យក្នុងពន្ធនាគារ ។ មកដល់ពេលនេះនៅមិនទាន់មានអង្គការណាមួយបានប្រមូលពត៌មានស្តីពីស្ថានភាពកុមារទាំងនេះ ឬ ប្រមូលទិន្នន័យដើម្បីវិភាគលើផលប៉ះពាល់ដល់កុមារនោះនៅឡើយទេ។ អង្គការមួយចំនួនតូច បានត្រឹមតែផ្តល់ជំនួយដល់មាតាដែលមានកូននៅជាមួយឬស្ត្រីមានផ្ទៃពោះនៅក្នុងពន្ធនាគារ។ លើសពីនេះទៀត ថ្វីត្បិតតែមានច្បាប់ជាតិ ដែល ពាក់ពន្ធ័ទៅនឹងប្រធានបទនេះក៏ដោយ ក៏ការយល់ដឹងអំពីបញ្ហានេះនៅមានកំរិតទាបនៅឡើយ ។

អង្គការលីកាដូ បានចាប់ផ្តើមការសិក្សាស្រាវជ្រាវនេះ ចាប់ពីខែ តុលា ឆ្នាំ ២០០១ រហូតមកដល់ ខែ មេសា ឆ្នាំ ២០០២ កន្លងមកនេះ ដើម្បីធ្វើការប្រមើលមើលនូវស្ថានភាពរស់នៅរបស់កុមារទាំងនោះ ហើយ សិក្សាមើលថាតើស្ថានភាពបែបនេះវាបណ្តាលអោយខ្វះខាតសិទ្ធិកុមារដែរទេ។ ការវាយតំលៃស្ថានភាព មាន រួមបញ្ចូលនូវការពិនិត្យគោលការណ៍ឡើងវិញ ព្រមទាំងឯកសារបោះពុម្ព ដែលជាប់ពាក់ព័ន្ធទាំងឡាយ ក៏ដូច ជាការសម្ភាសន៍ជាមួយមាតាទណ្ឌិត ឬ ពិរុទ្ធជនទាំងឡាយ ស្ត្រីមានផ្ទៃពោះ កុមាររស់នៅក្នុងពន្ធនាគារ បុគ្គ លិកពន្ធនាគារ និង អ្នកដែលជាប់ពាក់ព័ន្ធកិច្ចការនេះមួយចំនួននៅតាមបណ្តាអង្គការផ្សេងៗ ។ ការសម្ភាសន៍ ត្រូវបាន ធ្វើនៅពន្ធនាគារ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់សោម (ក្រុងព្រះសីហនុ) ភ្នំពេញ (មណ្ឌលកែប្រែទី ២ ព្រៃសរ) ពោធិសាត់ សៀមរាប និង ពន្ធនាគារតាខ្មៅ ខេត្តកណ្តាល ។ មាតាមានកូន រស់នៅក្នុងពន្ធនាគារចំនួន ១៣ នាក់ និង ស្ត្រីមានផ្ទៃពោះចំនួន ៧ នាក់ ត្រូវបានសម្ភាសន៍ ។ មានកុមារតែ ម្នាក់គត់ដែលមានអាយុ៧ឆ្នាំធំល្មមអាចសម្ភាសន៍បាន ។ លើសពីនេះ ក៏បានសម្ភាសន៍ចាងហ្វាងពន្ធនាគារចំនួន ៨ នាក់ បុគ្គលិកពន្ធនាគារ ចំនួន ៦ នាក់ និង សម្ភាសន៍គ្រូពេទ្យប្រចាំពន្ធនាគារចំនួន ៥ នាក់ទៀតផងដែរ ។

ក្រោយពីបានបញ្ចប់ការសិក្សានេះ អង្គការលីកាដូ បានរកឃើញបញ្ហាជាច្រើន ដែលប៉ះពាល់យ៉ាងធ្ងន់ ធ្ងរដល់សិទ្ធិកុមាររស់នៅក្នុងពន្ធនាគារទាំងនោះ ។ ទោះបីជាមានច្បាប់អន្តរជាតិ និង ច្បាប់ជាតិ ព្រមទាំង ច្បាប់ និង នីតិវិធីកម្ពុជាដែលតាក់តែងឡើង ដើម្បីការពារស្ត្រីមានផ្ទៃពោះជាប់ពន្ធនាគារ ព្រមទាំងការពារ មាតាដែលមានកូននៅមួយក្នុងពន្ធនាគារក៏ដោយ ក៏គេនៅតែបន្តធ្វើមិនដឹងមិនឮ អំពីតំរូវការរបស់មនុស្ស មួយក្រុមនេះឡើយដែរ ។ មាតា ស្ត្រីមានផ្ទៃពោះ ជាទណ្ឌិត ឬ ជាពិរុទ្ធជន ព្រមទាំងកូនៗរបស់ពួកគេ ត្រូវ គេបដិសេធជាប្រចាំ មិនអោយមានលទ្ធភាពទទួលការព្យាបាលអោយបានសមរម្យ ឬ ម្ហូបអាហារគ្រប់គ្រាន់ ការអប់រំត្រឹមត្រូវ ព្រមទាំងមិនអោយមានសិទ្ធិជាមូលដ្ឋានសមស្របទៀតផង ។

កុមារមួយចំនួនធំដែលរស់នៅក្នុងពន្ធនាគារសព្វថ្ងៃ មានអាយុក្រោម៥ ឆ្នាំ នេះមានន័យថា ពួកគេកំ ពុងតែស្ថិតក្នុងដំណាក់កាលលូតលាស់ពិសេសទាំងផ្នែករាងកាយនិងផ្នែកសង្គម ។ កុមារ ៥ នាក់ក្នុងចំណោមកុ មារ ទាំង ១៥ នាក់ ដែលលើកយកមកសិក្សាស្រាវជ្រាវនេះ មានអាយុក្រោម ៦ ខែ ហើយស្ត្រីចំនួន ៧ នាក់ ក្នុងចំណោមស្ត្រី១០នាក់ ដែលបានផ្តល់ការសម្ភាសន៍បានរាយការណ៍អោយដឹងថា ពុំមានទឹកដោះគ្រប់គ្រាន់ សំរាប់បំបៅកូនទេ ដោយមូលហេតុមិនមានម្ហូបអាហារបរិភោគគ្រប់គ្រាន់ ។ នេះគ្រាន់តែជាសន្ទស្សន៍មួយ បង្ហាញពីកង្វះអាហារូបត្ថម្ភដែលកុមាររស់នៅក្នុងពន្ធនាគារកំពុងតែប្រឈមមុខ។ ទោះបីជាកុមារទាំងនោះ

ភាគច្រើនញ៉ាំអាហារជាចំណែករបស់ម្តាយដែលពន្ធនាគារចែកអោយក៏ដោយ ក៏គេមិនដែលថែមរបបអាហារអោយស្ត្រីដែលមានកូនរស់នៅជាមួយទាំងនោះដែរ ។ ម្ហូបអាហារដែលផ្តល់អោយអ្នកជាប់ពន្ធនាគារនោះពុំមានបរិមាណសមល្មមសំរាប់មនុស្សពេញវ័យផង ដូច្នេះ ត្រូវខ្វះសំរាប់កុមារដែលកំពុងត្រូវការលូតលាស់នោះ ។ នៅពេលដែលរំលែកអាហារនេះអោយកូនម្នាក់ឬពីរឬបីនាក់ ជួនកាលច្រើនជាងនេះ នោះបរិមាណម្ហូបអាហារវាកាន់តែតិចថែមទៀត ។ ទោះជាឃើញមានវិធានការដើម្បីបន្ថែមម្ហូបអាហារអោយស្ត្រីមានផ្ទៃពោះនិងស្ត្រីបំបៅដោះកូនក៏ដោយ ក៏គេសង្កេតឃើញថា នៅតែមិនទាន់បានចាត់ការអ្វីមួយដើម្បីផ្តល់ម្ហូបអាហារដល់កូនស្ត្រី ដែលឈប់បៅដោះ នូវម្ហូបអាហារដាច់ដោយឡែកពីមាតាគេឡើយ ។

លើសពីនេះទៅទៀត មាតា និង ស្ត្រីមានផ្ទៃពោះទាំងនោះ បានរៀបរាប់ថា ពួកគាត់នៅតែមិនមានលទ្ធភាពទទួលការថែទាំសុខភាពអោយបានសមរម្យទេ ទោះសំរាប់ផ្ទាល់ខ្លួន ឬសំរាប់កូនៗ ក៏ដោយ ។ ពេលខ្លះបញ្ហានេះ គឺពីព្រោះតែស្ត្រីទាំងនោះខ្វះថវិកា ដើម្បីទៅព្យាបាលខាងក្រៅពន្ធនាគារ ឬ ថវិកាសំរាប់ការធ្វើដំណើរទៅមន្ទីរពេទ្យ ។ ករណីខ្លះទៀតគឺពីព្រោះតែស្ត្រីទាំងនោះមិនត្រូវបានអនុញ្ញាតអោយចេញទៅព្យាបាលនៅមន្ទីរពេទ្យជំនាញ ។ បញ្ហាលំបាកមួយទៀត គឺពីព្រោះ ផ្នែកសុខភាពពន្ធនាគារមិនសូវយកចិត្តទុកដាក់ ចំពោះសំណើសុំការថែទាំសុខភាពរបស់ស្ត្រីឡើយ ។ ទោះបីជាអង្គការមួយចំនួន និងគ្រូពេទ្យរដ្ឋាភិបាលបានផ្តល់ការថែទាំសុខភាពនៅក្នុងពន្ធនាគារក៏ដោយ ក៏គេមិនអាចធ្វើបានរៀងរាល់ថ្ងៃដែរ ព្រមទាំងមិនអាចផ្តោតការយកចិត្តទុកដាក់ពិសេសទៅលើតែមាតាមានកូននៅជាមួយ ឬស្ត្រីមានផ្ទៃពោះនោះទេ ។ នៅពេលដែលផ្នែកសេវាសុខភាពផ្តល់ការថែទាំសុខភាព ក៏ច្រើនតែមិនបានគ្រប់គ្រាន់ទេ ដោយសារតែពុំមានធនធានគ្រប់គ្រាន់ ។ ជាឧទាហរណ៍ ថ្នាំដែលមានស្រាប់ហើយនោះ គឺប្រើសំរាប់តែមនុស្សពេញវ័យច្រើនជាងសំរាប់កុមារ ហើយផ្នែកផ្តល់សេវាសុខភាពពន្ធនាគារច្រើនតែទទួលការងារច្រើនហួសកំរិតមានបុគ្គលិកតិចនិងច្រើនតែពុំបានទទួលការហ្វឹកហ្វឺនអោយបានត្រឹមត្រូវទៀតផង ។

ការរស់នៅក្នុងពន្ធនាគារក៏បានបង្ហាញនូវការគំរាមកំហែងមួយដល់សុវត្ថិភាពកុមារផងដែរ ។ វាអាចកើតមាននូវការធ្វើបាបដល់កុមារពីសំណាក់ អ្នកជាប់ពន្ធនាគារផ្សេងៗ ឬ បុគ្គលិកពន្ធនាគារដែលតែងតែកើតមាន ជាពិសេសនៅពន្ធនាគារដែលសំរាប់ឃុំឃាំងជនល្មើសរំលោភផ្លូវភេទ ឬ ជនល្មើសលើកុមារ ។

ផលប៉ះពាល់លើការអភិវឌ្ឍន៍របស់កុមារគឺមានទាំងការប៉ះពាល់ផ្នែកសង្គម និង ផ្នែកផ្លូវចិត្ត ក៏ដូចជាផ្នែករាងកាយផងដែរ ។ បើពុំបានផ្តល់ការអប់រំបានត្រឹមត្រូវតាមបទដ្ឋានទេ វាជាគុណវិបត្តិមួយចំពោះកុមារក្នុងការលូតលាស់ខាងផ្នែកសតិបញ្ញា ។ លើសពីនេះទៀត គេប្រាកដជាបាត់បង់នូវឱកាសក្នុងការទំនាក់ទំនងគ្នា

ទៅវិញទៅមកជាមួយនឹងកុមារដទៃៗទៀតស្រករគ្នា ឬ ពិភពលោកខាងក្រៅទៀតជាទូទៅ ។ កុមារទាំងនេះកម្របានចេញទៅណាអោយហួសពីជញ្ជាំងពន្ធនាគារណាស់ដូច្នេះពួកគេមានឱកាសតិចតួចណាស់ដើម្បីសម្របខ្លួនទៅនឹងអ្វីដែលហៅថាសង្គមធម្មតានោះ ។ ពិភពលោករបស់ពួកគេត្រូវបានកំណត់ក្នុងទំហំមួយ ហើយពួកគេទទួលឥទ្ធិពលមួយភាគធំពីអ្វីដែលបានឃើញក្នុងពន្ធនាគារតែប៉ុណ្ណោះ ។ គំរូតួនាទីវិជ្ជមានប្រហែលជាកម្រមានណាស់នៅក្នុងបរិយាកាសបែបនេះវាអាចបង្អាក់នូវការលូតលាស់ផ្នែកសីលធម៌របស់កុមារថែមទៀត ។

កុមារទាំងនេះច្រើនតែហ៊ុំព័ទ្ធទៅដោយវប្បធម៌ភ័យខ្លាចនិងភាពតែលតោលជាជំនួសវិញ ។ សាច់រឿងជាទូទៅរបស់ទណ្ឌិតនិងពិរុទ្ធជនដែលបានផ្តល់សម្ភាសន៍គឺភាពងាយរងទទួលគ្រោះថ្នាក់ជាទីបំផុត ។ ស្ត្រីទាំងនោះបានចាត់ទុកខ្លួនគេថាជាមនុស្សទន់ខ្សោយដោយមូលហេតុរាប់មិនអស់ ។ ទីមួយពួកគេជួបប្រទះនូវភាពក្រខ្សត់ក្នុងជីវភាពប្រចាំថ្ងៃ ។ ទោះបីជាកត្តានេះអាចកើតឡើងដោយមិនទាក់ទងគ្នាក្នុងជីវិតអ្នកជាប់ពន្ធនាគារក៏ដោយការពិតវាគឺជាកត្តាសំខាន់មួយនៅក្នុងជីវិតមានគុណភាពរបស់ពួកគេ និងរបស់កូនគេ ។ កង្វះថវិកាអាចធ្វើអោយគេមិនអាចមានម្ហូបអាហារបន្ថែមបាន ឬមិនអាចទទួលបាននូវការថែទាំសុខភាពដែលមានលក្ខណសមរម្យ ។ ចំពោះស្ត្រីមួយចំនួន វាអាចបណ្តាលអោយមានការពន្យាដល់រយះពេលនៃការបំរើទោសថែមទៀតផង ក្នុងករណីដែលការវិនិច្ឆ័យទោសនោះតំរូវអោយមានការសងនូវសំណងជំងឺចិត្តនោះហើយអ្នកដែលមិនអាចបង់ថ្លៃពិន័យនេះបាននឹងត្រូវបន្តជាប់ពន្ធនាគារថែមទៀតជាជំនួសវិញ ។ កត្តានេះអាចជាលទ្ធផលធ្វើអោយកុមារដែលរស់នៅជាមួយម្តាយក្នុងពន្ធនាគារត្រូវជាប់នៅកាន់តែយូរឡើង ។

ស្ត្រីដែលបានផ្តល់ការសម្ភាសន៍បានបង្ហាញនូវភាពទន់ខ្សោយមួយក្នុងប្រព័ន្ធគ្រប់គ្រងពន្ធនាគារ ។ ទោះបីជាច្បាប់កម្ពុជាបានចែងយ៉ាងច្បាស់អោយរកវិធីដោះស្រាយភាពអយុត្តិធម៌របស់ស្ត្រីក៏ដោយក៏បច្ចុប្បន្ននេះនៅតែមិនទាន់មានរចនាសម្ព័ន្ធណាមួយសំរាប់អនុវត្តការងារនេះដែរ ។ ស្ត្រីទាំងនោះបានបញ្ជាក់ម្តងហើយម្តងទៀតថា មិនដែលមានអ្នកណាម្នាក់យកចិត្តទុកដាក់ពីការត្អូញត្អែររបស់ពួកគេឡើយ ។ ប្រហែលជាសំខាន់ជាងនេះទៀតនោះ គឺស្ត្រីជាច្រើនមិនដែលបានគិតគូរលើកឡើងពីទុក្ខកង្វល់របស់គេផងដោយគេគិតថាទោះជាលើកឡើងក៏ពិតជាគ្មានអ្នកណាឮដែរ ។ ស្ត្រីខ្លះទៀតក៏ភ័យខ្លាចក្នុងការបង្ហាញនូវការអាក់អន់ចិត្តរបស់ខ្លួនពីព្រោះខ្លាចក្រែងមានផលវិបាកទៅថ្ងៃក្រោយដល់ខ្លួនគេ និងកូនៗរបស់គេន័យដ៏ទូលំទូលាយនៃភាពតែលតោលនេះមិនអាចឱ្យមានតទៀតបានឡើយ ពីព្រោះវាទាំងនាំឱ្យបាត់បង់ប្រយោជន៍ផ្នែកសិទ្ធិរបស់អ្នកជាប់ពន្ធនាគារ ហើយសំខាន់ជាងនេះទៀតចំពោះបញ្ហាដែលនៅជុំវិញ ដូច្នេះវានឹងធ្វើអោយខូចដល់ប្រយោជន៍ផ្នែកសិទ្ធិរបស់កុមារផងដែរ ។

ច្បាប់បច្ចុប្បន្ននិងនីតិវិធីបច្ចុប្បន្នបានចែងពីការទទួលខុសត្រូវដើម្បីធានាអោយមាននូវការថែទាំគ្រប់គ្រាន់ដល់កុមាររស់នៅក្នុងពន្ធនាគារថាជាបន្ទុករបស់បុគ្គលិកពន្ធនាគារនិង នាយកដ្ឋានពន្ធនាគារ ដែលស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ ។ បច្ចុប្បន្ននេះ ពុំមានផ្នែកណាមួយអនុវត្តការទទួលខុសត្រូវបញ្ហានេះឡើយ ។ ទោះបីជា គេទទួលខុសត្រូវភារៈកិច្ចដើម្បីធ្វើអោយមានការថែទាំកុមារមាតា និងស្ត្រីមានផ្ទៃពោះនៅក្នុងពន្ធនាគារអោយមានកំរិតបទដ្ឋានខ្ពស់មួយនោះ តាមការពិតបើសិនមាននោះ ក៏គេបានផ្តល់ការព្យាបាលតិចតួចណាស់បើធៀបទៅនឹងគោលការណ៍ដែលបានចែងនាពេលបច្ចុប្បន្ននេះ ។ បុគ្គលិកពន្ធនាគារមិនដែលត្រួតពិនិត្យមើលស្ថានភាពកុមារ ឬ ស្ត្រីមានផ្ទៃពោះនៅក្នុងពន្ធនាគារតាមតំរូវការឡើយ ព្រមទាំងមិនបានសម្រួលដល់កិច្ចសហប្រតិបត្តិការជាមួយនឹងភ្នាក់ងារខាងក្រៅ ដែលអាចជួយផ្តល់នូវការថែទាំសុខភាពសមរម្យផង។ លើសពីនេះទៅទៀតគេក៏មិនដែលធ្វើការវាយតំលៃនូវកាលៈទេសៈរបស់កុមារដើម្បីធានាថា កុមារទទួលបាននូវប្រយោជន៍ដ៏ល្អបំផុត ។ គោលការណ៍និងនីតិវិធីដើម្បីដោះស្រាយបញ្ហាទាំងប៉ុន្មានខាងលើគ្រប់គ្រាន់សមរម្យហើយ ប៉ុន្តែជាធម្មតាគេមិនបានអនុវត្តទេ។ ការមិនបានអនុវត្តតាមកំរិតបទដ្ឋានដែលបានគូសបញ្ជាក់ក្នុងច្បាប់និង នីតិវិធី គឺនាយកដ្ឋានពន្ធនាគារ និង រាជរដ្ឋាភិបាលកម្ពុជាបានបណ្តោយអោយមានគ្រោះថ្នាក់ចំពោះបញ្ហាសិទ្ធិកុមារនេះ ។ ដោយពុំមានការអនុវត្តន៍ប្រព័ន្ធបច្ចុប្បន្ន និង ការទាមទារអោយមានការទទួលខុសត្រូវនោះហើយ ដែលវានាំអោយបន្ត មានការកើតឡើងម្តងហើយម្តងទៀតឥតឈប់ឈរ។

## III- វិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវ

របាយការណ៍ខាងក្រោម ធ្វើឡើងដោយផ្អែកទៅលើវិធីសាស្ត្រនៃការសិក្សាដែលរួមមាន:

- ការសម្ភាសន៍ជាមួយមាតា កុមារ និង ស្ត្រីមានផ្ទៃពោះដែលកំពុងរស់នៅក្នុងពន្ធនាគារ ។
- ការសម្ភាសន៍ជាមួយបុគ្គលិកពន្ធនាគារ រួមមាន: ចាងហ្វាង ឆ្មាំពន្ធនាគារ បុគ្គលិករដ្ឋបាល និង បុគ្គលិកពេទ្យពន្ធនាគារ ។
- ការសង្កេតដោយផ្ទាល់ទៅលើមាតា ស្ត្រីមានផ្ទៃពោះ និងកុមារដែលកំពុងរស់នៅក្នុងពន្ធនាគារទាំងនោះ ព្រមទាំងការសង្កេតមើលពន្ធនាគារដោយផ្ទាល់ជារួមមានៈស្ថានភាពក្នុងការរស់នៅ និងផ្នែកថែទាំសុខភាព នៅកន្លែងដែលអាចធ្វើទៅបាន ។
- ការសម្ភាសន៍ និង ពិភាក្សាជាមួយតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និង អន្តរជាតិ ដែលពាក់ព័ន្ធ ។

- ការពិនិត្យមើលច្បាប់ គោលនយោបាយ និងនីតិវិធីជាតិ និងអន្តរជាតិទាំងឡាយ ដែលជាប់ទាក់ទងទៅនិងបញ្ហានេះ ។
- ការពិនិត្យមើលឡើងវិញនូវឯកសារបោះពុម្ពដែលពាក់ព័ន្ធទៅនិងឥទ្ធិពលដែលមានលើជីវិតកុមារក្នុងពន្ធនាគារនិងគ្រួសារ ក៏ដូចជាការពិនិត្យឡើងវិញនូវឯកសារបោះពុម្ពទាំងឡាយស្តីពីកម្មវិធីនៅក្នុងប្រទេសដទៃដែលអាចផ្តល់ជាវិធីចម្លាស់ជំនួសការដាក់ពន្ធនាគារសំរាប់មាតា និង ស្ត្រីមានផ្ទៃពោះទាំងនោះ ។

ការស្រាវជ្រាវនិងការសម្ភាសន៏ត្រូវបានធ្វើឡើងនៅក្នុងពន្ធនាគារចំនួនប្រាំពីរ ចាប់ពីខែ តុលាឆ្នាំ ២០០១ រហូតមកដល់ខែមេសាឆ្នាំ ២០០២ ។ ក្នុងការអនុវត្តន៏ការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវមានបំណងធ្វើការសម្ភាសន៏គ្រប់មាតាទាំងអស់ដែលមានកូនរស់នៅជាមួយក្នុងពន្ធនាគារកម្ពុជាបច្ចុប្បន្ន ព្រមទាំងកូនអ្នកបំរើការងារក្នុងពន្ធនាគារដែលមានអាយុប្រហែលគ្នាហើយសមរម្យក្នុងការធ្វើការសម្ភាសន៏នោះ។ អ្នកស្រាវជ្រាវបានសម្ភាសន៏មាតាជាទណ្ឌិតនិងពិរុទ្ធជនចំនួន ១៣នាក់ ដែលមានកូនរស់នៅក្នុងពន្ធនាគារជាមួយ។ អាស្រ័យដោយកុមារដែលរស់នៅក្នុងពន្ធនាគារមួយភាគធំមានអាយុក្រោម ៤ឆ្នាំ ហើយមានកុមារតែម្នាក់គត់ដែលមានអាយុ ៧ឆ្នាំរស់នៅជាមួយម្តាយជាទណ្ឌិតនោះ យើងអាចធ្វើការសម្ភាសន៏គាត់បានយ៉ាងក្បោះក្បាយ[៥] ។ ដូច្នេះពតិមានភាគច្រើនយើងប្រមូលបានពីមាតា អនាគតមាតានិងបុគ្គលិកពន្ធនាគារទាំងនោះ។ យើងបានសម្ភាសន៏ទណ្ឌិតនិងពិរុទ្ធជនមានផ្ទៃពោះចំនួន៧នាក់ ដើម្បីស្វែងយល់ពីលក្ខ័ណ្ឌនៃការថែទាំសុខភាពនៅមុនពេលនិងក្រោយពេលសម្រាលកូនរួចនៅក្នុងពន្ធនាគារ និង ដើម្បីស្វែងយល់ថែមទៀតពីជម្រៅចិត្តនៅក្នុងសម្រេចចិត្តរបស់ស្ត្រីទាំងនោះ ក្នុងការរក្សាកូនទើបតែកើតក្នុងពន្ធនាគារទុកអោយនៅជាមួយគាត់ ។ លើសពីនោះទៅទៀត យើងក៏បានសម្ភាសន៏ចាងហ្វាងពន្ធនាគារចំនួន៨នាក់[៦] បុគ្គលិកពន្ធនាគារចំនួន ៦ នាក់ (ប្រុស៤ នាក់ និង ស្រី ២នាក់) និង ពេទ្យពន្ធនាគារចំនួន ៥ នាក់ (ប្រុស ១ នាក់ស្រី ៤នាក់) ក្នុងគោលបំណងដើម្បីស្វែងយល់ថែមទៀតពីលក្ខ័ណ្ឌនៃការរស់នៅនិងការអនុវត្តន៏ទៅលើមាតា កូន

---

[៥] *យើងក៏បានសម្ភាសន៏កុមារបីនាក់ថែមទៀត: កុមារពីរនាក់ជាកូនរបស់បុគ្គលិកពន្ធនាគារដែលរស់នៅលើបរិវេណពន្ធនាគារ និង កុមារម្នាក់ទៀតរស់នៅជិតខាងនោះដែលបានចូលមកលេងច្រើននៅពន្ធនាគារ ។ ប៉ុន្តែយើងបានកំណត់ថាបញ្ហារបស់កុមារដែលជាកូនបុគ្គលិករស់នៅក្នុងបរិវេណពន្ធនាគារ និងកូនអ្នកជិតខាង គឺស្ថិតនៅក្រៅវិសាលភាពនៃការសិក្សាស្រាវជ្រាវនេះ ហើយដូច្នេះចំលើយរបស់កុមារទាំងនោះមិនបានបញ្ចូលក្នុងទិន្នន័យរបាយការណ៍នេះទេ ។*

[៦] *ចំនួនចាងហ្វាងពន្ធនាគារដែលបានសំភាសន៏ ច្រើនជាងចំនួនពន្ធនាគារដែលបានសិក្សា ព្រោះនៅម២ចាងហ្វាង២នាក់ ។*

របស់គាត់និងស្ត្រីមានផ្ទៃពោះទាំងឡាយដែលកំពុងស្ថិតក្រោមការឃុំឃាំង ។ គួរតែសង្កត់ធ្ងន់លើករណីសិក្សាដែលបានរៀបរាប់នៅក្នុងផ្នែក III ដែលរបកគំហើញដ៏សំខាន់ក្នុងការស្រាវជ្រាវ គឺភាគច្រើនជាគុណភាព ពុំមែនជាបរិមាណទេ ។ ទោះបីជាក្រុមអ្នកដែលបានផ្តល់ការសម្ភាសន៍ជាក្រុមគំរូមួយមានទ្រង់ទ្រាយតូចមែន ប៉ុន្តែអ្នកដែលត្រូវបានសម្ភាសន៍ទាំងនោះជាតំណាងពិតជាក់ស្តែងអោយក្រុមមាតាទាំងមូល ដែលមានកូនរស់នៅក្នុងពន្ធនាគារជាមួយពួកគាត់ និងស្ត្រីមានផ្ទៃពោះទាំងឡាយដែលកំពុងរស់នៅក្នុងពន្ធនាគារក្នុងពេលដែលយើងធ្វើការសម្ភាសន៍នោះ ។ ហេតុនេះហើយ អ្នកស្រាវជ្រាវយល់ឃើញថាលទ្ធផលទាំងនេះអាចយកមកធ្វើជាសេចក្តីសន្និដាន និងតំណាងនៃស្ថានភាពស្មុគស្មាញទាំងឡាយដែលស្ត្រី និងកុមារទាំងនោះកំពុងប្រឈមមុខ ។

អ្នកស្រាវជ្រាវបានធ្វើការសម្ភាសន៍នៅពន្ធនាគារក្នុងតំបន់ចំនួន៧រួមមាន: បន្ទាយមានជ័យ បាត់ដំបង ក្រុងព្រះសីហនុ ភ្នំពេញ (មណ្ឌលកែប្រែទី២ ព្រៃសរ) ពោធិសាត់ សៀមរាប និងតាខ្មៅ ខេត្តកណ្តាល ។ យើងជ្រើសរើសពន្ធនាគារទាំងនេះដោយផ្អែកទៅតាមទិន្ន័យ ដែលទទួលបានពីផ្នែកពន្ធនាគារនៃអង្គការលីកាដូ និងការផ្តល់ពត៌មានជាក់លាក់របស់បុគ្គលិកលីកាដូស្តីពីវត្តមាននៃមាតាកុមារ និងស្ត្រីមានផ្ទៃពោះទាំង នោះនៅក្នុងពន្ធនាគារដែលបានរៀបរាប់ខាងលើ ។

ទំនាក់ទំនងដែលមានរួចហើយរបស់អង្គការលីកាដូជាមួយ និងពន្ធនាគារទាំងនោះបានបង្ករលក្ខណៈងាយស្រួលដល់អ្នកស្រាវជ្រាវក្នុងការសុំការអនុអញ្ញាតធ្វើការសម្ភាសន៍ក្នុងបរិវេណពន្ធនាគារទាំងនោះ ។ ក្នុងនាមជាអង្គការសិទ្ធិមនុស្សដែលមានការិយាល័យនៅតាមបណ្តាខេត្តចំនួន១៤ខេត្តក្នុងទូទាំងប្រទេសកម្ពុជា បុគ្គលិកអង្គការលីកាដូបានបង្កើតទំនាក់ទំនងការងារយ៉ាងល្អប្រសើរជាមួយបុគ្គលិកពន្ធនាគារទាំងនោះ ដើម្បីធ្វើការត្រួតពិនិត្យស្ថានភាពពន្ធនាគារនិងផ្តល់ការជួយឧបត្ថម្ភដល់អ្នកទោសនៅពេលមានការចាំ បាច់និងមានលទ្ធភាពធ្វើបាន។ ការធ្វើដំណើរជាច្រើនលើករបស់អ្នកស្រាវជ្រាវទៅតាមបណ្តាខេត្តគឺស្របពេលជាមួយនឹងការចុះទៅពិនិត្យព្យាបាលសុខភាពនៅពន្ធនាគាររបស់ក្រុមគ្រូពេទ្យលីកាដូ។ ប្រការនេះធ្វើអោយអ្នកស្រាវជ្រាវយើងទទួលបាននូវការយល់ព្រមអោយចូលធ្វើការសម្ភាសន៍និងមានទំនុកទុកចិត្តពីសំណាក់បុគ្គលិកពន្ធនាគារក៏ដូចជាការធានានូវភាពពេញច្បាប់នៃការសិក្សាស្រាវជ្រាវនៅក្នុងក្រសែភ្នែកនៃអ្នកគ្រប់គ្រងពន្ធនាគារ ។ អ្នកស្រាវជ្រាវបានសរសេរសំណួរសម្ភាសន៍ឡើងដោយមានការសហការណ៏ជាមួយនិងការិយាល័យសិទ្ធិកុមារនៃអង្គការលីកាដូ ហើយមានគោលបំណងកំណត់រកអោយឃើញថាតើការរស់នៅក្នុងពន្ធនាគាររបស់កុមារទាំង

នោះមានផលប៉ះពាល់ដល់សិទ្ធិ[៧] របស់កុមារយ៉ាងណាខ្លះ ។ សំណួរទាំងនោះក៏មានគោលដៅរកដំណោះស្រាយបញ្ហាសុខភាព និងសុខុមាលភាពរបស់មាតាទាំងនោះដែរ ក៏ដូចជាសំដៅដោះស្រាយដល់បញ្ហាស្ត្រីជាពិរុទ្ធជននិងទណ្ឌិតដែលមានផ្ទៃពោះទាំងឡាយដែរ ដោយហេតុថាបញ្ហានេះនឹងមានការប៉ះពាល់ដល់សុខភាពរាងកាយនិងផ្លូវចិត្តរបស់កុមារដោយផ្ទាល់និងដោយប្រយោល ។

បទដ្ឋានសំណួរមួយឈុតត្រូវបានរៀបចំឡើងសំរាប់សម្ភាសន៏ក្រុមនីមួយៗមានៈ ក្រុមមាតាដែលមានកូនកំពុងរស់នៅជាមួយក្នុងពន្ធនាគារ ក្រុមស្ត្រីមានផ្ទៃពោះ ក្រុមអ្នកគ្រប់គ្រងពន្ធនាគារក្រុមបុគ្គលិកពន្ធនាគារ និងក្រុមកុមារដែលជាកូនរបស់ទណ្ឌិតនិងពិរុទ្ធជន ឬកូនរបស់បុគ្គលិកពន្ធនាគារដែលរស់នៅក្នុងបរិវេណពន្ធនាគារដែរ ។ ប៉ុន្តែអាស្រ័យដោយពេលវេលាមានកំណត់និងឧបសគ្គមួយចំនួន បង្ខំអោយអ្នកស្រាវជ្រាវក៏រិតឬប្តូរនូវសំណួរដែលបានរៀបចំទាំងនោះខ្លះ ។ ជាឧទាហរណ៏ជួនកាលក្នុងពេលសម្ភាសន៏ក៏មានវត្តមានឆ្មាំនិងមន្ត្រីពន្ធនាគារនៅក្បែរនោះដែរ ជាហេតុធ្វើអោយអ្នកស្រាវជ្រាវយើងមិនហ៊ានពិភាក្សាបញ្ហាសំខាន់ៗជាមួយនិងអ្នកទោសឡើយ ។ ដូចគ្នានេះដែរ កង្វះទីកន្លែងដាច់ដោយឡែកពេញលេញសំរាប់សម្ភាសន៏ក៏ធ្វើអោយអ្នកទោសញញើតមិនហ៊ានឆ្លើយទៅនិងសំណួរពិសេសៗខ្លះដែរ ។ ដូច្នេះរឿងនេះយើងអាចសន្និដ្ឋានបានថា បញ្ហាដែលលើកឡើងមកនេះអាចមានផលប៉ះពាល់ទៅលើការពិតនៃចំលើយមួយចំនួនរបស់អ្នកផ្តល់ការសម្ភាសន៏ ប៉ុន្តែក៏រិតនៃការប៉ះពាល់ដល់លទ្ធភាពក្នុងការប្រមូលពតិមានត្រឹមត្រូវ និងពេញលេញរបស់អ្នក ស្រាវជ្រាវនោះ យើងក៏មិនអាចកំណត់បានដែរ ។

អ្នកស្រាវជ្រាវយល់ថាជាការប្រសើរណាស់ចំពោះខ្លួនជាស្ត្រីភេទ ហើយធ្វើការសម្ភាសន៏ទណ្ឌិតនិងពិរុទ្ធជនស្ត្រីដូចគ្នា ដែលមានភាពងាយស្រួលក្នុងការសួរសំណួរមួយចំនួនដែលជួនកាលជាសំណួរមួយពិបាកសួរ ហេតុនេះវាបានបង្ករអោយមានភាពងាយស្រួលនិងការយល់ចិត្តគ្នាទៅវិញទៅមក ។ ប៉ុន្តែដោយសារមានបញ្ហាផ្នែកភាសា អ្នកស្រាវជ្រាវបានអនុវត្តការងារនេះដោយមានជំនួយពីអ្នកបកប្រែ ។ ប៉ុន្តែ ទោះជាអ្នកស្រាវជ្រាវ ជឿជាក់ថាពតិមានដែលមាននៅក្នុងរបាយការណ៏នេះ នៅតែមានគុណភាពខ្ពស់ ហើយចំលើយរបស់អ្នកផ្តល់សម្ភាសន៏ទាំងឡាយគឺមានភាពក្បោះក្បាយនិង មានសារសំខាន់ក៏ដោយ អ្នកស្រាវជ្រាវក៏នៅតែស្ទាក់ស្ទើរ មិនហ៊ានស្រង់សំដីអ្នកផ្តល់សម្ភាសន៏ដោយត្រង់ៗទេ អាស្រ័យដោយបញ្ហាភាសានេះ ។

---

[៧] *ចំពោះអត្ថបទពេញនៃសំណួរ សូមមើល ឧបសម្ព័ន្ធ----*

# IV- ក្នុងបរិវេណបន្ទប់ឃុំឃាំង

## សេចក្តីសង្ខេបនៃរបកគំហើញពីការស្រាវជ្រាវ

មានគំរូច្បាស់ៗមួយចំនួនបានលេចឡើងក្នុងពេលដែលកំពុងធ្វើការសម្ភាសន៍របស់អ្នកស្រាវជ្រាវ ។ ការសំរេចចិត្តរបស់មាតាក្នុងការរក្សាទុកកូនរបស់នាងក្នុងពន្ធនាគារជាមួយនាងនោះ គឺច្រើនតែឆ្លុះបញ្ចាំងនូវភាពទាល់ច្រកជាទូទៅរបស់ស្ត្រីដូចជាការខ្វះខាតមណ្ឌលថែទាំច្បាស់សំរាប់កុមារជំនួសមាតាជាដើម ។ ស្ត្រីជាមាតានិង ស្ត្រីមានផ្ទៃពោះទាំងនោះបានរៀបរាប់ប្រាប់អោយយើងបានដឹងនូវការកង្វល់របស់ពួកគាត់ដូចៗគ្នាជាច្រើនអំ ពី ផលប៉ះពាល់មិនល្អក្នុងការរស់នៅក្នុងពន្ធនាគារនេះមកលើកូនៗនិងអនាគតកូនៗរបស់ពួកគាត់ ។ បញ្ហាចម្បងដែលលើកយកមកពិភាក្សាជាមួយ និងស្ត្រីទាំងនោះក៏ដូចជា ជាមួយនិងបុគ្គលិកពន្ធនាគារ និងអ្នកគ្រប់គ្រងពន្ធនាគារនឹងត្រូវបានលើកមកបញ្ជាក់ និង ស្វែងយល់ថែមទៀតត្រួសៗនៅក្នុងកថាខ័ណ្ឌខាងក្រោម ហើយនិងបញ្ជាក់បន្ថែមដោយករណីសិក្សាមួយចំនួនដែលបានដកស្រង់ចេញពីការសម្ភាសន៍ធ្វើជាឧទាហរណ៏បញ្ជាក់អោយកាន់តែច្បាស់ថែមទៀតនូវការលំបាកទាំងឡាយរបស់ស្ត្រីទាំងនោះ ។

## ក –តើស្ត្រីទាំងនោះជាអ្នកណាខ្លះ ?

**ប្រជាសាស្ត្រអ្នកដែលបានផ្តល់ការសម្ភាសន៍ :**

**សេចក្តីបញ្ជាក់ទាំងនេះផ្អែកទៅលើពត៌មានដែលប្រមូលបានពេលសម្ភាសន៍** [៨]

*Chart 1:* អាយុរបស់កុមាររស់នៅជាមួយមាតាក្នុងពន្ធនាគារ




[៨] *ស្ថិតិនេះគឺមានភាពប្រហាក់ប្រហែលច្រើនដោយសារអ្នកផ្តល់សម្ភាសន៍ខ្លះបានផ្តល់នូវចំលើយស្មានៗចំពោះរយ:ពេលដែលគេបានជាប់ឃុំឃាំងរួចមកហើយនៅក្នុងពន្ធនាគារ ដូចជា ឆ្លើយថា: "៧-៨ ខែ " ឬ "ជាងមួយឆ្នាំ " ។*

*Chart 2:* អាយុរបស់ម្តាយ ដែលមានកូន និងស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារ




*Chart 3:* ថេរៈវេលានៃការជាប់ទោសរបស់ម្តាយជាឆ្នាំ



*Chart 4:* ថេរៈវេលាដែលមាតា និងស្ត្រីមានផ្ទៃពោះបានបំរើទោសរួចហើយ




- **សញ្ជាតិ** : ជនជាតិខ្មែរ ១៥ នាក់ និង ជនជាតិវៀតណាម ៥ នាក់
- **ចំនួនសរុបនៃកុមាររស់នៅក្នុងពន្ធនាគារជាមួយម្តាយដែលយើងបានសម្ភាសន៍** : ១៥ នាក់
- **ភេទរបស់កុមារ** : កុមារា ៨ នាក់ និង កុមារី ៧ នាក់
- **អាយុមធ្យមរបស់កុមារ** :ប្រហែល ២,២ ឆ្នាំ
    - កុមារអាយុ១ ខែ ឬតិចជាង១ ខែ : ៤ នាក់
    - កុមារអាយុពី ១ ខែ ដល់ ៦ ខែ : ១ នាក់
    - កុមារអាយុពី ៦ ខែ ដល់ ១១ ខែ : ១ នាក់
    - កុមារអាយុពី ១ ឆ្នាំ ដល់ ៣ ឆ្នាំ : ៥ នាក់
    - កុមារអាយុពី៤ឆ្នាំដល់៥ឆ្នាំ:៣នាក់
    - កុមារអាយុពី ៦ ឆ្នាំ និងលើសពីនេះ : ១ នាក់
- **រយៈពេលមធ្យមដែលកុមារបានរស់នៅក្នុងពន្ធនាគារ** : ៩,៦ ខែ
    - ចំនួនកុមារដែលបានរស់នៅក្នុងពន្ធនាគារតាំងពីកំណើត:៦ នាក់
    - ចំនួនកុមារដែលបានរស់នៅជាមួយម្តាយស្មើនិងរយៈពេលបំរើទោស ឬឃុំខ្លួនរបស់ម្តាយ : ៨ នាក់

ដូចដែលបានឃើញក្នុងតារាងប្រជាសាស្ត្រខាងលើ កុមារមួយភាគធំដែលកំពុងរស់នៅក្នុងពន្ធនាគារ (១៤ នាក់ ក្នុងចំណោម ១៥ នាក់ ស្មើនឹង ៩៣ %) មានអាយុ ៥ ឆ្នាំ ឬទាបជាងនេះ ។ នេះគឺជាចំណុចសំខាន់ពិសេសមួយដែលយើងត្រូវយល់ដឹងថាអាយុ៥ឆ្នាំដំបូងនៃជីវិតរបស់កុមារជាដំណាក់កាលមួយដ៏សំខាន់

បំផុតនៃការវិវឌ្ឍន៏របស់ពួកគេ[៥] ។ រយៈពេលនៃការផ្តន្ទាទោសរបស់មាតាទាំងនោះ មានជា មធ្យម ៦ ឆ្នាំ ហើយរយៈពេលដែលបានបំរើទោសរួច ជាមធ្យមប្រមាណជាមួយឆ្នាំកន្លះ។ នេះចង្អុលបង្ហាញអោយឃើញ ថាកុមារដែលកំពុងរស់នៅក្នុងពន្ធនាគារបច្ចុប្បន្ន ទាំងនោះនឹងត្រូវចំណាយពេលមួយភាគធំនៃដំណាក់កាល លូតលាស់ដ៏សំខាន់របស់គេនៅទីនោះ ។

ចំណុចសំខាន់មួយទៀតដែលយើងគួរកត់សម្គាល់ផងដែរនោះគឺ ចំនួនកុមារជាងពាក់កណ្តាលតែ បន្តិចប៉ុណ្ណោះគឺ (៨នាក់ក្នុងចំណោម ១៥ នាក់ ស្មើនឹង ៥៣%)បានមកតាមម្តាយភ្លាមៗតាំងពីពេលដែលគេ នាំម្តាយយកមកឃុំឃាំងម្ល៉េះ។ ចំណុចមួយទៀតគឺ ចំនួនកុមារតិចជាងពាក់កណ្តាលបន្តិចនៃចំនួនកុមារសរុប គឺ (៦នាក់ ក្នុងចំណោម ១៥នាក់ ស្មើនឹង ៤0%)ជាកុមារដែលបានកើតក្នុងពន្ធនាគារ ។ មានកុមារតែ ម្នាក់គត់ដែលបានចូលមករស់នៅក្នុងពន្ធនាគារជាមួយម្តាយក្រោយពេលដែលម្តាយបានជាប់ឃុំឃាំងមួយរយៈ ហើយ ។ នេះបង្ហាញអោយឃើញថាការចូលមករស់នៅក្នុងពន្ធនាគាររបស់កុមារជាកូនរបស់អ្នកជាប់ពន្ធនាគារ ទាំងនោះគឺមានការពាក់ព័ន្ធដោយផ្ទាល់ទៅនិងការជាប់ឃុំឃាំងក្នុងពន្ធនាគាររបស់មាតា ។ កុមារទាំងនោះ មិនចង់រស់នៅក្នុងពន្ធនាគារទេ តែគេត្រូវតែធ្វើដូច្នេះក្រោយពីមិនអាចស្វះស្វែងរកកន្លែងផ្សេងទៀតរស់នៅ បាន ។ កត្តានេះអាចបណ្តាលមកពីការខ្វះខាត ការមិនចង់បាន និងការមិនបានផ្តល់នូវការថែទាំចម្លាស់ សំរាប់ កុមារប្រភេទនេះ ក្នុងខណៈពេលដែលគេនាំម្តាយមកឃុំខ្លួន ឬឃុំឃាំងនោះ ។

*Chart 5:* ថេរៈវេលាដែលកុមារចូលមកក្នុងពន្ធនាគារ




[៥] *តាមការសិក្សាប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២000 រយៈមធ្យមនៃការបំបៅដោះកូន គឺ ២៤ ខែ ។ ស្ថិតិនេះ ក៏បានបញ្ចូលទាំងក្មេងដែញុំាអាហារបន្ថែមផង ដូចជាទឹក ឬអាហាររាងផ្សេងទៀតដែលថែមពីលើទឹកដោះ ។*

## ៩-សួរថា ហេតុអ្វី ?

### មូលហេតុដែលស្ត្រីទាំងនោះយកកូនមករស់នៅក្នុងពន្ធនាគារ

ការសម្ភាសន៏ បានលាតត្រដាងអោយឃើញថា ស្ត្រីទាំងនោះបានជួបប្រទះនូវបញ្ហាប្រហាក់ប្រហែលគ្នា និងមានគំនិតស្របគ្នានៅពេលសំរេចចិត្តនោះគឺ ជាការពិតប្រសិនបើគេគិតថាគេមានជំរើស ត្រូវជ្រើសរើសនោះ - គឺជ្រើសរើសយកការនាំកូនមករស់នៅជាមួយក្នុងពន្ធនាគារ ។

ខាងក្រោមនេះគឺជាមូលហេតុសំខាន់ៗដែលកូនរបស់ស្ត្រីទាំងនោះរស់នៅជាមួយពួកគាត់ [១០] :

- គ្មានញាតិជួយមើលកូនអោយ-កត្តានេះអាចបណ្តាលមកពីពុំមានញាតិ- ការពិតដែលញាតិនៅឆ្ងាយពីកន្លែងដែលម្តាយកំពុងត្រូវឃុំឃាំងនោះ (ដូចជាករណីស្ត្រីម្នាក់ដែលមានដើមកំណើតជាវៀតណាមនោះញាតិរបស់គាត់ទាំងអស់រស់នៅវៀតណាម) ឬដោយមូលហេតុខ្វះថវិកា ឬធនធានផ្សេងៗនៅក្នុងគ្រួសាររបស់គាត់ ។
- កូននៅកំពុងបៅដោះ-មាតានិងបុគ្គលិកពន្ធនាគារទាំងឡាយដែលយើងបានធ្វើសម្ភាសន៏បានឯកភាពថាកូនដែលនៅបៅដោះគួរតែអោយនៅជាប់ជាមួយម្តាយនៅក្នុងដំណាក់កាលបៅដោះនេះ [១១] ។
- ម្តាយមិនចង់ឃ្លាតពីកូន - មានមាតាជាច្រើនបានពោលថា គាត់ស្រឡាញ់កូនខ្លាំងណាស់ ហើយមិនចង់អោយអ្នកណាមើលថែទាំកូនជំនួសគាត់ឡើយ ។ មានមាតាខ្លះបាននិយាយថា គាត់នឹងមានការអផ្សុកនិងមិនសប្បាយចិត្តបើយកកូនគាត់ចេញពីពន្ធនាគារបាត់ទៅ ។ មានស្ត្រីខ្លះក៏លើកឡើងពីការបារម្ភថា តើជំរើសដទៃផ្សេងដូចជាការផ្ញើកូនអោយនៅអង្គការឬមណ្ឌលកុមារកំព្រានោះ មានការថែរក្សាក្មេងបានត្រឹមត្រូវដែរឬទេ ?

---

[១០] *នេះក៏បានរួមបញ្ចូលទាំងពត៌មានដែលបានមកពីការសម្ភាសន៏អ្នកជាប់ពន្ធនាគារស្ត្រីមានផ្ទៃពោះផងដែរ អាស្រ័យដោយការពិត "កុមារដែររស់នៅក្នុងពន្ធនាគារខ្លះ" មិនទាន់បានកើតមកនៅឡើយទេ ។ ប៉ុន្តែស្ត្រីមានផ្ទៃពោះទាំងនោះបានផ្តល់នូវហេតុផលស្រដៀងគ្នា ក្នុងការគិតទុកកូនគាត់អោយរស់នៅក្នុងពន្ធនាគារជាមួយ ហេតុដូច្នេះហើយទើបយើងបានបញ្ចូលចំលើយ របស់គាត់មកក្នុងទិន្នន័យនេះដែរ ។*

[១១] *យោងតាមការសិក្សាលើប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ ២០០០ រយៈមធ្យមនៃការបំបៅកូនគឺ ២៤ខែ ។ ស្ថិតិនេះក៏បញ្ចូលពួកដែលទទួលអាហារបន្ថែម ដូចជាទឹក ឬវត្ថុរាវផ្សេងៗ បន្ថែមលើទឹកដោះ ។*

● គ្មានជំរើស- អ្នកផ្តល់សម្ភាសន៏ជាច្រើន បានប្រើនូវពាក្យពេចន៏ដូចៗគ្នាទាំងអស់នៅពេលពិភាក្សា អំពីបញ្ហាថាតើហេតុអ្វីបានជាយកកូនមករស់នៅក្នុងពន្ធនាគារ ? ចំលើយខុសគ្នាតែបន្តិចប៉ុណ្ណោះ ដូចជាគាត់ឆ្លើយថា *"ខ្ញុំគ្មានជំរើសណាក្រៅពីនេះទេ"* ឬឆ្លើយថា *"គ្មានជំរើស"* ។ នៅពេលដែលមានចំលើយបែបនេះច្រើនដងនៅក្នុងការសម្ភាសន៏នោះធ្វើអោយយើងមានការចាប់អារម្មណ៏ជាខ្លាំង។ ភាគច្រើននៃពាក្យសំដីទាំងនោះ ច្រើនតែចេញមកពីស្ត្រីដែលជឿជាក់ថា ការយកកូនមករស់នៅជាមួយក្នុងពន្ធនាគារបែបនេះមិនមែនជាផលប្រយោជន៏ដ៏ល្អបំផុតរបស់កូននោះទេ ប៉ុន្តែពួកគាត់គិតថាគ្មានដំណោះស្រាយជាជំរើសណាក្រៅពីធ្វើដូច្នេះឡើយ ។

*Chart 6:* មូលហេតុដែលម្តាយរក្សាកូនទុកឱ្យរស់នៅក្នុងពន្ធនាគារ




| **ករណីសិក្សា ទី ១** |
| --- |
| ធារ៉ា[១២] បាននិយាយថា កូនស្រីរបស់គាត់ឈ្មោះស្រី គានឹងបន្តរស់នៅជាមួយគាត់ក្នុងរយៈពេលបីឆ្នាំដែលគាត់នៅសល់ត្រូវជាប់ទោសនោះទៀត ដែលមានរយៈពេលផ្តន្ទាទោសសរុបទាំង អស់៥ឆ្នាំ ពីព្រោះជីដូនរបស់ស្រីគាក្រីក្រ ហើយថែមទាំងជាប់មើលថែទាំចៅច្រើនណាស់ហើយ។ បើអោយកូនទៅរស់នៅជាមួយជីដូនធារ៉ាបារម្ភខ្លាច ស្រីគា គ្មានអាហារញ៉ាំគ្រប់គ្រាន់ទេ ។ ដូច្នេះនាងគិតថាយកល្អ ស្រីគាគួរតែរស់នៅជាមួយគាត់ក្នុងពន្ធនាគារនេះហើយ ។ |

[១២] *ឈ្មោះនិងអត្តសញ្ញាណរបស់អ្នកជាប់ពន្ធនាគារ កុមារ និងបុគ្គលិកពន្ធនាគារត្រូវបានដូរដើម្បីសុវត្ថិភាព របស់ពួកគេ ។*

| ករណីសិក្សាទី ២ |
|---|
| សុខ ហួ មានការខ្វាយខ្វល់ចំពោះកូនគាត់ដែលរស់នៅក្នុងពន្ធនាគារជាមួយគាត់ ពីព្រោះគាត់គ្មានលុយសំរាប់ចិញ្ចឹមកូននោះឡើយ ប៉ុន្តែគិតថា គ្មានជំរើសណាក្រៅពីនេះទេ ។ |

| ករណីសិក្សាទី ៣ |
|---|
| មានគេប្រាប់ សុធាថា គេមិនអនុញ្ញាតអោយកូន១រស់នៅជាមួយនិងម្តាយក្នុងពន្ធនាគារទេ ។ ប៉ុន្តែពេលនេះកូន សុធា នៅបៅដោះនៅឡើយ ដូច្នេះមិនអាចបំបែកចេញពីនាងបានទេ ។ ដោយសារមានគេប្រាប់គាត់ដូច្នេះ ទើប សុធាមានការព្រួយបារម្ភយ៉ាងខ្លាំងខ្លាចគេមិនអនុញ្ញាត អោយកូនគាត់បន្តរស់នៅក្នុងពន្ធនាគារជាមួយគាត់តទៅទៀត ។ គាត់បន្តនិយាយថាបើមិនបានកូនគាត់រស់នៅជាមួយនោះ គាត់ប្រាកដជាពិបាកចិត្តស្លាប់ហើយ ។ |

| ករណីសិក្សាទី ៤ |
|---|
| លោកចាងហ្វាងពន្ធនាគារបានប្រាប់បុប្ផាថានៅពេលដែលកូនប្រុសរបស់នាងធំល្មមហើយ មិនអាចបន្តនៅក្នុងពន្ធនាគារបាននោះ គេនឹងយកកូននោះទៅនៅក្នុងមណ្ឌលកុមារកំព្រា ។ បុប្ផាយល់ថា អោយកូនទៅរស់នៅក្នុងមណ្ឌលកុមារកំព្រាមិនមានសុវត្ថិភាពដូចទុកកូនអោយនៅជាមួយខ្លួនក្នុងពន្ធនាគារទេ ។ នៅពេលកូនធំល្មមត្រូវចាកចេញពីពន្ធនាគារនោះ បុប្ផា មិនដឹងថាកូននឹងទៅនៅឯណាទេ ពីព្រោះនាងគ្មានញាតិណាទទួលយកកូនទេ ។ |

## គ-ការបញ្ចេញមតិ

**ក្តីកង្វល់ធំបំផុតរបស់មាតា និង ស្ត្រីមានផ្ទៃពោះជាពិរុទ្ធជន និង ទណ្ឌិត**

ក្នុងពេលសម្ភាសន៏ស្ត្រីទាំងនោះ ពួកគាត់បានបញ្ចេញអោយដឹងនូវអារម្មណ៏ផ្សេង១គ្នាស្តីអំពីការរស់នៅរបស់កូនពួកគាត់នៅក្នុងពន្ធនាគារ ហើយការកង្វល់របស់ពួកគាត់ជាច្រើនគឺដដែល១ជាន់គ្នា ។ ភាគច្រើននៃគំនិតដែលគេបានលើកឡើងនោះ យើងអាចបែងចែកចេញជា៦ប្រភេទដូចខាងក្រោម :

**១-ម្ហូបអាហារ អាហារបំប៉ន និង ទឹក :**

ពេលដែលយើងពិភាក្សាជាមួយអ្នកទោសស្ត្រីនោះ យើងដឹងថា បញ្ហាដែលកើតមានជាយូរលង់ណាស់មកហើយនោះគឺ ការខ្វះម្ហូបអាហារ និង ពុំមានអាហារ បំប៉នគ្រប់គ្រាន់ ។ មានស្ត្រី ១៤ នាក់ក្នុងចំណោមស្ត្រី

២០នាក់ស្មើនឹង ៧០% បាននិយាយថា ពួកគាត់និងកូន របស់ពួកគាត់មិនដែលបានទទួលអាហារនិងចំណីបំប៉នគ្រប់គ្រាន់ឡើយ ។ ស្ត្រី៨នាក់ក្នុងចំណោមស្ត្រី ១៣ នាក់ស្មើនឹង ៦២% បាននិយាយថាកូន១របស់ពួកគាត់តែងតែត្អូញត្អែរថាហេវបាយជាប្រចាំ ។

ភាគច្រើននៃអ្នកជាប់ពន្ធនាគារបានទទួលទានអាហារបាយពីរដងក្នុងមួយថ្ងៃ ហើយជាធម្មតាម្ហូបរបស់ពួកគាត់មានតែបាយមួយចាន និង សម្លរមួយចាន ដែលជារឿយៗមានតែបន្លែ ។ ទាំងបុគ្គលិកពន្ធនាគារ និង ទាំងអ្នកជាប់ពន្ធនាគារបានលើកឡើងច្រើនលើកច្រើនសារថាម្ហូបអាហារសំរាប់ អ្នកទោសនោះមិនគ្រប់គ្រាន់ ទេ ទាំងគុណភាព និង បរិមាណ ។ តាមគោលការណ៍រដ្ឋ -គេបានកំណត់របបអោយអ្នកជាប់ពន្ធនាគារម្នាក់ ១000 រៀល ក្នុងមួយថ្ងៃសំរាប់ថ្លៃម្ហូបអាហារ ប៉ុន្តែថវិកានេះត្រូវបានគេយកទៅប្រើមិនត្រឹមតែម្ហូបតែម្ហូបអាហារប៉ុណ្ណោះទេតែថែមទាំងសំរាប់បង់ថ្លៃអគ្គីសនី និងការជួសជុលថែទាំអគារផ្សេងៗ ។ល ។ផងដែរ ។

ចំនួនថវិកានេះគឺនៅតែដដែលដោយគេមិនបានគិតដល់អ្នកដែលរស់នៅជាមួយអ្នកជាប់ពន្ធនាគារនោះទេ ដោយហេតុនេះហើយមានកូនអ្នកជាប់ពន្ធនាគារជាច្រើនបានញ៉ាំចំណែកបាយរបស់ម្តាយដែលពន្ធនាគារបានចែកអោយសំរាប់តែម្តាយម្នាក់តែប៉ុណ្ណោះ ។ ផ្តើមចេញពីម្ហូបអាហារដែលវាស្តួចស្តើងរួចស្រាប់ទៅហើយនោះ ពេលគេបែងចែកជាមួយកូនថែមទៀតនោះវាកាន់តែស្តួចស្តើងថែមទៀតហើយចុះបើគេមានកូនលើសពីនេះទៀតនោះចំណែកបាយដែលគេបានហូបវារឹតតែតិចណាស់ទៅទៀត ។ ឧទាហរណ៍កូន១ទាំង៣នាក់របស់សូភីរស់នៅក្នុងពន្ធនាគារជាមួយនាងដែរ ហើយទាំងអស់ញ៉ាំរបបអាហារ ដែលបុគ្គលិកពន្ធនាគារបានចែកអោយនាង ។ សូភីនិយាយថាកូន១នាងមិនដែលបានញ៉ាំបាយឆ្អែតទេ ជាពិសេសកូនប្រុសរបស់នាងតែងតែត្អូញថាហេវបាយជារាល់១ថ្ងៃ ។

| **ករណីសិក្សាទី ៥** |
| --- |
| **កញ្ញា គិតថា បើនាងរស់នៅក្រៅពន្ធនាគារ នោះកូនរបស់នាងនឹងមានបាយញ៉ាំឆ្ងាញ់ជាងនេះ ។ នាងបាននិយាយថា មិនដែល "ហ៊ានសុំ" បាយថែមទៀតទេ ដោយនាងយល់ថា គេមានរបបបាយកំណត់សំរាប់ចែកអោយអ្នកជាប់ពន្ធនាគារផ្សេងៗទៀត ។ នាងក៏មិនសង្ឃឹមថា បុគ្គលិកពន្ធនាគារនោះមានបាយអោយនាងថែមទៀតដែរ ។** |

| **ករណីសិក្សាទី ៦** |
| --- |
| **រស្មីបានគិតថា នាងមិនមានវីតាមីនគ្រប់គ្រាន់ទេ ក្នុងខណៈពេលដែលនាងមានផ្ទៃពោះនេះ ប៉ុន្តែនាងមិនដែលហ៊ាននិយាយរឿងនេះប្រាប់អ្នកណាមួយនៅក្នុងពន្ធនាគារទេ ។ នាងបាននិយាយថា នាង** |

**"មិនហ៊ាននិយាយប្រាប់គេ" ។ នាងខ្លាចក្នុងការនិយាយប្រាប់បុគ្គលិកពន្ធនាគារ ហើយនាងក៏មិនដែលហ៊ាន សាកល្បងម្តងដែរ ។ រស្មីដឹងថានាងនឹងមិនបានការជួយឧបត្ថម្ភអ្វីពីសំណាក់បុគ្គលិកពន្ធនាគារនេះទេ ពីព្រោះពួកគេមិនមានធនធានសំរាប់ជួយទេ ។ ពួកបុគ្គលិកទាំង នោះក៏ជួបប្រទះបញ្ហាការខ្វះខាតម្ហូប អាហារ និងម្ហូបអាហារដូចអ្នកជាប់ពន្ធនាគារដែរ ។ នាង គិតថា បុគ្គលិកពន្ធនាគារនឹងមិនឆ្លើយតបមក នាងវិញទេ បើនាងនិយាយរឿងខ្វាយខ្វល់នេះប្រាប់គេ ។**

ញាតិរបស់អ្នកជាប់ពន្ធនាគារក៏អាចយកម្ហូបអាហារបន្ថែមអោយគេបាន ដែរប៉ុន្តែករណីនេះកម្រ ជួបប្រទះណាស់ក្នុងចំណោមស្ត្រីដែលបានសម្ភាសន៍ទាំងអស់ ។ មានស្ត្រីជាប់ពន្ធនាគារ ២នាក់ស្មើនឹង ១០% ដែលយើងសម្ភាសន៍នោះនិយាយថា ពួកគេបានទទួលម្ហូបអាហារបន្ថែមពីគ្រួសាររបស់ពួកគេ ។ របាយការណ៍ លីកាដូមួយ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងពន្ធនាគារមួយបានអោយដឹងថា "ស្ត្រីជាធម្មតាទទួលបានម្ហូបអាហារបន្ថែមពីគ្រួសារតិចជាងបុរស ។ បញ្ហាម្ហូបអាហារនេះកាន់តែមានលក្ខណៈលំបាកខ្លាំងឡើងចំពោះអ្នកជាប់ពន្ធនាគារណាដែលមានកូននៅជាមួយ ដោយសារតែគ្មានរបបម្ហូបអាហារបន្ថែមដល់កុមារទាំងនោ "[១៣] ។ គ្រួសាររបស់ទណ្ឌិត និងពិរុទ្ធជនភាគច្រើនរស់នៅឆ្ងាយ ឬពួកគេជាអ្នកក្រីក្រមិនមានលទ្ធភាពធ្វើដំណើរមកសួរសុខទុក្ខនៅពន្ធនាគារបាន ។ លើសពីនេះទៅទៀតក៏មានពិរុទ្ធជន និងទណ្ឌិតមួយចំនួនមិនមានសាច់ញាតិតែម្តង ។

យើងសង្កេតឃើញមានពន្ធនាគារតែពីរប៉ុណ្ណោះដែលនិយាយថាមានការផ្តល់ម្ហូបអាហារបន្ថែមអោយស្ត្រីណាដែលមានកូននៅជាមួយ និងស្ត្រីមានផ្ទៃពោះជាប្រចាំ ។ នៅពន្ធនាគារតាខ្មៅខេត្តកណ្តាល មានស្ត្រីតែម្នាក់គត់ដែលមានកូននៅជាមួយ ហើយនិយាយថាបានទទួលរបបអាហារលើសពីស្ត្រីដទៃទៀត ហើយបុគ្គលិកសុខាភិបាល និង ប្រធានពន្ធនាគារ ក៏បានបញ្ជាក់ថា មានការផ្តល់អោយលើសដូច្នោះមែន ។
ដូចគ្នានេះដែរ មណ្ឌលកែប្រែទី២ព្រៃសរ លោកចាងហ្វាងពន្ធនាគារបានមានប្រសាសន៍ថា លោកបានសុំអោយចុងភៅផ្តល់របបអាហារច្រើនៗជាពិសេសសំរាប់ស្ត្រីដែលទើបតែសម្រាលកូន ។ ក្នុងពេលសម្ភាសន៍ ពន្ធនាគារកំពុងចែកអាហារបន្ថែមដល់ស្ត្រីពីរនាក់ដែលទើបតែសម្រាលកូនរួច គឺអោយត្រីយកទៅស្ងោរដោយខ្លួនឯង ។ ប៉ុន្តែមានស្ត្រីម្នាក់ក្នុងចំណោមអ្នកទាំងពីរនោះបាននិយាយថា នាងមិនមានគ្រឿងសំរាប់ស្ងោរទេ ហើយម្នាក់ទៀតនិយាយថានាងបានទទួលម្ហូបអាហារបន្ថែមនេះត្រឹមតែមួយខែប៉ុណ្ណោះក្រោយពេលសម្រាលរួច ។ ស្ត្រីទីបីម្នាក់ទៀត ដែលបានសម្ភាសន៍ ទើបតែសម្រាលកូនបាន ១០ ថ្ងៃកន្លងមក និយាយថា នាង

---

[១៣] *លីកាដូ : ពន្ធនាគារកម្ពុជា -បញ្ហាសិទ្ធិមនុស្សទាំងឡាយ -(ភ្នំពេញ: លីកាដូឆ្នាំ ១៩៩៨ ) ទំព័រ ៦*

បានទទួលម្សៅទឹកដោះគោពីគ្រូពេទ្យប្រចាំពន្ធនាគារ ។ គ្រូពេទ្យនោះបានអោយម្សៅទឹកដោះគោ ១ គីឡូក្រាម ហើយនាងមិនបានដឹងថាទៅថ្ងៃក្រោយនឹងបានអោយទៀតឬអត់ទេ ។ អាហារបន្ថែមនៅមណ្ឌលកែប្រែទី ២មានសំរាប់តែស្ត្រីណាដែលទើបតែសម្រាលកូនថ្មីៗ ហើយក៏ឃើញមានស្ត្រីម្នាក់ដែលមានកូនអាយុ ៥ ឆ្នាំបានទទួលអាហារច្រើនជាងអ្នកទោសដទៃទៀត ហើយចំពោះមាតា ៥ នាក់ទៀតបាននិយាយថាពួកគាត់អោយកូនហូបរបបបាយជាមួយគាត់ដែលគាត់បានទទួលចំណែកមក។

បុគ្គលិកពន្ធនាគារចំនួនពីរកន្លែងបានអះអាងប្រាប់យើងថា គាត់បានផ្តល់អាហារបន្ថែមដល់កូនអ្នកជាប់ពន្ធនាគារ ដោយបន្ថែមថា ជួនកាលគាត់ប្រើប្រាស់ថវិកាផ្ទាល់ខ្លួនដើម្បីទិញ "នំដែលមានជីវជាតិ " ឬ " នំដែលមានជាតិទឹកដោះគោ " ដើម្បីបំពេញបន្ថែមនូវចំណីអាហារដល់កុមារ ឬ ទិញទឹកដូងអោយស្ត្រីដែលមានកូនបៅដោះ ។ ប៉ុន្តែ ចំណុចនេះក៏ពុំមានការបញ្ជាក់ពីអ្នកជាប់ពន្ធនាគារផ្ទាល់ថាពិត ឬមិនពិតទេនៅក្នុងការសម្ភាសន៏ជាមួយគេនោះ ។ តាមការពិត មាតានៅក្នុងពន្ធនាគារទាំងពីរបានបង្ហើបអោយដឹងថា ដើម្បីបានទទួលអាហារបន្ថែម គាត់ត្រូវចំណាយខ្លះៗ មានជាថវិកា ឬ ជាផ្ទួរអ្វីមួយ ។ មានស្ត្រីម្នាក់បាននិយាយថានាងជួនកាលបោកគក់សំលៀកបំពាក់អោយប៉ូលីស "អ្នកយាម "ដើម្បីបានទទួលអាហារបន្ថែម ។ ស្ត្រីម្នាក់នៅពន្ធនាគារមួយផ្សេងទៀតនិយាយថា នាងអាចបានទទួលអាហារបន្ថែមតែនៅពេលណាដែលប្តីរបស់នាងមកសួរសុខទុក្ខនាងនិងអោយលុយនាង ដែលនាងអាចទិញអ្វីៗពីខាងក្រៅពន្ធនាគារតាមរយៈបុគ្គលិកពន្ធនាគារតែប៉ុណ្ណោះ ។

ប្រការដែលមិនបានផ្តល់ចំណីអាហារនិង អាហារមានតុល្យភាពល្អសំរាប់រាងកាយដល់កុមារ និងស្ត្រីមានផ្ទៃពោះនៅក្នុងពន្ធនាគារ ជាមូលហេតុមួយនាំអោយមានកង្វល់ជាខ្លាំង ។ កង្វះខាតអាហារូបត្ថម្ភ គឺជាលក្ខណ្ឌធ្ងន់ធ្ងរមួយ ដែលបង្ហាញអោយឃើញនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កុមារដោយផ្ទាល់ និង ដោយប្រយោល។ ការផ្តល់ចំណីអាហារមិនបានគ្រប់គ្រាន់គឺជាលក្ខណ្ឌធ្ងន់ធ្ងរនិងពាក់ព័ន្ធ ដែលធ្វើអោយបាត់បង់ការលូតលាស់និងការអភិវឌ្ឍន៍ ព្រមទាំងបណ្តាលអោយមានជំងឺផ្សេងៗផងដែរ ។ លើសពីនេះទៅទៀត កង្វះខាតអាហារបំប៉នក្នុងពេលមានផ្ទៃពោះ អាចប៉ះពាល់ដល់ការលូតលាស់នៃគភ៌ ព្រមទាំងអាចកើតមានគ្រោះថ្នាក់ដល់អាយុជីវិតម្តាយ និងទារកផងក៏មាន ។ "*សភាពនៃមាតាពិភពលោក* " ឆ្នាំ២០០១ជារបាយការណ៏មួយដែលចេញផ្សាយដោយអង្គការសង្រ្គោះកុមារទទួលស្គាល់ថា "សុខភាពទារកគឺពឹងផ្អែកមួយភាគយ៉ាងធំ

ទៅនិងស្ថានភាពចំណីអាហាររបស់ម្តាយ ។ ការលុបបំបាត់ចោលបាននូវកង្វះអាហារូបត្ថម្ភ ក្នុងពេលមានផ្ទៃពោះ បានកាត់បន្ថយកំរិតគ្រោះថ្នាក់ដល់ជីវិត និងជំងឺរបស់កុមាររហូតជិតដល់មួយភាគបី ”[១៤] ។

ក្រោយពេលសម្រាលកូនរួច កង្វះចំណីអាហារអាចបណ្តាលអោយមាតាមិនមានទឹកដោះគ្រប់គ្រាន់ ហើយបញ្ហានេះបានកើតឡើងច្រើនក្នុងចំណោមស្ត្រីដែលយើងបានសម្ភាសន៍។ ស្ត្រីចំនួន៧នាក់ក្នុងចំណោមស្ត្រី ១០នាក់ដែលស្មើនឹង៧០%ដែលមានកូន បានត្អូញត្អែរថាពុំមានទឹកដោះគ្រប់គ្រាន់សំរាប់បំបៅកូន ឬមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផលិតទឹកដោះអោយបានគ្រប់គ្រាន់សំរាប់កូនបៅទេ។ ស្ត្រីទាំងនោះជួនកាលបញ្ចុកបន្ថែមអោយកូននូវអាហារដូចជាទឹកបបូរឬបាយសម្លរដែលពន្ធនាគារចែក។ ស្ត្រីម្នាក់បាននិយាយថា នាងបានអោយកូនញុំាបបរ ដោយសារនាងមិនអាចមានទឹកដោះគ្រប់គ្រាន់សំរាប់កូន។ គាត់បានយកអង្ករដែលសុំបានពីអ្នកជាប់ពន្ធនាគារដូចគ្នានោះមកដាំធ្វើបបរអោយកូនញុំា ពីព្រោះខាងពន្ធនាគារមិនមានផ្តល់បបរនេះទេ។

សារៈសំខាន់នៃការបំបៅដោះត្រូវបានប្រទេសជឿនលឿនគេយកចិត្តទុកដាក់តាំងពីយូរយារណាស់មកហើយថាជាគន្លឹះសំខាន់បំផុតចំពោះសុខភាពកុមារ ។ យោងតាមការស្រាវជ្រាវមួយរបស់អង្គការសុខភាពពិភពលោកនិងអង្គការផ្សេងៗទៀត ព្រមទាំងរបាយការណ៍ *សភាពនៃទារកពិភពលោក* របស់អង្គការសង្គ្រោះកុមារថាៈ ការពិនិត្យសារឡើងវិញថ្មីៗនេះបានបង្ហាញនូវប្រយោជន៍យ៉ាងក្រាសក្រែលនៃការចិញ្ចឹមកូនដោយការបំបៅដោះទាំងស្រុង ដោយមិនប្រើអាហារផ្សេងៗមកជំនួស ឬបំពេញបន្ថែមលើការបំបៅដោះនោះ។ វាក៏នូវបានបង្ហាញអោយឃើញថែមទៀតថា ក្នុងចំណោមការចិញ្ចឹមទាំងឡាយ មានតែការបំបៅដោះតាំងពីដំបូងរហូតមក និងអោយបៅតែទឹកដោះម្តាយតែមួយមុខគត់នោះ វានឹងបានកាត់បន្ថយនូវកំរិតមរណៈភាពរបស់កុមារពីការឆ្លងជំងឺផ្សេងៗ[១៥] ។ ជាធម្មតាស្ត្រីដែលសម្រាលកូននៅក្នុងពន្ធនាគារច្រើនតែមិនមានលទ្ធភាពផ្តល់ការបំបៅដោះតាមសេចក្តីត្រូវការទាំងស្រុងរបស់កូនបានទេ ។

| **ករណីសិក្សា ទី ៧ៈ** |
|---|
| **កូនប្រុសរបស់ គន្ធាបានបៅដោះ និងបៅទឹកដោះគោថែមទៀត ។ ជួនកាល គន្ធាបានពឹងអោយអ្នកណាម្នាក់ក្នុងពន្ធនាគារ ជួយទិញទឹកដោះគោពីខាងក្រៅពន្ធនាគារអោយនាង ដោយនាងមិនទាន់អាច** |

---

[១៤] *ឌីយ៉ាណេ ស្យាម៉ាន សភាពនៃមាតុតាពិភពលោក ឆ្នាំ ២០០១ សរសេរដោយអង្គការសង្គ្រោះកុមារ ទំព័រ ៨-៩*

[១៥] *អានតូនី កូស្តេឡូនិងសហការី សភាពនៃទារកពិភពលោក សរសេរដោយអង្គការសង្គ្រោះកុមារ ទំព័រ ៣៤*

ដើរបានស្រួល ។ កូនប្រុសរបស់នាងត្រូវការទឹកដោះគោបន្ថែមទៀត ដោយសារ គន្ធា មិនមានអាហារញ៉ាំគ្រប់គ្រាន់ដូច្នេះហើយនាងមិនអាចមានទឹកដោះគ្រប់គ្រាន់សំរាប់បំបៅកូនទេ ។ នាងមិនដែលមានសាច់ញាតិណាមកសួរសុខទុក្ខទេ ហេតុនេះទើបនាងមិនដែលបាន ទទួលចំណីអាហារបន្ថែមពីខាងក្រៅសោះ ។ ជួនកាលអ្នកទោសដទៃទៀតបានអោយលុយនាង ៥០០រៀល ឬ ១០០០ រៀលដើម្បីទិញចំណី ។

ក្នុងពេលដែលនាងមានផ្ទៃពោះ គន្ធាបានពឹងអ្នកជាប់ពន្ធនាគារដទៃទៀតអោយជួយដងទឹកពីអណ្តូងអោយនាង ហើយនាងថា នឹងអោយលុយគេក្នុងការជួយនោះ ។ ឥឡូវនេះ នាងបានជំពាក់លុយអ្នកជាប់ពន្ធនាគារដទៃទៀតយ៉ាងច្រើន។

**ករណីសិក្សាទី ៨**

ជួនកាល រតនា មិនមានទឹកដោះ ដោយសាររបបហូបចុកមិនគ្រប់គ្រាន់ដែលបណ្តាលអោយនាងមិនអាចមានទឹកដោះគ្រប់គ្រាន់ ដូច្នេះកូនប្រុសរបស់នាងត្រូវបៅទឹកស្ករ ។ កូនគាត់មិនអាចញ៉ាំបាយជាមួយគាត់បានទេ ព្រោះកូននោះនៅតូចពេក ហើយមិនអាចញ៉ាំបាយដូចមនុស្សធំបាន ។ រតនា និយាយថា ដោះនាងម្ខាង " មិនល្អ " (ឧទាហរណ៍ដូចជា មិនមានទឹកដោះ) ដូច្នេះនាងបានបំបៅដោះកូនត្រឹមតែ ៦ ខែប៉ុណ្ណោះ ។ កូនគាត់យំរាល់ថ្ងៃដោយឃ្លានបៅខ្លាំងពេក ។ កូននោះទារញ៉ាំសាច់តែនាងមិនមានលុយទិញទេ ។

សរុបសេចក្តីទៅយើងសង្កេតឃើញថា ស្ត្រីនៅពន្ធនាគារខេត្តបាត់ដំបង ពោធិសាត់ និង មណ្ឌលកែប្រែទី ២ ព្រៃសរ ខ្វាយខ្វល់ពីការជួបការលំបាកអំពីកង្វះទឹកស្អាតបរិភោគ ។ ស្ត្រី៣នាក់ក្នុងចំណោមស្ត្រីទាំង ១៨ នាក់ ដែលយើងបានសម្ភាសន៍ស្មើនឹង ១៧% បានបង្ហាញអូរមួយនៅក្បែរនោះថាជាប្រភពទឹក ដែលគេប្រើប្រាស់សំរាប់ផឹករាល់ថ្ងៃ។ ស្ត្រីចំនួន១%ទៀត បាននិយាយថា ទឹកដែលគាត់ផឹកសព្វថ្ងៃនេះ គេយកមកពីស្ទឹងមួយនៅជិតនោះ ចំណែកឯស្ត្រីចំនួន៦នាក់ទៀតស្មើនឹង ៣៣% និយាយថា មិនដឹងគេយកទឹកនោះមកពីណាទេ។ ក្នុងចំណោមស្ត្រីទាំងនេះ មានតែស្ត្រី ៦នាក់ប៉ុណ្ណោះស្មើនឹង ៣៣% ដែលដាំ ទឹកមុននឹងផឹក ហើយស្ត្រី២នាក់ទៀតនិយាយថា ពួកគាត់មិនបានដាំទឹកផឹកទេ ពីព្រោះមិនមានឧបករណ៍សំរាប់ដាំ ។ ដូចដែលនឹងបានឃើញនៅក្នុងឧទាហរណ៍បញ្ជាក់ក្នុងករណីសិក្សាខាងក្រោម មានស្ត្រី២នាក់ដែល ជួនកាលត្រូវចំណាយថវិកាខ្លះ១ផងក៏មានដើម្បីអោយបានទឹកគ្រប់គ្រាន់សំរាប់ខ្លួនគាត់និងកូន ។

| **ករណីសិក្សាទី ៩** |
|---|
| **ម៉ុម បាននិយាយថា មានទឹកតិចតួចណាស់សំរាប់បរិភោគ បុគ្គលិកពន្ធនាគារបានចែកទឹកអោយពួកគាត់មួយកែវពេលព្រឹក និង មួយកែវពេលល្ងាច ។ បើអ្នកជាប់ពន្ធនាគារណាមានលុយ គេអាចចំណាយខ្លះទើបនឹងបានទឹកថែមទៀត ។** |

## ២-បញ្ហាសុខភាព និង លទ្ធភាពនៃការទទួលបានការព្យាបាល

កង្វះការថែទាំសុខភាព គឺជាបញ្ហាមួយធំទៀត ដែលត្រូវបានលើកឡើងជារឿយៗនៅក្នុងពេលសម្ភាសន៏។ មានស្ត្រីចំនួន ១១ នាក់ក្នុងចំណោមស្ត្រី ១៨ នាក់ (៨៥%) បានលើកឡើងថា កូនរបស់ពួកគេបានជួបប្រទះបញ្ហាសុខភាពក្នុងខណៈដែលរស់នៅក្នុងពន្ធនាគារ ។ បញ្ហាសុខភាពភាគច្រើនត្រូវបានចាត់ទុកថាជាបញ្ហាស្រាល១ ដូចជា ក្អក ផ្តាសាយ គ្រុន ឆ្អល់ពោះ និងជំងឺផ្សេង១ទៀតស្រដៀងគ្នានេះ។ ប៉ុន្តែ ស្ត្រីជាច្រើនបានបង្ហាញនូវការព្រួយបារម្ភខ្លាំងថា បើកូន១របស់ពួកគាត់ឈឺធ្ងន់ នោះនឹងមិនអាចមានលទ្ធភាពព្យាបាលបានត្រឹមត្រូវទេ ។

គ្រូពេទ្យលីកាដូក៏បានធ្វើការព្យាបាលស្ត្រី និង កុមារដែររាល់ពេលដែលគ្រូពេទ្យទាំងនោះចុះទៅពិនិត្យព្យាបាលអ្នកជាប់ពន្ធនាគារទាំងនោះរៀងរាល់ខែនៅតាមពន្ធនាគារចំនួន១២កន្លែង។ ក្នុងរបាយការណ៏ឆ្នាំ២០០១ ចំនួនស្ត្រីដែលបានទទួលការព្យាបាលមានចំនួនស្មើនិង ៧,៧%នៃចំនួនអ្នកជាប់ពន្ធនាគារទាំងអស់ដែលបានព្យាបាល ដោយរួមទាំងស្ត្រីមានផ្ទៃពោះផងដែរ (ពុំមានស្ថិតិណាមួយបានបញ្ជាក់ពីចំនួនកុមារដែលបានព្យាបាលទេ)។ ប៉ុន្តែគ្រូពេទ្យលីកាដូមិនបានចុះធ្វើការពិនិត្យព្យាបាលរោគនៅគ្រប់ពន្ធនាគារដែលយើងបានធ្វើការសិក្សាស្រាវជ្រាវនោះទេ។

លើសពីនេះទៅទៀត គ្រូពេទ្យអង្គការលីកាដូមិនមានលទ្ធភាពក្នុងការផ្តល់ការថែទាំសុខភាពប្រចាំថ្ងៃឬជាបន្តគ្រប់ពេលនោះទេ ហើយក្រៅពីការចុះទៅពិនិត្យព្យាបាលរោគអ្នកជាប់ពន្ធនាគារប្រចាំខែគ្រូពេទ្យអង្គការលីកាដូមានត្រឹមតែធនធានសំរាប់ផ្តល់នូវជំនួយសង្គ្រោះជាបន្ទាន់ឬក្នុងកាលៈទេសៈចាំបាច់ណាមួយប៉ុណ្ណោះ។ ដូច្នេះស្ត្រីជាមាតា កុមារ និងស្ត្រីមានផ្ទៃពោះទាំងនោះត្រូវបង្ខំចិត្តពឹងពាក់ទៅលើគ្រូពេទ្យ និងជំនួយពីគ្រូពេទ្យពន្ធនាគារមួយភាគធំ ។

**ករណីសិក្សាទី ១០**

**សុភាព បាននិយាយថា លោកវេជ្ជបណ្ឌិតមិនបានធ្វើការពិនិត្យព្យាបាលកូនរបស់នាងទេ ក្រោយពីនាងសម្រាលកូនរួចពីព្រោះនាងពុំមានថវិកា ។ ការពិតនាងចង់អោយលោកវេជ្ជបណ្ឌិតពិនិត្យព្យាបាលកូននាងដែរ ប៉ុន្តែនាងមិនដែលបានសុំស្នើម្តងទេ - នាងនិយាយថា នាង "មិនហ៊ានសុំទេ"សុភាពក៏បាននិយាយផងដែរថា នាង"យល់ថាវេជ្ជបណ្ឌិតនោះមិនយល់អំពីបញ្ហាសុខភាពរបស់ទារកទេ ។**

ករណីសិក្សាខាងលើបានបង្ហាញអោយឃើញនូវចំណុចសំខាន់ៗពីរថែមទៀតទាក់ទងទៅនិងស្ថានភាពរស់នៅជាក់ស្តែងរបស់កុមារក្នុងពន្ធនាគារ ដូចជាបញ្ហាកង្វះការថែទាំសំរាប់ផ្នែកសុខភាពម្តាយនិង កុមារព្រមទាំងតំរូវការថវិកាសំរាប់ចាយលើការព្យាបាលនៅមន្ទីរពេទ្យខាងក្រៅពន្ធនាគារ ។ ស្ត្រី២នាក់ក្នុងចំណោមស្ត្រី៧នាក់បានសម្រាលកូនក្នុងពេលដែលកំពុងស្ថិតនៅក្រោមការឃុំឃាំងក្នុងពន្ធនាគារ ដោយខាងពន្ធនាគារបានយកពួកគេទៅសម្រាលកូននៅមន្ទីរពេទ្យខាងក្រៅពន្ធនាគារ ហើយការធ្វើបែបនេះគឺអាស្រ័យដោយប្រកាសលេខ២១៧របស់កម្ពុជាស្តីអំពីការគ្រប់គ្រងពន្ធនាគារ និងនីតិវិធីពន្ធនាគារនិងក៏ដូចជាយោងទៅលើបទដ្ឋានអប្បបរមារបស់អ.ស.ប.សំរាប់ការអនុវត្តន៏ទៅលើអ្នកជាប់ពន្ធនាគារ ដែលបានចែងថាៈ ស្ត្រីមានផ្ទៃពោះត្រូវតែនាំយកទៅសម្រាលកូននៅមន្ទីរពេទ្យ[១៦] ។ មានស្ត្រីមានផ្ទៃពោះ២នាក់ក្នុងចំណោមស្ត្រីមានផ្ទៃពោះ៧នាក់បាននិយាយថា នាងចង់សម្រាលកូននៅក្នុងពន្ធនាគារវិញ ហើយមាន៤នាក់ទៀតនិយាយថាគាត់មិនទាន់ដឹងថានឹងទៅសម្រាលកូននៅឯណាទេ ។ ដូច្នេះចំណុចខាងលើនេះបង្ហាញថាមិនទាន់មានការធានាអោយបានជាក់លាក់ថា ស្ត្រីមានផ្ទៃពោះទាំងនោះត្រូវទៅសម្រាលកូននៅក្នុងមន្ទីរពេទ្យក្រៅពន្ធនាគារទេនេះបង្ហាញថា ពុំដែលបានធ្វើផែនការច្បាស់លាស់សំរាប់ពួកគេក្នុងការទៅសំរាលកូននៅកន្លែងណាមួយទេ។

ផ្នែកថែទាំសុខភាពដែលមាននៅក្នុងពន្ធនាគារច្រើនតែមានកំរិត អាស្រ័យដោយកង្វះខាតសម្ភារៈ បរិក្ខារថ្នាំពេទ្យ ។ បុគ្គលិកពេទ្យ៣នាក់ ក្នុងចំណោម៥នាក់ (៦០%) ដែលបានសម្ភាសន៏ បាននិយាយថា ពួកគាត់ពុំអាចផ្តល់ការព្យាបាលដល់អ្នកជាប់ពន្ធនាគារទាំងអស់បានទេ ពីព្រោះគាត់មិនមានពេលវេលាដើម្បីមើលព្យាបាលពួកអ្នកជាប់ពន្ធនាគារទាំងអស់នោះផង និងដោយសារពុំមានសម្ភារៈ បរិក្ខារចាំបាច់គ្រប់គ្រាន់ក្នុងការអនុវត្តន៏ការងារផង ។ លើសពីនេះទៀត ក្នុងចំណោមបុគ្គលិកពេទ្យទាំងអស់ដែលយើងបានសម្ភាសន៏មានម្នាក់ជាវេជ្ជបណ្ឌិត បុគ្គលិកពេទ្យម្នាក់ទៀតនិយាយថា គាត់មិនដែលបានរៀនសូត្រវិជ្ជាពេទ្យទាល់តែ

---

[១៦] *ចំពោះការពិភាក្សាបន្ថែមអំពីសេចក្តីប្រកាសលេខ២១៧សូមមើលផ្នែកIV. B.2 នៃរបាយការណ៍នេះ។*

សោះ។ មានគិលានុប្បដ្ឋាយិការ២នាក់បានរៀនសូត្រនិងមានសញ្ញាប័ត្រផ្នែក "សម្ភព " ហើយបុគ្គលិកពេទ្យ ៣នាក់ទៀតដែលយើងបានសម្ភាសន៏បាននិយាយថា ពួកគាត់មិនដែលបានហ្វឹកហ្វឺនផ្នែកសុខភាពមាតា និង កុមារអោយបានត្រឹមត្រូវទេ ។

ទោះបីជាគ្រូពេទ្យទាំងនោះមានសមត្ថភាពខាងសុខភាពកុមារ ឬរោគស្ត្រីក៏ដោយ ក៏នៅមានបុគ្គលិក ពេទ្យពន្ធនាគារជាច្រើនជួបប្រទះនូវការលំបាកយ៉ាងច្រើនណាស់ដែរ ។ មណ្ឌលសុខភាពដែលអ្នកស្រាវជ្រាវ បានឃើញមានលក្ខណៈអត្តខាត់ និងបំពាក់ទៅដោយឧបករណ៏ចាំបាច់ជាមូលដ្ឋានមួយចំនួនតែប៉ុណ្ណោះ ។ ក្នុងចំណោមមណ្ឌលសុខភាពទាំងអស់ដែលយើងបានពិនិត្យមើល យើងមិនបានឃើញមណ្ឌលសុខភាពណា មួយដែលបានបំពាក់ឧបករណ៏ចាំបាច់សមរម្យត្រឹមត្រូវសំរាប់ព្យាបាលកុមារទេ ។ តាមការពិត បុគ្គលិកពេទ្យ ទាំងនោះច្រើនតែនិយាយថា ពួកគាត់មិនមានថ្នាំគ្រប់គ្រាន់ដើម្បីព្យាបាលអ្នកជាប់ពន្ធនាគារពេញវ៏យផងទេ ដូចេះត្រូវទុករឿងកុមារម្ដុំសិន ។

| **ករណីសិក្សាទី ១១** |
| --- |
| **បុគ្គលិកពេទ្យម្នាក់ ឈ្មោះ កុល ឡាយុន និយាយថា គាត់ពុំមានថ្នាំសំរាប់ព្យាបាលកុមារទេ ។ គាត់បានព្យាបាលកុមារដោយប្រើប្រាស់ថ្នាំ និងរបៀបព្យាបាលដូចមនុស្សចាស់ដែរ ។ កុល ឡាយុន និយាយថាគាត់ពុំមានថ្នាំសំរាប់ព្យាបាលអ្នកជាប់ពន្ធនាគារទាំងអស់អោយបានត្រឹមត្រូវទេ ។ គាត់បាន ស្នើសុំថ្នាំបន្ថែមពីក្រសួងសុខាភិបាលហើយ ជួនកាលក៏បានច្រើន និងមានពេល ខ្លះក៏ស្នើមិនបាន។** |

| **ករណីសិក្សាទី ១២** |
| --- |
| **អ្នកជំនួយការផ្នែកពេទ្យម្នាក់ឈ្មោះ ជា សុនបាននិយាយថា បរិមាណថ្នាំដែលគាត់មាននោះគឺ " តិចតួចណាស់ ហើយមិនគ្រប់គ្រាន់ទេ ។ នៅពេលសួរថាតើគាត់មានបានធ្វើសំណើសុំទៅក្រសួង សុខាភិបាលដែរឬទេនោះ គាត់និយាយថា ពេលគាត់ទៅប្រជុំនៅក្រសួងសុខាភិបាល គាត់បាលស្នើសុំថ្នាំ ថែមទៀតដែរ ប៉ុន្តែខាងក្រសួងអោយតែថ្នាំគ្រាប់មកតែប៉ុណ្ណោះ ។ គាត់និយាយថាក្រសួងសុខាភិបាលមិន អាចអោយថ្នាំតាមសំណើរបស់គាត់បានទេ ពីព្រោះថ្នាំនោះថ្លៃណាស់ ។ ជា សុន និយាយថែមទៀតថា ចំពោះកុមារគាត់អាចជួយព្យាបាលបានតែជំងឺណាមិនធ្ងន់ធ្ងរទេ ។ គាត់យល់ថាការព្យាបាលដែលគាត់បាន ផ្តល់នោះមិនគ្រប់គ្រាន់សំរាប់ពួកគេទេ ពីព្រោះគាត់មានតែម្នាក់ឯងគត់ត្រូវព្យាបាលអ្នកជាប់ពន្ធនាគារ ទាំងអស់គ្នា ។ ថ្នាំដែលគាត់មានភាគច្រើនគឺសំរាប់ តែមនុស្សពេញវ៏យ ។ គាត់ក៏និយាយដែរថា គាត់មិន អាចផ្តល់ការថែទាំដែលស្ត្រីៗត្រូវការទេ ។** |

បុគ្គលិកពេទ្យពន្ធនាគារក៏ជួបប្រទះការលំបាកផងដែរ ដោយសារតែបញ្ហាធំពេកហើយហួសពីសមត្ថភាពរបស់ពួកគេ ដូចដែលបានបង្ហាញនៅក្នុងករណីសិក្សាខាងក្រោមដែលបានពិពណ៌នាដោយបុគ្គលិកពេទ្យពន្ធនាគារម្នាក់ ។ នៅក្នុងកាលៈទេសៈបែបនេះ លទ្ធភាពនៃការព្យាបាលអោយបានត្រឹមត្រូវរបស់គ្រូពេទ្យ ដល់ទារកត្រូវជួបឧបសគ្គ ដោយពុំមានការជួយឧបត្ថមអោយបានជិតដល់ពីសំណាក់ក្រសួងសុខាភិបាលឡើយ ។

| **ករណីសិក្សាទី ១៣:** |
|---|
| **ទារកទាំងឡាយមិនបានទទួលការព្យាបាលពីវេជ្ជបណ្ឌិតនៅក្នុងពន្ធនាគារទេ ដោយសារ តែក្រសួងសុខាភិបាលមិនដែលចុះមកពិនិត្យមើលពួកគេទាំងនោះសោះ ។ វីបុល ជាអ្នកជំនួយការផ្នែកសុខាភិបាលបាននិយាយថា គាត់បានសុំស្នើអោយវេជ្ជបណ្ឌិតមកពីក្រសួងសុខាភិបាលចុះមកជួយព្យាបាលទារកទាំងនោះ ប៉ុន្តែគេមិនដែលចុះមកសោះ ។ ក្រសួងសុខាភិបាលនិយាយថា មានទារកត្រឹមតែ២នាក់ (តិចតួចពេក) ដូច្នេះក្រសួងបានស្នើអោយប្រធានពន្ធនាគារយកទារកទាំងនោះទៅព្យាបាលនៅពេទ្យក្រសួងវិញ ។ ពេលនោះបុគ្គលិកពេទ្យពន្ធនាគារបានរងចាំការចុះមកព្យាបាលនៅពន្ធនាគារពីសំណាក់គ្រូពេទ្យក្រសួងដោយ គេធ្លាប់មានកម្មវិធីចុះមកព្យាបាលក្នុងរយៈបីខែម្តង ។** |

ប្រសិនបើស្ត្រីណាម្នាក់ចង់អោយគ្រូពេទ្យជំនាញមកជួយព្យាបាលខ្លួនគាត់ ឬកូនរបស់គាត់ វាច្រើនតែថ្លៃខ្លាំងណាស់ ហើយគេពុំអាចរកបានឡើយ ។ កត្តានេះវាបានឆ្លុះបញ្ចាំងនូវភាពទាល់ច្រកដូចគ្នាដោយកង្វះនូវការព្យាបាលវេជ្ជសាស្ត្រ និងភាពក្រីក្រដែលបានជះឥទ្ធិពលដល់ស្ត្រីទណ្ឌិតនិងពិរុទ្ធជនជាច្រើន ។ មានចាងហ្វាងពន្ធនាគារមួយចំនួនបានមានប្រសាសន៏ថា មន្ទីរពេទ្យនៅតាមមូលដ្ឋានរបស់ពួកគាត់បានយកថ្លៃព្យាបាលពីអ្នកជាប់ពន្ធនាគារក្នុងតំលៃអប្បបរមា ដោយយល់ពីស្ថានភាពលំបាករបស់ពួកគេ។ ទោះជាយ៉ាងនេះក្តី ក៏នៅមានឧបសគ្គដ៏ធំមួយទៀត ដែលស្ត្រីទាំងនោះប្រឈមមុខក្នុងបញ្ហាសុខភាពនេះដែរគឺតំរូវការសំរាប់ចំណាយទៅលើការទិញថ្នាំព្យាបាល និងសោហ៊ុយដឹកជញ្ជូនទៅមន្ទីរ ពេទ្យខាងក្រៅពន្ធនាគារ ។

| **ករណីសិក្សាទី ១៤:** |
|---|
| **សូភា នាងបានចុះខ្សោយកំលាំងខ្លាំង ហើយវិលមុខ ពេលនោះនាងបានសុំអោយបុគ្គលិកពេទ្យពន្ធនាគារយកនាងទៅមន្ទីរពេទ្យ ហើយគេក៏បានយកនាងទៅ ។ វេជ្ជបណ្ឌិតនៅឯមន្ទីរពេទ្យនិយាយថា នាងខ្សោយដោយសារពុំមានចំណីអាហារបរិភោគគ្រប់គ្រាន់ ។ គាត់បានអោយថ្នាំសូភាខ្លះ ហើយក្រោយពីលេបថ្នាំនោះមក នាងមានអារម្មណ៏ធូរស្រាលជាងមុន ប៉ុន្តែមិនមានថ្នាំប្រើគ្រប់តាមកំណត់ឡើយ ។** |

នៅពេលដែលនាងអស់ថ្នាំនោះ នាងក៏ ចាប់ផ្តើមឈឺវិញទៀត ។ នាងមិនបានគិតថាទៅជួបវេជ្ជបណ្ឌិតទៀតទេពីព្រោះនាងមិន មានថវិកាគ្រប់គ្រាន់សំរាប់សោហ៊ុយធ្វើដំណើរទៅមកនិងថវិកាសំរាប់ថ្នាំទេ ។ វាត្រូវចំណាយ ១០០០០រៀល សំរាប់ថ្លៃម៉ូតូ និងត្រូវចំណាយលើការពិនិត្យព្យាបាល និងថ្នាំថែមទៀតផងនៅពេលទៅពេទ្យម្តងៗ ។

**ករណីសិក្សាទី ១៥ :**

សូលីណា បានសម្រាលកូនប្រុសរបស់នាងនៅក្នុងពន្ធនាគារ ។ នាងមិនបានទៅសម្រាលនៅមន្ទីរពេទ្យទេដោយនាងពុំមានថវិកាសំរាប់ចំណាយនៅទីនោះ ។ ពេលសួរថាតើនាងយល់ ថាការសម្រាលកូននៅក្នុងពន្ធនាគារនេះមានសុវត្ថិភាពគ្រប់គ្រាន់សំរាប់នាងដែរឬទេ សូលី ណានិយាយថា វាមានការលំបាកខ្លាំងណាស់ ប៉ុន្តែដោយនាងពុំមានជំរើសណាក្រៅពីនេះ និងដោយនាងពុំមានថវិកាសំរាប់ចំណាយដល់ការសម្រាលកូននេះនៅក្នុងមន្ទីរពេទ្យនេះ ។

ទោះជានៅក្នុងពន្ធនាគារក្តីស្ត្រីទាំងនោះរាយការណ៍ថាគេច្រើនតែជួបប្រទះបញ្ហាក្នុងការទទួលការព្យាបាលពីសំណាក់គ្រូពេទ្យ ។ ស្ត្រីមួយចំនួនបាននិយាយថា ការស្នើសុំការព្យាបាលម្តងៗរបស់ពួកគេសំរាប់ខ្លួនគេ ឬកូនរបស់ពួកគេ មិនត្រូវបានទទួលការយកចិត្តទុកដាក់ពីសំណាក់គ្រូពេទ្យទេ ។

**ករណីសិក្សាទី ១៦:**

ពេលដែលនាងមានផ្ទៃពោះ ម៉ាលី បានទទួលការពិនិត្យព្យាបាលពីសំណាក់វេជ្ជបណ្ឌិតតែម្នាក់គត់ដែលធ្វើការប្រចាំនៅក្នុងពន្ធនាគារនេះ ។ នាងមិនឃើញមានវេជ្ជបណ្ឌិតពីក្រៅពន្ធនាគារមកពិនិត្យទេ រហូតដល់ពេលសម្រាលកូន ។ កាលពេលមានផ្ទៃពោះជួនកាលនាងកើតជំងឺគ្រុនក្តៅ ហើយវេជ្ជបណ្ឌិក៏បានអោយថ្នាំនាង ។ ម៉ាលីក៏បានសុំស្នើអោយវេជ្ជបណ្ឌិតពី ខាងក្រៅពន្ធនាគារមកជួយពិនិត្យព្យាបាលដែរ ប៉ុន្តែពេទ្យពន្ធនាគារមិនព្រម ។ គាត់និយាយថា នាងមានសុខភាពល្អ ហើយមិនចាំបាច់រកពេទ្យពីខាងក្រៅមកព្យាបាលទេ ។

**ករណីសិក្សា ទី ១៧ :**

ពេលកូនស្រីរបស់គាត់ ឈ្មោះស្រីនាង មានជំងឺ ឃុន លីណាបានទៅរកគ្រូពេទ្យនៅក្នុងពន្ធនាគារ ប៉ុន្តែនាងនិយាយថា ពិបាកសុំថ្នាំពីគ្រូពេទ្យក្នុងពន្ធនាគារណាស់ ។ ឃុនលីណា និយាយថា បើនាងមានថវិកានោះជាការងាយស្រួលវិញក្នុងការសុំថ្នាំ ប៉ុន្តែបើនាងគ្មានថវិកា ទេ គ្រូពេទ្យមិនរវល់នឹងនាងសោះ ។

**នាងនិយាយទៀតថា គ្រូពេទ្យតែងតែប្រាប់នាងថា អោយរង់ចាំសិន ឧទាហរណ៏ថា បើនាងទៅពេលព្រឹកគ្រូពេទ្យប្រាប់គាត់ថាចាំពេលរសៀល ។ ស្រីនាងបានទទួលការព្យាបាលតែពីរឬបីដងតែប៉ុណ្ណោះក្នុងកំឡុងពេលស្ថិតនៅក្នុងពន្ធនាគារ ។ គ្រូពេទ្យតែងតែនិយាយថា ជំងឺរបស់នាងមិនធ្ងន់ធ្ងរទេ ។ ឃុន លីណាបានប្រាប់គ្រូពេទ្យវិញថា ជំងឺនេះប្រាកដជាធ្ងន់ធ្ងរពីព្រោះស្រីនាងគ្រុនក្តៅ ប៉ុន្តែគ្រូពេទ្យនៅតែនិយាយថា មិនធ្ងន់ធ្ងរទៀត ។**

**ករណីសិក្សាទី ១៨:**

**សុខ ឃីម និយាយថា នាងបានសុំជួបវេជ្ជបណ្ឌិត ប៉ុន្តែគាត់មិនអោយថ្នាំសំរាប់កូននាងទេ ។ គ្រូពេទ្យនិយាយថា គាត់កំពុងជាប់រវល់ ដូច្នេះពេលទំនេរទើបគាត់មកជួបនាង ប៉ុន្តែគ្រូពេទ្យនោះមិនដែលមានពេលទេ ។ ក្នុងពេលសម្ភាសន៏នោះ សុខ ឃីម ក៏កំពុងតែឈឺដៃរអស់រយៈពេលពីរបីថ្ងៃមកហើយ ប៉ុន្តែនាងនៅតែមិនទាន់បានជួបគ្រូពេទ្យនៅឡើយ ។ គ្រូពេទ្យពន្ធនាគារធ្លាប់បានអោយថ្នាំគាត់ពីរដងរួចមកហើយកាលពីមុនមក។ ហើយនៅពេលដែលនាងសុំថ្នាំ លើកនេះគាត់និយាយថា នាងមិនឈឺធ្ងន់ផង ហេតុអ្វីចាំសុំថ្នាំព្យាបាលធ្វើអ្វី ? ។**

មូលហេតុលើសពីនេះទៀតដែលនាំអោយមានកង្វល់នោះគឺការមិនបានចាក់ថ្នាំបង្ការរោគរដល់ទារក។

ការសិក្សាស្រាវជ្រាវសុខភាពនិងប្រជាសាស្ត្រកម្ពុជាឆ្នាំ២000កន្លងទៅដែលចេញផ្សាយដោយក្រសួងផែនការនិងក្រសួងសុខាភិបាល បានអោយដឹងពីសារសំខាន់នៃការចាក់ថ្នាំបង្ការរោគដល់កុមារគ្រប់រូប ដើម្បីកាត់បន្ថយអត្រាមរណៈរបស់កុមារ ដោយទប់ស្កាត់នូវជំងឺមួយចំនួនដូចជា របេង ខាន់ស្លាក់ ក្អកមាន់ តេតាណុសគ្រុនស្វិតដៃជើងនិងកញ្ជ្រឹល[១៧] ។ របាយការណ៏របស់អង្គការសង្គ្រោះកុមារស្តីពីស្ថានភាពនៃ ទារកក៏បានសង្កត់ធ្ងន់ទៅលើតំរូវការក្នុងការចាក់ថ្នាំបង្ការថា ជាវិធីមួយដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺដ៏សាហាវដល់កុមារដែរ[១៨]។ ប៉ុន្តែ ការចាក់ថ្នាំបង្ការច្រើនតែពុំមានសំរាប់កុមារកើតនៅក្នុងពន្ធនាគារឡើយ។ ឧទាហរណ៏ អ្នកជំនួយការពេទ្យនៅក្នុងពន្ធនាគារម្នាក់និយាយថា គេមិនបានអនុញ្ញាតអោយនាងចាក់ថ្នាំបង្ការដល់កុមារនៅក្នុងពន្ធនាគារទេ គេប្រាប់អោយយកកុមារទាំងនោះទៅមន្ទីរពេទ្យដើម្បីចាក់ថ្នាំ

[១៧] *វិទ្យាស្ថានជាតិស្ថិតិ និងអគ្គនាយកដ្ឋានសុខភាព។ កម្ពុជា: ការសិក្សាស្រាវជ្រាវសុខភាព និង ប្រជាសាស្ត្រកម្ពុជា ឆ្នាំ ២000។(ភ្នំពេញ វិទ្យាស្ថានជាតិស្ថិតិ ២00១) ទំព័រ ១៥0 ។*

[១៨] *កូស្តេឡូ សភាពនៃទារកពិភពលោក ទំព័រ ៦, ២៧ -៨,៣៥*

នេះ។ ដូចដែលបានលើកឡើងជារឿយៗពីកង្វះលទ្ធភាពរបស់មាតានិងទារកក្នុងការទៅមន្ទីរពេទ្យ ដូចបានគូសបញ្ជាក់ខាងលើកុមារភាគច្រើនអាចមិនបានទទួលការចាក់ថ្នាំបង្ការរោគណាមួយសោះ។ ករណីសិក្សាខាងក្រោមបង្ហាញនូវបញ្ហាទាំងនេះ។

| **ករណីសិក្សាទី ១៩ :** |
| --- |
| **ស្រី ម៉ុម មិនដែលបានជួបអោយវេជ្ជបណ្ឌិតណាព្យាបាលក្រៅពីគ្រូពេទ្យនៅក្នុងពន្ធនាគារឡើយ នាងក៏មិនដែលបានចាក់ថ្នាំបង្ការរោគណាមួយដែរ ។ ម្តាយរបស់នាងឈ្មោះ ផូ ថាមិនដឹងហេតុអ្វីបានជាដូច្នេះ ។ នាងផូនិយាយថានាងខ្លាចណាស់ក្នុងការសុំអោយកូនបានចាក់ថ្នាំបង្ការ។ នាងនិយាយថា នាងខ្លាចមិនហ៊ានសួរលោកចាងហ្វាងពន្ធនាគារអំពីរឿងចាក់ថ្នាំបង្ការនេះ ដោយគាត់មិនដែលនិយាយអំពីរឿងនេះទាល់តែសោះ ព្រមទាំងគាត់មិនដែលស្នើនាំយកកូនទៅចាក់ថ្នាំបង្ការនៅមន្ទីរពេទ្យណាទេ ។ នាងនិយាយថា នាងនឹងយកកូនទៅពេទ្យដើម្បីចាក់ថ្នាំបង្ការ បើលោកចាងហ្វាងពន្ធនាគារនិយាយពីរឿងនេះ ។ ពេលសួរថា ហេតុអ្វីបានជាខ្លាចមិនហ៊ានសួរពីរឿងចាក់ថ្នាំបង្ការនេះ ផូនិយាយថា នាងមិនចង់សួរ ដោយនាងមិនដឹងពីបញ្ញត្តិនៅក្នុងពន្ធនាគារនេះ។ នាងគិតថា បើនាងសួររកអ្វីពីលោកចាងហ្វាងពន្ធនាគារ នោះនាងនឹងត្រូវគាត់ស្តីបន្ទោស ។** |

អនាម័យក៏នៅតែបង្ហាញថាជាបញ្ហាសុខភាពមួយទៀត ដែលមាតានិងកុមារទាំងនោះកំពុងតែប្រឈមមុខដែរ។ ពេលខ្លះបន្ទប់ឃុំឃាំងមានលក្ខណៈចង្អៀត ។ ស្ត្រីម្នាក់និយាយថា នាងត្រូវឃុំក្នុងបន្ទប់មួយដែលមានអ្នកជាប់ពន្ធនាគារចំនួន២៦នាក់ទៀត[១៩] ហើយបញ្ហាអនាម័យជាធម្មតាមិនដល់កំរិតបទដ្ឋានគំរូទេ។ ក្នុងចំណោមរោគវិនិច្ឆ័យទាំងឡាយដែលគ្រូពេទ្យលីកាដូបានព្យាបាលក្នុងឆ្នាំ ២០០១ គេសង្កេតឃើញថាប្រមាណ២០%នៃជំងឺទាំងនោះគឺបណ្តាលមកពី បញ្ហាខ្វះអនាម័យ ដូចជាជំងឺរាគជំងឺបង្ករឡើងដោយពពួកប៉ារ៉ាស៊ីត គ្រុនពោះវៀន និង ជំងឺសើរស្បែក[២០] ជាដើម។ របាយការណ៍របស់លីកាដូឆ្នាំ ២០០១ ស្តីអំពីបញ្ហាសុខភាពក្នុងពន្ធនាគារបានលើកឡើងថា:

---

[១៩] *ទោះជាពុំមានស្ថិតិច្បាស់លាស់ ស្តីពីទំហំបន្ទប់ឃុំឃាំងក៏ដោយ ក៏ផ្អែកតាមគំរោងកម្មវិធីពន្ធនាគាររបស់ អង្គការលីកាដូបានរាយការណ៍ថា មានភាពចង្អៀតខ្លាំងជាទិច្ច នៅគ្រប់ពន្ធនាគារដែលបានពិនិត្យ ។ ពត៌មានបន្ថែមសូមមើល របាយការណ៍លីកាដូ "បញ្ហាពន្ធនាគារ និង បញ្ហាសុខភាពទាំងឡាយ" (២០០១) ។*

[២០] *លីកាដូ " បញ្ហាពន្ធនាគារ និង បញ្ហាសុខភាព " ទំព័រ ៥-២០០១ "*

*" ដោយគ្រាន់លើកយកមកបង្ហាញតែបញ្ហាចង្អៀតខ្លាំងនិងកង្វះអនាម័យនៅក្នុងពន្ធនាគារកម្ពុជា នោះយើងនឹងមិនភ្ញាក់ផ្អើលទេដឹងថាជំងឺផ្លូវដង្ហើមមានចំនួនជាភាគរយយ៉ាងខ្ពស់នៅក្នុងចំណោមជំងឺទាំងឡាយនៃពន្ធនាគារ[២១] "*។

បញ្ហាធំមួយដែលស្ត្រីនៅក្នុងពន្ធនាគារមួយចំនួនបានលើកឡើងនោះគឺបញ្ហាកង្វះទឹកនៅក្នុងរដូវប្រាំង ដែលរារាំងមិនអាចអោយស្ត្រីនិងកូនៗរបស់គេទាំងនោះមានអនាម័យល្អប្រសើរបាន។ នៅក្នុងករណីមួយដែលរៀបរាប់ខាងក្រោមមានស្ត្រីម្នាក់ដែលនាងជួនកាលត្រូវទិញទឹកគេដើម្បីងូតទឹកអោយកូន ដោយនាងមិនទុកចិត្តនូវគុណភាពទឹកដែលមាននៅក្នុងពន្ធនាគានោះ ។

| **ករណីសិក្សាទី ២០ :** |
|---|
| **សូភា បានទិញទឹកគេពីខាងក្រៅពន្ធនាគារដើម្បីងូតអោយកូននាង ពីព្រោះនាងគិតថាទឹកដែលមាននៅក្នុងពន្ធនាគារនោះមិនស្អាតសំរាប់ងូតអោយកូននាងទេ ។ នាងនិយាយថា បុគ្គលិកពន្ធនាគារជាអ្នកលក់ទឹក។ ក្នុងរយៈពេលពីបីទៅបួនថ្ងៃនាងចំណាយអស់ ១៥០០ រៀល ហើយទឹកនោះនាងប្រើសំរាប់តែងូតប៉ុណ្ណោះ មិនសំរាប់ផឹកទេ ។** |

បញ្ហាសំខាន់មួយដែលការិយាល័យពេទ្យលីកាដូបានលើកឡើង នៅក្នុងរបាយការណ៏ប្រចាំឆ្នាំ២០០១ របស់ខ្លួននោះ ទាក់ទងនឹង ការមានផ្ទៃពោះដោយការរំលោភផ្លូវភេទលើស្ត្រីជាប់ពន្ធនាគារ។ ការពិពណ៌នាលំអិតក្នុងផ្នែកទីមួយនៃករណីសិក្សាខាងក្រោមត្រូវបានដកស្រង់ចេញពីរបាយការណ៏ការិយាល័យពេទ្យ ។

| **ករណីសិក្សាទី ២១** |
|---|
| **កាលពីខែវិច្ឆិកាឆ្នាំ ២០០១ កន្លងទៅ អង្គកាលីកាដូបានធ្វើការស៊ើបអង្កេតទៅលើករណីរបស់ស្ត្រីម្នាក់ឈ្មោះ នារី ជាអ្នកទោសភេទស្រីដែលជាប់ពន្ធនាគារតាំងពីឆ្នាំ ១៩៩៥មកម្ល៉េះ ហើយនាងបានមានផ្ទៃពោះ៧ខែ នៅក្នុងពន្ធនាគារ។ តាមសំដីនារីបាននិយាយថា នាង ធ្លាប់បានរួមរ័ក្សជាមួយ និងអ្នកយាមពន្ធនាគាម្នាក់កាលពីចូលឆ្នាំខ្មែរក្នុងឆ្នាំនោះ។ ។**<br>**នៅវេលាប្រហែលម៉ោង ១០ព្រឹក នាថ្ងៃទី ១ នៃបុណ្យចូលឆ្នាំ នារីបានទៅបន្ទប់ទឹក ។ ពេលនាងចេញពីបន្ទប់ទឹកមកវិញនាងបានជួបប្រទះនិងអ្នកយាមពន្ធនាគារម្នាក់ ហើយគាត់នោះក៏បានប្រាប់នាងអោយចូលទៅក្នុងបន្ទប់ទឹកវិញជាមួយគាត់ ។ ស្រាប់តែនារីយល់ព្រមចូលទៅ ដោយជួនពេលនោះថា នាងបានស្រវឹងស្រាបន្តិចបន្តួចផង (ព្រោះបុណ្យចូលឆ្នាំគេបានអោយអ្នកជាប់ពន្ធនាគារផឹកស្រាបន្តិចបន្តួច)។ ពេលចូលទៅដល់ខាងក្នុង អ្នកយាមនោះនិយាយថា** |

---

២១ *របាយការណ៏ដដែល " ទំព័រ ៦*

គាត់ចង់រួមរ័ក្សជាមួយនាង ។ ដំបូងនាងបដិសេធ ប៉ុន្តែអ្នកយាមនោះនៅតែទទូចដដែលៗព្រម ទាំងនិយាយថា បើមានបញ្ហាអ្វីកើតឡើងនោះគាត់ជាអ្នកធានាខុសត្រូវទាំងអស់ ។

នៅល្ងាចថ្ងៃដដែល អ្នកយាមនោះក៏ប្រាប់អោយនារីចូលទៅក្នុងបន្ទប់ទឹកដដែលនោះទៀត ហើយពួកគេទាំងពីរនាក់នោះក៏បានរួមរ័ក្សម្តងទៀត ។ នៅថ្ងៃចុងក្រោយនៃបុណ្យចូលឆ្នាំ អ្នកយាមនោះបានប្រាប់អោយនារីចូលនាំគាតទៅបន្ទប់ទឹកនោះម្តងទៀតដើម្បីរួមរ័ក្ស។ ពេលនេះក៏ដូចពេលមុនៗដែរ នារីតែងតែបដិសេធ ប៉ុន្តែអ្នកយាមនោះចេះតែទទូចដដែលៗ ។

លទ្ធផលចុងក្រោយ នារីមានផ្ទៃពោះ។ ពេលដឹងថានារីមានផ្ទៃពោះដូច្នេះ អ្នកយាមនោះបានយកថ្នាំដែលនារីមិនស្គាល់មកអោយនាងលេបយ៉ាងច្រើន ដើម្បីទំលាក់គភ៌ប៉ុន្តែមិនបានលទ្ធផលល្អទេ។ ក្នុងពេលសម្ភាសន៍នោះ នារីបានសំដែងនូវការព្រួយបារម្ភខ្លាំង ព្រោះដល់ពេលសម្រាលកូននាងនឹងជួបការលំបាកជាច្រើន ពីព្រោះនាងពុំមានថវិកា ហើយមកដល់ពេលនេះអ្នកយាមនោះក៏បានបាត់ខ្លួនទៀត ។ នារីបានរាយការណ៏ទៀតថានាងពុំបានជួបគាត់ជាង១ខែមកហើយ ។

**<u>ការតាមដាន:</u>**

នៅខែកុម្ភៈ ឆ្នាំ២០០២ នៅពេលអ្នកស្រាវជ្រាវយើងទៅពន្ធនាគារ ដែលកើតហេតុនោះ នារីសម្រាលបានកូនប្រុសម្នាក់អាយុ ១ខែ ហើយនាងសម្រាលនៅក្នុងពន្ធនាគារនេះតែម្តង មិនបានទៅមន្ទីរពេទ្យទេ ។ នារីបានឃើញឪពុកក្មេងនោះ ជាចុងក្រោយអង្គស់នៅពេល ដែលនាងមានផ្ទៃពោះគម្រប់៧ ខែ ហើយនាងពុំបានទទួលការជួយឧបត្ថម្ភពីគាត់ដើម្បីចិញ្ចឹមកូនទេ ។ នារីនិយាយថា នាងពុំមានលទ្ធភាពបំបៅដោះកូនគ្រប់គ្រាន់ទៀតឡើយ ដោយគ្មានទឹកដោះ ហើយនាងក៏មិនចង់ពិភាក្សារឿងនេះជាមួយគ្រូពេទ្យក្នុងពន្ធនាគារដែរ ដោយនាងគិតថា គាត់នឹងរិះគន់នាង ដោយព្រោះតែនាងមានទំនាក់ទំនងផ្លូវភេទជាមួយអ្នកយាមម្នាក់នោះ ។

កន្លងមក ធ្លាប់មានបុគ្គលិកពន្ធនាគារ និងអ្នកជាប់ពន្ធនាគារដូចគ្នាមួយចំនួននិយាយអាក្រក់ពី នារីដោយហេតុនាងបានថ្លោះធ្លោយមានផ្ទៃពោះជាមួយអ្នកយាមពន្ធនាគារម្នាក់នោះ ។

ពេលសម្ភាសន៏ចប់ នារីបានសុំអោយអង្គការលីកាដូ ជួយស្វែងរកអ្នកយាមនោះ ហើយសុំអោយគាត់ជួយឧបត្ថម្ភដល់នាងនិងកូនផង ។ នារីនិយាយថា នាងចង់រកប្តីនាងអោយឃើញ ហើយចង់ចាកចេញពីពន្ធនាគារនេះ ទៅរស់នៅកន្លែងណាផ្សេងដែលមានសុវត្ថិភាព ។ តាមសំដីនារី នាង

**និយាយថា ពេលមានទំនាក់ទំនងជាមួយគ្នានោះ គាត់បានសន្យាថានឹងជួយរកវិធីដោះស្រាយអោយនារីចេញពីពន្ធនាគារនេះ ។**

បញ្ហាខាងលើនេះបានឆ្លុះបញ្ចាំងមិនត្រឹមតែកង្វល់ដែលបានលើកឡើងរួចមកហើយនោះមានដូចជា បញ្ហាថែទាំសុខភាព និង ចំណីអាហារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការគំរាមកំហែងដែលស្ត្រីបានប្រឈមមុខជាអ្នករងគ្រោះខ្លាំងដោយអំពើរំលោភផ្លូវភេទពីមនុស្សដទៃទៀតក្នុងពន្ធនាគារផងដែរ។ អំពើនេះអាចជះឥទ្ធិពលដល់ពួកគេជាម្តាយព្រមទាំងកូនៗដែលគេបង្កើតមកផង ។ នៅក្នុងករណីខាងលើការតស៊ូជាធម្មតារបស់អ្នកជាប់ពន្ធនាគាររូបនោះគឺការប្រមូលផ្តុំតួនាទីរបស់នាងជាអ្នកថែទាំកូនតែម្នាក់ឯងគត់ និងជាអ្នកផ្គត់ផ្គង់ដល់កូនដែលនាងបានមានផ្ទៃពោះតាមរយៈរំលោភផ្លូវភេទនោះ ។ របាយការណ៍ការិយា ល័យពេទ្យរបស់អង្គការលីកាដូបានធ្វើការសង្ខេបអំពីបញ្ហាសុខភាពដែលឆ្លុះបញ្ចាំងដោយខ្លីៗពីស្ថានភាពរបស់នាងនារី ថា:

"វាជាការច្បាស់ណាស់ដែលថា តំរូវការសុខភាព(របស់ស្ត្រី) មានភាពខុសគ្នាពីតំរូវការសុខភាពរបស់បុរស។ ស្ត្រីត្រូវការសេវាផ្នែករោគស្ត្រី និងសម្ភពអោយបានល្អប្រសើរជាងនេះ ។ លើសពីនេះទៅទៀត អំពើរំលោភផ្លូវភេទក៏នៅជាបញ្ហាសុខភាពមួយដ៏ធ្ងន់ធ្ងរនៅឡើយ"[២២] ។ ដូចបានបង្ហាញខាងលើ បញ្ហានីមួយៗ អាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទាំងលើមាតានិងទារក ហេតុនេះហើយ ទើបយើងមិនត្រូវធ្វើព្រងើយកន្តើយក្នុងរឿងនេះឡើយ ។

**៣-បញ្ហាផ្នែកហិរញ្ញវត្ថុ :** បញ្ហាកង្វះខាតផ្នែកហិរញ្ញវត្ថុនេះ ច្រើនតែ កើតឡើងពាក់ព័ន្ធទៅបញ្ហាម្ហូបអាហារនិងការថែទាំផ្នែកពេទ្យ ។ ភាពខ្សត់ខ្សោយផ្នែកថវិកាត្រូវចាត់ទុកថាជាកត្តាចម្បងមួយដែល មិនអាចអោយពិរុទ្ធជននិងទណ្ឌិតជាស្ត្រីមានម្ហូបអាហារដែលមានគុណភាពល្អប្រសើរនិងការថែទាំសុខភាពឬទឹកផង។ លើសពីនេះទៅទៀត ក៏នៅមានស្ត្រីមួយ ចំនួនទៀតបានលើកឡើងពីការអោយលុយទៅអ្នកយាម ដើម្បីអោយអ្នកយាមនោះជួយទិញសំភារៈ ពីខាងក្រៅអោយ ។ មានស្ត្រីមួយចំនួនទៀតបានរងនូវបញ្ហាទាល់ច្រកផ្នែកបញ្ហាហិរញ្ញវត្ថុត្រួតគ្នាដែលបណ្តាលមកពីការជាប់ឃុំឃាំងរបស់គេ ។ ក្រៅពីកង្វះលទ្ធភាពក្នុងការទិញសំភារៈប្រើប្រាស់ពីខាងក្រៅពន្ធនាគារ ឬការចំណាយលើសោហ៊ុយធ្វើដំណើរទៅមកមន្ទីរពេទ្យ ស្ត្រីទាំងនោះអាចប្រឈមមុខនិងការជាប់ពន្ធនាគារបន្តទៀតដោយសារតែកង្វះលទ្ធភាពក្នុងការសងបំណុលដែលបានជំពាក់ក្នុងកំឡុងពេលជាប់

---

[២២] *របាយការណ៍ដដែល ទំព័រ ១១*

ពន្ធនាគារនោះ ។ ស្ត្រីបែបនេះនឹងត្រូវទទួលរងការកាត់ទោសអោយសងបំណុលគេ ព្រមទាំងជាប់ពន្ធនាគារផងដែរ ។ ករណីសិក្សាខាងក្រោមធ្វើការពិពណ៌នានូវហេតុការណ៍ដែលត្រូវកើតឡើង បើអ្នកទោសម្នាក់មិនមានលទ្ធភាពក្នុងការចំណាយនូវអ្វីដែលនាងចាំបាច់ត្រូវចំណាយនោះ ។

**ករណីសិក្សាទី ២២:**

**សេចក្តីវិនិច្ឆ័យបានសំរេចអោយសុខហួ សងសំណងថ្លៃម៉ូតូដែលបានបាត់ទៅនោះ។ នាងត្រូវសងគេក្នុងចំនួន ៣៥០.០០០រៀល ( ប្រហែល ៩២ ដុល្លា) ប៉ុន្តែនាងមិនទាន់បានសងនៅឡើយទេ ។ បើនាងមិនអាចសងសំណងនោះបានទេ នាងនឹងត្រូវនៅជាប់ពន្ធនាគារក្នុងរយៈពេលមួយដែលស្មើនិងប្រាក់ជំពាក់ ៥០០រៀលក្នុងមួយថ្ងៃ ហើយជាប់រហូតកាត់អស់ទឹកប្រាក់ចំនួន ១០០.០០០ រៀល ទើបចប់។ ក្រោយពីនោះមកទៀត នាងនឹងត្រូវជាប់ពន្ធនាគារ កាត់បំណុលក្នុង ១ថ្ងៃ១០០០រៀល។ ហើយចំនួនបំណុលរបស់នាង ទាំងនេះគិតទៅនាងត្រូវជាប់ពន្ធនាគាក្នុងរយៈពេលប្រហែល ១៥ខែថែមទៀត (៤៥០ថ្ងៃ)។ សុខហួនិយាយថា បើនាងនៅបន្តជាប់ពន្ធនាគារថែមទៀតនោះ កូនស្រីដែលទើបមានអាយុ៣ខែរបស់នាងក៏នឹងត្រូវនៅបន្តជាមួយនាងទៀតដែរ ។**

ករណីសិក្សានេះផ្តល់នូវឧទាហរណ៍យ៉ាងច្បាស់ នូវរបៀបដែលភាពខ្សត់ខ្សោយផ្នែកហិរញ្ញវត្ថុ អាចបន្តប៉ះពាល់ដល់មាតានិងកុមារ ទោះបីជាមាតាបានបំរើទោសជាផ្លូវការចប់សព្វគ្រប់ហើយក៏ដោយ ។

## ៤-លទ្ធភាពក្នុងការសិក្សា:

សូម្បីតែមាតារបស់ទារកនិងកុមារទាំងនោះ ក៏ពោលថាកង្វះឱកាសក្នុងការអប់រំជាការពិបាកយ៉ាងខ្លាំងនៅក្នុងគំនិតរបស់ពួកគេដែរ។ ស្ត្រីជាច្រើនបាននិយាយថា ការរស់នៅក្នុងពន្ធនាគារបានបណ្តាលអោយកូនរបស់គេខកខានមិនបានចូលរៀន។ កត្តានេះអាចបណ្តាលមកពីហេតុផលផ្សេងៗច្រើន ដូចជាកង្វះលទ្ធភាពរបស់មាតាក្នុងការចំណាយទៅលើសោហ៊ុយដឹកជញ្ជូនកុមារទៅ/ មកពីសាលារៀន ទិញសំលៀកបំពាក់អោយកូនដើម្បីទៅរៀននិងសំភារៈដទៃៗទៀត ឬក៏ពុំមានសាលានៅក្បែរនោះជាដើម ។ ស្ត្រីដែលយើងបានសម្ភាសន៏បានដឹងយ៉ាងច្បាស់អំពីផលប៉ះពាល់មិនល្អនៃកង្វះការអប់រំមកលើកូនៗរបស់ពួកគាត់ ។

**ករណីសិក្សាទី ២៣ :**

**ប្រសិនបើ ចិន្តា ត្រូវបានវិនិច្ឆ័យទោស ហើយកូនប្រុសអាយុ ៥ឆ្នាំរបស់នាងបន្តរស់នៅជាមួយ នាងក្នុងពន្ធនាគារនោះ គេមិនអាចទៅរៀនបាន ពីព្រោះពុំមានសាលានៅក្នុងពន្ធនាគារទេ។ ចិន្តានិយាយថានាងចង់អោយកូនរស់នៅភ្នំពេញដើម្បីបានចូលរៀនប៉ុន្តែគាត់ពុំមានញាតិនៅភ្នំពេញទេ។ ចិន្តាគិតថា កូនគួរតែរស់នៅជាមួយអង្គការណាមួយប្រសើរជាងការរស់នៅក្នុងពន្ធនាគារ ព្រោះថា បើមានគេយកគាត់ទៅនៅក្នុងអង្គការណាមួយនោះ គាត់អាចរៀន សរសេរ អាន ហើយនឹងអាចមានអនាគតល្អផង ។**

ចំពោះស្ត្រីមួយចំនួនទៀត ឱកាសនៃការអប់រំនេះបានក្លាយទៅជាកត្តាសំរេចចិត្តមួយក្នុងការកំណត់ថាតើកូនរបស់គាត់នឹងត្រូវនៅក្នុងពន្ធនាគារតទៅទៀតដែរឬទេ ហើយនៅដល់អាយុប៉ុន្មាន ?

**ករណីសិក្សាទី ២៤ :**

**ទៀង ហា បានបំរើទោសក្នុងពន្ធនាគារអស់រយៈពេល២ឆ្នាំហើយក្នុងកំរិតទោសរួមទាំងអស់ ១៥ ឆ្នាំ នាងបាននិយាយថា នាងមិនចង់អោយកូនប្រុសរបស់នាងដែលឥឡូវនេះមានអាយុ១៤ខែ បន្តរស់នៅក្នុងពន្ធនាគារជាមួយនាងតទៅទៀតទេ ពីព្រោះនាងមិនមានម្ហូបអាហារគ្រប់គ្រាន់សំរាប់ហូបចុក ។ នាងក៏បារម្ភពីការដែលកូនរបស់នាងត្រូវទៅសាលាដែរ ពីព្រោះនាងមិនមានថវិកាសំរាប់អោយកូនសោះ ។**

ក្នុងចំណោមកុមារទាំង៣នាក់មានអាយុ៥ឆ្នាំ និងលើសពីនេះ ដែលកំពុងរស់នៅក្នុងពន្ធនាគារទាំងឡាយរួមទាំងពន្ធនាគារដែលនៅក្នុងការស្រាវជ្រាវនេះផង មានតែកុមារម្នាក់គត់ ដែលបានទទួលការសិក្សាមួយបែប។ ប៉ុន្តែសាលានេះគឺសំរាប់អ្នកទោសពេញវ័យតែប៉ុណ្ណោះ ហើយកុមារីអាយុ៧ឆ្នាំនេះជាក្មេងតែម្នាក់គត់ដែលចូលរៀនក្នុងថ្នាក់នោះជាមួយគេដែរហើយនាងពុំមានជំរើសផ្សេងអាចទៅចូលរៀនសាលាធម្មតាបាទេ ។ នាងត្រូវរៀនក្នុងថ្នាក់៥ម៉ោងក្នុងមួយសប្តាហ៍ ការពិតក្មេងដែលមានអាយុប្រហែលនាងនេះជាធម្មតាគេរៀននៅក្នុងសាលារដ្ឋ និងចំណាយពេលជិត ១៧ ម៉ោង ក្នុងមួយសប្តាហ៍ ហើយប៉ុណ្ណោះហើយនៅតែឆ្ងាយពីកំរិតអន្តរជាតិទៀតផង [២៣] ។ ខាងក្រោមនេះគឺជាការរៀបរាប់ពីស្ថានភាពនៃការសិក្សារបស់នាង។

**ករណីសិក្សាទី ២៥ :**

**ស្រី ផា មានអាយុ ៧ឆ្នាំ ចូលរៀននៅសាលាមួយដែលបង្រៀនដោយអង្គការគ្រីស្តសាសនា**

---

[២៣] *បាប ម៉ាក់ឡូលីន (Care Int'l Cambodia) ម៉ោងបង្រៀនដែលមានប្រសិទ្ធិភាព"របកគំហើញនិងអនុសាសន៍" ក្រសួងអប់រំ យុវជន និង កីឡា ភ្នំពេញ ខែមិថុនា (ភ្នំពេញ ១៩៩៩) ទំព័រ ៨-៩ ។*

ផ្ទាល់នៅខាងក្រៅពន្ធនាគារ ។ សាលាបង្រៀន៣ម៉ោងក្នុង១ ថ្ងៃ ហើយ៣ថ្ងៃក្នុង១ សប្តាហ៍។
ស្រី ផា ទៅសាលា ៣ព្រឹកក្នុង ១សប្តាហ៍ ពីម៉ោង ៧ ដល់ម៉ោង ១០ព្រឹក ហើយចេញពីរៀនត្រូវត្រឡប់មកពន្ធនាគារវិញ ។ ស្រី ផា ចូលចិត្តសាលារៀន ពីព្រោះនាងស្រឡាញ់ការសិក្សា ប៉ុន្តែ នាងមិនអាចមានមិត្តភ័ក្តនៅឯសាលាទេ ពីព្រោះសិស្សដទៃទៀតនៅក្នុងថ្នាក់ជាស្ត្រីវ័យចំណាស់ដែលមកពីពន្ធនាគារដែរ ។

## ៥-ការប្រព្រឹត្តមិនគប្បីចំពោះកុមារ :

ការធ្វើបាបកុមារដែលរស់នៅក្នុងពន្ធនាគារគឺការខ្វាយខ្វល់ពិសេសមួយដែលបាន ពិពណ៌នាយ៉ាងច្រើននៅក្នុងបញ្ហាទាំងឡាយ ។ ទោះបីជាមិនមានមាតាណាម្នាក់បានរាយការណ៍ត្រឹមត្រូវច្បាស់ឬរាយការណ៍ជាពិសេសពីការធ្វើបាបធ្ងន់ធ្ងរណាមួយដល់កូនៗរបស់គេក៏ដោយក៏ពួកគេ មួយចំនួនបានដំណាលប្រាប់នូវការធ្វើបាបខ្លះដែរ ដែលពួកគាត់ផ្ទាល់ឬកូនរបស់ពួកគាត់ទទួលរងនូវការរំលោភបំពានមកលើផ្លូវចិត្តនិងរាងកាយ ពីសំណាក់បុគ្គលិកពន្ធនាគារនិងអ្នកជាប់ពន្ធនាគារដូចគ្នា ។ ចំណុចសំខាន់យើងត្រូវកត់សំគាល់ថា ការសាកសួរស្ត្រីទៅលើប្រធានបទមួយនេះគឺជាការពិបាក ហើយស្មៀបរមាស់ទៀតផង។ ដោយហេតុថា ការសម្ភាសន៍ភាគច្រើនគឺមានវត្តមានបុគ្គលិក ពន្ធនាគារនៅជិតជានិច្ចនោះ ក្នុងករណីខ្លះអ្នកស្រាវជ្រាវមិនអាចលើកយកសំណួរនេះមកសួរបានទេ ។ លើសពីនេះទៀត លទ្ធភាពនៃការឆ្លើយអោយបានពិតត្រឹមត្រូវរបស់ស្ត្រីនោះអាចត្រូវបាន បង្ខូចសុវត្ថិភាពដោយត្រូវមានវត្តមានរបស់បុគ្គលិកនិងការបារម្ភពីផលវិបាកដែលនឹងអាចកើតឡើងជាយថាហេតុបន្ទាប់ពីការឆ្លើយសំនួររបស់គាត់ ។ គ្មានស្ត្រីណាម្នាក់ហ៊ាននិយាយថា បុគ្គលិកពន្ធនាគារបានធ្វើបាបកូនៗរបស់ពួកគាត់ទេ ។ ប៉ុន្តែមានស្ត្រី៣នាក់ក្នុងចំណោមស្រីចំនួន១១នាក់ បាននិយាយថាពួកគេផ្ទាល់ធ្លាប់ទទួលការធ្វើបាបពីសំណាក់បុគ្គលិកពន្ធនាគារ ។ ដូច្នេះ នេះអាចជាការធ្វើបាបលើផ្លូវចិត្តឬលើរាងកាយ ដូចដែលនឹងរៀបរាប់ខាងក្រោមនេះ។

| ករណីសិក្សាទី ២៦: |
| --- |
| ខុម និយាយថា បើនាងធ្វើអ្វីអាក្រក់នោះ បុគ្គលិកពន្ធនាគារ នឹងវ៉ាយគាត់ ។ នាងក៏និយាយដែរថា គេក៏ធ្វើដូច្នេះដែរចំពោះអ្នកជាប់ពន្ធនាគារដទៃៗទៀត ។ |

| ករណីសិក្សាទី ២៧: |
|---|
| ជួនកាលនៅពេលដែលនាង សំដា អោយកូននាងដើរខាងក្រៅម្នាក់ឯង បុគ្គលិកពន្ធនាគារសួរ នាងថា ហេតុអ្វីបានជាបណ្តោយអោយកូនដើរតែម្នាក់ដូច្នេះ ម៉េចក៏មិនមើលវាអោយបានត្រឹមត្រូវហើយក៏និយាយអាក្រក់លើសពីនេះថែមទៀតផង ។ |

លើសពីនេះទៅទៀតស្ត្រីទាំងនោះបានរៀបរាប់ពីការកើតឡើងខ្លះៗពីការដែលកូនៗរបស់ពួកទេទួលរងការធ្វើបាបដោយអ្នកជាប់ពន្ធនាគារដូចគ្នា ។រឿងមួយដែលកើតឡើងញឹកញាប់ជាងគេនៅក្នុងការកើតឡើងទាំងឡាយនោះគឺម្តាយមានអារម្មណ៏ថានាងគ្មានលទ្ធភាពជួយកូនបាននិងការពុំមានលទ្ធភាពក្នុងការការពារខ្លួន ឯង ឬការពារកូនរបស់ពួកគេបាន ។

| ករណីសិក្សាទី ២៨ : |
|---|
| ភាព និយាយថាបុគ្គលិកពន្ធនាគារបានប្រព្រឹត្តិចំពោះកូននាងជាធម្មតា ប៉ុន្តែមានអ្នកជាប់ពន្ធនាគារ មួយចំនួនបានវាយកូនគាត់នៅពេលយប់ ពីព្រោះកូននោះយំ ។ ជាញឹកញយណាស់ អ្នកជាប់ពន្ធនាគារទាំងនោះ ក្តិចកូនរបស់គាត់ ហើយជួនកាលក៏វាយកូននោះពីក្រោយ ។មិនមែនតែម្នាក់ទេអ្នកជាប់ពន្ធនាគារជាច្រើនបានធ្វើដូច្នេះចំពោះកូននាងយ៉ាងនេះហើយ ស្ទើរតែរាល់យប់ ។ ភាព និយាយថា នាងមិនអាចធ្វើអ្វីដើម្បីបញ្ឈប់អំពើនេះបានទេពីព្រោះនាងតែម្នាក់ឯងមិនអាចប្រយុទ្ធតទល់ជាមួយអ្នកជាប់ពន្ធនាគារ ដទៃៗទៀតទេ។ ភាពនិយាយថា បើកូនគាត់ចេះតែបន្តយំ អ្នកជាប់ពន្ធនាគារទាំងនោះក៏ចេះតែបន្តវាយកូនគាត់រហូត ។ |

| ករណីសិក្សាទី ២៩: |
|---|
| ជួនកាលអ្នកជាប់ពន្ធនាគារដទៃទៀតក្តិចកូនស្រីរបស់ សាមឿន ឈ្មោះ មេម ឬ ត្បូកក្បាលនាងដោយក្រញ៉ាំដៃ ។នៅពេលអ្នកជាប់ពន្ធនាគារដទៃទៀតខឹងសាមឿនគេក៏ធ្វើបែបនេះដាក់នាងមេមដែរ។ អ្នកជាប់ពន្ធនាគារដែលធ្វើបែបនេះ គឺនៅក្នុងបន្ទប់ឃុំឃាំងជាមួយគ្នា ។ ទង្វើបែបនេះបានកើតឡើងយ៉ាងហោចណាស់ក៏ពីរដងដែរចាប់តាំងពីគេចូលមកក្នុងពន្ធនាគារនេះ។ មានអ្នកជាប់ពន្ធនាគារខ្លះស្រែកដាក់នាងមេម ពីព្រោះនាងចេះតែដើរទៅជិតបន្ទប់ឃុំឃាំងរបស់ពួកគេ ។ សាមឿន បាននិយាយថា រឿងនេះកើតឡើងប្រហែលជាពី ៣ដង |

**ទៅ ៤ដងក្នុងមួយសប្តាហ៍ ។ ពេលដែលអ្នកជាប់ពន្ធនាគារដទៃទៀតស្រែកដាក់នាង នាងក៏យំហើយរត់ត្រឡប់មកបន្ទប់ឃុំឃាំងរបស់ម្តាយនាងវិញ ។**

ការសម្ភាសន៍មួយធ្វើឡើងជាមួយនិងកូនស្រីម្នាក់របស់មាតាដែលជាប់ពន្ធនាគារបានលាតត្រដាងនូវបញ្ហារបស់នាងដែលរងការធ្វើបាបពីសំណាក់អ្នកជាប់ពន្ធនាគារដទៃៗ និងការភ័យខ្លាចដែលរឿងនោះ នៅជិតជាប់ក្នុងខួរក្បាលរបស់នាង ។ រឿងរបស់នាងក៏ឆ្លុះបញ្ចាំងផងដែរនូវអត្ថន័យមួយគឺភាពតែលតោល ដូចដែលនាងបានរៀបរាប់ពីការខ្វះលទ្ធភាពរបស់នាងក្នុងការជួយម្តាយបាន។ នាងមិនចង់និយាយរឿងនេះប្រាប់ម្តាយនាងឬបុគ្គលិកពន្ធនាគារទេ ដោយខ្លាចមានគំនុំសងសឹកមកនាងវិញ ។ ក្តីកង្វល់ដែលនាងបង្ហាញឡើងអំពីសុខុមាលភាព ទាំងម្តាយនាង និងខ្លួននាងគឺជាការពិបាកបំផុតចំពោះកុមារអាយុត្រឹមតែ ៧ឆ្នាំ ។ ករណីរបស់នាងមានរៀបរាប់ដូចខាងក្រោម ។

| **ករណីសិក្សាទី ៣០:** |
|---|
| **ឡេងមានការភ័យខ្លាចអ្នកជាប់ពន្ធនាគារដទៃទៀតវាយនាង ដោយនាងធ្លាប់ត្រូវអ្នកជាប់ពន្ធនាគារស្រ្តីម្នាក់វាយម្តងរួចមកហើយ។ ស្រ្តីម្នាក់ក្តិចជើងនាង ហើយជួនកាលវាយនាង។ នាងនិយាយថាស្រ្តីនោះវាយរាល់ថ្ងៃ ប៉ុន្តែម្តាយនាងមិនអាចវាយជាមួយអ្នកជាប់ពន្ធនាគារផ្សេងៗបានទេ ដោយគាត់មានតែម្នាក់ឯង។ ឡេងមិនដឹងត្រូវធ្វើយ៉ាងណាទេ។ ពេលសួរថាតើនាងមានធ្លាប់បាននិយាយរឿងនេះប្រាប់អ្នកណាឬទេ នាងនិយាយថា នាងមិនចង់និយាយប្រាប់ម្តាយនាងទេ ដោយខ្លាចក្រែងម្តាយនាងទៅវាយជាមួយអ្នកនោះ។ នាងនិយាយថា នាងក៏មិនដែលនិយាយប្រាប់បុគ្គលិកពន្ធនាគារដែរ ។ ឡេងក៏និយាយផងដែរថា នាងចង់តែចេញអោយផុតពីពន្ធនាគារនេះ ។** |

## ៦- ការប៉ះពាល់ទូទៅនៃបរិយាកាសពន្ធនាគារ:

អ្នកផ្តល់ការសម្ភាសន៍ជាច្រើនបានបង្ហាញនូវការធុញថប់ អំពីបរិយាកាសទូទៅក្នុងពន្ធនាគារនិងការប្រព្រឹត្តចំពោះគ្នាទៅវិញទៅមករវាងអ្នកជាប់ពន្ធនាគារការប៉ះពាល់ទូទៅនៃបរិយាកាសពន្ធនាគារ អ្នកផ្តល់ការសម្ភាសន៍ជាច្រើនបានបង្ហាញនូវការធុញថប់អំពីបរិយាកាសទូទៅក្នុងពន្ធនាគារ និង ការប្រព្រឹត្តិចំពោះគ្នាទៅវិញទៅមករវាងអ្នកជាប់ពន្ធនាគារ និងអ្នកជាប់ពន្ធនាគារ ដែលវានឹងអាចជះឥទ្ធិពលអាក្រក់ដល់កុមារដែលកំពុងរស់នៅក្នុងបរិវេណពន្ធនាគារ ។ ការលើកឡើងនេះវាជាការពិតណាស់ក្នុងចំណោមពិរុទ្ធជនទណ្ឌិត និង បុគ្គលិកពន្ធនាគារ។

| ករណីសិក្សាទី ៣១: |
| --- |
| ម៉ៃ គិតថាការរស់នៅក្នុងពន្ធនាគារ "ទទួលឥទ្ធិពលមិនល្អទេ " ចំពោះកូនស្រីនាង ប៉ុន្តែនាងមិនដឹងថាត្រូវធ្វើដូចម្តេចដើម្បីផ្លាស់ប្តូរវាទេ ។ |

| ករណីសិក្សាទី ៣២: |
| --- |
| លោក វេជ្ជបណ្ឌិតប្រចាំពន្ធនាគារ ឈ្មោះ សុខ សៃ បាននិយាយថា ប្រសិនបើកុមាររស់នៅក្នុងពន្ធនាគារពួកគេមិនអាចទៅរៀនបានទេ ហើយអាកប្បកិរិយារបស់គេខុសពីកុមារដែលរស់នៅខាងក្រៅពន្ធនាគារ។ គាត់ជឿជាក់ថា កុមារមិនគួរនៅក្នុងពន្ធនាគាជាមួយម្តាយគេទេ ។ ពេលសួរថា តើកុមារដែលរស់នៅខាងក្នុងពន្ធនាគារខុសគ្នាយ៉ាងដូចម្តេចខ្លះពីកុមារដែលរស់នៅខាងក្រៅ សុខ សៃនិយាយថា កុមាររស់នៅក្នុងពន្ធនាគារ គឺរស់នៅក្នុង "ភាពងងឹត " ហើយគេមើលឃើញតែអ្នកជាប់ពន្ធនាគារ។ អ្នកជាប់ពន្ធនាគារខ្លះមានលក្ខណៈ "អាក្រក់ខ្លាំងណាស់ " ហើយនៅពេលដែលកុមារឃើញគេ ក៏ ចំលងយកនូវឧទាហរណ៍នេះ ។ |

| ករណីសិក្សាទី ៣៣: |
| --- |
| ពេលយើងសួរថា ហេតុអ្វីបានជានាងគិតថា ស្រី នាត ត្រឡប់ទៅផ្ទះរស់នៅជាមួយឪពុកប្រសើរ ជាងរស់នៅក្នុងពន្ធនាគារ សុផាណានិយាយាថា នាងខ្លាចដល់ពេលស្រីនាតធំដឹងក្តីនៅក្នុងពន្ធនាគារនឹងអាចមានការជះឥទ្ធិពលមិនល្អដល់នាង ។ សុផាណា និយាយថា គាត់ឮគេថា គេមិន អនុញ្ញាតអោយកុមារធំៗរស់នៅក្នុងពន្ធនាគារទេ ប៉ុន្តែនាងមិនដឹងថារឿងនេះពិតដែរឬទេ? អ្នក ជាប់ពន្ធនាគារខ្លះនិយាយថា ខ្ញុំមិនគួរទុកកូននៅក្នុងពន្ធនាគារទេ ព្រោះពេលនាងធំ នឹងទទួលឥទ្ធិពលមិនល្អ។ មានអ្នកជាប់ពន្ធនាគារម្នាក់និងបុគ្គលិកម្នាក់បានផ្តល់អោយនាងនូវគំនិតមួយ ថា បើខ្ញុំចង់ទុកកូននៅក្នុងពន្ធនាគារក៏បានដែរ ប៉ុន្តែក្រែងវាមិនល្អសំរាប់កូន ។ |

នៅក្នុងករណីខាងលើ ការខ្លាចរបស់មាតាគឺលាយឡំជាមួយនឹងអ្វីដែលនាងបានឮពីអ្នកជាប់ពន្ធនាគារដូចគ្នា និង បុគ្គលិកពន្ធនាគារ ។

ស្ត្រីមួយចំនួនបានធ្វើការអះអាងជាក់លាក់ចំពោះបញ្ហាបរិស្ថាននៃពន្ធនាគារ និងការដែលអាចធ្វើអោយខូចប្រយោជន៍ដល់កុមារទាំងឡាយ ។ បញ្ហានេះនឹងមានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម ។

| **ករណីសិក្សាទី ៣៤:** |
| --- |
| **សុវណ្ណា មិនចង់អោយកូនស្រីរបស់នាង ឈ្មោះ ស្រី ធា រស់នៅក្នុងពន្ធនាគារទេ ពីព្រោះវាជាកន្លែងដែលអាក្រក់ចំពោះនាង ។ សុវណ្ណា និយាយថា វាជាកន្លែងអាក្រក់ ពីព្រោះស្រី ធា មិនអាចឃើញអ្វីខាងក្រៅពន្ធនាគារឡើយ ។** |

| **ករណីសិក្សាទី ៣៥ :** |
| --- |
| **កញ្ញា គិតថា វាមិនល្អទេ ចំពោះកូននាងរស់នៅក្នុងពន្ធនាគារ ។ កូនខ្ញុំមើលជុំវិញ ហើយមិន អាចឃើញអ្វីទាំងអស់ ឃើញតែអគារ និង ដែក ។ វាធ្វើអោយកូននោះមួម៉ៅ ។** |

## ៧ -ចំណុចផ្សេងៗទៀតដែលជាបញ្ហាព្រួយបារម្ភ :

បញ្ហាផ្សេងៗទៀតដែលបានលើកឡើងក្នុងពេលសម្ភាសន៍នោះគឺ :

១- ព្រួយបារម្ភថា កុមារទាំងនោះនឹងទទួលការបន្តុះបង្អាប់មើលងាយដោយកុមារដទៃៗទៀតដែលស្រករៗគ្នា ដោយសារតែឪពុកម្តាយគេជាអ្នកជាប់ពន្ធនាគារ ។

២- បារម្ភថា នៅពេលដែលកូនរបស់គេធំដឹងក្តីឡើង ហើយលុះដឹងថាឪពុក ម្តាយរបស់គេត្រូវបានកាត់ទោសដោយការប្រព្រឹត្តិបទឧក្រិដ្ឋ ឬជាពិរុទ្ធជននោះ គេនឹងមានអារម្មណ៏ខឹង ឬតូច ចិត្តចំពោះឪពុកម្តាយរបស់គេ ។

៣-ការព្រងើយកន្តើយរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបទៅនិងសំណើសុំជំនួយរបស់អ្នកដឹកនាំគ្រប់គ្រងពន្ធនាគារ ឬបុគ្គលិកពន្ធនាគារក្នុងនាម មាតា កុមារ និង ស្ត្រីមានផ្ទៃពោះនៅក្នុងពន្ធនាគារទាំងនោះ ។

## V- ការទទួលខុសត្រូវ ប៉ុន្តែមិនបានអើពើដល់ការអនុវត្តច្បាប់-និតិវិធី :

### កង្វះចំណេះដឹងស្តីពីច្បាប់ជាតិ អន្តរជាតិ និង បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធ

ការសម្ភាសន៏ជាមួយបុគ្គលិកពន្ធនាគារ រួមទាំងនាយកពន្ធនាគារផង បានឆ្លុះបញ្ចាំងអោយឃើញនូវកង្វះខាតយ៉ាងខ្លាំងនូវចំណេះដឹងផ្នែកច្បាប់និង បញ្ញត្តិទាំងឡាយដែលទាក់ទងទៅនឹងមាតា ដែលមានកូននៅជាមួយ និងស្ត្រីមានផ្ទៃពោះរស់នៅក្នុងពន្ធនាគារ។ មានចាងហ្វាងពន្ធនាគារ៥នាក់ក្នុងចំណោមចាងហ្វាងពន្ធនាគារ ៨ នាក់ និង បុគ្គលិកចំនួន៧ នាក់ក្នុងចំណោមបុគ្គលិកចំនួន ១៣ នាក់ ដែលយើងបានសម្ភាសន៏បានអោយយើងដឹងថា ពុំមានការយល់ដឹងអំពីច្បាប់កម្ពុជា ដែលទាក់ទងទៅនឹងប្រធានបទនេះទេ ។

| **ករណីសិក្សាទី ៣៦:** |
|---|
| **លោក ផល ជាចាងហ្វាងពន្ធនាគារដែលបានធ្វើការនេះអស់រយៈពេល ៨ ឆ្នាំកន្លងមកហើយ បាននិយាយថាគាត់មិនដែលបានចេះដឹងច្បាប់កម្ពុជាណាមួយដែលពាក់ព័ន្ធនិងកុមាររស់នៅក្នុងពន្ធនាគារជាមួយមាតាគេឡើយ ។ បន្ទាប់មក លោក ផល និយាយថា តាមគោលការណ៍រដ្ឋាភិបាលចែងថា ពន្ធនាគារត្រូវតែជួយឧបត្ថម្ភដល់កូន១ទាំងឡាយរបស់អ្នកជាប់ពន្ធនាគារ ដូចជាផ្ដល់អាហារ ថ្នាំពេទ្យជាដើម - ប៉ុន្តែនេះមិនមែនជាច្បាប់ទេ វា "គ្រាន់តែជាលិខិតមួយរបស់រដ្ឋាភិបាល តែប៉ុណ្ណោះ" ។** |

មានចាងហ្វាងពន្ធនាគារចំនួន៤នាក់ក្នុងចំណោមចាងហ្វាងចំនួន៨នាក់បានលើកឡើងថានៅក្នុងពន្ធនាគាររបស់ពួកគេពុំមានគោលការណ៍ណាស្តីអំពីកូន១របស់អ្នកជាប់ពន្ធនាគាររស់នៅក្នុងពន្ធនាគារទេ។ ហើយនៅមានចាងហ្វាងពន្ធនាគារចំនួន៥នាក់ទៀតក្នុងចំណោមចាងហ្វាងទាំងអស់៨នាក់ក៏បាននិយាយថា ពុំមានគោលនយោបាយណាមួយស្តីអំពីស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារទេ ។

ស្រដៀងគ្នានេះដែរ មាតានិង ស្ត្រីមានផ្ទៃពោះដែលយើងបានសម្ភាសន៍ មានការយល់ដឹងតិចតួចបំផុតអំពីបញ្ញត្តិពាក់ព័ន្ធទានឹងមាតាមានកូនតូច ឬស្ត្រីមានផ្ទៃពោះជាប់ឃុំឃាំងក្នុងពន្ធនាគារ ។ ពេលសួរថាតើពួកគេបានដឹងពីបញ្ញត្តិរបស់ពន្ធនាគារ ដលចែងពាក់ព័ន្ធទៅនឹងមាតាមានកូនរស់នៅជាមួយនិងស្ត្រីមានផ្ទៃពោះនៅក្នុងពន្ធនាគារនេះដែរឬទេ យើងសង្កេតឃើញថាមានស្ត្រី ៩នាក់ក្នុងចំណោមស្ត្រី ១៤ នាក់បាននិយាយថាគេមិនដែលចេះដឹងបញ្ញត្តិណាមួយសោះ។ មានស្ត្រីចំនួន ១២នាក់ក្នុងចំណោមស្ត្រី១៤នាក់ បាននិយាយថាពួកគេមិនដែលដឹងអ្វីទាល់តែសោះអំពីច្បាប់កម្ពុជា ដែលពាក់ព័ន្ធទៅនឹងកុមាររស់នៅក្នុងពន្ធនាគារជាមួយមាតាពួកគេឡើយ។

ចំណែកឯលោកចាងហ្វាងភាគច្រើនមានការយល់ដឹងអំពីបញ្ញត្តិទាំងនោះ តែគេនិយាយថា គេមិនអាចអនុវត្តទៅតាមបញ្ញត្តិទាំងនោះអោយបានត្រឹមត្រូវបានទេ ពីព្រោះតែភាពខ្សត់ខ្សោយផ្នែកហិរញ្ញវត្ថុ ។

| **ករណីសិក្សាទី ៣៧ :** |
|---|
| **លោកចាងហ្វាងពន្ធនាគារ ឈ្មោះ ច័ន្ទ ដារា គាត់មានការយល់ដឹងអំពី ប្រកាសលេខ ២១៧ ប៉ុន្តែគាត់និយាយថា បុគ្គលិកពន្ធនាគារមិនអាចអនុវត្តតាមបញ្ញត្តិនេះបានទេ អាស្រ័យដោយភាពខ្សត់ខ្សោយផ្នែកហិរញ្ញវត្ថុ ។ ច័ន្ទដារា និយាយថា គាត់ត្រូវតែលក់ដូរខ្លះដើម្បីបានថវិកាយកមកផ្គត់ផ្គង់ដល់អ្នកជាប់ពន្ធនាគារទាំងនោះ ។ជួនកាលអ្នកជាប់ពន្ធនាគារផលិតកន្ទេល** |

ដើម្បីលក់យកថវិកា។ ថវិកាមួយចំនួនបែងចែកទៅអោយអ្នកជាប់ពន្ធនាគារ និងមួយចំនួនទៀតបែងចែកដល់ពន្ធនាគារទុកសំរាប់បង់ថ្លៃអគ្គិសនី ថ្នាំពេទ្យ និង សម្ភារៈផ្សេងៗទៀត ។

**ករណីសិក្សាទី ៣៨ :**

សុផាតជាចាងហ្វាងពន្ធនាគារបាននិយាយថា គោលនយោបាយរដ្ឋាភិបាលបានចែងថា នៅពេលដែលអ្នកជាប់ពន្ធនាគារម្នាក់ត្រូវបានដោះលែងពីពន្ធនាគារ យើងត្រូវផ្គត់ផ្គង់ដល់គាត់នូវសំលៀកបំពាក់ និង ថវិកាសំរាប់ធ្វើសោហ៊ុយត្រលប់ទៅផ្ទះវិញ ។ ប៉ុន្តែរដ្ឋាភិបាលមិនដែលផ្តល់ថវិកាអោយពន្ធនាគារសំរាប់ការអនុវត្តន៏កិច្ចការនេះសោះ ។ សុផាតនិយាយថា វាជាការពិបាកបំផុតចំពោះអ្នកជាប់ពន្ធនាគារណាដែលរស់នៅឆ្ងាយពីទីនេះ។ គាត់បានធ្វើសំណើសុំដល់រដ្ឋាភិបាលម្តងជាពីរដងហើយ ប៉ុន្តែមិនដែលបានទទួលអ្វីបន្តិចសោះ ដូច្នេះគាត់មិនចង់សួរម្តងទៀតឡើយ ជួនកាលគាត់អោយលុយផ្ទាល់ខ្លួនទៅអ្នកដែលបានបំរើ ទោសចប់សំរាប់ធ្វើសោហ៊ុយទៅផ្ទះ ។

## VI- ចំណេះដឹង : ការវិភាគស្រាវជ្រាវ

ការស្រាវជ្រាវរកឃើញ ដែលបានបង្ហាញយ៉ាងលំអិតខាងលើ នឹងត្រូវបានគេវិភាគដោយផ្អែកលើមូលដ្ឋាន ដូចតទៅ :

- របៀបនៃការរកឃើញមាន៤ប្រភេទសំខាន់នៃសិទ្ធិកុមារ ដូចដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារ : ការរស់នៅ ការអភិវឌ្ឍន៏ ការការពារ និង ការចូលរួម ។
- របៀបនៃការរកឃើញដែលទាក់ទិនទៅនឹងបទបញ្ញត្តិ ច្បាប់អន្តរជាតិ និង ច្បាប់របស់ប្រទេសកម្ពុជា ហើយជាពិសេស របៀបនៃការរកឃើញដែលបង្ហាញពីការអនុវត្តន៏ ឬ ការមិនអនុវត្តន៏នៃបទបញ្ញត្តិ និង ច្បាប់ដែលបានពោលខាងលើ ។

### ក -ចង្កោមសិទ្ធិទាំង ៤ របស់កុមារ

អ្នកធ្វើការជាច្រើននៅក្នុងវិស័យសិទ្ធិកុមារ ជាធម្មតាបែងចែកប្រភេទសិទ្ធិ ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ជាបួនផ្អែកសំខាន់ៗ ដោយឱ្យនិយមន័យ "ចង្កោម"សិទ្ធិទាំង៤របស់កុមារ : សិទ្ធិនៃការរស់នៅ សិទ្ធិទទួលការការពារ សិទ្ធិអភិវឌ្ឍន៏ និង សិទ្ធិចូលរួម ។ គោលគំនិតមួយនៃការស្រាវជ្រាវរបស់អ្នកនិពន្ធ គឺត្រូវកំណត់ថា តើសិទ្ធិរបស់កុមារកម្ពុជាដែលកំពុងរស់នៅក្នុងពន្ធនាគារកំពុង

ត្រូវបានគេគោរពទៅតាមចង្កោមសិទ្ធិទាំង ៤នោះឬទេ ។ ប្រភេទនៃចង្កោមសិទ្ធិនិមួយៗទាំងនេះនឹងត្រូវបានគេឱ្យនិយមន័យយ៉ាងច្បាស់បន្ថែមទៀតរួមជាមួយនឹងការវិភាគមួយនៃការអនុវត្តនីរបស់វាចំពោះកុមារដែលកំពុងរស់ក្នុងពន្ធនាគារ ។

**១-សិទ្ធិរស់រានមានជីវិត:**

ដូចដែលគេសង្ឃឹមទុក "សិទ្ធិនៃការរស់នៅ" រួមមានសិទ្ធិរស់រានមានជីវិតជាមូលដ្ឋាន ។ បន្ថែមលើសពីនេះទៀត មធ្យោបាយនៃការការពារនៃសិទ្ធិរស់រានមានជីវិត សិទ្ធិនេះធានាការទទួលបាននូវកំរិតថៃទាំសុខភាព និង ការព្យាបាលដ៏ខ្ពស់បំផុតដែលអាចធ្វើទៅបាន ។

ការធានាសិទ្ធិនៃការរស់នៅ ចាំបាច់ត្រូវការការពារ មរណៈភាពរបស់ទារក និង កុមារដែលតម្រូវឱ្យមានការថែរទាំសុខភាពសមរម្យ និង មិនអាចផ្តាច់បានចំពោះកុមារ និងទារកទើបនឹងកើត ។ ការទទួលបានការថែទាំព្យាបាល និងអាគារសមរម្យសំរាប់កូនរបស់គេ គឺជាការចាប់អារម្មណ៏មួយដ៏សំខាន់ក្នុងចំណោមមាតាដែលគេបានធ្វើការសំភាសន៏ ។ មាតាទាំងនោះបានឱ្យឧទាហរណ៏យ៉ាងច្បាស់ថា ទាំងខ្លួនគាត់ផ្ទាល់ ឬកូនរបស់ពួកគាត់ត្រូវបានគេបដិសេធមិនយក ចិត្តទុកដាក់ដោយយោងតាមធនធានថវិកាការខ្វះខាតធនធានថ្នាំព្យាបាល ឬការបដិសេធមិនព្រមផ្តល់ការព្យាបាលរបស់មន្ត្រីពន្ធនាគារ ដែលពួកគាត់មានអារម្មណ៏ថា ជាការចំបាច់ (មើលករណីសិក្សា ទី ១៤-១៩) ។

ការការពារមរណៈភាពរបស់កុមារ និងទារកទាមទារផងដែរឱ្យមានការថែទាំល្អប្រសើរមុនពេលសំរាលកូន ដើម្បីធានាសុខភាពទារកទើបនឹងកើត ។ ជាថ្មីម្តងទៀត ទណ្ឌិត និងជនជាប់ចោទដែលមានផ្ទៃពោះ ហាក់ដូចជាមិនបានទទួលការថែទាំដូច្នេះទេ ។ ការទៅពិគ្រោះជាមួយវេជ្ជបណ្ឌិតមានកំណត់ ។ បន្ថែមលើសពីនេះទៀត ការខ្វះខាតចំណីអាហារក្នុងចំណោមមាតា ឬស្ត្រីទើបនឹងសំរាលកូន អាចមានឥទ្ធិពលទៅលើការរស់នៅ និង សុខភាពរបស់ទារក ។

ការមិនមានលទ្ធភាពផលិតទឹកដោះគ្រប់គ្រាន់របស់មាតា គឺជាការចង្អុលបង្ហាញទាំងសុខភាព ខ្សោយ និងភាពគ្រោះថ្នាក់ដល់សុខភាពកូនរបស់គេ ។ ការសំរាលកូននៅក្នុងពន្ធនាគារជាជាងនៅក្នុងមន្ទីរពេទ្យអាចប៉ះពាល់ដល់ការរស់នៅរបស់កុមារផងដែរ ។ ប្រសិនបើស្ត្រីម្នាក់ប្រឈមមុខនឹងភាពស្មុគស្មាញ (ជុំងឺ) ក្នុងពេលសំរាលកូន ការខ្វះបុគ្គលិកវេជ្ជសាស្ត្រដែលបាន ហ្វឹកហ្វឺន និង ខ្វះសម្ភារៈគ្រាប់គ្រាន់នៅក្នុងមជ្ឈមណ្ឌលថែទាំសុខភាពរបស់ពន្ធនាគារ អាចនាំឱ្យមានមរណៈភាព ឬ គ្រោះថ្នាក់

យ៉ាងធ្ងន់ធ្ងរទាំងមាតានិងទារក ។ នៅក្នុងរបាយរណ៍របស់ អង្គការ មាតាពិភពលោកឆ្នាំ ២០០១ អ្នកនិពន្ធសរសេរថា :

> វត្តមាននៃអ្នកជំនាញប្រសូតបុត្រក្នុងកំឡុងពេលធ្វើការ ឬ សំរាលបុត្រ គឺមានសារៈសំខាន់ផងដែរ ចំពោះការការពារមរណៈភាព និង ជម្ងឺផ្សេងៗនៃមាតានិងទារកទើបនឹងកើត... ។ ប្រហែល ១៥% នៃស្ត្រីមានផ្ទៃពោះទាំងអស់ នឹងប្រឈមមុខភាព ស្មុគស្មាញ(ជម្ងឺ)ដែលតម្រូវឱ្យមានការថែទាំព្យាបាល ។ ការការពារមរណៈភាពរបស់មាតានៅក្នុងករណីមានភាពស្មុគស្មាញ(ជម្ងឺ) ទាំងនេះតម្រូវឱ្យមានការវះកាត់សង្គ្រោះបន្ទាន់ដ៏មានគុណភាពនៅក្នុងមន្ទីរពេទ្យ ។ នៅពេលដែលមន្ទីរពេទ្យនៅឆ្ងាយផ្លូវ ឬ មិនអាចមានលទ្ធភាពផ្តល់ការវះកាត់ សង្គ្រោះបន្ទាន់ ភាពស្មុគស្មាញ(ជម្ងឺ) តែងតែទទួលបានលទ្ធផលមរណៈភាព ឬពិការ រយៈពេលយូរ ។[២៤]

ជាទីបញ្ចប់, ការខកខានមិនបានចាក់ថ្នាំបង្ការដល់ទារកទើបនឹងកើត អាចបន្ថយឱកាសនៃការរស់នៅរបស់គេឱ្យបានល្អប្រសើនៅពេលអនាគត ។

ទោះបីជាយ៉ាងណាក៏ដោយ គ្មានរបាយការណ៍ណាមួយដែលបង្ហាញថាមានទារកស្លាប់នៅក្នុងពន្ធនាគារទេ ការស្រាវជ្រាវខាងលើចង្អុលបង្ហាញថា សិទ្ធិនៃការរស់នៅរបស់កុមារដែលកំពុងរស់នៅក្នុងពន្ធនាគារស្ថិតក្នុងភាពគ្រោះថ្នាក់គួរឱ្យកត់សំគាល់ ។

## ២-សិទ្ធិទទួលការការពារ :

ប្រភេទនៃ"សិទ្ធិដែលត្រូវបានគេការពារ" រួមមានការការពារពីការរើសអើង ការបំពារបំពាន និងការមិនយកចិត្តទុកដាក់ ។ វាបង្កើតការការពារសិទ្ធិកុមារផងដែរ ជាពិសេសនៅក្នុង កាលៈទេសៈលំបាកដែលអាចងាយស្រួលអនុវត្តចំពោះកុមារទាំងឡាយដែលគេចិញ្ចឹមនៅក្នុង មជ្ឈមណ្ឌលអប់រំ ។

យោងទៅតាមការការពារកុមារដែលកំពុងរស់នៅក្នុងពន្ធនាគារ, ការចាប់អារម្មណ៍ជាបឋម គឺការគោរពសិទ្ធិទទួលបានការរីករាយក្នុងជីវិតរួចផុតពីការបំពារបំពានការមិនយកចិត្តទុកដាក់ ឬការធ្វើទុក្ខទោស។ ករណីសិក្សាចាប់ពីលេខ ២៨-៣០ ដែលបានកត់ត្រាអំពីជនជាប់ឃុំឃាំងដែលទទួលរងគ្រោះ ឬក៏វាយធ្វើបាបដល់កុមាររកឃើញថាបរិយាកាសក្នុងពន្ធនាគារមិនបាន ការពារកុមារទាំងនោះឱ្យល្មមគ្រាប់គ្រាន់រួចផុតពីការ

---

[២៤] *សង្គ្រោះកុមារ : អង្គការមាតាពិភពលោក ២០០១ ទំព័រ ១០, ១១ ។*

គ្រោះថ្នាក់ដល់រូបរាងកាយទេ ។ ឧទាហរណ៍ អំពីអ្នកជាប់ពន្ធនាគារ ឬ បុគ្គលិកពន្ធនាគារស្រែកគំរាមដល់មាតា ឬ កុមារអាចធ្វើការគំរាមកំហែងតាមពាក្យសំដីដដែលៗ និងអាចនាំឱ្យមានវិបត្តិផ្លូវចិត្ត ឬ ជម្ងឺសតិអារម្មណ៍ យ៉ាងខ្លាំងក្នុងករណីខ្លះ ។ ការខកខានមិនបានចាក់ថ្នាំដល់ទារកទើបនឹងកើត និង ការមិនបានឱ្យថ្នាំព្យាបាលគ្រប់គ្រាន់នៅពេលមានការស្នើសុំអាចត្រូវបានគេពិចារណាឃើញថា មានការមិនយកចិត្តទុកដាក់ពីមន្ត្រីពន្ធនាគារ ឬក៏ពីអ្នកទទួលខុសត្រូវផ្សេងទៀត ។

ប្រហែលជាមានការព្រួយបារម្ភច្រើនជាងគ្រោះថ្នាក់ផ្ទាល់គឺជាខ្លឹមសារនៃការមិជួយគ្នាដែលញ៉ាំញីដល់អ្នកជាប់ពន្ធនាគា និងកុមារក្នុងកាលៈទេសៈដូចនេះ ។ ដូចដែលបានពិភាក្សានៅក្នុងផ្នែក បញ្ញត្តិច្បាប់ដូចតទៅនីតិវិធីពន្ធនាគារលេខ ១២ គូសបញ្ជាក់ អំពីសេរីភាពរបស់អ្នកជាប់ ពន្ធនាគារ ដើម្បីធ្វើសំណើ និង ប្ដឹងនិងការនិយាយលំអិតពីការទទួលខុសត្រូវរបស់បុគ្គលិកពន្ធនាគារក្នុងការគូសបញ្ជាក់ទៅលើការចាប់អារម្មណ៍ដូចនេះ ។ ស្ត្រីនៅក្នុងករណីសិក្សាខាងលើនៅតែមានអារម្មណ៍ថា គ្មានសុវត្ថិភាព ឬវិធានការទទួលខុសត្រូវអាចកើតមានឡើងទេ ប្រសិនបើពួកគេឬកូនរបស់គេឋិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ណាមួយ ។ ដោយហេតុថា អ្នកជាប់ពន្ធនាគារមិនបានដឹងអំពីច្បាប់ ឬ និយាយសាមញ្ញដោយសារច្បាប់មិនត្រូវបានគេអនុវត្តប្រព័ន្ធអប់រំបច្ចុប្បន្ន មិនបានអនុញ្ញាតគ្រាប់គ្រាន់ ឱ្យអ្នកជាប់ពន្ធនាគាររាយការណ៍អំពីការ រំលោភបំពាន ឬសុំឱ្យជួយនោះទេ ។ តាមពិតស្ត្រីជាច្រើន ក៏ដូចជាកុមារដែលត្រូវបានគេសំភាសន៍បាននិយាយថា ការភ័យខ្លាចបានបង្ការពួកគេមិនឱ្យសុំឱ្យជួយពីមន្ត្រីពន្ធនាគារ ។ ស្ត្រីភាគច្រើនមានសង្ឃឹមតិចតួចថា សំណើរបស់គេនឹងផ្ដល់នូវលទ្ធផលវិជ្ជមានទាំងនោះហើយ ដែលមិនបានលើកទឹកចិត្តពួកគេឱ្យរាយការណ៍អំពីការប្រព្រឹត្តខុសឆ្គង ហើយជាលទ្ធផលមកវិញ ធ្វើឱ្យមានគ្រោះថ្នាក់ដល់សិទ្ធិរបស់កុមារ ។

លើសពីនេះទៀត ទិន្នន័យដែលគេទទួលបានក្នុងកំឡុងពេលធ្វើសំភាសន៍បង្ហាញថា មិនមានពន្ធនាគារណាមួយមានបញ្ញត្តិច្បាប់ដែលទាក់ទងទៅនឹងការទំនាក់ទំនងគ្នាទៅវិញទៅមករវាងអ្នកជាប់ឃុំឃាំង និងកូនរបស់ទណ្ឌិត និង ជនជាប់ឃុំបណ្ដោះអាសន្ន ។ កុមារទាំងនោះហាក់ដូចជាមានសេរីភាពលេង និងនិយាយស្ដីជាមួយនរណាម្នាក់ដែលគេចង់និយាយលើសលែងតែឪពុកម្ដាយរបស់គេមិនឱ្យធ្វើដូច្នោះ ។ ការព្រួយបារម្ភពីការខ្វះខាតជាទូទៅដែលបានបង្ហាញ ទាំងបុគ្គលិកពន្ធនាគារ និង មាតាដែលត្រូវបានជាប់ឃុំឃាំងអំពីទំនាក់ទំនងគ្នារវាងកុមារ និងទណ្ឌិតផ្សេងទៀត គឺថាវាកំពុងតែបង្ហាញពីភាពរំជើបរំជួលដែលគេពិចារណាថា អង្គហេតុទាំងនោះថា ទណ្ឌិតដែលមានទោសពីបទរំលោភ បំពារបំពានលើសិទ្ធិកុមារ និងបទល្មើសទាក់ទងនឹងការរួមភេទឋិតនៅក្នុងពន្ធនាគារទាំងនេះផងដែរ ។ ក្នុងករណីមួយ បុគ្គលិកពន្ធនាគារត្រូវបានគេ

សំភាសន៍និយាយថា កូនរបស់ពួកគេដែលបានរស់នៅ ឬ លេងនៅទីធ្លាពន្ធនាគារជាធម្មតា គឺជាពិសេសចូលចិត្ត និយាយទៅកាន់ជនជាប់ឃុំឃាំងដែលពួកែនិយាយលេងច្រើន ។ ទោះជាយ៉ាងណាក៏ដោយកុមារទាំងនោះ និយាយទៅកាន់បុគ្គលិកពន្ធនាគារ និង អ្នកជាប់ពន្ធនាគារវាបង្ហាញថា កុមារម្នាក់ដែលកំពុងរស់នៅជាមួយ នឹងម្តាយរបស់វានឹងមានសេរីភាពចូលរួមទាក់ទងជាមួយនឹងអ្នកជាប់ពន្ធនាគារដូចគ្នានេះដែរ ផ្ទុយទៅវិញ ការទទួល ទោសរបៀបនេះ គឺដូចជារធ្វើបាបកុមារ ។ ក្នុងស្ថានភាពដូច្នេះ នឹងនៅក្នុងករណីស្រដៀងគ្នា ច្រើនផ្សេងទៀត ដែលមិនអាចយកជាភស្តុតាងបានបង្ហាញយ៉ាងច្បាស់ទៅលើគ្រោះថ្នាក់ដល់ សុវត្ថិភាពរបស់ កុមារនៅក្នុងពន្ធនាគារ ។

ក្នុងន័យនៃការការពារពីការរើសអើង មានតែនាយកពន្ធនាគារមួយក្នុងចំណោមនាយកពន្ធនាគារ ទាំង៧ បានទទួលស្គាល់ថា លិខិតកំណើតរបស់កុមារមិនមានចុះបញ្ជីនៅក្នុងអាគារពន្ធនាគារ ដូចកន្លែងចុះ លិខិតកំណើតនោះទេ។ ការខ្វះការយល់ដឹងអំពីឬមិនយកចិត្តទុកដាក់ចំពោះបទបញ្ញត្តិនេះដែលបានអធិប្បាយ ពិភាក្សាច្បាប់ដូចខាងក្រោមបង្ហាញអំពីកំហុសយ៉ាងធ្ងន់ធ្ងរមួយ ដើម្បីការពារកុមារពីការរើសអើងនាពេល អនាគត ដោយយោងទៅតាមកាលៈទេសៈរបស់មាតាបិតារបស់គេ ។

ផ្អែកលើការស្រាវជ្រាវខាងលើ វាអាចត្រូវបានគេនិយាយថាពន្ធនាគារជាច្រើនមិនបានការពារឱ្យ បានគ្រប់គ្រាន់ចំពោះសិទ្ធិដែលត្រូវទទួលបានការការពាររបស់កុមារ ដែលកំពុងរស់នៅជាមួយម្តាយដែល ជាប់ឃុំឃាំង ។ សន្ទុះនៃការបំពារបំពានការមិនយកចិត្តទុកដាក់ ឬ ការធ្វើទុក្ខទោស ក៏ដូចជា ការរើសអើង ប្រឆាំងនឹងកុមារ ផ្តល់ឱកាសឱ្យមានការរំលោភសិទ្ធិ យ៉ាងធ្ងនធ្ងរ ។

### ៣-សិទ្ធិទទួលការអភិវឌ្ឍន៍

"សិទ្ធិអភិវឌ្ឍន៍"របស់កុមារ គឺពិតជាមានលក្ខណៈទូលំទូលាយរួមទាំងសិទ្ធិទទួលការអប់រំ និង សិទ្ធិទទួលបាននូវកំរិតនៃការរស់នៅ ដែលធ្វើឱ្យមានការអភិវឌ្ឍន៍ជាវិជ្ជមានទាំងរូបរាងកាយ និងបញ្ញាព្រម ទាំងផ្សេងៗទៀត ។

នៅពេលដែលគេឱ្យនិយមន័យមិនច្បាស់លាស់ ន័យនៃពាក្យ"អភិវឌ្ឍន៍" អាចមានកត្តាជាច្រើន ដែលជះឥទ្ធិពលដល់ការលូតលាស់រាងកាយ និងបញ្ញារបសលកុមារ ។ អ្នកនិព្វន្តនៅក្នុងច្បាប់កម្ពុជា និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារគួសបញ្ជាក់អំពីអត្ថន័យនៃពាក្យនេះយ៉ាងទូលំទូលាយ ហើយព្រមទាំង ចង្អុលបង្ហាញអំពីសិទ្ធិខ្លះ រួមមាន :

សេរីភាពខាងនយោបាយ, ការធានាអំពីសិទ្ធិមនុស្ស, ការជ្រើសរើសសង្គម, ការគោរព បុគ្គលឯកជន និងការធ្វើឱ្យមនុស្សមានលក្ខណៈល្អប្រសើរ, សមត្ថភាពសង្គម និងសេដ្ឋកិច្ច គឺទាំងអស់នេះត្រូវបានគេពិចារណាថា គឺជាចង្កោមសិទ្ធិដ៏មានសារៈសំខាន់ ដូចជាមធ្យោបាយមួយ និងទិសដៅមួយក្នុងការអភិវឌ្ឍន៍ ។ សិទ្ធិរស់នៅ និងសិទ្ធិអភិវឌ្ឍន៍ដែលមានចែងនៅក្នុងមាត្រា៦មានអត្ថន័យទូលំទូលាយ ដូចជា អភិវឌ្ឍន៍សង្គម អភិវឌ្ឍន៍សីលធម៌ និង សតិបញ្ញា ។[២៥]

នៅពេលពិចារណាឃើញថា តើការពិចារណាដ៏សំខាន់មួយ ដែលគេបានផ្តល់ឱ្យទៅលើការអភិវឌ្ឍន៍នៃកុមារដែលកំពុងរស់នៅក្នុងពន្ធនាគារទាំងនោះ វាជាការចាំបាច់ដើម្បីពិនិត្យឱ្យឃើញថា ការអភិវឌ្ឍន៍នៅក្នុងសង្គម និងមនោសញ្ចេតនាក៏ដូចជាការអភិវឌ្ឍន៍នៃរាងកាយ ។ កុមារទាំងឡាយដែលកំពុងរស់នៅក្នុងពន្ធនាគារមិនមានឱកាសលូតលាស់ដូចគ្នាទៅនឹងការលូតលាស់តាមវ័យរបស់វានោះទេ ។ ការឋិតនៅឯកកោក្រៅពីពិភពលោកក៏ដូចជាក្រៅពីមិត្តភក្តិ និងក្រុមគ្រួសារអាចបង្អាកុមារទាំងនោះពីការរៀនបំពេញមុខងារនៅក្នុងសង្គម ឬទំនាក់ទំនងគ្នាជាមួយអ្នកដ៏ទៃទៀត ។ ឧបសគ្គចំពោះការចូលរៀនក្នុងសាលាធ្វើឱ្យរាំងស្ទះនូវការលូតលាស់ផ្នែកបញ្ញាញាណរបស់កុមារក្នុងខណៈពេលបង្កើនការឯកកោ និងបន្ថយភាពទំនាក់ទំនងគ្នាតាមវ័យ ។ កុមារភាគច្រើនដែលកំពុងរស់នៅក្នុងពន្ធនាគារមានគ្នាលេងតិចតួច ហើយអ្នកដែលពួកគេលេងជាមួយនោះ គឺជាធម្មតាជាកូនរបស់អ្នកជាប់ឃុំឃាំងផ្សេងទៀត ឬជាកូនរបស់មន្ត្រីពន្ធនាគារ ។ ជីវិតនៅក្នុងពន្ធនាគារគឺមានលក្ខណៈតូចចង្អៀត ។ ស្ត្រីភាគច្រើនបានអះអាងក្នុងពេលធ្វើការសំភាសន៍ថា កូនរបស់ពួកគេមិនបានឃើញអ្វីលើសពីជញ្ជាំងពន្ធនាគារនោះទេ ។ នេះអាចប្រៀបបានទៅនឹងការឃុំឃាំងផ្លូវចិត្តរបស់កុមារក៏ដូចជាការឃុំឃាំងផ្លូវកាយរបស់កុមារផងដែរ ។

មាត្រា ២៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ទាមទារឱ្យមានការយកចិត្តទុកដាក់ចំពោះកត្តាផ្សេងទៀតនៃការលូតលាស់របស់កុមារ : តម្រូវការឱ្យមាន"ការអភិវឌ្ឍន៍សីលធម៌ " វិជ្ជមាន ។ វាអាចត្រូវបានគេសន្មតដោយមានហេតុផលថា ពន្ធនាគារគឺមិនមែនជាកន្លែងដ៏ល្អ ដែលធ្វើឱ្យមានកាអភិវឌ្ឍន៍សីលធម៌របស់កុមារបានល្អប្រសើរនោះទេ ។ នៅក្នុងការស្រាវជ្រាវដោយសង្ខេបរបស់គេទៅលើអក្សរសាស្ត្រដែលមានក្រុមគ្រួសារនៃជនជាប់ឃុំឃាំងជានីតិជន អេវិនហាសស្ទីតទ័រ និង ដូរូធៀ ចានណោ សរសេរថា :

> ឪពុកម្តាយដែលត្រូវបានគេដាក់គុកប្រឈមមុខយ៉ាងធ្ងន់ធ្ងរ ចំពោះការបង្កើតតម្លៃដល់កុមារ ។ ក្រៅពីពាក្យសមរម្យ និង អកប្បកិរិយាថ្លៃថ្នូររបស់ឪពុកម្តាយទៅ

---

[២៥] *ច្បាប់ប្រទេសកម្ពុជា និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ដោយជំនួយផ្នែកច្បាប់នៃកម្ពុជា ទំព័រ ៤៧*

កាន់កូនអំពើព្រហ្មទណ្ឌដែលប្រព្រឹត្តដោយឪពុកម្តាយ គឺផ្តល់ពតិមានមិនល្អដែលមានអំណាចដល់កូន ។ កូនរបស់អ្នកជាប់ពន្ធនាគារទាំងនោះ គឺឋិតនៅក្នុងភាពគ្រោះថ្នាក់នៃសកម្មភាពឧក្រិដ្ឋកម្ម និង សកម្មភាពប្រឆាំង នឹងសង្គម ។[២៦]

អ្នកសម្ភាសន៍ជាច្រើនបានចាប់អារម្មណ៍យ៉ាងជាក់លាក់អំពីឥទ្ធិពលអវិជ្ជមានចំពោះការរស់នៅក្នុងពន្ធនាគារក្នុងចំណោមអ្នកជាប់ឃុំឃាំងជាច្រើនដែលមានកូន និង អង្គហេតុដែលកូនអាចឆាប់ទទួលបានតិរិយាបថឧក្រិដ្ឋកម្ម ។ បន្ថែមលើសពីនេះទៀត ម្តាយជាច្រើនមានការភ័យខ្លាចថាអំពើព្រហ្មទណ្ឌរបស់ខ្លួនអាចបណ្តាលឱ្យកូនរបស់គេមានការឈឺចាប់ និងខូចទំនាក់ទំនងរវាងម្តាយនិងកូន ជាពិសេសគឺចំណុចសំខាន់គឺជាការអភិវឌ្ឍន៍របស់កូន ។

តាមរូបនិយម, ការខ្វះម្ហូមអាហារអាចបង្អាក់ការលូតលាស់របស់កុមារយ៉ាងធ្ងន់ធ្ងរ ។ ការខ្វះម្ហូមអាហារចំពោះស្ត្រីមានផ្ទៃពោះ និង កុមារអាចរារាំងការអភិវឌ្ឍន៍នៃការយល់ដឹងផងដែរ ។ ចាប់តាំងពីមានស្ត្រីមានផ្ទៃពោះជាច្រើនម្តាយដែលកំពុងបំបៅកូន និង កុមារទាំងឡាយកំពុងរស់នៅក្នុងពន្ធនាគារគ្មានម្ហូបអាហារ និងចំណីអាហារដែលធ្វើឱ្យធំធាត់ ។ ដូច្នេះហើយ សិទ្ធិរបស់កុមារក្នុងការអភិវឌ្ឍន៍ផ្លូវកាយនិងផ្លូវចិត្តរបស់កុមារឋិតនៅក្នុងភាពគ្រោះថ្នាក់ ។

**៤-សិទ្ធិក្នុងការចូលរួម :**

ទីបញ្ចប់កត្តិកាសញ្ញាអន្តរជាតិរួមមានសិទ្ធិចូលរួម ដែលគ្របដណ្តប់ទៅលើសិទ្ធិរបស់កុមារ ដើម្បីបញ្ចេញទស្សនៈរបស់គេនឹងបានដឹងរាល់បញ្ហាដែលជះឥទ្ធិពលមកលើខ្លួនរបស់គេសិទ្ធិទទួលបាន នឹងស្វែងរកពត៌មាន និងសិទ្ធិចូលរួមសមាគម ។

ផ្នែកមួយនៃសិទ្ធិរបស់កុមារដើម្បីចូលរួម គឺមានឱកាស ដើម្បីជូនមតិ និងបានដឹងគ្រប់រឿងហេតុដែលទាក់ទងនឹងខ្លួនរបស់គេ ។ កុមារីអាយុ ៧ឆ្នាំ បានសំភាសន៍ដោយអ្នកនិពន្ធបាននិយាយថា គ្មាននណាម្នាក់និយាយទៅកាន់នាងអំពីទីកន្លែងណាដែលនាងគួររស់នៅ ។ ក្នុងកំឡុងពេលសំភាសន៍នាងបាននិយាយដដែលៗថា នាងចង់ចាកចេញពីពន្ធនាគារទៅរស់នៅជាមួយបងស្រីរបស់នាង ។ កុមារីនោះមិនបានដឹងផងដែរថា ហេតុអ្វីបានជាម្តាយរបស់នាងចិតនៅក្នុងពន្ធនាគារ ឬរយៈពេលប៉ុន្មានដែលនាងនឹងចិតនៅក្នុងពន្ធនាគារជាមួយម្តាយរបស់នាង ។ សិទ្ធិរបស់កុមារីដើម្បីពិភាក្សា ឬទទួលពតិមានអំពីកាលៈទេសៈផ្សេងៗទៀត

---

[២៦] *ដកស្រង់ពី "ការស្រាវជ្រាវសង្ខេប : ក្រុមគ្រួសាររបស់ជនជាប់ចោទពេញវ័យ" ដោយ* ***អេវិន បាសស្ទីតទ័រ និង ជូរធៀ ចានណា*** *រក្សាសិទ្ធិដោយ អាហារូបករណ៍សំរាប់ស្រាវជ្រាវពន្ធនាគារ ១៩៩៣ ។*

របស់នាងហាក់ដូចជាមិនត្រូវបានគេយកចិត្តទុកដាក់ដរាបណាវាមិនត្រូវបានគេកំណត់ថា នេះគឺជាផលប្រយោជន៍ដ៏ប្រសើរបំផុតរបស់នាង។ យោងទៅតាមការសំភាសរបស់ម្តាយកុមារី វាបង្ហាញថា កូនស្រីនាងចិតក្នុងពន្ធនាគាដោយការខ្វះខាតជំរើសដែលអាចធ្វើទៅបាន "ជាជាងផលប្រយោជន៍ល្អបំផុតរបស់នាងផ្ទាល់"។ គំនិតរបស់កុមារីអំពីស្ថានភាពរស់នៅរបស់នាងមិនដែលបានស្នើរសុំ ហើយគំនិតទាំងនោះមិនដែលគេយកមកពិចារណារ ។

យោងទៅតាម "សិទ្ធិទទួលបាននិងស្វែងរកពតិមាន" និង "សិទ្ធិចូលជាសមាគម" កុមារដែលកំពុងរស់នៅក្នុងពន្ធធនាគារគឺស្ថិតនៅក្នុងគុណវិបត្តិគួរអោយចាប់អារម្មណ៏ ។ អង្គហេតុនិមួយៗកំនត់ការចូលរួមក្នុងពិភពខាងក្រៅហាមឃាត់ពួកគេពីការទទួលពតិមាន រឺចូលរួមក្នុងសកម្មភាពផ្សេងៗក្នុងមធ្យោបាយដែលគេអាចទទួលបានតាមវ័យ។ បើយើងសន្មត់ថាការ "ចូលរួមសមាគម" រួមមាន ក្លិប សាលារៀន ក្រុម ក្រុមកីឡា និង អង្គការដទៃទៀត រឺ ក្រុម ក្រៅផ្លូវការ ដូចជាការលេងល្បែងកំសាន្តជាមួយអ្នកជិតខាង ។ ទោះជាយ៉ាងណាក៏ដោយ កុមារដែលជាប់ក្នុងពន្ធធនាគារកំរមានឱកាសចូលរួមក្នុងបែបនេះឡើយ ។ រាល់រចនាសម្ព័ន្ធជីវិតក្នុងពន្ធនាគារ និងការរិតត្បិតជីវិតនៅក្រៅពន្ធធនាគារបានរារាំងយ៉ាងខ្លាំងចំពោះការគោរពតាមសិទ្ធិចូលរួមរបសកុមារទាំងនេះ។

## ខ. ការពិចារណារលើការស្រាវជ្រាវរកឃើញដោយយោងទៅតាម ច្បាប់អន្តរជាតិ និង ច្បាប់របស់ប្រទេសកម្ពុជា

នៅក្នុងឧទាហរណជាច្រើន ករណីសិក្សាជាច្រើនផ្តល់ឧទាហរណថាតើច្បាប់ប្រទេសកម្ពុជានិងច្បាប់អន្តរជាតិកំពុងត្រូវបានគេអនុវត្តចំពោះមាតា កុមារ និងស្ត្រីមានផ្ទៃពោះដែលកំពុងរស់នៅក្នុងពន្ធធនាគារ ។ ការវិភាគដូចតទៅនេះនឹងពិភាក្សាទៅលើច្បាប់គោលនយោបាយ និង និតិវិធីដ៏មានសារៈប្រយោជន៍បំផុតនីមួយៗដែលទាក់ទងទៅនឹងការអនុវត្តន៏របស់វាដូចដែលបានរកឃើញក្នុងអំឡុងពេលធ្វើការស្រាវជ្រាវ ។

ច្បាប់ជាតិ និង អន្តរជាតិជាច្រើនត្រូវបានគេពិនិត្យមើលដើម្បីបញ្ចូលទៅក្នុងការស្រាវជ្រាវ នេះ ។ ការពិភាក្សាស៊ីជំរៅនៃច្បាប់នីមួយៗមានដូចតទៅ :

១. សារាចរលេខ ១៥សខក ស្តីអំពីការទំនាក់ទំនងទៅនឹងជនជាប់ឃុំជាស្ត្រី និងជនជាប់ពន្ធធនាគារដែលមានកូនតូចនៅជាមួយ (១៩៩៥)។

២. សេចក្តីប្រកាសលេខ ២១៧ ស្តីអំពីការគ្រប់គ្រងពន្ធធនាគារ (មីនា ១៩៩៨)

៣. និតិវិធីនិងបញ្ញត្តិនៃពន្ធធនាគារប្រទេសកម្ពុជា( ផ្អែកលើសេចក្តីប្រកាសលេខ ២១៧ ចុះខែ មិនា ១៩៩៨) និងបទដ្ឋានសេវាសុខភាពពន្ធធនាគារ ( ឆ្នាំ ២០០០)
៤. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ( ១៩៩៣)
៥. កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិកុមារ ( ១៩៨៩)
៦. បទដ្ឋានអប្បបរមារបស់អង្គការសហប្រជាតិសំរាប់ការប្រព្រឹត្តិមកលើជនជាប់ពន្ធនាគារ ( ១៩៥៥)
៧. បទដ្ឋានអប្បបរមារបស់អង្គការសហប្រជាតិសំរាប់គ្រប់គ្រងអនីតិជន (បទបញ្ញត្តិប៉េកាំង ១៩៨៥)

បទបញ្ញត្តិច្បាប់ជាច្រើនដ៏ទៃទៀតដែលត្រូវបានគេពិគ្រោះក្នុងអំឡុងពេលធ្វើការស្រាវជ្រាវមានដូចតទៅ:

១. កតិការសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (១៩៦៦ កម្ពុជាអោយសច្ចាប័ណ្ណ ១៩៩២) មាត្រា ១០.២ ។
២. គោលការណ៏ណែនាំរបស់អង្គការសហប្រជាជាតិសំរាប់ការការពារអនីតិជនដែលបានប្រព្រឹត្តិបទល្មើស (គោលការណ៏ណែនាំ រីយ៉ាត ១៩៩០) មាត្រា ១ ២ ១១ ១២ ១៤ ១៦ ១៩ ២០ ២៤ និង ៤៥ ។
៣. បទបញ្ញត្តិរបស់អង្គការសហប្រជាជាតិសំរាប់ការពារអនីតិជនដែលត្រូវបានគេរំលោភសិទ្ធិសេរីភាព ( ១៩៩០) មាត្រា ២ ៣ ១២ ១៣ ២០ ៣៧ ៣៨ ៤៩ និង ៥៩ ។
៤. ច្បាប់ប្រទេសកម្ពុជាស្តីអំពីអាពាហ៏ពិពាហ៏និងគ្រួរសា មាត្រា ១១៥ និង ១១៩ ។
៥. សេចក្តីប្រកាសពិភពលោកស្តីអំពីការរស់នៅ និង ការការពារនិងការអភិវឌ្ឍន៏របស់កុមារ (ពិភពលោកដាក់ជូនសំរាប់កុមារ១៩៩០) និងគំរោងសកម្មភាពសំរាប់ការអនុវត្តន៏សេចក្តីប្រកាសពិភពលោកស្តីអំពីការរស់នៅការការពារ និងការអភិវឌ្ឍន៏របស់កុមារក្នុងទសវត្ស ១៩៩០ ។

**១. សារាចរលេខ១៥ស.ខ.ក ស្តីអំពីការទំនាក់ទំនងទៅនឹងជនជាប់ឃុំជាស្ត្រី និងជនជាប់ពន្ធនាគារដែលមានកូនតូចនៅ ជាមួយ**

សារាចរលេខ ១៥ ត្រូវបានចេញនៅថ្ងៃទី ២២ ឧសភា ១៩៩៥ ដោយក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន (មូសាលរី)។[២៧] សារាចរនេះត្រូវបានបង្កើតឡើងផ្អែកលើមូលដ្ឋាននៃ "ការប្រជុំរបស់អន្តរក្រសួងជាមួយនឹងតំណាងយូនីសេហ្វ" ដែលប្រព្រឹត្តិទៅនៅថ្ងៃទី ២៥ កក្កដា ១៩៩៤ នៅក្រសួងយុត្តិធម ។ ខ្លឹមសារនៃសារាចរនេះចង្អុលបង្ហាញថា ការប្រជុំនេះនិងលទ្ធផលនៃឯកសារត្រូវបានបង្កើត ឡើងឆ្លើយតបទៅនឹងកំនើនទារក និងកុមារដែលកំពុងរស់នៅក្នុងពន្ធនាគារជាមួយម្តាយដែលជាប់ឃុំឃាំង ។ នៅក្នុងពាក្យនៃសារាចរនេះបានបង្កើតភាពលំបាកដល់ពន្ធធនាគារ ។ ម្យ៉ាងវិញទៀតកុមារទាំងនោះមិនអាចនាំទៅរកភាពថ្លៃថ្នូរសមរម្យក្នុងជីវិត។

សារាចរលេខ ១៥ ចែងថាៈ

ក្នុងគោលបំណងការពារកុមារ និង អនុវត្តកតិកាសញ្ញាស្តីពីសិទ្ធិកុមារឱ្យបានត្រឹមត្រូវក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជននឹងមានការទទួលខុសត្រូវបំបែកកុមារទាំងនោះចេញពីម្តាយរបស់គេដើម្បីអោយគេរស់នៅជាមួយក្រុមគ្រួសារ បងប្អូន រឺ នៅក្នុងមជ្ឈមណ្ឌលសង្គ្រោះដោយយោងតាមកិច្ចព្រមព្រៀងរបស់មាតា និងតាមកាលៈទេសៈជាក់ស្តែង។

"ន័យរបស់កាលៈទេសៈជាក់ស្តែង " មិនត្រូវបានគេអោយនិយមន័យច្បាស់លាស់ទេ ទោះបីជាយ៉ាងណាក៏ដោយវាបើកចំហរ ដើម្បីអោយមានការបកស្រាយដ៏ទូលំទូលាយដល់ភាគីទាក់ទិន។ ជាការពិតណាស់វាមិនអាចអនុវត្តសារាចរបានដោយគ្មានអោយនិយមន័យពិតប្រាកដនៃពាក្យ "កាលៈទេសៈជាក់ស្តែង" និងអត្ថន័យអ្វីដែលត្រូវបន្ថែម។

បន្ទាប់មកទៀតសារាចរនេះចែងថា ការិយាល័យអធិការកិច្ចនៃក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន នឹងអនុវត្តវិធានការខាងលើដោយចាត់វិធានការរួមមាន :

១- រក្សាទំនាក់ទំនងរវាងព្រះរាជអាជ្ញាខេត្តក្រុងនិងពន្ធធនាគារ
២- សិក្សាកាលៈទេសៈរបស់កុមារនិងសហប្រតិបត្តិការជាមួយមន្ត្រីពន្ធនាគារដើម្បីរៀបចំកម្មវិធីដ៏សមរម្យមួយក្នុងការថែទាំ "ដោយយោងតាមស្ថានភាពជាក់ស្តែង"
៣- ធ្វើការជាមួយមន្ត្រីពន្ធធនាគារ រឺ បុគ្គលិកជាស្ត្រី ដើម្បីឱ្យកុមារទាំងនោះអាចស្នាក់នៅក្រៅពន្ធធនាគារ ។

---

[២៧] *ឈ្មោះរបស់ក្រសួងត្រូវបានគេប្តូរទៅជាក្រសួង សង្គមកិច្ច ការងារ វិជ្ជាជីវៈ និងយុវនីតិសម្បទា ថ្ងៃទី ១៧ មិថុនា ១៩៩៩។ ពាក្យក្រសួងនៅក្នុងអត្ថបទនេះនឹងសំដៅទៅលើអក្សរកាត់ មូសាសវី។*

៤- ធ្វើការទាក់ទងជាមួយស្ថានបន័ផ្សេងៗដូចជាមន្ទីរពេទ្យ រដ្ឋអំណាចមូលដ្ឋាន និង សាលារៀន ដើម្បីជួយក្នុងការបង្ហាញពីតំរូវការរបស់កុមារទាំងនោះ។

វាហាក់ដូចជាគ្មានការខំប្រឹងប្រែងធ្វើឡើង ដើម្បីពិនិត្យមើលកាលៈទេសៈរបស់មាតានីមួយៗនិង កុមារទាំងឡាយ និងបង្កើតកម្មវិធីឱ្យបានសមរម្យក្នុងកិច្ចសហប្រតិបត្តិការណ៏ជាមួយប្រធានពន្ធធនាគារ ដូចចំនុចទី២តំរូវឱ្យមាន ។ ក្នុងខណៈនេះការខ្វះមន្ត្រីពន្ធធនាគារជាស្ត្រីបង្កើតជាឧបសគ្គមួយក្នុងការអនុវត្តន៏ ចំនុចទី៣ដូចដែលមានចែងខាងលើ ។ ពន្ធធនាគារជាច្រើនដែលរួមមាននៅក្នុងការសិក្សានេះ មានបុគ្គលិកស្ត្រី ជាមធ្យម២នាក់នៅក្នុងពន្ធធនាគារនីមួយៗ (ក្នុងចំនោមបុគ្គលិកពី ៤០-៩០ នាក់) រួមទាំងជនទាំងឡាយ ដែលទាក់ទងនឹងការងាររដ្ឋបាល រឺ សុខភាព ។ ក្នុងចំណោមពន្ធធនាគារទាំង៧ដែលមានក្នុងការសិក្សានេះ សរុបរួមមានបុគ្គលិកជាស្ត្រីចំនួន ១៤នាក ។ ក្នុងចំណោមស្ត្រីទាំងនេះមានតែ៤នាក់ប៉ុណ្ណោះដែលមាន ដំណែងជាអ្នកគ្រប់គ្រងស្ត្រីដែលជាប់ពន្ធធនាគារ (នៅក្នុងពន្ធធនាគារ ៣ : បាត់ដំបង ស៊ីស៊ី២ និង កំពង់សោម) មាន៣នាក់បន្ថែមទៀតមានតួនាទីជាអ្នកយាមពន្ធនាគារដែលមានការទាក់ទងជាមួយជនជាប់ ឃុំឃាំងជាស្ត្រី ។ នៅសល់៧នាក់ទៀត មាន៣នាក់ជាអ្នកធ្វើការផ្នែកសុខភាព ម្នាក់ជាចុងភៅ និង ៣នាក់ទៀតជាមន្ត្រីរដ្ឋបាល។ ភាពខ្វះខាតមន្ត្រីពន្ធធនាគារជាស្ត្រី ដូចនេះធ្វើឱ្យវាគ្មានហេតុផលនិងសង្ឃឹមថា "មានកិច្ចសហប្រតិបត្តិការនៃមន្ត្រី រឺ បុគ្គលិកពន្ធធនាគារជាស្ត្រី" ក្នុងការយកកុមារទាំងនោះអោយនៅក្រៅ ពន្ធធនាគារ។

ក្រៅពីសំណើរបស់នាយកពន្ធធនាគារដែលម្តាយទុកកូនរបស់ពួកគេជាមួយអង្គការក្រៅរដ្ឋាភិបាល រឺ មជ្ឈមណ្ឌលកុមារកំព្រានោះហាក់ដូចជាមានការសំរបសំរួលបន្តិចបន្តួចនៃការរក្សាកូនទាំងនោះ ហើយគ្មាន ការកំនត់ថាតើភ្នាក់ងារថែរក្សាមានសមត្ថកិច្ច រឺក៏ស្របច្បាប់ ។ ករណីសិក្សាជាច្រើនបង្ហាញផងដែរថា ការខក ខានមិនបានបង្កើតសម្ព័ន្ធមិត្តរវាងពន្ធធនាគារ និងស្ថាប័នផ្សេងទៀតដូចជា សាលារៀន រឺ មន្ទីរពេទ្យដែល ធានាបានថា តំរូវការរបស់កុមារទាំង នោះត្រូវបានបំពេញ ។

សារាចរនេះចែងបន្តទៀតថា "វិធីសាស្ត្រនៃការអនុវត្តន៏ " ដែលត្រូវបានគេប្រើក្នុងការអនុវត្តន៏បទ បញ្ជាទាំងនេះ :"មន្ត្រីនិងបុគ្គលិកដោយមានកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីពន្ធធនាគារជាស្ត្រី និងធ្វើការខិត ខំប្រឹងប្រែងដើម្បីធ្វើការពិគ្រោះជាមួយជនជាប់ឃុំបណ្តោះអាសន្ន និងជនជាប់ពន្ធធនាគារនៅពេលមាន ផ្ទៃពោះនិងមានកូនមកជាមួយ "។ សារាចរចែងយ៉ាងច្បាស់ថា ការឱ្យយោបល់ និងបញ្ចូលការពិនិត្យមើល កាលៈទេសៈក្រុមគ្រួសាររបស់កុមារ និងជំនួយក្នុងការរៀបចំឱ្យកុមាររស់នៅក្រៅពន្ធធនាគារ ។ ក្នុងខណៈ

នេះដែរការស្រាវជ្រាវរកឃើញបង្ហាញថាមានស្ត្រីតិចតួចទទួលបានទំរង់នៃការ " ពិគ្រោះយោបល់ " ទាក់ទងទៅនឹងកុមារទើបនឹងកើត រឺ កំពុងរស់នៅជាមួយគេក្នុងខណៈពេលដែលពួកគេស្ថិតក្នុងពន្ធនាគារ ។

វិធីសាស្ត្រក្នុងការអនុវត្តន៍ បង្ហាញឱ្យឃើញផងដែរថា កុមារទាំងឡាយនឹងត្រូវបានបំបែកចេញពីម្តាយក្នុងពន្ធនាគារនៅពេលមានអាយុដល់ ៦ឆ្នាំ ឬឋិតនៅក្រោម "កាលៈទេសៈចាំបាច់ ពិសេសច្រើនទៀត" មុនដល់អាយុ៦ឆ្នាំ ។ ហេតុផលក្នុងការបំបែកកូនពីម្តាយនៅពេលមានអាយុ៦ឆ្នាំ គឺមិនមានលក្ខណៈច្បាស់លាស់ទេ ។ គ្មានបញ្ញត្តិចែងគាំទ្រ ឬយោងនៅក្នុងអត្ថបទនៃសារាចរចំពោះលក្ខខណ្ឌទាំងនេះទេ ។ ទោះជាយ៉ាងណាក៏ដោយគំនិតនេះមិនត្រូវបានគេអនុវត្តទេ ។

យោងទៅតាមវិធានអនុវត្ត ការបំបែកកុមារចេញពីឪពុកម្តាយជាប់ពន្ធនាគារ ឬ ចេញពីម្តាយដែលជាប់ឃុំឃាំងរបស់គេតំរូវអោយ" កិច្ចព្រមព្រៀងរបស់មាតាដោយមានការអនុញ្ញាតិពី ពន្ធនាគារ ថាតើនរណាហើយទីកន្លែងណាដែលកុមារត្រូវបញ្ជូនឱ្យថែរក្សា " ។ សៀវភៅរបស់អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ១៩៩៨ ស្តីពីច្បាប់របស់កម្ពុជា និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ការសិក្សាប្រៀបធៀបមួយ និយាយលំអិតពីបញ្ហាជាច្រើនដែលទាក់ទងទៅនឹងសារាចរ លេខ ១៥" សារាចរនោះបានអធិប្បាយអំពីអតិបរិមានៃដំណើរការការពារសំរាប់មាតាដែលត្រូវបានគេដាក់ពន្ធនាគារ ដោយអនុញ្ញាតឱ្យមាតាមានសិទ្ធិបញ្ចេញមតិរបស់ខ្លួនក្នុងការធ្វើសេចក្តីសំរេចអំពីទីកន្លែងដែលកូនរបស់នាងនឹងរស់នៅ ។ ទោះបីជាយ៉ាងណាក៏ដោយតើនេះជាឱកាសពិតប្រាកដដែលត្រូវបានគេផ្តល់ឱ្យដោយរដ្ឋអំណាចក្នុងការធ្វើការ ពិចារណាហើយត្រូវការវាយតំលៃឬទេ [២៨] ។

ពត៌មានដែលប្រមូលបានពីការសំភាសន៍ ដែលត្រូវបានគេធ្វើឡើងសំរាប់របាយការណ៍នេះបានបង្ហាញថា បុគ្គលិកពន្ធនាគារពិតជាគោរពទៅតាមតម្រូវការនៃការយល់ព្រមរបស់មាតាដើម្បីយកកូនរបស់នាងចេញពីពន្ធនាគារ ។ ទោះជាយ៉ាងណាក៏ដោយអ្នកសំភាសន៍បានរាយការណ៍ថា បុគ្គលិកពន្ធនាគារបានស្នើសុំឱ្យកូនរបស់គេរស់នៅទីកន្លែងផ្សេង ប៉ុន្តែគ្មានស្ត្រីណាម្នាក់បានរាយការណ៍ថា មានការកៀបសង្កត់ដើម្បីបោះបង់កូនរបស់ខ្លួននោះទេ ។ ផ្ទុយទៅវិញនាយកពន្ធនាគារ និងបុគ្គលិកពន្ធនាគារទាំងអស់បាននិយាយថាពួកគេកំរឱ្យ "គំនិត" ទៅលើស្ត្រីអំពីទីកន្លែងណាដែលកូនរបស់គេគួររស់នៅនឹងថាគេមិនបានបង្ខំស្ត្រីឱ្យប្រគល់កូនរបស់គេទៅភ្នាក់ងារផ្សេងទៀតនោះទេ ។ នាយកពន្ធនាគារខ្លះបានធ្វើសេចក្តីថ្លែងការណ៍ ដោយបង្កប់ន័យថាស្ត្រីម្នាក់នឹងគ្មានជំរើស ប៉ុន្តែពេលណាមួយត្រូវតែប្រគល់កូនរបស់គេនៅពេលកូនរបស់គេមានអាយុដល់

---

[២៨] *ច្បាប់ប្រទេសកម្ពុជា និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ដោយជំនួយផ្នែកច្បាប់ ទំព័រ ៨១ ។*

ក៏វិតណាមួយ ( ការកំណត់អាយុផ្សេងៗពីគ្នាដោយយោងតាមនាយកពន្ធនាគារ ។ ការរៀបចំនេះចាប់ពីកូនឈប់បៅដោះរហូតដល់កុមារអាយុ ១០ឆ្នាំ ។

ការសិក្សាអ្នកនិពន្ធនៃអង្គការជំនួយផ្នែកច្បាប់បានគូសបញ្ជាក់ផងដែរថា "សារាចរនេះមានលក្ខណៈមិនគ្រប់គ្រាន់ក្នុងការផ្តល់ឱកាសឱ្យតុលាការពិនិត្យមើលសេចក្តីសំរេចចំពោះការបំបែកកុមារចេញពីឪពុកម្តាយរបស់ពួកគេ ។ សារាចរទទួលស្គាល់សារៈសំខាន់នៃសេចក្តីសំរេចដើម្បីបំបែកកូនពីមាតាបីតារបស់គេដែលធ្វើឡើងដោយសមត្ថកិច្ច អ្នកធ្វើការក្នុងសង្គម ទោះជាយ៉ាងណាក៏ដោយវាមិនបានបង្ហាញថា មានការត្រួតពិនិត្យមើល ឬ ហ៊ឹកហ៊ឺនដល់មន្ត្រីទទួល ខុសត្រូវនោះទេ" [២៩] ។

បន្ថែមលើសពីនេះទៀត មធ្យោបាយក្នុងការអនុវត្តន៍ តម្រូវឱ្យអ្នកធ្វើការក្នុងសង្គមសំរបសំរួលថែរក្សាទំនាក់ទំនងរវាង ឪពុកម្តាយដែលត្រូវបានគេដាក់គុក ឬឃុំខ្លួន និងកូនរបស់គេដោយ មិនបានគិតថាកូនរបស់គេរស់នៅកន្លែងណានោះទេ ។ ក្នុងករណីជាច្រើនមាននៅក្នុងការសិក្សានេះ អ្នកធ្វើការក្នុងសង្គមមិនបានបំពេញតួនាទីដ៏យ៉ាងសកម្មក្នុងការរក្សាទុកកុមារឱ្យនៅក្រៅពន្ធនាគារ ឬ ចាត់ចែងចំពោះកុមារដែលកំពុងរស់នៅក្រៅពន្ធនាគារឱ្យជួបសួរសុខទុក្ខជាមួយម្តាយរបស់គេនោះទេ ។ គ្មានពន្ធនាគារណាមួយជួលមនុស្សឱ្យធ្វើការទាក់ទងជាមួយនឹងអ្នកធ្វើការងារក្នុងសង្គមទេ មានតែបុគ្គលិកពន្ធនាគារតែប៉ុណ្ណោះបានរាយការណ៍អ្នកធ្វើការក្នុងសង្គមមកពិនិត្យមើលពន្ធនាគារ ។ អ្នកធ្វើការក្នុងសង្គមទាំងនេះគឺជាអ្នកតំណាងឱ្យអង្គការក្រៅរដ្ឋាភិបាលនៃអង្គការជំនួយផ្នែកច្បាប់កម្ពុជា ។ មាតាដែលត្រូវបានគេសំភាសន៍ចំនួន ១០ នាក់សំរាប់ការសិក្សានេះមានកូនម្នាក់ ឬច្រើននាក់កំពុងរស់នៅក្រៅពន្ធនាគារ ។ ហើយមានតែស្ត្រីម្នាក់ទេបាននិយាយថា កូនរបស់នាងបានមកសួរសុខទុក្ខនាងជាប្រក្រតី ។ ស្ត្រី៥នាក់ក្នុងចំណោមស្ត្រីទាំងនោះបាននិយាយថា គេមិនដែលជួបកូនរបស់គេដែលរស់នៅក្រៅពន្ធនាគារនោះទេ ។ នេះអាចបណ្តាលមកពីតម្លៃនៃការធ្វើដំណើរ ឬឧបសគ្គផ្សេងៗទៀត ។ ឧទាហរណ៍ ក្នុងរបាយការណ៍អង្គការ លីកាដូ ឆ្នាំ ២០០១ ស្តីពីសិទ្ធិមនុស្សនៅក្នុងពន្ធនាគារបាននិយាយថា នៅពេលពួកគេមកដល់ពន្ធនាគារសមាជិកក្រុមគ្រួសារជាច្រើនអាចត្រូវតែបង់ ប្រាក់ឱ្យមន្ត្រីពន្ធនាគារ ដើម្បីបានជួបបងប្អូនដែលបានជាប់ឃុំក្នុងពន្ធនាគារ [៣០] ។

### ២) សេចក្តីប្រកាសលេខ ២១៧ ស្តីអំពីការគ្រប់គ្រងពន្ធធនាគារ

---

[២៩] *ច្បាប់ប្រទេសកម្ពុជា និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ដោយជំនួយផ្នែកច្បាប់ ទំព័រ ៨១ ។*

[៣០] *លីកាដូ " បញ្ហាសិទ្ធិមនុស្ស និង ពន្ធនាគារៈ ខែមករា- ខែធ្នូ ២០០១" ក្រុងភ្នំពេញ ២០០២ ។*

សេចក្តីប្រកាសលេខ ២១៧ ចេញនៅថ្ងៃទី ៣១ មីនា ១៩៩៨ ដោយក្រសួងមហាផ្ទៃ មានផ្នែកសំខាន់ៗដែលទាក់ទងទៅនឹងការអនុវត្តន៏ចំពោះម្តាយដែលមានកូនខ្ចីនៅជាមួយ និងស្ត្រីមានផ្ទៃពោះនៅក្នុងពន្ធនាគារ ។ នេះមានសារៈសំខាន់ដើម្បីកត់សំគាល់ថា ឋានានុក្រមនៃច្បាប់របស់កម្ពុជា សេចក្តីប្រកាសមានអទិភាពលើសារាចរ [៣១] ។

ជាច្រើនដងបុគ្គលិកពន្ធនាគារមិនបានដឹងពីសេចក្តីប្រកាស ឬគោលការណ៏ជាមូលដ្ឋានរបស់វាទេ ។ នាយកពន្ធនាគារចំនួន៤ក្នុងចំណោមនាយកពន្ធនាគារទាំង៧នាក់ដែលត្រូវបានគេធ្វើសំភាសន៏ ក៏ដូចជាបុគ្គលិកម្នាក់ទៀតដឹងថាបទបញ្ញត្តិកំពុងតម្រូវឱ្យជនជាប់ឃុំ និងទណ្ឌិតមានផ្ទៃពោះត្រូវបានយកទៅមន្ទីរពេទ្យដើម្បីសំរាលបុត្ររបស់គេ ។ ៤នាក់ក្នុងចំណោមមន្ត្រីរដ្ឋបាល៧នាក់បានធ្វើសេចក្តីយោងទៅនឹងសេចក្តីប្រកាសដែលចង្អុលបង្ហាញអំពីចំណេះដឹងរបស់គេ ទោះបីជានាយកពន្ធនាគារខ្លះមិនបាននិយាយលំអិតឱ្យបានជាក់លាក់ក៏ដោយ ។ ការស្រាវជ្រាវនោះរកឃើញថា មានការខ្វះខាតការយល់ដឹងជាទូទៅនៃសេចក្តីប្រកាសលេខ ២១៧ ។ ការយល់ដឹងពីច្បាប់មិនគ្រប់គ្រាន់ ដូច្នេះ ធ្វើឱ្យវាមិនអាចពិនិត្យមើលការអនុវត្តន៏ទូទៅបានល្អប្រសើរនោះទេ ។

ផ្អែកទៅតាមជនជាប់ឃុំមានផ្ទៃពោះ មាត្រា ១៨ ក នៃសេចក្តីប្រកាសចែងថា បុគ្គលិកពន្ធនាគារត្រូវតែធ្វើកិច្ចការដូចតទៅនេះ :

១- ផ្តល់ជំនួយពិសេសដល់ស្ត្រីជាប់ឃុំឃាំង មុននិងក្រោយពេលសំរាលកូនរួច ។
២- អនុញ្ញាតឱ្យស្ត្រីជាប់ឃុំឃាំង ទៅសំរាលកូននៅក្រៅពន្ធនាគារ ឬ នៅមន្ទីរពេទ្យ ។ ប្រសិនបើនាងសំរាលកូនក្នុងពន្ធនាគារ អ្នកធ្វើការផ្នែកថែទាំសុខភាពត្រូវតែចូលរួមចំណែក ឬពិនិត្យសុខភាពម្តាយនិងទារកទើបនឹងកើតភ្លាមៗ ដូចដែលអាចធ្វើទៅបាន ។
៣- ធានាថា ប្រសិនស្ត្រីដែលសំរាលកូនក្នុងពន្ធនាគារ សំបុត្រកំណើតរបស់ទារក មិនទាក់ទងទៅនឹងកន្លែងកំណើតនៅពេលចុះបញ្ជីកំណើត ។[៣២]

---

៣១ *យោងទៅតាម គោលការណ៏នៃណាំទាក់ទងទៅនឹងច្បាប់ព្រហ្មទណ្ឌកម្ពុជា សេចក្តីក្រាស គឺចេញដោយ ប្រធានក្រសួងមួយ ឬច្រើន ដើម្បី រៀបចំ និង គ្រប់គ្រងសកម្មភាពនៃនាយកដ្ឋាន ឬផ្នែកនិមួយៗ នៅក្រោមចំណុះក្រសួង( ទំព័រ ៤៣) ។ សារាចរ គឺចេញដោយក្រុមប្រឹក្សារដ្ឋ មន្ត្រី សាម៉ីក្រសួងឬស្ថាប័នរដ្ឋបាល ដើម្បី "ផ្តល់ការបំភ្លឺបញ្ហាច្បាប់មួយចំនួន ការនៃណាំ ឬលក្ខខណ្ឌរដ្ឋបាល"( ទំព័រ ៤៤) ។*

៣២ *ចំណុចនេះត្រូវបានចែងផងដែរក្នុងមាត្រា ២២ នៃអនុក្រិត្យរបស់កម្ពុជា "ចុះថ្ងៃទី ២៩ ធ្នូ ២០០០" ។ ដូចដែលបានបកប្រែដោយយូនីសេហ្វ មាត្រា ២២ ចែងថា: "ក្នុងករណីទណ្ឌិតសំរាលកូន ទីកន្លែងកំណើតរបស់ទារក នឹងជាទីលំនៅរបស់ឪពុកឬម្តាយ" ។*

ផ្អែកទៅលើសារាចរលេខ១៥ បញ្ហាមួយក្នុងចំណោមបញ្ហាច្រើនក្នុងមាត្រា១៨ ក នៃសេចក្តីប្រកាសលេខ២១៧ គឺមានខ្វះភាពច្បាស់លាស់ ។ ក្នុងចំណុចទីពីរ និងទី៣ ដែលបាននិយាយមកខាងលើ វាគ្មាននិយមន័យនៃពាក្យកាលៈទេសៈដែលស្ត្រីត្រូវបានអនុញ្ញាតឱ្យសំរាលកូននៅក្នុងពន្ធនាគារ (ដោយហេតុដូចនេះមានការរំលោភយ៉ាងច្បាស់នៅក្នុងអត្ថន័យចំណុចទី២ដែលស្ត្រីត្រូវ តែបានអនុញ្ញាតសំរាលកូននៅក្នុងមន្ទីរពេទ្យ) ។ ទាំងនេះវាលំបាកកំណត់ថាតើក្នុងករណីស្ត្រីសំរាលកូននៅក្នុងពន្ធនាគារ គឺជាការរំលោភសេចក្តីប្រកាស ។ ស្រដៀងគ្នានេះដែរ ការប្រើពាក្យដែលមិនបានឱ្យនិយមន័យដោយយោងតាម "ជំនួយពិសេស" មុន ឬ ក្រោយសំរាលកូនអនុញ្ញាតឱ្យមានការបកស្រាយយ៉ាងទូលំទូលាយ និងមានឥទ្ធិពលក្នុងការខ្វះខាតការថែរក្សាសមរម្យ ចំពោះស្ត្រីមានផ្ទៃពោះហើយនឹងទារក ។

ចំណុចទី ១ នៃមាត្រា ១៨ ក ដែលបានបង្ហាញមកខាងលើ បញ្ជាក់យ៉ាងច្បាស់ថា "ការការពារពិសេសមួយ" ឬ "ជំនួយពិសេស" គួរត្រូវបានផ្តល់ឱ្យចំពោះស្ត្រីមានផ្ទៃពោះដោយផ្អែកតាមសេចក្តីប្រកាស់ដែលមានចែងអំពីសិទ្ធិនេះចំពោះស្ត្រីមានផ្ទៃពោះជាប់ឃុំឃាំង ។ ទោះជាយ៉ាងណាក៏ដោយ "ជំនួយពិសេស" យ៉ាងតិចតួចហាក់ដូចជាត្រូវបានផ្តល់ឱ្យចំពោះស្ត្រីជាប់ឃុំមុនពេលឬក្រោយពេលសំរាលកូន ។ បន្ថែមលើសពីនេះទៀត មាតាខ្លះមិនត្រូវបានគេផ្តល់ឱកាសឱ្យសំរាលកូននៅខាងក្រៅពន្ធនាគារ ដោយមិនយោងទៅតាមមាត្រា១៨ ក ចំណុច២ ដែលទាមទារឱ្យអនុវត្តសិទ្ធិនេះ ។

ការមិនគោរពតាមចំណុច ៣ ដែលកំណត់ថាសំបុត្រកំណើតរបស់កុមារមិនអាចចុះក្នុងពន្ធនាគារជាកន្លែងកំណើត ដូចដែលបានពិភាក្សារួចមកហើយនៅក្នុងផ្នែកខាងលើ ស្តីពីសិទ្ធិការពាររបស់កុមារ ។

បុគ្គលិកពន្ធនាគារហាក់ដូចជាអនុវត្តមាត្រា១៥ ដែលមានចំណងជើងថា "ធ្វើការ" ដែលបានចែងថា ស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារ "នឹងមិនត្រូវបានគេបង្ខំអោយធ្វើការក្នុងរយៈពេល៩០ថ្ងៃមុន រឺ ៩០ថ្ងៃក្រោយសំរាលកូន" ។ អ្នកសំភាសន៍បានអះអាងថា ពួកគេត្រូវបានអនុគ្រោះមិនឱ្យធ្វើការក្នុងពន្ធនាគារ (ដូចជាយួរទឹក ឬ បោកខោអាវ) ។ ក្នុងកំឡុងពេលឬភ្លាមក្រោយពេលមានផ្ទៃពោះ ។

ក្នុងសារាចរលេខ១៥ មាត្រា១៨ ខ នៃសេចក្តីប្រកាសចែងថា កុមារទាំងឡាយអាចរស់នៅក្នុងពន្ធនាគារជាមួយម្តាយរបស់គេរហូតដល់អាយុ៦ឆ្នាំ ។ សេចក្តីសំរេចនេះ បានពិភាក្សារួចហើយក្នុងផ្នែកខាងលើស្តីពីសារាចរលេខ១៥ ។ សេចក្តីប្រកាសកំណត់យ៉ាងច្បាស់ថា ម្តាយទទួលខុសត្រូវជា បឋមក្នុងការថែទាំកូនរបស់គេក្នុងកំឡុងពេលនៅក្នុងពន្ធនាគារ ។ ទោះជាយ៉ាងណាក៏ដោយនាយកដ្ឋានពន្ធនាគារដែលឋិតនៅក្រោមក្រសួងមហាផ្ទៃ ត្រូវផ្តល់ឱ្យកុមារទាំងនោះនូវម្ហូបអាហារ និងថ្នាំព្យាបាល ។ ថ្វីបើពន្ធនាគារ

ទាំងអស់ផ្តល់ម្ហូបអាហារក្នុងករណីជាច្រើន ប៉ុន្តែគុណភាព និងបរិមាណនៃម្ហូបអាហារគឺមានបញ្ហា ។ ជាច្រើនដងណាស់ម្ហូបអាហារដែលផ្តល់ឱ្យគឺមិនមានលក្ខណៈគ្រប់គ្រាន់សមរម្យសំរាប់កុមារ (ឧទាហរណ៍ កុមារនោះក្មេងពេកតែត្រូវបរិភោគម្ហូបអាហាររឹង) ។ មានការប្រឹងប្រែងយ៉ាងតិចតួចឆ្ពោះទៅធានាឱ្យមានម្ហូបអាហារត្រឹមត្រូវ ជាពិសេសនៅពេលដែលម្តាយមិនអាចមានទឹកដោះបំបៅកូនបាន ។ ថ្នាំពេទ្យត្រូវបានគេផ្តល់ឱ្យត្រឹមតែពេលខ្លះប៉ុណ្ណោះ ហើយជារឿយៗមិនមានចេតនាប្រើប្រាស់សំរាប់កុមារទាំងនោះទេ ។ ទោះជាម្ហូបអាហារនិងថ្នាំពេទ្យមាននៅក្នុងពន្ធនាគារការមិនអាចផ្តល់ឱ្យបានគ្រប់គ្រាន់ និងសមរម្យចំពោះកុមារអាចចាត់ជាកំហុស ដោយផ្អែកទៅលើសេចក្តីប្រកាសលេខ ២១៧ ។

បន្ថែមលើពីនេះទៀត កុមារដែលកំពុងរស់នៅក្នុងពន្ធនាគារគួរតែត្រូវបានអនុញ្ញាតឱ្យចេញចូលក្នុងពន្ធនាគារដោយយោងតាមបទបញ្ញត្តិរបស់ពន្ធនាគារ ។ មាតាម្នាក់ដែលត្រូវបានគេសំភាសន៍ទោះជាយ៉ាងណាក៏ដោយបាននិយាយថា នាងស្ទាក់ស្ទើរ ដើម្បីអនុញ្ញាតឱ្យកូនស្រីរបស់នាងចេញពីពន្ធនាគារសូម្បីតែពីរឬបីថ្ងៃដោយសារនាយកពន្ធនាគារប្រាប់នាងថា ប្រសិនបើកូនស្រីរបស់នាងចាកចេញពីពន្ធនាគារនាងត្រូវចាកចេញរហូត និងមិនអនុញ្ញាតឱ្យមករស់នៅក្នុងពន្ធនាគារវិញទេ ។

ចុងបញ្ចប់មាត្រា១៨ គ នៃសេចក្តីប្រកាសចែងថា ប្រសិនបើម្តាយមិនអាចថែទាំកូនបានត្រឹមត្រូវនាយកពន្ធនាគារត្រូវ "ផ្តល់ផលប្រយោជន៍ដ៏ល្អបំផុតសំរាប់កុមារឬកុមារទាំងនោះ" ដោយទាក់ជាមួយនឹងក្រសួងមានសមត្ថកិច្ច ឬ បងប្អូន ដើម្បីធានាថា កុមារឬកុមារទាំងនោះមានការថែទាំត្រឹមត្រូវនៅក្រៅពន្ធនាគារ ។ នាកយពន្ធនាគារត្រូវរាយការណ៍ពីការចាត់ចែងរបៀបនេះទៅនាយដ្ឋានពន្ធនាគារ ។ ក្នុងករណីជាច្រើនដែលបានធ្វើការសំភាសន៍សំរាប់របាយការណ៍នេះ គ្មានការវាយតម្លៃណាមួយត្រូវបានគេធ្វើឡើងដើម្បីពិនិត្យមើលពីសមត្ថភាពរបស់មាតាចំពោះការថែទាំកូនរបស់គេនោះទេ ។ ប្រសិនបើស្ត្រីម្នាក់គ្មានលទ្ធភាពថែទាំកូនរបស់គេវាមិនច្បាស់ថា តើវិធានការអ្វីដែលនាយកពន្ធនាគារគួរចាត់ការដើម្បីធានាការថែទាំដ៏មានគុណភាព ។

សេចក្តីប្រកាសបានចែងផងដែរ ចំពោះការគ្រប់គ្រងស្ត្រីជាប់ឃុំឃាំង ។ មាត្រា ១៨ ឆ(៖) គួសបញ្ជាក់អំពីសកម្មភាពដែលត្រូវអនុវត្តក្នុងពននាគារ ចំពោះស្ត្រីជាប់ឃុំបណ្តោះអាសន្ន ឬ ទណ្ឌិត ។ មាត្រានេះតម្រូវឱ្យពន្ធនាគារនិមួយៗមានមន្ត្រីពន្ធនាគារដែលមានការហ្វឹកហ្វឺននៅប្រចាំការគ្រប់ពេលវេលា ដើម្បីពិនិត្យមើលស្ត្រីជាប់នៅក្នុងបន្ទប់ឃុំឃាំង ។ ដូចដែលបានបង្ហាញការវិភាគខាងលើស្តីពីការអនុវត្តន៍សារចរ

លេខ១៥ការខ្វះខាតជាទូទៅនូវបុគ្គលិកពន្ធនាគារជាស្ត្រី ធ្វើឱ្យការគ្រប់គ្រងបែបនេះមិនមានលក្ខណៈប្រាកដប្រជា ។

### ៣- និតិវិធី បទញ្ញត្តិប្រទេសកម្ពុជា និង ករិតថែទាំសុខភាពក្នុងពន្ធធនាគារ

នាយកដ្ឋានពន្ធនាគារនៅក្រោមក្រសួងសុខាភិបាលចេញនិតិវិធីបទញ្ញត្តិប្រទេសកម្ពុជា និងករិតថែទាំ សុខភាពក្នុងពន្ធធនាគារ ដើម្បីផ្តល់គំរោងការងារសំរាប់អនុវត្តសេចក្តីប្រកាសលេខ២១៧ ចុះថ្ងៃទី ៣១ មិនា ១៩៩៨ ។ ដើម្បីជាខ្នាតសំរាប់វាស់ការអនុវត្តនំសេចក្តីប្រកាសនេះនីតិវិធីទាំងនេះគឺមានសារៈសំខាន់ចំពោះការវិភាគទៅលើការថែទាំរបស់មាតាកុមារ និងស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារ ។ នីតិវិធីដែលបញ្ជាក់ពីកាលៈទេសៈនៃជនទាំងនេះ នឹងត្រូវបានពិភាក្សាដូច ខាងក្រោម :

### ១- នីតិវិធីទូទៅ

### *ក/ នីតិវិធីលេខ ៦: បទបញ្ញត្តិស្តីពីម្ហូបអាហារសំរាប់អ្នកជាប់ពន្ធនាគារ*

នៅក្នុងនីតិវិធីលេខ៦ ចំណុច៣ នាយកពន្ធនាគារនិមួយៗ ត្រូវផ្តល់ម្ហូបអាហារគ្រប់គ្រាន់ដល់ជនជាប់ពន្ធនាគារទាំងអស់យ៉ាងហោចណាស់២ដងក្នុងមួយថ្ងៃ ទន្ទឹមនឹងនេះក៏ដូចជាផ្តល់ "ទឹកបរិភោគឱ្យបានគ្រប់គ្រាន់" គ្រប់ពេលវេលា ។ នីតិវិធីលេខ៦ ចំណុច៤ ចែងថា ប្រភេទម្ហូប ក៏ដូចជាចំនួនម្ហូបអប្បរិមាត្រូវតែបានផ្តល់ឱ្យជាប្រចាំរៀងរាល់ថ្ងៃ ។[៣៣]

ការតវ៉ាជាច្រើនទាក់ទងទៅនឹងការខកខានមិនបានផ្តល់អោយម្ហូបអាហារគ្រប់គ្រាន់ដល់ជនជាប់ឃុំនិងកូនរបស់គេ បានអធិប្បាយរួចមកហើយនៅក្នុងករណីសិក្សាជាច្រើន និងក្នុងការពិភាក្សាពី សេចក្តីប្រកាសលេខ២១៧ខាងលើ។ លើសពីនេះទៀតស្ត្រីជាច្រើនដែលជាប់ឃុំនៅពន្ធនាគារបីផ្សេងគ្នាមានការចាប់អារម្មណ៍អំពីកង្វះទឹកស្អាតសំរាប់បរិភោគ ។ ក្នុងចំណោមប្រភព ធនធានទឹកបរិភោគជាបឋមដែលគេចុះបញ្ជីគឺ បឹង និង ទន្លេ ។ ទឹកបរិភោគពីប្រភពទាំងនេះអាចនាំអោយងាយមានជំងឺជាពិសេសក្នុងចំណោមទារកទើបនឹងកើតដែលប្រព័ន្ធការពារនៅខ្សោយនៅឡើយ ។ យ៉ាងហោចណាស់ក្នុងករណីសិក្សាទៅលើអ្នកដែលបានសំភាសន៍២នាក់បានបង្ហាញថា ការមិនអាចមានលទ្ធភាពចំអិនទឹក ឬមិនអាចបន្សុតទឹកបានដើម្បីបង្ការពួកគេពីភាពគ្រោះថ្នាក់នៃជំងឺបណ្តាលមកពីការប្រើប្រាស់ទឹកមិនស្អាត។

ដើម្បីទទួលបានម្ហូមអាហាគ្រប់គ្រាន់សំរាប់ជនជាប់ឃុំ នីតិវិធីទី៦ ចំនុច១០ អនុញ្ញាត្តអោយរដ្ឋបាលពន្ធនាគា ដើម្បីស្នើរសុំម្ហូបអាហារពីអង្គការក្រៅរដ្ឋាភិបាល និងអនុញ្ញាត្តអោយលក់ ឬដោះដូរផលិតផល

---

[៣៣] *ពត៌មានពិស្តាបន្ថែមស្តីពីម្ហូបអ្វី និង ប៉ុន្មានដែលត្រូវផ្តល់ឱ្យ: មើលឧបសម្ពន្ធ័សមាមាត្រនៃឯកសារ ។*

ដែលពន្ធនាគារបានផលិតសំរាប់បន្ថែមទៅលើម្ហូមអាហារ ។ ការអនុញ្ញាត្តអោយធ្វើដូចនេះអាចបណ្តាលអោយមានការព្រួយបារម្ភ ។ ក្នុងខណៈនោះវាអាចងាយស្រួលនាំទៅរកការរំលោភអំណាច ឬបង្ខំអោយធ្វើការក្នុងពន្ធនាគារ ។ ទោះជាយ៉ាងណាក៏ដោយជនជាប់ពន្ធនាគារដែលត្រូវបានគេសំភាសក្នុងការសិក្សានេះមិនបានរាយការណ៍ថាមានបញ្ហានេះកើតឡើងទេ ប៉ុន្តែនាយកពន្ធនាគារម្នាក់ពិតជាអះអាងថាបានលក់ផលិតផលដែលធ្វើដោយពន្ធនាគារដើម្បីបង់ថ្លៃសំភារៈប្រើប្រាស់ក្នុងពន្ធនាគារ (មើលករណីសិក្សាទី៣៧ខាងលើ) ។

ជាសំខាន់បំផុតនិតិវិធីទី៦ ចំនុច៧ ផ្តល់សេចក្តីយោងជាពិសេសចំពោះបញ្ញត្តិស្តីពីម្ហូបអាហារសំរាប់ជនជាប់ឃុំឃាំងជាមួយនឹងកូនរបស់គេនឹងជនជាប់ឃុំដែលមានផ្ទៃពោះ : "ជនជាប់ឃុំឃាំងដែលមានកូនក្នុងពន្ធនាគារគឺត្រូវបានផ្តល់ម្ហូបអាហារអោយបានសមរម្យ ដើម្បីធានាសុខភាពនិងការរស់នៅបានល្អប្រសើរដល់កុមារ ។ ជនជាប់ឃុំឃាំងជាស្ត្រីដែលកំពុងបំបៅកូនអាចទទួលម្ហូបអាហារបន្ថែមសំរាប់ខ្លួនគេ ប្រសិនបើមានការស្នើសុំអោយមានការថែទាំសុខ ភាពពីអ្នកផ្តល់សេវាសុខភាព" ។ និតិវិធីនេះមានសារៈសំខាន់សំរាប់ហេតុផលពីរយ៉ាង ។ ទីមួយវាផ្តល់អោយមានការទទួលខុសត្រូវរបស់នាយកដ្ឋានពន្ធនាគារសំរាប់ទ្រទ្រង់ចំណីអាហារ អោយបានគ្រប់គ្រាន់ដល់កុមារដែលកំពុងរស់នៅជាមួយម្តាយដែលត្រូវបានគេដាក់គុគឺ ឃុំខ្លួនទី២វាអនុញ្ញាតិអោយផ្តល់ម្ហូមអាហារបន្ថែមចំពោះស្ត្រីដែលកំពុងបំបៅដោះកូន ប៉ុន្តែវាអាចធ្វើទៅបានក្នុងករណីមានការស្នើសុំពីអ្នកធ្វើការថែទាំសុខភាព ។

ដូចដែលបានពិភាគ្សាក្នុងការស្រាវជ្រាវ ម្តាយទាំងឡាយ កូនរបស់គេ និងស្ត្រីមានផ្ទៃពោះជាញឹកញាប់មិនបានទទួលការព្យាបាលសូម្បីតែនៅពេលដែលគេស្នើសុំ ។ ជារឿយៗគេមិនបានធ្វើការស្នើសុំដោយហេតុថា សំណើរបស់គេមិនត្រូវគេពិចារណារឺដោះស្រាយ ។ ក្នុងករណីសិក្សាទី៦ ឧទាហរណ៏ រស្មីមិនហ៊ានប្រាប់បុគ្គលិកពន្ធនាគារថា នាងមានអារម្មណ៏នាងមិនបានទទួលម្ហូបអារហារគ្រប់គ្រាន់នៅពេលនាងមានផ្ទៃពោះ ។ ករណីសិក្សាទី៧និង៨ អោយឧទាហរណ៏ ចំពោះម្តាយដែលមិនអាចផលិតទឹកដោះ ដើម្បីចិញ្ចឹមកូនរបស់គេបាន ។ គ្មានស្ត្រីណាម្នាក់បានទទួលបញ្ជាដើម្បីទទួលម្ហូបអារហារបន្ថែមពីបុគ្គលិកពន្ធនាគារទេ ។ លក្ខខ័ណ្ឌនៃបទបញ្ជានេះដែលមានចែង នៅក្នុងនិតិវិធីទី៦ ចំនុច៧ អាចបង្អាក់យ៉ាងពិតប្រាកដជៀសជាងបង្កើនលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានម្ហូបអារហារចាំបាច់ដើម្បីបំបៅដោះកូនដោយដោះម្តាយ ។ បុគ្គលិកសុខភាពពន្ធនាគារមិនបានបង្ហាញពីការត្រួតពិនិត្យមើលម្ហូបអារហារសំរាប់ស្ត្រីដែលកំពុងបំបៅដោះកូន រឺសំណើរដែលគេស្នើសុំទទួលម្ហូបអាហារបន្ថែម ។ នៅពេលម្ហូបអាហារត្រូវបានគេផ្តល់នោះវាទទួលបានដោយសារការបញ្ជារបស់ប្រធានពន្ធនាគារ រឺមកពីប្រភពខាងក្រៅ ដូចជាក្រុមគ្រួសារ រឺអង្គការក្រៅរដ្ឋាភិបាល ។

### ខ- និតិវិធីទី ១២ : ការស្នើសុំរឺបណ្តឹងរបស់ជនជាប់ឃុំឃាំង

គោលបំណងនៃនិតិវិធីទី១២ "ត្រូវផ្តល់និតិវិធីសំរាប់ជនជាប់ឃុំឃាំង ដើម្បីធ្វើសំណើរនិងធ្វើពាក្យបណ្តឹង" ។ ដូចនេះនិតិវិធីបានផ្តល់សិទ្ធិជនជាប់ឃុំដើម្បីធ្វើសំណើរ រឺពាក្យបណ្តឹងនឹងត្រូវមានការបកស្រាយអោយបានសមរម្យនឹងទាន់ពេលវេលា ។ និតិវិធីកន្លងមកបញ្ជាក់ថា ជនជាប់ឃុំឃាំងនឹងមានឱកាសបានជឹងពីប្រធានពន្ធនាគារ រឺ សមត្ថកិច្ចផ្សេងទៀតនៅក្នុងមួយថ្ងៃ៧នៃសប្តាហ៍ ។ បន្ថែមលើសពីនេះវាចែងអំពីសិទ្ធិជនជាប់ចោទនិយាយដោយសេរី នឹងដោយគ្មានការគ្រប់គ្រងរួមទាំងគ្មានបុគ្គលិកពន្ធនាគារណាម្នាក់ដែលត្រូវបានអនុញ្ញាតិអោយត្រួតពិនិត្យពន្ធនាគារទេ ។ លើសពីនេះ ជនជាប់ឃុំឃាំងម្នាក់ៗគឺត្រូវបានផ្តល់ដំណឹងពីមធ្យោបាយដែលពួកគេអាចស្នើសុំរឺធ្វើការប្តឹង ។ ដូចដែលបាននិយាយទាំងអស់ខាងលើនេះនិតិវិធីទី១២ ព្យាយាមដាក់ប្រព័ន្ធដ៏មានប្រសិទ្ធិភាពដែលជនជាប់ឃុំឃាំ ងអាចប្រាស្រ័យទាក់ទងបញ្ហារបស់ពួកគេដោយគ្មានប្រត្តិកម្មអវិជ្ជមាន ។ ឧទាហរណ៍ជាច្រើនដែលបានផ្តល់អោយក្នុងករណីសិក្សាបញ្ជាក់ពីការខកខានដើម្បីបង្កើតប្រព័ន្ធអោយបានត្រឹមត្រូវមួយសំរាប់ដោះស្រាយចំពោះមាតាកុមារ និងស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារ ។ កថាខ័ណ្ឌពីរនៃផ្នែកខាងលើ ស្តីអំពីសិទ្ធិការពាររបស់កុមារមានការពិភាក្សាលំអិតបន្ថែមទៀតនៅក្នុងបញ្ហានេះ ។

### គ- និតិវិធីទី ៣៨ : ជនជាប់ឃុំឃាំងជាស្ត្រីនិងកូនរបស់ពួកគេ

និតិវិធីដ៏សំខាន់បំផុតដោយយោងទៅតាមការស្រាវជ្រាវនេះ និតិវិធីទី៣៨ចែងដោយផ្ទាល់ចំពោះការព្យាបាល និងថែទាំស្ត្រីជាប់ឃុំមានផ្ទៃពោះ និងកុមារដែលកំពុងរស់នៅជាមួយជនជាប់ឃុំឃាំង ។ បន្ថែមទៅលើរចនាសម្ព័នដែលមានចែងនៅក្នុងសេចក្តីប្រកាសលេខ ២១៧ និតិវិធីទី៣៨ នៃនាំអ្នកធ្វើការផ្នែកសុខភាពក្នុងពន្ធនាគារអោយត្រួតពិនិត្យមើលស្ថានភាពរបស់ស្ត្រីជាប់ឃុំមានផ្ទៃពោះអោយបានទៀងទាត់ ។ វាក៏បានចែងផងដែរពីតំរូវការចាំបាច់ដើម្បីផ្តល់ដល់ស្ត្រីដែលមានផ្ទៃពោះ រឺស្ត្រីដែលកំពុងបំបៅដោះកូននៅក្នុងតុល្យភាពម្ហូបអារហារដើម្បីអោយត្រូវតាមតំរូវការចាំបាច់របស់នាង ហើយក៏បានចែងយ៉ាងច្បាស់ថែមទៀតថាទណ្ឌិតដែលមានផ្ទៃពោះអាចរួចផុតពីការធ្វើការក្នុងពន្ធនាគារក្នុងរយៈពេលពីពីរទៅបីខែមុនរឺ ក្រោយសំរាលកូន ។[៣៤] ដូចដែលបានចែងរួចមកហើយលក្ខ័ណម្ហូបអារហារចំពោះទណ្ឌិត និងស្ត្រីជាប់ឃុំបណ្តោះអាសន្នមានផ្ទៃពោះគឺកំរទទួលបានតាមលក្ខ័ណ្ឌនេះ ហើយស្របគ្នានេះដែរ អ្នកធ្វើការខាងផ្នែកសុខភាពមិនបាន

---

៣៤ *និតិវិធីទី១១" កិច្ចការរបស់ជនជាប់ឃុំឃាំង និង ការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ" គឺមានលក្ខណៈអនុគ្រោះយ៉ាងច្រើននៅពេលដែលវាចែងអំពីស្ត្រី ដែលរកឃើញថាមានទោស នឹងមិនត្រូវបានគេអោយធ្វើការ៩០មុន និង ៩០ថ្ងៃក្រោយពេលសំរាលកូន ។*

ពិនិត្យមើលលក្ខខ័ណរបស់ពួកគេទេ ។ ចំនុចមួយទៀត បានកត់សំគាល់តាំងពីមុនមក គឺការខកខានមិនបាន ផ្តល់សំលៀកបំពាក់ម្ហូបអាហារ និងថ្នាំព្យាបាលគ្រប់គ្រាន់ដល់កុមារដែលកំពុងរស់នៅក្នុងពន្ធនាគារដែលនិតិវិធីទី៣៨ តំរូវអោយបុគ្គលិកពន្ធនាគារធ្វើកិច្ចការនេះ ។

និតិវិធីជាកញ្ចក់ឆ្លុះបញ្ចាំងទៅលើសេចក្តីប្រកាស ក្នុងតំរូវការចាំបាច់អោយមន្ត្រីរដ្ឋបាលពន្ធនាគាររៀបចំចាត់ចែងថៃទាំកុមារខាងក្រៅពន្ធនាគារនៅពេលត្រូវការថែទាំដូចនេះ ។

ទោះជាយ៉ាងណាក៏ដោយវាបានឈានទៅមុខមួយជំហានទៀត ដោយចែងថា នាយកពន្ធនាគារត្រូវតែសំរបសំរួលការប្រជុំរវាងមាតា តំណាងក្រសួងពាក់ព័ន្ធ រឺក្រុមគ្រួសារ រឺ បងប្អូន ដើម្បីធានាអោយបានថា កុមារ រឺ កុមារទាំងឡាយត្រូវបានគេថែរក្សាអោយបានសមរម្យនៅពេលមានអាយុ៦ឆ្នាំ ។ មិនដូចសេចក្តីប្រកាសជាទូទៅទេ នេះទាមទារអោយមានសកម្មភាពជាក់លាក់ដោយមន្ត្រីរដ្ឋបាលពន្ធនាគារដើម្បីធានាអោយមានសុវត្ថិភាពនិងបរិយាកាសល្អប្រសើរសំរាប់កុមារ ។ មន្ត្រីរដ្ឋបាលពន្ធនាគាររឺបុគ្គលិករដ្ឋបាលផ្សេងទៀត រឺតំណាងរដ្ឋាភិបាលមិនបានបំពេញលក្ខ័ណ្ឌទាំងនេះតាមបញ្ញត្តិច្បាប់ទេ ។

និតិវិធីទី៣៨ ពង្រីកអត្ថន័យបន្ថែមទៀតដែរ ទៅលើសេចក្តីប្រកាសនៅពេលដែលវាចេញថា " នាយកដ្ឋានពន្ធនាគារទទួលខុសត្រូវក្នុងការផ្តល់ឱកាសដល់កុមារក្នុងការអភិវឌ្ឍសារពាង្គកាយអប់រំ និងបញ្ញា" និងទាមទារ មន្ត្រីរដ្ឋបាលពន្ធនាគារធ្វើការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើកិច្ចការផ្នែកកុមារ និងការិយាល័យរដ្ឋាភិបាលដែលពាក់ព័ន្ធដើម្បីសំរេចកិច្ចការនេះ ។ និតិវិធីទី៣៨ព្យាយាមធ្វើអោយមានការលូតលាស់នឹងអភិវឌ្ឍដល់កុមារដែលកំពុងរស់នៅក្នុងពន្ធនាគារក្នុងក៏រិតជាច្រើន នឹងដាក់បន្ទុកធ្វើកិច្ចការនេះយ៉ាងជិតស្និត ជាមួយនឹងនាយកដ្ឋាន ពន្ធនាគារ និង មន្ត្រីពន្ធនាគារ ។

ផ្នែកទី៣ (សិទ្ធិអភិវឌ្ឍ) នៃការវិភាគទៅលើចង្កោមសិទ្ធិទាំងបួនរបស់កុមារ មានការពិភាក្សាយ៉ាងហ្មត់ចត់ ពីការខកខានមិនបានគោរពតាមគោលការណ៍នេះ ប៉ុន្តែវាត្រូវតែបានគូសបញ្ជាក់ ថានាយកពន្ធនាគារជាច្រើនមិនបានចាត់វិធានការណ៍យ៉ាងសកម្ម ដើម្បីលើកទឹកចិត្តដល់ការលូតលាស់របស់កុមារទេ ។ គ្មានមន្ត្រីពន្ធនាគារណាម្នាក់បាននិយាយពីកិច្ចសហប្រត្តិបត្តិការណ៍ជាមួយភ្នាក់ងារខាងក្រៅក្នុងការបង្កើតសកម្មភាព រឺកម្មវិធីដើម្បីធ្វើអោយការអភវឌ្ឍន៏របស់កុមារទាំងនោះមានភាពល្អប្រសើរ ។ ទោះបីជានិតិវិធីតំរូវអោយចាត់វិធានការណ៍នេះដោយ ផ្ទាល់ក៏ដោយ ។

***និតិវិធីទី ៣៨ ចែងថា :***

និតិវិធី៣៨ ចែងថា ស្ត្រីមានផ្ទៃពោះអាចបណ្តោយអោយធ្វើការក្នុងពន្ធធនាគាររយៈ២ខែមុន រឺ ៣ខែក្រោយពីសំរាលកូន ។ ដូចដែលបានពោលខាងលើគ្មានស្ត្រីមានផ្ទៃពោះណាម្នាក់ដែលគេសំភាសន៍ត្រូវគេបង្ខំឱ្យធ្វើការក្នុងអំឡុងពេលរឺក្រោយពេលមានផ្ទៃពោះទេ ។ តាមពិតម្តាយជា ច្រើនដែលមានកូននៅជាមួយបានរាយការណ៍ថា បុគ្គលិកពន្ធធនាគារអនុគ្រោះឱ្យពួកគេមិនធ្វើការ ដូច្នេះគេមានពេលអាចថែទាំកូនរបស់ពួកគេ រឺ ដោយសាគេនៅខ្សោយក្រោយពេលសំរាលកូន ។

## ២. ក៏រិតសេវាថែទាំសុខភាពក្នុងពន្ធធនាគារ

ក៏រិតសេវាថែទាំសុខភាពក្នុងពន្ធនាគារដែលចេញដោយនាយដ្ឋានពន្ធនាគារក្រោមក្រសួងមហាផ្ទៃឆ្នាំ ២000 ផ្តល់គោលការណ៍យ៉ាងច្បាស់ស្តីពីបញ្ញត្តិថែទាំសុខភាពចំពោះទណ្ឌិតនិងជនជាប់ឃុំបណ្តោះអាសន្ន ។ គោលគំនិតសំខាន់នៃនិតិវិធីទាំងនេះនៅពេលដែលវាមានចែងអំពីការថែទាំស្ត្រី កុមារ និងស្ត្រីមានផ្ទៃពោះក្នុងពន្ធធនាគារ គឺត្រូវបានគេអធិប្បាយដូចតទៅ :

កថាខណ្ឌ័ផ្តើមនៃបទដ្ឋានសេវាសុខភាពទី១ ដែលមានចំនងជើងថា **ការរៀបចំ និង រដ្ឋបាល** ផ្តល់ការពិនិត្យជាទូទៅយ៉ាងច្បាស់នៃការរំពឹងទុកទាក់ទងនឹងការថែទាំសុខភាព ចំពោះជនកំពុងរស់នៅក្នុងពន្ធធនាគារ សេវាសុខភាពពន្ធធនាគារត្រូវបានគេរៀបចំនិងចាត់ចែងឡើងក្នុងមធ្យោបាយមួយដើម្បីលើកតំកើងធ្វើឱ្យល្អប្រសើរ និងថែរក្សាសុខភាពរបស់ជនជាប់ពន្ធធនាគារដែលគេគួរទទួលបាន ។ ក៏រិតសេវាទី១ ចែងថាសេវាសុខភាពពន្ធធនាគារត្រូវតែព្យាយាមធ្វើឱ្យត្រូវទៅតាមតំរូវការរបស់ជនជាប់ ពន្ធធនាគារទាំងអស់ខាងលើ និងផ្តល់ការថែទាំដែលបញ្ជាក់ពីការរស់នៅដ៏ល្អប្រសើររបស់ជនជាប់ពន្ធធនាគារ ។

ដូចគ្នានេះដែរបទដ្ឋានទី៣ ដែលគេហៅថាសេវាបញ្ជូនទាមទារឱ្យមាន "ការថែទាំជាបន្តការលើកតំកើងពីសុខភាព និង ការអន្តរាគមន៍ជាមុន" ។ យោងតាមក៏រិតសេវាទី៣ សេវាសុខភាព ពន្ធធនាគារត្រូវតែមានការថែទាំជាបន្តនិងវិធានការពារបន្ថែមទៅការព្យាបាលជាចាំបាច់ ។

នៅពេលបច្ចុប្បន្ន សុខភាពក្នុងពន្ធធនាគារដែលបញ្ចូលក្នុងរបាយការណ៍នេះ មិនបានទទួលជោគជ័យក្នុងការផ្តល់ការថែទាំសុខភាពជាបន្តនិងល្អប្រសើរ ។ នៅពេលទទួលបានការថែទាំ ការព្យាបាលត្រូវបានគេរៀបចំបំរុងចំពោះតែការព្យាបាលជំងឺ រឺ របួសថ្មីតែប៉ុណ្ណោះ។ ការព្យាបាលដោយការការពារ រឺ ការថែដែលមិនអាចឈឺចាប់ដល់រាល់រាងកាយផ្ទាល់ គឺគ្មានក្នុងរបបសេវាកម្មសុខភាពពន្ធធនាគារ ។

បទដ្ឋានទី៣ចែងពីសិទ្ធិជនជាប់ពន្ធធនាគារផងដែរ ។ បទដ្ឋានទី៣ ចំនុច១០ និង ១២ ស្នើរសុំឱ្យជនជាប់ពន្ធធនាគារទទួលដំណឹងពីសិទ្ធិថែទាំសុខភាព និង មានឱកាសត្រួតពិនិត្យសុខភាពរបស់គេដែល

ត្រូវទទួលបាន ។ គ្មានពន្ធធនាគារណាមួយនៅក្នុងការសិក្សានេះបានធ្វើការប្រជុំដើម្បីជូនដំណឹង ទាំងនេះដល់ទណ្ឌិត រឺ ជនជាប់ឃុំបណ្តោះអាសន្ន ហើយគេថែមទាំងមិនមានប្រពន្ធ័អនុវត្តសំរាប់ទទួលនិងធ្វើការស៊ើបអង្កេតបណ្តឹងអំពីសេវាសុខភាពដូចដែលក៏រិតសេវាទីតំរូវឱ្យមាននោះទេ ។

បទដ្ឋានទី២ បុគ្គលិកនិងទិសដៅ ក៏រិតសេវាទី២ព្យាយាមធានាថា បុគ្គលិកសុខភាពពន្ធធនាគារគឺបានរឹករឹនល្អនិងមានសម្ថភាពបំពេញការងាររបស់គេ ប៉ុន្តែវាមិនបានផ្តល់នូវលក្ខ័ណ្ឌជាក់លាក់សំរាប់បំពេញលក្ខណ្ឌ័ទាំងនេះទេ។[៣៥] បទដ្ឋានទី២ តំរូវថាសេវាសុខភាពពន្ធធនាគារដែលពិនិត្យជាទូទៅដោយបុគ្គលគឺមានលក្ខណៈត្រឹមត្រូវដោយការអប់រំហ្វឹកហ្វឺន និង បទពិសោធន៏ "ហើយបុគ្គល ដែលមានលក្ខណៈត្រឹមត្រូវនោះអាចទទួខុសត្រូវអង្គភាពសេវាសុខភាព ទោះជាមិនបានឱ្យនិយមន័យ ច្បាស់លាស់ទៅលើគុណសម្បត្តិចំពោះពាក្យ"សមរម្យ" រឺ"ត្រឹមត្រូវ" ត្រូវបានគេផ្តល់ឱ្យ ។

បទដ្ឋានទី២ ទាមទារឱ្យសេវាសុខភាពជួលមនុស្សឱ្យបានគ្រប់គ្រាន់សំរាប់ដំណើរការឱ្យមានប្រសិទ្ធិភាពក្នុងការបំពេញគោលបំណងដូចដែលមានចែងខាងលើ ។ តាមពិតសេវាសុខភាពពន្ធនាគារដែលបានពិនិត្យមើលជាធម្មតាថិតនៅក្រោមការគ្រប់គ្រងបុគ្គលិក ។ ដូចដែលបានអធិប្បាយក្នុងករណីសិក្សាជាច្រើនបុគ្គលិកខ្លះមានគុណសម្បត្តិតិចតួចប្រសិនបើមាន ។ បុគ្គលិកសុខភាព ៤នាក់ ដែលបានសំភាសន៏នៅកន្លែង៤ផ្សេងគ្នា ម្នាក់បានរឹករឹនជាគិលានុប្បដ្ឋាយិកាដែលមានលិខិតបញ្ជាក់ការសិក្សាផ្នែកឆ្មបម្នាក់បានហ្វឹកហ្វឺនជាគ្រូពេទ្យម្នាក់បានប្រាប់ថាបានសិក្សាវិជ្ជសាស្ត្រមុនរបបខ្មែរក្រហម និងទី៤ មិនបានរៀនអ្វីទាំងអស់ ។ គ្មានអ្នកធ្វើការណាម្នាក់បានហ្វឹកហ្វឺនជាវេជ្ជបណ្ឌិត និងថែមទាំងគ្មានពន្ធនាគាររាយការណ៏ថាគ្មានបុគ្គលិកជាអនុបណ្ឌិតឡើយ ។

បន្ថែមលើនេះទៀតបុគ្គលិកពន្ធនាគារកំរមានអាគារ និង សំភារៈគ្រប់គ្រាន់នៅទីកន្លែងរបស់គេដែលជាតំរូវការចាំបាច់សំរាប់បំពេញការងារដូចដែលមានចែងក្នុងក៏រិតសេវាទី៦ស្តីអំពីអាគារ និង សំភារៈ។ បទដ្ឋានទី៦ ចំនុច៧ និង ៨ តំរូវឱ្យមានសំភារៈនិងឧបករណ៏ឱ្យបានគ្រប់គ្រាន់ដើម្បីឱ្យបុគ្គលិកអាចបំពេញការងាររបស់គេបានហើយបុគលិកនោះមានការហ្វឹកហ្វឺនគ្រប់គ្រាន់ក្នុងការប្រើប្រាស់ឧបករណ៏ដូចនេះ ។ បុគ្គលិក២នាក់ដែលបានធ្វើការសំភាសន៏បានបញ្ជាក់ពីការខ្វះខាតថ្នាំពេទ្យ និង ឧបករណ៏ពិនិត្យសុខភាពនៅ

---

[៣៥] *ក៏រិតសេវាទី៣ ចំនុច៧ បញ្ជាក់ចំនុចនេះផងដែរដោយចែងថា បុគ្គលិកត្រូវផ្តល់សេវា" យោងទៅតាមអត្តិភាពវិជ្ជាជីវដែលទទួលបានក្នុង ក៏រិតសំរាប់សុខភាពក្នុងពន្ធធនាគារ" ។ទោះជាណាក៏ដោយជាថ្មីម្តងទៀតគ្មាននិយមន័យជាក់លាក់ថាអ្វីដែលជា"ក៏រិតវិជ្ជាជីវដែលទទួលបាន" ។*

ពន្ធធនាគារ ។ អ្នកធ្វើការផ្នែកសុខភាពនៅក្នុងពន្ធនាគារបានអះអាងយ៉ាងច្បាស់ថាគេមិនផ្តល់ការថែទាំសុខភាពដល់ជនជាប់ពន្ធធនាគារបានទេ ដោយហេតុថាគេជាបុគ្គលម្នាក់នៃបុគ្គលិកសុខភាពពន្ធធនាគារ ។

### ៣. សៀវភៅដំណើរការសុខភាពរបស់ពន្ធធនាគារ

សេចក្តីផ្តើមនៃសៀវភៅសុខភាពពន្ធធនាគារ "ការរៀបចំនិងគ្រប់គ្រង" សរុបគោលបំណងនៃសេវាសុខភាពពន្ធធនាគារ ។ ចំនុចជាច្រើននៅក្នុងគោលបំណងទាំងនេះគឺ គូសបញ្ជាក់ពីនិតិវិធីសុខភាពពន្ធនាគារដែលបានអធិប្បាយដូចខាងលើ ប៉ុន្តែសៀវភៅប្រតិបត្តិសុខភាពបានបង្កើនការចាប់អារម្មណ៍ទៅលើសិទ្ធិជាប់ឃុំឃាំងចំពោះការថែទាំសុខភាពកំរិតខ្ពស់ ។ ការសង្កត់ធ្ងន់នេះគឺបានបង្ហាញជូនក្នុងផ្នែកទី១ ចំនុច១ "ទស្សនវិទ្យា": "យើងជឿជាក់ថារាល់កូនក្តីមានសិទ្ធិទទួលបានការថែទាំដ៏ល្អប្រសើរដែលគេពិចារណាអំពីតំរូវការរបស់បុគ្គលផ្នែករាងកាយមនោសញ្ចេតនា សង្គមបញ្ហា និង ផ្នែកវប្បធម៌" ។ ពាក្យបច្ចេកទេសដែលបានប្រើនៅទីនេះ ដូចជាការប្រើផ្សេងទៀតនៅក្នុងផ្នែកទី១ ចំនុច១ ឧទាហរណ៍ កូនក្តីមានសិទ្ធិសង្ឃឹមលើសមត្ថកិច្ចពីបុគ្គលិក សុខភាព និងថាជនជាប់ពន្ធនាគារ គឺជាអ្នកយល់ព្រមចូលក្នុងសេវាថែទាំសុខភាពជាជាងគោលបំណងថែទាំសុខភាពទាំងនេះបង្ហាញឱ្យ ឃើញការផ្តោតអារម្មណ៍ទៅលើសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ពន្ធនាគារក៏ដូចជាសិទ្ធិទទួលបានការថែទាំសុខភាពរបស់គេ ។ លើសពីនេះផ្នែកទី១ចំនុច១ បញ្ជាក់យ៉ាងច្បាស់ថា មានការផ្តល់ថ្នាំជាច្រើនរីយកចិត្តទុកដាក់ចំពោះការឆ្លងជំងឺដល់រាងកាយ ។ នាយកដ្ឋានពន្ធនាគារហាក់ដូចជា ពិចារណាទៅការរស់នៅជាទូទៅរបស់ជនជាប់ពន្ធនាគារ ជាទស្សនៈសំខាន់សំរាប់សុខភាពរបស់គេទោះបីជាកន្លងមកប្រើ "ការព្យាបាលមនុស្សទាំងមូលជាជាងរោគរបស់សញ្ញាជំងឺ" ។[៣៦][៣៧] ជាថ្មីម្តងទៀតទោះបីជាយ៉ាងណាក៏ដោយការថែទាំដូចនេះមិនត្រូវបានគេផ្តល់ឱ្យទេ ។ ផ្ទុយទៅវិញជនជាប់ឃុំបណ្តោះអាសន្ននិងទណ្ឌិតដែលបានសំភាសន៍សំរាប់ការសិក្សានេះត្រូវតែស្នើសុំឱ្យមានការថែទាំ កូននិងខ្លួនរបស់គេដដែលៗទោះបីជាជំងឺកើតឡើងហើយក៏ដោយ ។ ជាច្រើនដងការទាមឱ្យជួយរបស់គេនៅតែគ្មានចំលើយដូចដែលបានបង្ហាញក្នុងករណីសិក្សាទី១៦ ១៧និង១៨ ។

ស្រដៀងគ្នានេះដែរ បុគ្គលិកសុខភាពពន្ធនាគារមិនបានគោរពតាមផ្នែកទី៣ចំណុច៧នៃសៀវភៅដំណើរការសុខភាពដែលតម្រូវឱ្យពួកគេរៀបចំដឹកជញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យខាងក្រៅក្នុង ករណីចាំបាច់

---

[៣៦] *នេះមានចែងយ៉ាងច្បាស់ផងដែរក្នុងផ្នែកទី១ចំនុច២: សេចក្តីថ្លែងពីបេសកម្ម ។*

[៣៧] *ផ្នែកទី ៣ នៃសៀវភៅដំណើរការសុខភាព "គោលនយោបាយ និតិវិធី ពិធីការ" ធ្វើសេចក្តីយោងផងដែរទៅនឹងតំរូវការថែទាំសុខភាព ទាំងអស់ដោយផ្តោតទៅលើតំរូវការសំរាប់ការពារក៏ដូចការព្យាបាល ។*

រួមទាំងករណីសំរាលកូន ។ យោបល់របស់អ្នកដែលបានធ្វើការសំភាសន៍ជាច្រើនរកឃើញថា មានលក្ខណៈផ្ទុយថា ស្ត្រីជាច្រើនជាញឹកញាយមិនអាចទៅមន្ទីពេទ្យដោយការខ្វះខាត មធ្យោបាយដឹកជញ្ជូន ឬខ្វះលទ្ធភាពបង់ថ្លៃឈ្នួលសំរាប់ការដឹកជញ្ជូនពួកគេទាំងនោះ ដូចដែល បានចង្អុលបង្ហាញក្នុងករណីសិក្សាទី១៤ និង ១៥ ។

ដូចមានចែងនៅក្នុងចំណងជើងផ្នែកទី ៣ ចំណុច ៩ "ការថែទាំកុមារនៅក្នុងពន្ធនាគារ" គឺមានទំនាក់ទំនងជាពិសេសទៅនឹងការប្រព្រឹត្តនៃកុមារ ដែលកំពុងរស់នៅជាមួយមាតាដែលត្រូវជាប់ឃុំ ឬ ដាក់គុក ។ វានិយាយឡើងវិញចំពោះសេចក្តីប្រកាសលេខ ដែលថាកុមារទាំងឡាយអាចរស់នៅក្នុងពន្ធនាគាររហូតដល់អាយុ៦ឆ្នាំ ហើយនីតិវិធីទី៣៨ ស្តីពីការទាមទារឱ្យមានការលើទឹកចិត្តគ្រប់ លក្ខណៈនៃការលូតលាស់ និងអភិវឌ្ឍន៍របស់កុមារក៏បានអធិប្បាយឡើងវិញផងដែរ ។

ចំណុចសំខាន់នៃផ្នែកទី ៣ ចំណុច ៩ ទោះបីជាយ៉ាងណាក៏ដោយផ្តល់នូវការអធិប្បាយនូវរបៀបនឹងត្រូវអនុវត្តក្រោយមក ។ នីតិវិធីតម្រូវឱ្យបង្កើតរូបមន្តនៃគំរោងសកម្មភាពជាលាយលក្ខ័អក្សរ[៣៨] ដែលមានអាយុជាក់លាក់ និងត្រូវការភាពឆាប់ទទួលបានដើម្បីបញ្ជាក់ទៅលើសុខមាលភាពរបស់កុមារនិមួយៗតាមប្រព័ន្ធ និងតាមក្បួនខ្នាត ។ បន្ថែមលើសពីនេះ គួរបង្កើតគំរោងសកម្មភាព ដូច្នេះ ដោយពិគ្រោះជាមួយឪពុកម្តាយរបស់កុមារ ។ ភាពច្បាស់លាស់ទាំងនេះផ្តល់យ៉ាងច្បាស់នូវខ្នាតគំរូដើម្បីពិនិត្យមើលនីតិវិធីសុខភាពរបស់បុគ្គលិករបស់ពន្ធនាគារ ។

ផ្នែកទី៣ ចំណុច១១ "ការថែទាំមាតាដែលមានជម្ងឺនៅក្នុងពន្ធនាគារបានកំណត់ផងដែរ អំពីការបង្កើតគំរោងសកម្មភាពក្នុងករណីនេះបញ្ជាក់លំអិតពីសេវាសុខភាពដែលត្រូវបានផ្តល់ឱ្យចំពោះស្ត្រីមានផ្ទៃពោះ ។ គោលបំណងនៃនីតិវិធីដែលបានរៀបរាប់កន្លងមក គឺត្រូវតែផ្តល់ការថែទាំដល់ស្ត្រីដែលមានផ្ទៃពោះជាប់ឃុំឃាំងឱ្យបានសមរម្យ និងត្រឹមត្រូវមុនពេលនិងក្រោយសំរាលកូន ដើម្បីធានាឱ្យមានសុខភាពល្អរបសើបំផុតចំពោះមាតានិងទារក" ។

បុគ្គលិកសុខភាពពន្ធនាគារមិនបានធ្វើគំរោងសកម្មភាពជាលាយលក្ខ័អក្សរ ដែលបង្កើតជាក្របខណ្ឌ័ការងារសំរាប់ថែទាំទាំងកូនរបស់ជនជាប់ឃុំ ឬ ស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារ ។ គ្មានអ្នកដែលគេបានសំភាសន៍ណាម្នាក់បាននិយាយអំពីការបង្កើតគំរោងដូច្នេះទេ គ្មានទាំងបុគ្គលិក និងទណ្ឌិត ឬជនជាប់ឃុំ

---

[៣៨] *ផ្នែកទី ៣ ចំណុច ៧ សៀវភៅដំណើការសុខភាព អធិប្បាយពីគំរោងសកម្មភាព ដែលជាឯកសារមួយ ជាក់លាក់ចំពោះអ្នកជម្ងឺម្នាក់ ដែលត្រូវព្យាបាលទៅតាមលក្ខខណ្ឌ័ដែលតម្រូវឱ្យមានការព្យាបាលតាមប្រភេទជម្ងឺ ។*

សម្តែងឱ្យចេញនូវការពិចារណាពីយុទ្ធសាស្ត្រយូរអង្វែងណាមួយសំរាប់ថែទាំសុខភាពរបស់ស្ត្រីមានផ្ទៃពោះ ឬរបស់កុមារដែលកំពុងរស់នៅជាមួយម្តាយ ។

នេះទាក់ទងនឹងផ្នែកទី៣ ចំណុច១១ ដែលនិយាយសារឡើងវិញនូវសេចក្តីប្រកាស ២១៧ ដែលចែង ថា ស្ត្រីគួរសំរាលកូននៅមន្ទីពេទ្យ " លើកលែងតែក្នុងករណីចាំបាច់បន្ទាន់បំផុត" ។ ផ្នែកទី៣ ចំណុច ១១ ផងដែរបង្ហាញថា " គំរោងសំរាលកូននឹងត្រូវបានបញ្ចប់នៅចុងខែទី៧ នៃការមានផ្ទៃពោះ" ដោយរាប់បញ្ចូលទាំងការចាត់ចែងសំរាប់ការស្នាក់នៅក្នុងមន្ទីរពេទ្យ ហើយនឹងសម្ភារៈចាំបាច់សំរាប់ថែទាំទារក ។ នេះបង្កបន័យថា បុគ្គលិកពន្ធនាគារគួររៀបចំការសំរាប់ការសំរាលកូនមុនរយៈពេលមានផ្ទៃពោះគ្រប់៧ខែ និងកំណត់ពេលវេលាសំរាប់រៀបចំផងដែរ ។

ជាក់ស្តែងគ្មានការរៀបចំណាត្រូវបានគេធ្វើឡើងសំរាប់ការសំរាលកូនដល់ទណ្ឌិតឬជនជាប់ឃុំបណ្តោះអាសន្នដែលមានផ្ទៃពោះនោះទេ ។ ស្ត្រីយ៉ាងច្រើនមួយចំនួនមិនបានដឹងពីទីកន្លែងដែលគេត្រូវសំរាលកូន ។ ហើយបុគ្គលិកដែលត្រូវបានសំភាសន៍មានគំនិតទូលំទូលាយទាក់ទិនទៅនឹងការស្នាក់នៅរបស់ស្ត្រីនៅក្នុងមន្ទីពេទ្យប្រសិនបើគេគិតថា ស្ត្រីទាំងនោះគួរសំរាលកូននៅក្នុងមន្ទីរពេទ្យ ។ ឧទាហរណ៍ ស្ត្រីមានផ្ទៃពោះ ៦ខែ ស្ត្រីជាប់ឃុំបណ្តោះអាសន្នម្នាក់បាននិយាយថា ទីកន្លែងសំរាលកូន គឺស្រេចតែប្រធានពន្ធនាគារ ។ ហើយស្ត្រីជាប់ឃុំបណ្តោះអាសន្នម្នាក់ទៀត ដែលមានផ្ទៃពោះ៦ខែនិយាយយ៉ាងសាមញ្ញថា នាងមិនដឹងថាតើទីកន្លែងណាដែលនាងត្រូវសំរាលកូននោះទេ ស្ត្រីជាប់ឃុំបណ្តោះអាសន្នទី៣ដែលមានផ្ទៃពោះ៩ខែ បាននិយាយថា នាងនឹងសំរាលកូននៅក្នុងពន្ធនាគារពីព្រោះ នាយកពន្ធនាគារមិនអនុញ្ញាតឱ្យនាងចាក់ចេញពីពន្ធនាគារទេ ។

ផ្នែកទី៣ ចំណុច១១តម្រូវឱ្យបុគ្គលិកពន្ធនាគាររៀបចំការទៅពិនិត្យសុខភាពនៅមណ្ឌលពិនិត្យសុខភាពតាមខេត្ត ហើយផ្តល់ឱ្យនូវការតាមដានពិនិត្យដ៏ទៀងទាត់សំរាប់ស្ត្រីមានផ្ទៃពោះនៅក្នុងមណ្ឌលសុខភាពពន្ធនាគារ ដោយមានផ្តោតទៅលើការផ្តល់ម្ហូបអាហារ និង ការថែទាំដល់ទារក ។ បន្ថែមលើពីនេះផ្នែកនេះបានចែងថា ទណ្ឌិតដែលសំរាលកូនថ្មីៗគួរត្រូវបានផ្តល់"ការជួយគាំទ្រឱ្យបានសមរម្យ" ដោយស្ត្រីបុគ្គលិកពន្ធនាគារ ។

មានតែស្ត្រីមានផ្ទៃពោះ២នាក់ ក្នុងចំណោមស្ត្រី៧នាក់ ដែលបានសំភាសន៍បានទៅជួបវេជ្ជបណ្ឌិតនៅមណ្ឌលសុខភាពខេត្ត ។ ស្ត្រីទី៣បានជួបវេជ្ជបណ្ឌិតដែលមកពិនិត្យនៅពន្ធនាគារ ប៉ុន្តែនាងមិនដឹងថាតើវេជ្ជបណ្ឌិតនោះមកពីណាទេ ។ ស្ត្រី៤នាក់ក្នុងចំណោស្ត្រីជាច្រើនបានរាយការណ៍ថា បានទៅជួបអ្នកធ្វើ

ការខាងសុខភាព រួមទាំងបុគ្គលិកពេទ្យនៅក្នុងពន្ធនាគារផងដែរក្នុងខណៈពេលពួកគេមានផ្ទៃពោះ ។ ក្នុងចំណោមស្ត្រីទាំងនេះ២នាក់បានជួបពិគ្រោះជាមួយបុគ្គលិកពេទ្យពីរដងក្នុងរយៈពេលប្រហែល៤ខែ ហើយម្នាក់បានជួបបុគ្គលិកពេទ្យម្តងក្នុងរយៈពេល១០ថ្ងៃក្រោយពេលចូលពន្ធនាគារ ហើយម្នាក់មិនបានឆ្លើយទៅសំណួរឡែលបានសួរ ។ ទាំងនេះវាបង្ហាញថាបុគ្គលិកពន្ធនាគារ មិនបានធានាឱ្យស្ត្រីមានផ្ទៃពោះទទួលបានការថែទាំសុខភាពខាងក្រៅព្រមទាំងមិនបាន ផ្តល់ការតាមដានការថែទាំសុខភាពនៅគ្រប់ករណីនោះទេ ។

ចំណុចមួយទៀតនៃផ្នែកទី៣ចំណុច៩ ពន្យល់ពីវិធានការណ៍ដែលត្រូវចាត់ការដើម្បីផ្តល់ម្ហូបអាហារ ដើម្បីបង្កើនការអភិវឌ្ឍន៍ និង សុខភាពរបស់កុមារទាំងឡាយ ។ វិធានការទាំងនេះរួមមាន :

- ធានាឱ្យម្តាយមានទឹកដោះចិញ្ចឹមកូន
- ផ្តល់វិតាមីនដល់ទារក ដែលមិនបានចិញ្ចឹមដោយទឹកដោះ និង ធានាឱ្យមានការសំអាតឧបករណ៍បំបៅដោះ( ដប កំប៉ុងទឹកដោះគោ ។ល។) ។
- អប់រំដល់មាតាបិតាអំពីអនាម័យនៃម្ហូប និង ចំណីអាហារសំរាប់កុមារ
- ស្វែងរកប្រភពម្ហូបអាហារ ដើម្បីបន្ថែមទៅលើម្ហូបអាហារដែលបានផ្តល់ឱ្យដោយពន្ធនាគារ ។

ក្នុងខណៈនេះ មានស្ត្រីដែលសំរាលកូនថ្មីៗ ជាច្រើនគ្មានលទ្ធភាពបំបៅដោះកូន ។ គ្មាននរណាម្នាក់ទទួលបានវិតាមីនសំរាប់ទារករបស់គេទេ ។ ផ្ទុយទៅវិញគេប្រើប្រាស់ទឹកបបរទឹកដោះគោដែលទិញមកពីក្រៅពន្ធនាគារដើម្បីទ្រទ្រង់កូនរបស់គេ ។ ក្នុងករណីតិចតួចណាស់ដែលបុគ្គលិកពន្ធនាគារបានផ្តល់អាហារបន្ថែម ។

ផ្នែកទី៣ ចំណុច៩ ក៏បានបញ្ជាក់ផងដែរថា បុគ្គលិកសុខភាពពន្ធនាគារត្រូវពិនិត្យមើលកុមារទាំងនោះឱ្យបានទៀងទាត់ និង "ឱ្យថ្នាំឱ្យបានត្រឹមត្រូវ" ។[៣៩] អ្នកធ្វើការសុខភាពក្នុងពន្ធនាគារ ជាញឹកញយមិនគោរពតាមសេចក្តីនេះទេ ដោយសារគេមិនមានថ្នាំសំរាប់ព្យាបាលកុមារនៅក្នុងឃ្លាំងរបស់គេ ( មើលករណីសិក្សាទី ១១ និង ១២ ) ។

---

[៣៩] *ផ្នែកទី ៥ ចំណុច ២នៃសៀវភៅដំណើការសុខភាព ក៏បានបញ្ជាក់ផងដែរ "កន្លែងផ្ទុកសម្ភារៈពេទ្យក្នុងមណ្ឌលសុខភាពពន្ធនាគារគឺត្រូវតែមានបរិមាណសមហេតុផល សំរាប់តម្រូវការចាំបាច់ "។*

ការទាមទារអោយមានការពិនិត្យដល់កុមារជាប្រក្រតី ដែលមានចែងក្នុងផ្នែកទី៣ចំណុច៩មិនត្រូវបានគេគោរព ។ ម្តាយជាច្រើនដែលត្រូវបានគេសំភាសន៏បានរាយការណ៏ថា កូនរបស់គេបានត្រួតពិនិត្យតែក្នុងករណីដែលមានបញ្ហារោគសញ្ញាស្មុគស្មាញ ហើយពួកគេមិនបានព្យាបាលអោយបានជាញឹកញាប់ទេ ។

ផ្នែកទាំងអស់នៃជំពូក៣.៩ ពិភាក្សាអំពីការស៊ាំរបស់ក្មេងដែលរស់នៅក្នុងគុក[៤០] ។ អាណត្តិវ៉ាក់សាំងរបស់ក្មេង ព្រមទាំងការអប់រំឪពុកម្តាយពីសារៈសំខាន់ពីការបន្តចាក់វ៉ាក់សាំងទៅតាមរយៈពេលបញ្ចប់របស់វា ។ ម្តាយជាច្រើននិងអ្នកបំរើការផ្នែកសុខភាពនៅក្នុងពន្ធនាគារបាននិយាយថា កូន ក្មេងរស់នៅក្នុងពន្ធនាគារនៅតែមិនទាន់បានចាក់វ៉ាក់សាំង[៤១] ដូចដែលបានបង្ហាញនៅក្នុងករណី សិក្សាទី ១៩ ។

ជាទីបញ្ចប់ ផ្នែកទី៧ នៃជំពូក៣.៩ បានទទួលស្គាល់តួនាទីដ៏សំខាន់របស់ឪពុកម្តាយក្នុងការថែរក្សាសុខភាពរបស់កូន" ត្រូវតែទទួលស្គាល់ថា ការអប់រំនិងការជំរុញការលើកកំកើងផ្នែកសុខភាពអោយបានសមស្រប ជាតំរូវការជាពិសេសសំរាប់ម្តាយដែលមានវ័យក្មេងដែលមានកូនជាលើកដំបូងក្នុងពេលដែលគេជាអ្នកទោស " ។ ជំពូកនោះបានស្នើបុគ្គលិកពន្ធនាគារអោយផ្តល់សំភារៈអប់រំផ្នែកសុខភាពក្នុងទំរង់មួយដែលអាចអោយម្តាយក្នុងពន្ធនាគារទទួលបាន ។ ទោះជាយ៉ាងណាក៏ដោយពន្ធនាគារដែលនិយាយនៅក្នុងរបាយការណ៏នេះកំរផ្តល់ការណែនាំដូច្នេះទេ ។ មានអ្នកធ្វើ ការខាងផ្នែកសុខភាពម្នាក់គត់បានរាយការណ៏ថា បាននិយាយជាមួយស្ត្រីជាប់ឃុំមានផ្ទៃពោះអំពីការថែទាំសុខភាពរបស់ទារកទើបនឹងកើតរបស់គេ ។ ដូចដែលបានថ្លែងរួចមកហើយនៅផ្នែកជាច្រើននៃសៀវភៅដំណើការសុខភាពផ្នែកទី៣ ចំណុច១២ ពន្យល់អំពីសិទ្ធិជនជាប់ឃុំឃាំង ។ ផ្នែកនេះ ផ្តល់សិទ្ធិឱ្យជនជាប់ឃុំឃាំងទទួលបានពតិមានពីថែទាំសុខភាពរបស់គេ និងចែងថាបុគ្គលិកសុខភាពពន្ធនាគារ"មានការទទួលខុសត្រូវមួយ" ដើម្បីផ្តល់ពតិមាននេះនៅក្នុងមធ្យាបាយដ៏ល្អប្រសើរនៅពេលត្រូវបានឱ្យថ្នាំ ឬព្យាបាលអ្នកជម្ងឺ ។ ក្រៅពីនេះ ស្ត្រីជាច្រើនមួយចំនួនបានរាយការណ៏ថា បានទទួលថ្នាំពេទ្យដោយមិនបានដឹងថា ប្រភេទថ្នាំអ្វី ឬវាត្រូវប្រើប្រាស់ដោយរបៀបណា ។

---

*៤០ ក្រោមសៀវភៅដំណើរការសុខភាព ស្តីពីការសំរបសំរួល ឧបករណ៏ ជំពូក ៥.៥ ដែលអោយឈ្មោះ" វ៉ាក់សាំង" ដែលបានចែងថា ការទទួលបានវ៉ាក់សាំង រឺសេវ៉ាវ៉ាក់សាំង ត្រូវនៅក្រោមអំណាចគ្រប់គ្រងរបស់" វិជ្ជបណ្ឌិត រឺ អ្នកព្យាបាល ដែលជា អ្នកដឹកនាំក្រុមកម្មវិធីសុខភាពនៅក្នុងពន្ធនាគារ ។ សេវ៉ាវ៉ាក់សាំងសំរាប់ក្មេង ក្រោមអាយុ ១៦ ឆ្នាំ គួតែត្រូវបានចរចារជាមួយសេវ៉ាសុខភាពក្មេងនឹងម្តាយ នៅក្នុងមូលដ្ឋាន ។*

[៤១] *យោងទៅលើផ្នែកទី ៦ នៃផ្នែកទី ៣ ចំណុច១១ ទារកទើបកើត ត្រូវតែចាប់ផ្តើមចាក់ថ្នាំបង្ក មុនពេលដែលគេបញ្ជូនវាត្រឡប់ទៅពន្ធនាគារវិញ ។*

### ៤) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៨ បានប្រកាសថា "រដ្ឋជាអ្នកការពារសិទ្ធិកុមារ ដូចដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ "ដោយរាប់បញ្ចូលទាំងការការពារ" គ្រប់សកម្មភាពទាំងឡាយដែលបង្ករឱ្យមានគ្រោះថ្នាក់ដល់ឱកាសសិក្សារបស់ពួកគេ សុខភាព និងសុខមាលភាព"។[៤២] ហេតុដូច្នេះ មាត្រា៤៨ នៃរដ្ឋធម្មនុញ្ញបានផ្តល់តម្លៃយ៉ាងច្រើនដល់ការវិភាគនៃកតិកាសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារដោយស្របទៅតាមកាលៈទេសៈនៃការរស់នៅរបស់កុមារក្នុងពន្ធនាគារ (មើលការពិភាក្សាមុខវិជ្ជានេះបន្ថែមទៀតនៅខាងក្រោម) ។ ដូចដែលបានពណ៌នាមកខាងលើ នៅក្នុងផ្នែកស្តីពីសិទ្ធិការពារនឹងដូចដែលបានបង្ហាញ តាមរយៈករណីសិក្សាកុមាររស់នៅក្នុងពន្ធនាគារហាក់ដូចជាមិនត្រូវបានការពារ ដូចដែលបានធានា ដោយរដ្ឋធម្មនុញ្ញកម្ពុជា ។

### ៥-កតិកាសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ(១៩៨៩) បានឱ្យសច្ចានុមតិដោយ ព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩២

មាត្រាជាច្រើននៅក្នុងកតិកាសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ គឺទាក់ទងទៅនឹងការពិភាក្សាលើសិទ្ធិ និងសុខមាលភាពកុមារកំពុងរស់នៅក្នុងពន្ធនាគារ ។ មាត្រា៣ ចំណុច១ ផ្តល់យ៉ាងសង្ខេបនូវបំណងនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារចែងថា "រាល់សកម្មភាពដែលទាក់ទងនឹងកុមារ,.. ផលប្រយោជនរបស់កុមារដ៏ល្អបំផុតនឹងត្រូវបានគេពិចារណាជាបឋម"[៤៣] ម្យ៉ាងវិញទៀត មាត្រា៦ ចំណុច២ និយាយថា "រដ្ឋភាគីទាំងអស់នឹងធានាពង្រីកដល់កំរិតអតិបរិមាដែលអាចធ្វើទៅបានចំពោះការរស់នៅ និង ការអភិវឌ្ឍន៏កុមារ"[៤៤] ។

មាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ចែងដោយផ្ទាល់ទៅនឹងករណីរបស់កុមារដែលកំពុងត្រូវបានគេចិញ្ចឹមនៅក្នុងមជ្ឈមណ្ឌលកែប្រែ ។ មាត្រា៩ ចំណុច១ ធានាថាកុមារនឹងត្រូវបានគេបំបែកពីឪពុកម្តាយរបស់គេ ប៉ុន្តែត្រូវបានត្រួតពិនិត្យមើលដោយសមត្ថកិច្ច ហើយការសំរេចនោះត្រូវតែជាកម្មវត្ថុពិនិត្យឡើងវិញដោយតុលាការ ។ វាហាក់ដូចជាមានសារៈសំខាន់ ។ ក្នុងករណីដូច្នេះ អ្វីទាំងអស់ដែលមានឥទ្ធិពលដោយការគ្រប់គ្រងមានសិទ្ធិចូលរួម និងបញ្ចេញគំនិតរបស់គេដោយយោងតាមសេចក្តីសំរេច (មាត្រា

---

[៤២] *សិទ្ធិស្របច្បាប់របស់កុមារកម្ពុជា ដោយ អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ទំព័រ ២៩០*

[៤៣] *សិទ្ធិស្របច្បាប់របស់កុមារកម្ពុជា ដោយ អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ទំព័រ ៧៤*

[៤៤] *សិទ្ធិស្របច្បាប់របស់កុមារកម្ពុជា ដោយ អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ទំព័រ ៧៥*

៩ ចំណុច) ។ លើសពីនេះ ដោយយោងទៅតាមមាត្រា៩ ចំណុច៣ កុមារ ម្នាក់ដែលត្រូវបានគេបំបែកពីឪពុកម្ដាយម្នាក់ ឬឪពុកម្ដាយទាំងពីរមានសិទ្ធិថែរក្សាទំនាក់ទំនងជាមួយឪពុកម្ដាយរបស់គេ ប្រសិនបើទំនាក់ទំនងនោះមិនធ្វើឱ្យខូចផលប្រយោជន៏ដល់កុមារ ។ ចុងបញ្ចប់មាត្រា ៩ ចំណុច១ និយាយយោងជាក់លាក់ទៅនឹងករណីដែលការបំបែកឪពុកម្ដាយនិងកូនចេញលទ្ធផលពីការឃុំខ្លួន ឬ ដាក់ពន្ធនាគារ ។ ក្នុងឧទាហរណ៍ទាំងនេះកុមារ ឬ សមាជិកក្រុមគ្រួសារដ៏ទៃ ទៀតមានសិទ្ធិទទួលដំណឹងពីកន្លែងដែលឪពុកម្ដាយរបស់គេត្រូវជាប ឃុំ ឬ ដាក់ពន្ធនាគារ ។ ជាថ្មីម្ដងទៀត លើកលែងតែក្នុងករណីកាលៈទេសៈដែលពតិមានទាំងនោះធ្វើអោយគ្រោះថ្នាក់ដល់កុមារ ។

អ្នកនិពន្ធរបស់អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ស្ដីពីច្បាប់កម្ពុជា និង កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិកុមារឱ្យយោបល់ទៅលើសារៈប្រយោជន៏នៃមាត្រា៩ ដោយយោងទៅតាមការបំបែកកុមារចេញពីឪពុកម្ដាយ ។

ក្រោមមាត្រា ៩(១) កតិកាសញ្ញាអន្តរជាតិ តម្រូវឱ្យរដ្ឋភាគីបង្កើតវិធានការ និងនីតិវិធីដែលបញ្ជាក់យ៉ាងច្បាស់នៅពេលដែលកុមារអាចត្រូវបានគេបំបែកពីឪពុកម្ដាយរបស់ពួកគេ ហើយមានតែសមត្ថកិច្ច ឬសមត្ថកិច្ចដែលទទួលស្គាល់តាមផ្លូវច្បាប់ធ្វើសេចក្ដីសំរេច ។ បន្ថែមលើនេះទៀត រាល់ភាគីដែលមានផលប្រយោជន៏ត្រូវតែមានឱកាសដើម្បីចូលរួមក្នុងដំណើរការធ្វើសេចក្ដីសំរេច ហើយមានគំនិតរបស់គេត្រូវតែបានដឹងដល់ "ភាគីដែលមានផលប្រយោជន៏",, រួមទាំងនរណាម្នាក់ដែលមានពតិមានដែលទាក់ទងនឹងសេចក្ដីសំរេចនេះ ។ ម្យ៉ាងវិញទៀត មាត្រា៩ បានផ្ដល់នូវនីតិវិធីយ៉ាងច្បាស់លាស់ថា រដ្ឋជាភាគីត្រូវអនុវត្តតាមពីមុនមកថា រដ្ឋអាចប៉ះពាល់ដល់សិទ្ធិកុមារដែលត្រូវតែបានថែទាំពីឪពុកម្ដាយរបស់គេ ។ ក្នុងក៏រិតអប្បបរិមា នីតិវិធីនេះត្រូវតែត្រឹមត្រូវសមរម្យ ។[៤៥]

អត្ថបទនៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិកុមារ ត្រង់មាត្រា៩ តម្រូវអោយ "មានសមត្ថកិច្ច" ឬ "អជ្ញាធរស្របច្បាប់" ទទួលខុសត្រូវចំពោះការសំរេចចិត្ត ថាតើឪពុកម្ដាយហើយនិងកូនគួរត្រូវបានបំបែកចេញពីគ្នា ។ ដោយផ្អែកទៅលើសារាចរលេខ១៥ ដូចដែលបានពិភាក្សាខាងលើ វាស្ដែងឱ្យឃើញថាព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ការិយាល័យអធិការកិច្ចការងារ និងអតិតយុទ្ធជន ដែលជាសមត្ថកិច្ចក្នុងការត្រួតពិនិត្យមើលកិច្ចការនេះ ។ ទោះជាយ៉ាងណាក៏ដោយ មធ្យោបាយដែលការិយាល័យនេះធ្វើហាក់ដូចជា សមត្ថកិច្ចដែលគេមិនស្គាល់ គឺជាក៏រិតនៃកិច្ចការ និង បទពិសោធន៏របស់គេដែលទាក់ទង

[៤៥] *ច្បាប់កម្ពុជា និង កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិកុមារ ទំព័រ ៧៩*

ទៅនឹងបញ្ហានៃការបំបែកឪពុកម្តាយពីកូន ។ បទសំភាសន៍ជាច្រើន មិនបានបង្ហាញភស្តុតាង ឬការវាយតំលៃណាមួយពីរដ្ឋអំណាចដែលទាក់ទង ថាតើកុមារម្នាក់គួរស់នៅជាមួយម្តាយរបស់វាក្នុងពន្ធនាគារទេ ។ ជាញឹកញយ ម្តាយបាននិយាយយ៉ាងសាមញ្ញថា នាងបានយកកូនរបស់នាងទៅពន្ធាគារជាមួយ នៅពេលដែលនាងជាប់គុក ។ ក្នុងករណីកូនទើបនឹងកើត វាហាក់ដូចជាស្តែងចេញនូវការសន្មត្មមួយថា ទារកទើបនឹងកើតគួរនៅក្នុងពន្ធាគារជាមួយម្តាយ ។ ទាក់ទងនឹងចំនុចនេះ គ្មានការវិភាគណាមួយ ថាតើនេះគឺជាការពិតក្នុងការរក្សាផលប្រយោជន៍ដ៏ល្អប្រសើរបំផុតសំរាប់កុមារ ។[៤៦]

បន្ថែមពីលើនេះទៀត, ដូចដែលបានគូសបញ្ជាក់ នៅក្នុងការពិភាក្សាសារាចរលេខ១៥ និង សេចក្តីប្រកាស់លេខ២១៧ ប្រទេសកម្ពុជា ហាក់បីដូចជាមិនបានបង្កើត "បញ្ញាតិច្បាប់ និង និតិវិធីដែលបញ្ជាក់យ៉ាងច្បាស់ថា ក្នុងពេលណាកុមារអាចត្រូវបានគេបំបែកចេញពីឪពុកម្តាយរបស់ពួកគេ" ដូចដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ។

ស្រដៀងគ្នានេះដែរ មាត្រា៣ ចំណុច៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារធ្វើការការពារទៅលើការបំបែកកុមារចេញពីឪពុកម្តាយរបស់ពួកគេ ប៉ុន្តែជាថ្មីម្តងទៀតបានបើកឱកាសអោយរដ្ឋដើម្បីកំណត់ពីភ្នាក់ងារសមត្ថកិច្ច និងបុគ្គលណាមួយដែលទាក់ទិនក្នុងការថែទាំកុមារ :" រដ្ឋភាគីនឹងធានាថា ស្ថាប័ន សេវាអាគារដែលទទួលខុសត្រូវចំពោះការការពារ និង ថែទាំកុមារ និងត្រូវធ្វើឡើងស្របទៅនឹងកំរិតគំរូដែលបង្កើតឡើងដោយសមត្ថកិច្ច ជាពិសេសនៅក្នុងវិស័យសុវត្ថភាព និងសុខភាពនៅក្នុងចំនួន និង ភាពសមរម្យនៃបុគ្គលិករបស់គេក៏ដូចជាសមត្ថកិច្ចគ្រប់គ្រង ។"[៤៧] ទាក់ទងទៅនឹងប្រទេសកម្ពុជាមាត្រា៣ ចំណុច៣នាំអោយមានសំណួរដូចតទៅ : តើកំរិតគំរូត្រូវបានគេបង្កើតឡើង ដោយសមត្ថកិច្ចដែលមានសមត្ថកិច្ចគ្រប់គ្រាន់នៃអ្នកថែទាំសុខភាពអាចត្រូវបានគេធានាឬទេ ? ជាថ្មី ម្តងទៀតច្បាប់ថ្មី១និងការអនុវត្តមិនបានផ្តល់ការធានាច្បាស់លាស់ពីសមត្ថកិច្ចដូចនេះទេ ។ ចំណុចសំខាន់សមត្ថភាពពន្ធាគារដើម្បីផ្តល់ការថែទាំកុមារអោយបានត្រឹមត្រូវ មិនត្រូវបានគេពិនិត្យមើល ឬពិនិត្យមើល ដោយខ្លួនឯងទេ ។

---

[៤៦] *ទោះជាយ៉ាងណាក៏ដោយ វាមានការយល់ព្រមជាទូទៅថាកុមារ ដែលនៅតែកំពុងបៅដោះម្តាយគួរមិនត្រូវបានគេបំបែកចេញពីម្តាយរបស់គេ ។ នេះមិនមានជាបញ្ហាទេ ប្រសិនបើម្តាយមិនមានលទ្ធិភាពថែទាំកូនរបស់គេ ឬប្រសិនបើមានក្នុងករណីខ្លះដែលបានពណ៌នាក្នុងឯកសារនេះ ម្តាយគឺមិនអាច ចិញ្ចឹមទារករបស់គេបានល្អប្រសើនោះទេ ។*

[៤៧] *ច្បាប់កម្ពុជា និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ទំព័រ ៤៤*

ក្នុងខណៈពេលឪពុកម្តាយមានការទទួលខុសត្រូវជាចម្បងចំពោះការរស់នៅនៃកូនរបស់គេ ដោយយោងទៅតាមមាត្រា១៨ ចំណុច១ [៤៨] មាត្រានៃកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារជំរុញអោយមានការអនុវត្តតួនាទីរបស់រដ្ឋបន្ថែមទៀត ដើម្បីធានាអោយមានការថែទាំ និងការពារកុមារអោយបានត្រឹមត្រូវក្នុងកាលៈទេសមិនប្រក្រតី ។ នេះរួមទាំងការផ្តល់" ជំនួយអោយបានសមរម្យ " ចំពោះមាតាបិតា និងជនដែលចិញ្ចឹមកុមារផ្សេងទៀត ក៏ដូចជាការអភិវឌ្ឍន៍សេវា និងអាគារថែទាំកុមារ (មាត្រា១៨ ចំណុច២) ។ វារួមទាំងការចាត់វិធានការណ៍ទាំងអស់ដែលចាំបាច់ ដើម្បីការពារកុមារពីការរំលោភបំពាន និងការធ្វេសប្រហែសដោយសារអ្វីមួយ ទោះជាមានការលំបាកបែបណាក៏ដោយ ដើម្បីស្នើសុំឱ្យស្ថាប័ននៃសេវាកម្ម សង្គមជួយកុមារ និងអ្នកថែរក្សាររបស់ពួកគេ (មាត្រា១៩.១ និង ១៩.២ ចែងដូច្នេះ) ។ "ប្រសិនបើពួកគេមិនអាចរស់នៅក្នុងស្ថានភាពគ្រួសាររបស់ពួកគេបែបណាមួយ "រដ្ឋមិនត្រឹមតែការពារ និងជួយកុមារប៉ុណ្ណោះទេ រដ្ឋក៏ត្រូវតែធានានូវការយកចិត្តទុកដាក់ថែរក្សាតាមការជ្រើសរើសរបស់ពួកគេ ដូចមានចែងនៅក្នុងច្បាប់ជាតិ (មាត្រា២០.១ និង២០.២ ) ។ មធ្យោបាយជំរើសនៃការថែរក្សារបស់កុមារបែបនោះមិនត្រូវបានធានាដោយម្តាយ និង អ្នកជាប់ឃុំឃាំងដែលមានផ្ទៃពោះ ឬ អ្នកជាប់ឃុំ បណ្តោះអាសន្នមុនពេលសវនាការឡើយ ។

ខ្លឹម សារដែលមានសារៈសំខាន់ប្រហាក់ប្រហែលគ្នាគឺមាននៅក្នុងមាត្រាទី ២៧. ១ ដែលចែងថា :

រដ្ឋជាភាគីត្រូវទទួលស្គាល់សិទ្ធិរបស់កុមារគ្រប់ៗរូបទៅតាមកំរិត នៃការរស់នៅគ្រប់គ្រាន់សំរាប់ការអភិវឌ្ឍន៍រូបរាងកាយ ប្រាជ្ញា ស្មារតី សីលធម៌ និង សង្គម។

ដោយសំអាងលើមាត្រា២៧. ២ ឪពុកម្តាយ ឬអាណាព្យាបាលត្រូវទទួលខុសត្រូវជាចំបង ចំពោះការធានាដល់កំរិតនៃការរស់នៅបែបនោះ ។ យ៉ាងណាក្តី មាត្រាទី២៧.៣ តំរូវឱ្យរដ្ឋជាភាគីចាត់វិធានការណ៍ឱ្យបានសមស្រប ដើម្បីជួយឪពុកម្តាយ និងអ្នកដ៏ទៃទៀត ដែលទទួលខុសត្រូវចំពោះកុមារឱ្យអនុវត្តសិទ្ធិនេះ ហើយក្នុងករណីណាដែលចាំបាច់ត្រូវផ្តល់ជំនួយផ្នែកសម្ភារៈ និង កម្មវិធីឧបត្ថម្ភផ្សេងៗជាពិសេសគឺអ្វីដែលទាក់ទងដល់ចំណីអាហារ សំលៀកបំពាក់ និង ជំរក ។[៤៩]

មាត្រាខាងលើបង្ហាញឱ្យឃើញច្បាស់ថា រដ្ឋអាចទទួលខុសត្រូវមិនត្រឹមតែភ្នាក់ងារគាំទ្រ និងបុគ្គលទាំង ឡាយក្នុងការថែរក្សា និងការពារកុមារប៉ុណ្ណោះទេ ក៏ថែមទាំងធានាថា ការថែរក្សាដែលមានការយល់ដឹងដ៏ពេញលេញ និងត្រឹមត្រូវអាចផ្តល់ទៅឱ្យកុមារបាន ។ ការសិក្សារឿងក្តីបង្ហាញថា ម្តាយនិងស្ត្រីមាន

---

[៤៨] *សិទ្ធិស្របច្បាប់របស់កុមារកម្ពុជា ដោយអង្គការជំនួយផ្នែកច្បាប់ទំព័រ ៧៨ ។*

៤៩ សិទ្ធិស្របច្បាប់របស់កុមារកម្ពុជា ដែលរៀបរៀងឡើងដោយ ឡាជ ទំព័រ ៧៨-៨២។

ផ្ទៃពោះដែលជាប់គុក មិនត្រូវបានស្នើសុំឱ្យមានការគាំទ្របែបនោះទេ ថ្វីត្បិតតែហេតុការណ៍បង្ហាញឱ្យឃើញថា ជារឿយៗពួកគេបញ្ចេញឱ្យឃើញនូវសេចក្តីត្រូវការ ។ ក៏មានការទាក់ទងដែរ គឺអនុសញ្ញាស្តីពីសិទ្ធិរបសកុមារ (CRC) មាត្រា២.២ ដែលហាមឃាត់មិនឱ្យមានការរើសអើងឬទណ្ឌកម្មប្រឆាំងនឹងកុមារដោយសារតែអកប្បកិរិយានៃឪពុកម្តាយគ្រួសារ ឬអាណាព្យាបាលរបស់ពួកគេ ។ ក្នុងករណីដែលកុមារស្ថិតនៅជាមួយនឹងឪពុកម្តាយដែលជាប់ឃុំ មាត្រា ២. ២មានគោល បំណងធានាថា កុមារមិនត្រូវបានគេរើសអើងប្រឆាំងឡើយ ដោយសារតែស្ថានភាពរបស់ឪពុកម្តាយជាអ្នកជាប់ឃុំ ឬ អ្នកទោសជាប់គុកបណ្តោះអាសន្នមុនពេលសវនាការដែរ ។[៥០] ការពិភាក្សាខាងលើអំពីការការពារសិទ្ធិរបស់កុមារលើកឡើងឱ្យឃើញនូវការអនុវត្តន៍មាត្រានេះចំពោះកុមារដែលរស់នៅក្នុងគុក ។ អនុសញ្ញាស្តីអំពីសិទ្ធិរបស់កុមារ (CRC) បានចែងយ៉ាងជាក់លាក់អំពីការថែរក្សាសុខភាពរបស់កុមារផងដែរ ជាពិសេសមាត្រា ២៤. ១ គួរឱ្យកត់សម្គាល់ :

> រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារអំពីការរីករាយនូវកំរិតសុខភាពដែលអាចទទួលបានយ៉ាងខ្ពស់ និង ការសំរបសំរួលទីកន្លែងព្យាបាលជំងឺ និង ធ្វើឱ្យសុខភាពកាន់តែប្រសើរឡើង ។ រដ្ឋជាភាគីត្រូវព្យាយាមធានាថា គ្មានកុមារណាម្នាក់ត្រូវបានគេដកហូតសិទ្ធិរបស់ខ្លួន មិនឱ្យទទួលបានសេវាកម្មថែរក្សាសុខភាពដូចមានចែងឡើយ ។[៥១]

ដូចយើងបានឃើញស្រាប់ កុមារដែលរស់នៅក្នុងគុកមិនត្រូវបានគេផ្តល់អាទិភាពនេះ និងមិនត្រូវបានគេផ្តល់ចំណី "អាហារគ្រប់គ្រាន់ និងទឹកស្អាតទទួលទានដូចមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិរបស់កុមារឡើយ (CRC) : ។

ជាអវសាន្ត CRC ទទួលស្គាល់តួនាទីរបស់រដ្ឋជាភាគី ដើម្បីធានាឱ្យកុមារទទួលបានការអប់រំ។ មាត្រា ២៨.១ ចែងថា " រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារឱ្យមានការទទួលបាននូវការអប់រំ " ហើយដើម្បីធានាឱ្យកុមារទទួលបាននូវការអប់រំរ ដ្ឋជាភាគីត្រូវចាត់វិធានការណ៍រួមមាន "ធ្វើការជំរុញឱ្យចូលរៀននៅសាលាបឋមសិក្សាដោយមិនយកកំរៃដល់កុមារទាំងអស់ "។[៥២] មិនទាន់គ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌនៅឡើយ

---

*៥០ ចំណុចនេះជាប់ទាក់ទងនឹងសារាចរលេខ ១៥ ដែលប្រកាសថា ទារកដែលកើតនៅក្នុងពន្ធនាគារ មិនអាចមានសំបុត្រកំណើតដែលឆ្លុះ បញ្ចាំងនូវកន្លែងកំណើតបែបនេះ ។*

*៥១ សិទ្ធិស្របច្បាប់របស់កុមារកម្ពុជា ដែលរៀបរៀងឡើងដោយ LAC ទំព័រ ៨០ ។*

*៥២ សិទ្ធិស្របច្បាប់របស់កុមារកម្ពុជា ដែលរៀបរៀងឡើងដោយ LAC ទំព័រ ៨២ ។*

ទេ កុមារដែលរស់នៅក្នុងគុកបានទទួលការអប់រំជាអប្បបរិមា និងមិនអាចទទួលការសិក្សានៅសាលាបឋមសិក្សាបានល្អទេ ។

**៦. បទដ្ឋានអប្បបរិមានៃបទវិន័យរបស់អង្គការសហប្រជាជាតិសំរាប់គ្រប់គ្រងអ្នកទោសដែលបានអនុម័តជាបឋមដោយសភាអង្គការ សហប្រជាជាតិស្ដីអំពីការទប់ស្កាត់បទល្មើស និងការគ្រប់គ្រងជន ល្មើស ឆ្នាំ ១៩៥៥ ។**

ទោះបីជាបទដ្ឋានអប្បបរិមានៃបទវិន័យរបស់អង្គការសហប្រជាជាតិសំរាប់គ្រប់គ្រងអ្នកទោស គួសបញ្ជាក់នូវនីតិវិធីដែលចង់បាន ដើម្បីថែរក្សាអ្នកជាប់ពន្ធនាគារក្នុងវិស័យទាក់ទងដ៏ច្រើនក៏ដោយ ចំពោះគោលបំណងនៃរបាយការណ៍នេះមានតែវិធានអស់ទាំងនោះទេ ដែលទាក់ទងម្ដាយ និងកូនឬក៏ស្ត្រីមានផ្ទៃពោះនៅក្នុងគុកដែលនឹងត្រូវយកមកពិភាក្សា។

មាត្រា២៣ ក្នុងផ្នែក១ នៃបទដ្ឋានអប្បបរិមានៃបទវិន័យ " វិធាននៃការអនុវត្តន៏ជាទូទៅ " ចែងអំពី សេចក្ដីសង្ឃឹមចំពោះការយកចិត្តទុកដាក់ទៅលើអ្នកទោសជាប់គុកដែលមានផ្ទៃពោះ។ មាត្រា២៣.១ ទាមទារឱ្យមាន "ទីស្នាក់នៅជាពិសេស " សំរាប់ការថែរក្សា និង ព្យាបាលមុននិង ក្រោយផ្ដល់កំណើត ទោះបីជាវាមិនបានបញ្ជាក់ឱ្យ បានល្អិតល្អន់នូវអ្វីដែលមានការផ្ដល់ការស្នាក់នៅបែបនោះក៏ដោយ ។ តាមសេចក្ដីប្រកាសលេខ២១៧ របស់ប្រទេសកម្ពុជា ដែលបានពិភាក្សាខាងលើ មាត្រា២៣.១កំណត់ថា ស្ត្រីជាប់ឃុំដែលមានផ្ទៃពោះ និងស្ត្រីជាប់ឃុំបណ្ដោះ អាសន្នមុនពេលសវនាការ គួរតែឱ្យឆ្លងទន្លេនៅមន្ទីរពេទ្យជាជាងនៅក្នុងគុក " ដែលបានអនុវត្តជាទម្លាប់ " ហើយប្រសិនបើ ទារកកើតនៅក្នុងគុកលិខិតកំណើតរបស់ទារកនោះ មិនគួរចុះនៅក្នុងបញ្ជីកំណើតដាក់ថាកើតនៅក្នុងគុកឡើយ ។ យ៉ាងណាក្ដីសូមបញ្ជាក់ម្ដងទៀតថា ភាសានៃមាត្រាមិនបានផ្ដល់ការពន្យល់ឱ្យបានច្បាស់លាស់ថា តើនៅពេលណាដែលត្រូវពិចារណាថា មិនអាចអនុវត្តបានចំពោះស្ត្រីដែលផ្ដល់កំណើតនៅខាងក្រៅគុក។

តើចំនុចនេះគ្រាន់តែសំដៅទៅកាន់ស្ថានភាពដែលការឆ្លងទន្លេរបស់ម្ដាយត្រូវការពេលយ៉ាងឆាប់រហ័សមិនអាចធ្វើទៅបានចំពោះតំរូវការទៅមន្ទីរពេទ្យ ឬមួយក៏ជាការអនុវត្តន៏ទៅតាមស្ថានភាពមួយ ដែលស្ត្រីឬស្ថាប័នពន្ធនាគារមិនអាចផ្ដល់ថវិការសំរាប់បញ្ជូនទៅពេទ្យ ? ភាពមានន័យមិនច្បាស់លាស់នៃភាសាបណ្ដោយឱ្យមានការអត់ឱនជាច្រើនក្នុងការបកស្រាយបទដ្ឋាន ។

ដោយមិនគិតពីមាត្រា២៣ ដែលមិនបានយល់ស្របដោយយោងទៅតាមគំហើញនៃការស្រាវជ្រាវ។ គ្មាន អ្នក ដែលត្រូវគេសម្ភាសន៏ណាក្នុងចំណោមអ្នកដែលត្រូវគេសម្ភាសន៏ទាំងឡាយ ដែលបច្ចុប្បន្ននេះមាន

ផ្ទៃពោះ ឬកើតកូននៅក្នុងគុកឡើយ ក្នុងខណៈពេលក្នុងពន្ធនាគារបានទទួល "ការស្នាក់នៅជាពិសេស " ។ បន្ថែមលើពីនេះដូចដែលបានពិភាក្សារួចមកហើយ ទណ្ឌិត និង ជនជាប់ឃុំបណ្តោះអាសន្ន ជានិច្ចជាកាល មិនត្រូវបានគេអនុញ្ញាតិអោយសំរាលកូននៅក្នុងមន្ទីរពេទ្យទេ នេះស្តែងចេញថា វាជាកន្លែងដែលគេអាចអនុវត្ត ។

ការកត់សំគាល់ជាពិសេស និងត្រូវបានគេធ្វើឡើងដោយយោងតាមមាត្រា២៣ ចំណុច២ នៃបទដ្ឋានអប្បបរមានៅក្នុងខណៈនេះ វាគឺជាឧបករណ៍នីតិវិធីដែលយោងទៅនឹងមធ្យោបាយនៃការថែរក្សាទារកក្នុងពន្ធនាគារ ។ មាត្រានេះតម្រូវអោយពន្ធនាគារដែលមានទារកនៅបៅដោះផ្តល់អោយមានអ្នកមើលទារកដែលមានគុណសម្បត្តិនៅកន្លែងណាដែលទារកនឹងត្រូវបានគេផ្ញើរអោយថែរក្សានៅពេល ដែលកុមារទាំងនោះមិនមានការថែទាំពីឪពុកម្តាយ ។ ដូចដែលបានឃើញនៅក្នុងការពិភាក្សាខាងលើអំពីច្បាប់ និងនីតិវិធីពន្ធនាគាររបស់ប្រទេសកម្ពុជាមកដល់ពេលនេះគ្មាននយោបាយជាតិណាមួយ ដែលបង្ខំអោយអនុវត្តបទដ្ឋាននេះត្រូវបានគេធ្វើឡើងទេគ្មានពន្ធនាគារណាមួយដែលមាននៅក្នុងការសិក្សានេះមានអ្វី១ដែលតំណាងអោយអ្នកថែទាំកុមារដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីផ្តល់ការថែទាំដល់កុមារនោះទេ ។ ដូចដែលបានផ្តល់នៅក្នុងករណីសិក្សាខាងលើ និងភស្តុតាងពីប្រភពតិចតួចនៅក្នុងមជ្ឈមណ្ឌលពន្ធនាគារវាមានការលំបាកដើម្បីប្រមើលមើលចំពោះការអនុវត្តលក្ខ័ណនេះ ។ ផ្ទុយទៅវិញទារករស់នៅស្ថិតនៅក្រោមការថែទាំនៃម្តាយរបស់គេ អ្នកជាប់ឃុំឃាំងផ្សេងទៀត ឬអ្នកមើលកុមារផ្សេងទៀត ។

**៧) -បទដ្ឋានអប្បបរិមារបស់អង្គការសហប្រជាជាតិស្តីពីការគ្រប់គ្រងយុត្តធមិនៃអនីតជន ( បទបញ្ញាតិទីក្រុងបេកាំង) ដែលបានអនុម័តដោយមហាសន្និបាទរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ២៩ វិច្ឆិការ ១៩៨៥**

ទោះបីជាបទបញ្ញាតិបេកាំងដោះស្រាយជាបឋមចំពោះការប្រព្រឹត្តមកលើជនល្មើសជាអនីតិជន ក៏ប៉ុន្តែមានផ្នែកខ្លះនៃឯកសារដែលបញ្ចូលទៅក្នុងប្រធានបទនៃការសិក្សានេះ ។ ក្នុងផ្នែកទីមួយនៃបទបញ្ញាតិគោលការណ៍ទី១ ចំណុច២ ប្រកាសថា " សមាជិករដ្ឋជាភាគី ត្រូវតែខិតខំប្រឹងប្រែងអភិវឌ្ឍន៏លក្ខ័ខណ ដែលនឹងធានាអោយបានដល់អនីតិជន អោយមានជីវិតថ្លៃថ្នូរនៅក្នុងសង្គម ដែលនឹងធ្វើអោយដំនើរការអភិវឌ្ឍន៍ និង ការអប់រំរបស់គេបានល្អប្រសើរ ដែលរួចផុតពីការប្រព្រឹត្តបទល្មើស និងអំពើមិនល្អដែលក្នុងរយះពេលនោះ កុមារអាចងាយស្រួលទទួលបានចារិកព្រហ្មទណ្ឌ ។"[៥៣]

---

[53] សិទ្ធិស្របច្បាប់របស់កុមារកម្ពុជា ដោយអង្គការជំនួយផ្នែកច្បាប់ ទំព័រ ១០៥

ក្នុងខណៈពេលនេះ វាជួបប្រទះការលំបាក ដើម្បីពិនិត្យមើលថាតើបទបញ្ញាតិដូច្នេះត្រូវបានគេអនុវត្ត ការអនុវត្តនៃបញ្ញាតិនេះសំរាប់កុមារដែលកំពុងរស់នៅក្នុងពន្ធនាគារ គឺអាចមានបញ្ហា ។ ផ្នែកខាងលើដែល បាននិយាយលំអិតពីសិទ្ធិនៃការអភិវឌ្ឍន៏របស់កុមារផ្តោតលើបញ្ហានៃការអប់រំ និងអភិវឌ្ឍន៏ផ្ទាល់ខ្លួន ។ គោលការណ៏ទី១ ចំណុច២ លើកឡើងសំណួរថា តើវាអាចធ្វើទៅបានចំពោះពន្ធនាគារឬទេ ដើម្បីធ្វើអោយ បរិយាកាសល្អប្រសើរចំពោះកុមារទាំងឡាយ ជាពិសេសចំពោះកុមារទាំងឡាយដែលខ្លួនរបស់គេមិនបាន ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។ សេចក្តីអធិប្បាយមួយផ្នែកនៃផ្នែកទី២នៃបទបញ្ញាតិបេកាំងចែងយ៉ាងច្បាស់ អំពីចំណុចនេះនៅក្នុងខ្លឹមសារនៃជនជាប់ឃុំឃាំងជាអនីតិជន "ភាពគ្រោះថ្នាក់ចំពោះអនីតិជនដែលមានគំនិត ទុច្ចរិតក្នុងខណៈពេលត្រូវបានគេឃុំខ្លួនរងចាំសវនាការមិនត្រូវបានគេប្រមាណមើល "។[៥៤] វាហាក់ដូចជា សមហេតុផលចំពោះការឆ្លងចារិកព្រហ្មទណ្ឌចំពោះកុមារដែលកំពុងរស់នៅក្នុងចំណោមទណ្ឌិត និងជនជាប់ ឃុំបណ្តោះអាសន្ននេះអាចបណ្តាលអោយមានការព្រួយបារម្ភពីលទ្ធភាពនៃការឆ្លងចារិកព្រហ្មទណ្ឌចំពោះកូន របស់ជនជាប់ឃុំបណ្តោះអាសន្ន ក៏ដូចជាកូនរបស់ទណ្ឌិត ។

## VII- ការស្វែងរកដំណោះស្រាយ :

### ទាហរណ៏នៃវិធីចម្លាស់ក្នុងការថែទាំកុមារ កូនៗរបស់ពួកគេ និង ស្រ្តីមានផ្ទៃពោះជាប់ពន្ធនាគារ ។

បញ្ហាដែលថា តើកុមារ និង ទារក គួររស់នៅក្នុងពន្ធនាគារដែរឬទេនោះ វាបញ្ហាស្មុកស្មាញមួយ ហើយដើម្បី ដោះស្រាយវាអោយសមរម្យ តំរូវអោយមានការពិភាក្សាស៊ីជំរៅជាងរបាយការណ៏នេះ ។ ការស្រាវជ្រាវបាន រកឃើញទាំងចំណុចវិជ្ជមាននិងអវិជ្ជមានចំពោះកុមារដែលរស់នៅជាមួយម្តាយក្នុងពន្ធនាគារ។ ក្រុមប្រឹក្សា អឺរុប បានលើកឡើងបញ្ហានេះ កាលពីឆ្នាំ ២០០០ កន្លងទៅ នៅក្នុងរបាយការណ៏របស់គណកម្មការ សង្គម សុខាភិបាល និងកិច្ចការគ្រួសារៈ " ពន្ធនាគារមិនបានផ្តល់បរិយាកាសសមរម្យដល់ទារក កុមារតូចៗ ច្រើន តែបណ្តាលអោយមានការយឺតយ៉ាវដល់ការលូតលាស់ក្នុងរយៈពេលយ៉ាងវែងរបស់កុមារ ។ បើសិនជាកុមារ នោះត្រូវបង្ខំអោយបំបែកចេញពីម្តាយថែមទៀតនោះ គេនឹងទទួលរងការខូចខាតផ្លូវចិត្ត និង ផ្នែកសង្គមជា អចិន្ត្រៃយ៏[៥៥] ។ របាយការណ៏នេះឆ្លុះបញ្ចាំងនូវគំនិតផ្ទុយគ្នាមួយដែលច្រើនតែកើតមានការពិភាក្សាជុំវិញ ប្រធានបទនេះ ។ សេចក្តីអនុសាសន៏ និងអនុស្សរណៈពន្យល់របស់គណកម្មាធិការ ក៏បានបង្ហាញនូវ

---

[៥៤] *សិទ្ធិស្របច្បាប់របស់កុមារកម្ពុជា ដោយអង្គការជំនួយផ្នែកច្បាប់ ទំព័រ ១១៤ ។*

[៥៥] *ស្បែរម៉េន : សភាពនៃមាតាពពិភពលោក ឆ្នាំ ២០០០ ទំព័រ ១០-១១*

ភាពស្ទាក់ស្ទើរមួយក្នុងការទុកឬមិនទុកកុមារអោយរស់នៅក្នុងពន្ធនាគារ ខណៈដែលគេនៅតែព្យាយាមពិចារណាអំពីផលប្រយោជន៍ ដ៏ល្អបំផុតរបស់ កុមារ និង ទារក ។

អ្នកជំនាញជាច្រើនបានឯកភាពថា ការឆាប់បំបែកកូនចេញពីម្តាយ វានឹងបណ្តាលអោយការពិបាកយ៉ាងយូរអង្វែងច្រើន រួមមានការអន់ថយក្នុងការភ្ជាប់ចំណងជាមួយអ្នកដទៃ ពិបាកសម្របសម្រួលផ្នែកអារម្មណ៍ និងបញ្ហាវិបល្លាស់ក្នុងជីវិត ។ ចំណុចនេះក៏ត្រូវបានទទួលស្គាល់ដែរថា ការលូតលាស់របស់ទារកតូចៗ ត្រូវបានពន្យឺតដោយសារការពុំមានកត្តាជំរុញផ្សេងៗ ពីសំណាក់មនុស្សដែលជិតស្និត ។ វាជាផលប្រយោជន៍ដ៏ល្អបំផុតរបស់ទារកទើបនឹងកើតឬកុមារតូចៗក្នុងការដែលបានរស់នៅជាមួយនឹងមាតា ។

ការបង្ខំអោយបែកចេញពីម្តាយតាំងពីកំណើតមក ឬ តាំងពីនៅអាយុខ្ចីពេក គឺធ្វើអោយមានការប៉ះពាល់យ៉ាងខ្លាំងដល់ការលូតលាស់ផ្នែកសុខភាពរបស់កុមារ ហើយក៏នៅធ្វើអោយដាច់ទំនាក់ទំនងរវាងម្តាយ និងកូនទៀតផង ។ ការបំបៅកូនដោយទឹកដោះ ត្រូវបានទទួលស្គាល់ថា ជាការផ្តល់នូវអាហារនិងអារម្មណ៍ដំបូង ដ៏ប្រសើរបំផុតចំពោះជីវិត [៥៦] ។

នៅផ្នែកខាងក្រោមនៃរបាយការណ៍ ក៏បានបញ្ជាក់យ៉ាងច្បាស់ផងដែរនូវភាពទាល់ច្រក់សេចក្តីសន្និដ្ឋានសំខាន់នៃរបាយការណ៍នេះគឺ ពន្ធនាគារធ្វើអោយប៉ះពាល់ដល់កុមារតូចៗ ប៉ុន្តែការបំបែកចេញពីមាតាគឺជាភាពព្រៃផ្សៃ និងអមនុស្សធម៌ ហេតុនេះហើយគេត្រូវតែរកវិធីថ្មីមួយសំរាប់អនាគតដើម្បីគ្រប់គ្រងមាតាដែលបានប្រព្រឹត្តិបទល្មើស [៥៧] ។ របាយនោះក៏នូវបានបង្ហាញនូវឧទាហរណ៍មួយចំនួននៃវិធីចម្លាស់ផ្សេងៗក្នុងការផ្តន្ទាទោសមាតាដែលមានកូនតូចៗ ។

---

[៥៦] *ស្សេរី ប្រោន និងសហការី :ច្បាប់កម្ពុជា និង អនុសញ្ញាស្តីពីសិទ្ធិកុមារ : ការសិក្សាប្រៀបធៀប ( ភ្នំពេញ LAC ឆ្នាំ ១៩៩៨ ទំព័រ ៤៧ ។*

[៥៧] *) អេដវីន ស៊ី ហ្វូស្តេធី និង ដូរូធា ធី ជីណា សង្ខេបការស្រាវជ្រាវគ្រួសាររបស់អ្នកជាប់ពន្ធនាគារ ( ក្រុមសមគមពន្ធនាគារឆ្នាំ១៩៩៣) ទំព័រ ៧ ។*

របាយការណ៍របស់គណកម្មាធិការ ក៏បានឆ្លើយតបទៅនិងអនុសាសន៍ ក្នុងមាត្រាទី ៩ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារផងដែរ ដូចដែលបានពន្យល់ខាងក្រោម នៅក្នុងសេចក្តីដកស្រង់ចេញពី *ច្បាប់កម្ពុជា និង អនុសញ្ញាស្តីពីសិទ្ធិកុមារ:*

> ការស្រាវជ្រាវអំពីការអភិវឌ្ឍន៍របស់កុមារបានគាំទ្រសិទ្ធិកុមារ ដែលត្រូវបានថែទាំដោយមាតាបិតាជាពិសេសនៅក្នុងកំឡុងពេលពីរបីឆ្នាំដំបូងនៃ ជីវិត ។ ទោះបីជា (សារាចរលេខ ១៥) បានចែងឡើងដើម្បីការពារផលប្រយោជន៍របស់កុមារក៏ដោយ ក៏នៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ និយាយថាការបំបែកកូនចេញពីមាតា ត្រូវតែធ្វើនៅក្នុងដំណោះស្រាយចុងក្រោយ បង្អស់ ដើម្បីធានាអោយបាននូវសិទ្ធិទទួលការថែទាំរបស់កុមារពីមាតាបិតា ការមិនអនុវត្តដូច្នេះលុះត្រាតែវាពុំបានបំរើប្រយោជន៍ដ៏ល្អបំផុតរបស់ពួកគេ។
>
> ហេតុនេះហើយ គេគួរតែពិចារណាអំពីវិធីចម្លាស់ផ្សេងពីពន្ធនាគារវិញសំរាប់មាតាមានកូនតូចធ្វើដូច្នេះទើបអាចអោយមានទំនាក់ទំនងរវាងម្តាយឪពុកនិងកូនបាន បើសិនជាទំនងនោះមិនទុក្ខទោសដល់កុមារទេ[៥៨] ។

នៅផ្នែកចុងក្រោយនៃកថាខ័ណ្ឌ បានសង្កត់ធ្ងន់ទៅលើជំរើសមួយចំនួនក្នុងការផ្តន្ទាទោស ដែលអាចអោយក្នុងទំនាក់ទំនងរវាងមាតាបិតានិងកូនរីកចំរើនបានឆ្លុះបញ្ចាំងនូវទស្សនៈដែលយល់ច្បាស់ថា ការមិនបានរក្សាអោយមានទំនាក់ទំនងរវាងម្តាយឪពុកនិងកូនអាចបណ្តាលបាត់បង់ការអភិវឌ្ឍន៍របស់កុមារ ។ចំណងដ៏រឹងមាំនៅក្នុងគ្រួសារ គឺជាចំណុចមួយយ៉ាងសំខាន់សំរាប់កុមារជាពិសេសនៅក្នុងកាលៈទេសៈដ៏លំបាក១ ដូចជាកាលៈទេសៈដែលកូនរស់នៅជាមួយមាតាក្នុងពេលជាប់ពន្ធនាគារជាដើម ។ របាយការណ៍ឆ្នាំ ១៩៩៣ របស់ក្រុមប្រឹក្សាជាតិ សហរដ្ឋអាមេរិក ស្តីពីឧក្រិដ្ឋកម្ម និង អំពើល្មើស បានលើកឡើងថា " កុមារដែលម្តាយជាប់ឃុំឃាំងគេមានការប៉ះទង្គិចអារម្មណ៏យ៉ាងខ្លាំង ថប់បារម្ភ គិតថាធ្វើអ្វីខុសឬមានទោសដល់ខ្លួន និងមានការភិតភ័យ "។ ពួកគេអាចប្រឈមមុខនឹងគ្រោះថ្នាក់ដ៏ធំដូចជាការទទួលបាននូវជោគជ័យតិចតួចក្នុងការសិក្សា បោះបង់ការរៀនសូត្រ ចូលក្នុងក្រុមក្មេងពាល មានផ្ទៃពោះទាំងនៅវ័យក្មេង ប្រើប្រាស់គ្រឿងញៀន និងប្រព្រឹត្តិអំពើល្មើសជាដើម ។ ហើយកូនអ្នកជាប់ពន្ធនាគារនេះ អាចទំនងជានៅថ្ងៃណាមួយត្រូវធ្លាក់ខ្លួន

---

[៥៨] *ឈ្មោះក្រសួងត្រូវបានផ្លាស់ប្តូរទៅជាក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បទាចាប់តាំងពីថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ១៩៩៩ ។ នៅក្នុងផ្នែកបន្ទាប់ទៀតនៃឯកសារនេះ ឈ្មោះក្រសួងនឹងត្រូវសរសេរជាអក្សរកាត់* (MOSALVY )

ជាប់ពន្ធនាគាររហូតដល់៥ដងលើសក្មេងស្រករ១គ្នាដទៃទៀត[៥៩] ។ នេះជាហេតុផលមួយដែលត្រូវកង្វល់ដល់ការលូតលាស់ផ្នែកផ្លូវចិត្ត និងអារម្មណ៍របស់កុមារដែលមានមាតាបិតាជាប់ឃុំឃាំងនេះមិនទាន់និយាយដល់កុមាររស់នៅជាមួយមាតាក្នុងពន្ធនាគារទៀតផង ។

ការខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាដែលមាតា កូនរស់នៅជាមួយ និង ស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារ ប្រឈមមុខបែបនេះ និង ដើម្បីកាត់បន្ថយភាពចង្អៀត ហើយដើម្បីកែលំអស្ថានភាពទូទៅ គេបានបង្កើតនូវទំរង់ផ្សេង១ជំនួសជំនួសការផ្តន្ទាទោសវិញ ។ ជំរើសបែបនេះភាគច្រើនគឺមានចំពោះជនឧក្រិដ្ឋណាដែលមិនហឹង្សា និងត្រូវបានចាត់ទុកថាមិនគំរាមកំហែងដល់សង្គម ។
កម្មវិធីបែបនេះត្រូវបានប្រើច្រើនសំរាប់ដោះស្រាយបញ្ហា ជាពិសេសជនល្មើសដែលពាក់ព័ន្ធនឹងគ្រឿងញៀន ។ ទោះបីជានៅក្នុងការសិក្សាស្រាវជ្រាវនេះមិនមានស្ត្រីម្នាក់ត្រូវជាប់ឃុំឃាំង ដោយសារបទឧក្រិដ្ឋបែបនេះក៏ដោយ កម្មវិធីទាំងឡាយ ដែលបានបញ្ជាក់ខាងក្រោមនេះ នៅតែផ្តល់ជាឧទាហរណ៍ នៃវិធីដែលអាចកែលំអស្ថានភាពយ៉ាងច្រើនរបស់ មាតា កុមារ និងស្ត្រីមានផ្ទៃពោះទាំងឡាយដែលជាប់ក្នុងពន្ធនាគារបច្ចុប្បន្ននេះ ។

វិធីនីមួយ១នៃវិធីចម្លាស់ទាំងនេះ និង កម្មវិធីគាំទ្រទាំងឡាយដែលបានលើកឡើងខាងលើ តំរូវអោយមានធនធានចាំបាច់ជាច្រើន ទាំងហិរញ្ញវត្ថុ និង ថាមពលមនុស្ស ។ ការអនុវត្តន៏ដែលអាចទទួលបានជោគជ័យលើគ្រោងការណ៏ បែបនេះ ទាមទារអោយមានការសហប្រតិបត្តិការ និង ជំនួយពីសំណាក់រដ្ឋាភិបាល និងឬពីអង្គការក្រៅរដ្ឋាភិបាលផ្សេង១ ព្រមទាំងសេវាសង្គមផងដែរ ។ លើសពីនេះទៅទៀតកម្មវិធីនេះភាគច្រើន ពឹងផ្អែកទៅលើសហ គមន៏ និង ការគាំទ្រពីសាធារណជន ។ ការត្រួតពិនិត្យ និង វាយតំលៃអោយបានហ្មត់ចត់ក៏ជាទិដ្ឋភាពសំខាន់នៃកម្មវិធីនេះដែរ ។ ចំពោះហេតុផលទាំងនេះ លទ្ធភាពជាក់ស្តែងនៃវិធីចម្លាស់ទាំងឡាយដែលអាចជំនួសពន្ធនាគារបាន និង ទំរង់នៃការគាំទ្រចំពោះមាតាជាប់ពន្ធនាគារ ត្រូវតែធ្វើការប៉ាន់ប្រមាណមើលអោយបានដិតដល់ ក្នុងបរិបទកម្ពុជា ។ ដោយកិច្ចការនេះវាស្ថិតនៅក្រៅវិសាលភាពនៃការសិក្សាស្រាវជ្រាវនេះ វាត្រូវតែបានគូសបញ្ជាក់អោយឃើញថា ការផ្តួចផ្តើមគំនិតខាងលើអាចឬមិនអាចសមស្របសំរាប់ការអនុវត្តន៏នៅកម្ពុជា ហើយថា វាតំរូវអោយមានការសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីកំណត់រកអោយឃើញនូវលទ្ធភាពនៃការអនុវត្តន៏នៃវិធីសាស្ត្រទាំងនេះឬការបង្កើតនូវវិធីសាស្ត្រថ្មីទៀត ។ វិធីចម្លាស់ទាំងឡាយដែលបានលើកបង្ហាញរួចមកហើយនេះ នៅមិនទាន់បានផ្តល់នូវចំណុចចាប់ផ្តើមសំរាប់ការពិភាក្សារក

---

[៥៩] *លោកប្រោន និង សហការី : ច្បាប់កម្ពុជា និង អនុសញ្ញាស្តីពីសិទ្ធិកុមារ ទំព័រ ៨១ ។*

ដំណោះស្រាយណាមួយនៅឡើយចំពោះបញ្ហាទាំងឡាយ ដែលនៅជិត១ដៃនេះ ។ សង្ឃឹមថា គំរូទាំងនេះនឹងនាំទៅរកការបង្កើតនូវវិធីសាស្ត្រថ្មីច្រើនថែមទៀតដែលអាចអនុវត្តបាននៅក្នុងបរិបទកម្ពុជា ។

***ក – វិធីចម្លាស់ជំនួសការឃុំឃាំង***

- ការបញ្ជាអោយបំរើសហគមន៍៖ ក្នុងករណីខ្លះតុលាការមួយចំនួនបានដាក់អោយបំរើសហគមន៍ជំនួសការឃុំឃាំងក្នុងពន្ធនាគារវិញ ។ ក្រោមបញ្ជាអោយបំរើសហគមន៍ ជនល្មើសបានតំរូវអោយអនុវត្តការបំរើសេវាមានតំលៃមួយចំនួនដែលជាថ្នូរទៅនឹងបទឧក្រិដ្ឋរបស់ខ្លួន ។ ជនទាំងនោះអាចធ្វើការអោយស្ថាប័នសាធារណៈដូចជាមន្ទីរពេទ្យឬផ្នែកសួនឧទ្យានទៅតាមចំនួនម៉ោងមួយដែលបានកំណត់ដោយតុលាការ ។ ការបំរើសហគមន៍ ក៏អាចជំនួសការផាកពិន័យប្រាក់ដែរ ដែលទណ្ឌិតភាគច្រើនច្រើនតែក្រីក្រហើយមិនអាចបង់ផាកបាន (ដូច្នេះវានឹងនាំអោយមានការបន្តការឃុំឃាំង ដូចដែលបានពិណិនានៅក្នុងករណីសិក្សាលេខ ២២ខាងលើ) នៅប្រទេសហ្ស៊ីមបាវេ [៦០] គេបានទទួលជោគជ័យធំធេងក្នុងការប្រើវិធីបញ្ជាអោយបំរើសហគមន៍នេះហើយជាលទ្ធផលកម្មវិធីស្រដៀងគ្នានេះជាច្រើនក៏ត្រូវបានគេបង្កើតឡើងផងដែរនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅទ្វីបអាហ្វ្រិក ដូចជានៅប្រទេស អ៊ុយហ្កាន់ដា កិនយ៉ា ម៉ាឡាវី និង ហ្សាំប្បេរ [៦១]
- ***វិធីផ្សះផ្សា :*** វិធីនេះគេអនុវត្ត ចំពោះភាគីទាំងពីរ គឺខាងភាគីល្មើស និង ភាគីរងគ្រោះនៃបទឧក្រិដ្ឋដើម្បីកំណត់រកនូវទណ្ឌកម្ម និង ការយល់ព្រមទទួលយកបាន សមរម្យមួយសំរាប់ភាគីទាំងពីរ ។ គោល ដៅនៃការធ្វើការផ្សះផ្សានេះ គឺ ដើម្បីជំរុញអោយមានការទទួលយក និងការយោគយល់ ក៏ដូចជា ការលើកទឹកចិត្តអោយឧក្រិដ្ឋជនទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ។ លើសពីនេះទៀតវិធីនេះអាចនាំអោយមានការសងជំងឺចិត្តដល់ជនរងគ្រោះកាន់តែឆាប់ជាងបពៃណីរបស់ប្រព័ន្ធយុត្តិធមិទៀតផង ។ដំណើរការនេះត្រូវបានគេអនុវត្តជាជំនួសការឃុំឃាំងនៅប្រទេសរុស្ស៊ីប្រទេសសារណរដ្ឋ ឆែក និង នៅក្នុងប្រព័ន្ធយុត្តិធមិកុមារនៅប្រទេស ប៉ូឡូញ [៦២] ។

---

[៦០] *ឯកសារដដែល ។*

[៦១] *លីកាដូ: បញ្ហាពន្ធនាគារ និង បញ្ហាសិទ្ធិមនុស្ស ទំព័រ ៨ ។*

[៦២] *យោងតាមធនធានមគ្គុទេសក៍ច្បាប់ព្រហ្មទណ្ឌកម្ពុជា ប្រកាសមួយចេញផ្សាយដោយថ្នាក់ដឹកនាំក្រសួង ឬក្រសួងអន្តរក្រសួងដើម្បីរៀបចំនិងគ្រប់គ្រងនាយកដ្ឋានឬផ្នែកនីមួយ១ក្នុងក្របខ័ណ្ឌយុត្តធិការរបស់ក្រសួង" (ទំព័រ (៤៣) សារា*

- ❑ ***ការត្រួតពិនិត្យហ្មត់ចត់:*** ការកែប្រែដោយបន្ទឹងលក្ខ័ណ្ឌនៃការសាកល្បង "ការត្រួតពិនិត្យល្អិតល្អន់" តំរូវអោយឧក្រិដ្ឋជនជាទណ្ឌិតស្ថិតនៅក្នុងផ្ទះរបស់ខ្លួននៅក្នុងពេលម៉ោងកំណត់ណាមួយ ។ មន្ត្រីពិនិត្យការល្បង ឬសមត្ថកិច្ចផ្សេងៗទៀត ត្រូវចូលទៅឃ្លាំមើល "ដោយមិនអោយដឹងជាមុន" នៅក្នុងផ្ទះរបស់គេនោះក្នុងកំឡុងពេលកំណត់នេះ ដើម្បីចង់ដឹងថា គេបានគោរពតាមការកំណត់នៃការសាកល្បងដែរឬទេ ។ ប៉ុន្តែទង្វើបែបនេះ ជនល្មើសនៅតែអាចរស់នៅជាមួយគ្រួសារ បេស់គេដដែលប្រកបការងារ ព្រមទាំងនៅក្នុងសហគមន៏ជាធម្មតា ។ ក្នុងករណីខ្លះ អ្នកដែលស្ថិតក្រោមការត្រួតពិនិត្យហ្មត់ចត់បែបនេះ ត្រូវពាក់កងជើងអេឡិចត្រូនិក ដែលអាចអោយ អាជ្ញាធរធ្វើការត្រួពិនិត្យនូវកន្លែងដែលគេទៅដល់បានគ្រប់ពេលវេលា ហើយទង្វើនេះអាចអោយអាជ្ញាធរដឹងបានប្រសិន បើគេមិនគោរពនូវបញ្ញត្តិនៃការសាកល្បងនេះ ព្រមទាំងអោយអាជ្ញាធរដឹងផងដែរ ប្រសិនបើជននោះចូលទៅដល់តំបន់មួយដែលអាចប្រព្រឹត្តិនូវឧក្រិដ្ឋកម្មណាមួយ (ឧទាហរណ៏ ប្រសិនបើជននោះមិននៅផ្ទះពេលយប់គាត់ទៅក្នុងតំបន់មួយដែលធ្លាប់មានឈ្មោះជាតំបន់ប្រើប្រាស់គ្រឿងញៀនជាដើម) ។ ការសាកល្បងបែបនេះត្រូវបានគេអនុវត្តយ៉ាងទូលំទូលាយនៅក្នុង សហរដ្ឋ អាមេរិក[៦៣] ។
- ❑ ***ការឃុំខ្លួនក្នុងលំនៅដ្ឋាន:*** នៅក្នុងតំបន់ខ្លះ មន្ទីរឃុំឃាំងពិសេសមួយចំនួនបានអនុញ្ញាតអោយមាតាបំរើទោសរបស់គេនៅក្នុងលំនៅដ្ឋាន ក្នុងខណៈដែលគេមានកូនតូចៗ ។ គោលដៅនៃកម្មវិធីនេះ គឺ "ដើម្បីរក្សាគ្រួសារអោយនៅដូចដើម នៅពេលដែលស្ត្រីពេញចិត្តក្នុងកាតព្វកិច្ចរបស់ខ្លួនចំពោះប្រព័ន្ធយុត្តិធមិព្រហ្មទណ្ឌ "[៦៤] ។ មន្ទីរឃុំឃាំងបែបនេះច្រើនតែផ្តល់នូវការបង្កើតបរិយាកាសមិត្តភាពរបៀបក្មេងដល់កុមារ ។ ស្ត្រីដែលនៅក្នុងមណ្ឌលទាំងនោះ ជារឿយៗតំរូវអោយចូល រួមថ្នាក់ សំរាប់មាតាបិតា កម្មវិធីអប់រំ ឬកម្មវិធីព្យាបាលគ្រឿងញៀន ឬ ជាតិស្រវឹងនៅពេលចាំបាច់ ។ គេអាចតំរូវអោយមានការបំរុង ឬ រក្សាទុកនូវការងារខាងក្រៅមណ្ឌលឃុំឃាំងផងដែរ ។ ឧទាហរណ៏មួយនៃកម្មវិធីបែបនេះគឺ Summit House Inc., នៅរដ្ឋខារ៉ូឡាញណា ខាងជើង សហរដ្ឋអាមេរិក ។

---

*ចរមួយត្រូវចេញដោយទីស្តីការគណរដ្ឋមន្ត្រីសមីក្រសួងឬអង្គការរដ្ឋបាលណាមួយដើម្បី ផ្តល់នូវការបំភ្លឺបញ្ហាច្បាប់ឬសេចក្តីណែនាំឬតំរូវការរដ្ឋបាលផ្សេងៗ "ទំព័រ ៤៤ ។*

៦៣ *នេះក៏មានចែងក្នុងមាត្រា២២ នៃអនុក្រិត្យស្តីពីលក្ខ័ណ្ឌស៊ីវិល(២៩/១២/២០០០ ។ ដូចដែលយូនីសែហ្វបានបក ប្រែមាត្រា ២៧គឺ: ក្នុងករណីទណ្ឌិតសម្រាលកូន ទីកន្លែងកំណើតរបស់កូនត្រូវតាមលំនៅដ្ឋានមាតាឬបិតា ។*

៦៤ *ចំពោះពតិមានជាក់លាក់ស្តីពីម្ហូបអាហារដែលផ្តល់ដល់អ្នកទោសនិងបរិមាណ សូមមើល និតិវិធីពន្ធនាគារ ៦ ។*

លើសពីនេះទៀតរដ្ឋកាលីហ្វកញ៉ា បានបង្កើតឡើងនូវកម្មវិធីពីរ ដើម្បីផ្ទេរមាតាជាប់ឃុំឃាំងដែលអាចធ្វើទៅបានពីពន្ធនាគារអោយទៅរស់នៅក្នុងទីតាំងមួយដែលនៅក្នុងសហគមន៏វិញ [៦៥] ។ កម្មវិធីមាតានិង កូនជាមួយគ្នា ផ្តល់នូវជំរើសមួយដល់ស្ត្រីមានផ្ទៃពោះក្នុងកំឡុងពេលពីរខែមុនសម្រាលកូន និង បីខែក្រោយសម្រាលកូនរួច ដូច្នេះវាអាចអោយគេមានលទ្ធភាពក្នុងការ ថែទាំសុខភាពនៅមុន និងក្រោយពេលសម្រាលកូនរួច ព្រមទាំងបានចូលរៀនសូត្រក្នុងថ្នាក់មាតាបិតាដែលអាចបង្កើតនូវជំនាញនេះដល់គេទៀតផង [៦៦] ។

- ***ការឃុំឃាំងទាំងម្តាយនិងកូនក្នុងពន្ធនាគារ*** ពន្ធនាគារបួន នៅប្រទេសអង់គ្លេស និង នៅវ៉េល មានកន្លែងឃុំឃាំងសំរាប់ "មាតា និងទារក" ។ កន្លែងឃុំឃាំងនោះមិនដូចនៅក្នុងមណ្ឌលស្នាក់នៅទេដោយវាស្ថិតនៅក្នុងបរិវេណពន្ធនាគារតែម្តង ។ គេផ្តល់នូវទីឃុំឃាំងយ៉ាងសុវត្ថិភាពមួយសំរាប់ស្ត្រី ដែលបានប្រព្រឹត្តិឧក្រិដ្ឋកម្មយ៉ាងធ្ងន់ធ្ងរ ឬ បង្ករការអុកឡុកច្រើននៅក្នុងពន្ធនាគារ ប៉ុន្តែបានចំពោះតែអ្នកណាដែលសមត្ថកិច្ចបានកំណត់ថាមិនបង្ករអោយមានការគំរាមកំហែងដល់ខ្លួនឯងឬដល់កូនរបស់គេប៉ុណ្ណោះ ។ ការឃុំឃាំងបែបនេះ គឺមានគោលដៅដើម្បីផ្តល់នូវការគាំទ្របន្ថែមចំពោះ មាតា និង កុមារ ក្នុងខណៈដែលតំរូវអោយស្ត្រីនោះស្ថិតក្រោមការត្រួតពិនិត្យយ៉ាងខ្ពស់ជាងការដែលឃុំទុកស្ត្រីនោះនៅក្នុងមណ្ឌលស្នាក់នៅទៀត [៦៧] ។

## ៩- ប្រភេទកម្មវិធីផ្សេងទៀតដើម្បីការពារកុមារ និង ជំរុញអោយមានទំនាក់ទំនងរវាងមាតាបិតាធម៌ និងកូន។

កម្មវិធីមួយចំនួន ដោយមិនបានផ្តល់នូវវិធីចម្លាស់ពិតប្រាកដដើម្បីជំនួសពន្ធនាគារ គេបានកែច្នៃមធ្យោបាយក្នុងការផ្តល់ការគាំទ្រមាតាជាប់ពន្ធនាគារនិងកុមារដែលមានឪពុកម្តាយរស់នៅមួយក្នុងពន្ធនាគារនោះ ។

---

[៦៥] *និតិវិធីលេខ១១ "ការងារពន្ធនាគារ ការអប់រំ និង អប់រំវិជ្ជាជីវៈ" ។ ក៏បានចែងផងដែរ"ទណ្ឌិតស្ត្រីមិនត្រូវធ្វើការ នៅ ៩០ ថ្ងៃនិងក្រោយសម្រាលកូនទេ ។*

[៦៦] *បទដ្ឋាន ៣.៧ ក៏បានសង្កត់ធ្ងន់ចំណុចនេះដែរដោយចែងថា បុគ្គលិកត្រូវតែផ្តល់សេវាស្របទៅតាមបទដ្ឋាន ជំនាញដែលអាចទទួលយកបានសំរាប់សុខភាពពន្ធនាគារ ។ ប៉ុន្តែ ក៏ពុំមានការបញ្ជាក់ណាមួយថាតើ " បទដ្ឋានជំនាញ បែបណាដែលអាចទទួលយកបាននោះ" ។*

[៦៧] *នេះក៏មានចែងនៅក្នុងផ្នែក១,២ -សេចក្តីថ្លែងបពោក់-សូមអានអត្ថបទឯកសារបន្ថែម ។*

- *ជំនួយផ្នែកច្បាប់ :* ស្ត្រីមួយចំនួនដែលយើងបានសម្ភាសន៍ បានបង្ហាញនូវកង្វល់អំពីការចាត់ការតាមផ្លូវច្បាប់ចំពោះករណីរបស់ពួកគេ ដោយមេធាវី ឬ តុលាការរបស់ពួកគេ ។ ពួកគួព្រួយបារម្ភអំពីការអវត្តមានមេធាវី និង ចំណុចខ្លះដែលគេបានសន្យាថានឹងចាត់វិធានការតាមផ្លូវច្បាប់ បែរជាមិនដែលបានទទួលពត៌មាន ដូចដែលបានបញ្ជាក់នៅក្នុងករណីរបស់គេឡើយ ។ មាតាម្នាក់ដែលមិនបានដឹងពីលក្ខ័ណ្ឌផ្លូវច្បាប់ គឺមិនត្រឹមតែមិនមានពត៌មាន ក្នុងដំណើរការករណីរបស់នាងប៉ុណ្ណោះទេ ប៉ុន្តែ នាងបានខកខានក្នុងការរៀបចំផែនការសំរាប់អនាគតកូនរបស់នាងទៀតផង ។ ការស្រាវជ្រាវរកវិធីចម្លាស់សំរាប់ថែទាំកូននាង និងការសំរេចចិត្តថាតើ ការថែទាំប្រភេទណាដែលផ្តល់ផលប្រយោជន៍ដ៏ល្អបំផុតដល់កូនរបស់នាងនោះ អាចអាស្រ័យមួយភាគធំទៅនឹង រយៈពេលនៃការឃុំខ្លួន ឬការផ្តន្ទាទោស ។ របាយការណ៏អង្គការលីកាដូ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងពន្ធនាគារកម្ពុជា "លទ្ធភាពក្នុងការទទួលបានការពិគ្រោះផ្លូវច្បាប់នៅមិនដល់កំរិតកំណត់" ទោះជានៅតាមបទដ្ឋានជាតិក្តីឬបទដ្ឋាបទអន្តរជាតិក្តី ។ របាយការណ៏ក៏បញ្ជាក់ថែមទៀតថា "គ្រប់គ្នាមិនមានសិទ្ធិក្នុងការទាកទងពិគ្រោះយោប់តាមចិត្តបានទេ ពាក់ព័ន្ធទៅនឹងការកំណត់បទចោទប្រកាន់មកលើគាត់នោះ "[៦៨] ។ បើពុំមានការពិគ្រោះយោបល់បានច្បាស់លាស់ទេស្ត្រីប្រហែលជាមិនអាចការពារខ្លួនឯងទេ ក្នុងករណីចាប់ច្រឡំឬឃុំខ្លួនខុសច្បាប់ ។ ដូច្នេះនាង ហើយនិងកូននាងផងដែរអាចត្រូវរស់នៅរ៉ាំរ៉ៃក្នុងពន្ធនាគារដោយអយុត្តិធម៌ ។ នៅប្រទេសនេប៉ាល់ មណ្ឌលជនរងគ្រោះដោយទារុណ្ណកម្មបានប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ តាមរយៈគំរោងកម្មវិធីមួយដ៏ទូលំទូលាយ សំរាប់អ្នកជាប់ពន្ធនាគារស្ត្រី និងកូនៗរបស់ពួកគេ ។ សមាសភាគមួយចំនួនធំនៃគំរោងនេះ គឺផ្តល់ជំនួយផ្នែកច្បាប់ដល់ស្ត្រីដោយធានាអោយពួកគេមានតំណាងផ្នែកច្បាប់និងពិនិត្យករណីទាំងឡាយ ដែលស្ត្រីត្រូវឃុំខ្លួនដោយគ្មានមូលហេតុច្បាស់លាស់[៦៩] ។
- ***ការរក្សាអោយមានទំនាក់ទំនងរវាងមាតាបិតា និង កូន*** : ស្ត្រីមួយចំនួនធំដែលជាប់ពន្ធនាគារមិនអាចរក្សាទំនាក់ទំនងជាមួយកូនៗរបស់គេបានទេ ឬ អាចធ្វើទំនាក់ទំនងបានតាមរយៈទូរស័ព្ទ ឬសំ

---

[៦៨] *ភាគ៣ ក្បួនប្រតិបត្តិការសុខភាព "គោលនយោបាយ និតិវិធី និងពិធីការ ។ ក៏យោងទៅលើតំរូវការជីវិញការថែទាំសុខភាពដោយសង្កត់ធ្ងន់ទៅលើតំរូវការការពារ ក៏ដូចជាថ្នាំសំរាប់ព្យាបាល ( ទំព័រ ២៣)*

[៦៩] *ភាគ ៣,៧ នៃក្បួនប្រតិបត្តិការសុខភាព ពិពណ៌នានូវផែនការសកម្មភាពមួយជាឯកសារដែលដាក់លាក់សំរាប់អ្នកជំងឺម្នាក់ដែលត្រូវបានព្យាបាលសំរាប់លក្ខ័ណ្ឌមួយដែលតំរូវអោយមានការព្យាបាលបន្តទៀត( ៦៨)*

បុត្រតែប៉ុណ្ណោះ ។ ក្នុងចំនួនស្ត្រី ១០ នាក់ដែលមានកូនមួយឬ ច្រើនជាងនេះ រស់នៅក្រៅពន្ធនាគារ ហើយដែលយើងបានសម្ភាសន៍សំរាប់ការសិក្សាស្រាវជ្រាវនេះ មានស្ត្រីតែម្នាក់គត់ដែលនិយាយថា កូននាងមកលេងជាប្រចាំ ។ ស្ត្រី ៥ នាក់ក្នុងចំណោមស្ត្រីទាំងនោះបាននិយាយថា ពួកគេមិនដែលបានជួបមុខកូន ដែលមិនរស់នៅក្នុងពន្ធនាគារជាមួយទេ ។ កត្តានេះអាចបណ្តាលមកពីបញ្ហានៅឆ្ងាយ សោហ៊ុយធ្វើដំណើរ ឬឧបសគ្គផ្សេងៗទៀត ។ ឧទាហរណ៍ របាយការណ៍លីកាដូ ឆ្នាំ ២០០១ ស្តី អំពីសិទ្ធិមនុស្សក្នុងពន្ធនាគារលើកឡើងថា "ពេលមកដល់ពន្ធនាគារ គ្រួសារដែលមកសួរសុខទុក្ខត្រូវចំណាយថវិកាខ្លះៗអោយបុគ្គលិកពន្ធនាគារដើម្បីបានជួបសាច់ញាតិដែលជាប់ឃុំឃាំង[៧០] ។ កម្មវិធីដូចជា កុមារីលបមើលតាមចន្លឹះបង្អួច នៅសហរដ្ឋអាមេរិក បាននាំកូនស្រីមកទាំងអស់គ្នាជាមួយនិងមាតាជាប់ពន្ធនាគាររបស់ពួកគេ ហើយជំរុញអោយមានទំនាក់ទំនងរវាងម្តាយ-កូន តាមរយៈសកម្មភាពទាំងឡាយដែលតំរូវអោយមាតាបិតា និងកូនធ្វើរួមគ្នាដើម្បីឆ្ពោះទៅរកគោលដៅរួមគ្នាមួយ[៧១] ។ នៅសេនល្វីក្នុងរដ្ឋមីស៊ូរីនៃសហរដ្ឋអាមេរិកកម្មវិធីមាតា-កូនរួមគ្នាផ្តល់ការដឹកជញ្ជូនដោយឥតគិតថ្លៃទៅពន្ធនាគារ បួនដង ក្នុងមួយឆ្នាំសំរាប់គ្រួសាររបស់អ្នកជាប់ពន្ធនាគារ[៧២] ។ កម្មវិធីស្រដៀងគ្នានេះត្រូវបានអនុវត្តនៅរដ្ឋជាច្រើននៅសហរដ្ឋអាមេរិក[៧៣] ។

- ***ជំរាបស្ត្រីអោយដឹងអំពីសិទ្ធិរបស់ពួកគេ*** : គំរោងច្បាប់មាតាជាប់ពន្ធនាគារនៅក្រុងញូយ៉ក សហរដ្ឋអាមេរិកលើកស្ទួយអោយមានការប្រព្រឹត្តិសមរម្យចំពោះមាតាជាទណ្ឌិតដោយអប់រំស្ត្រីបែបនេះអំពីសិទ្ធិរបស់ពួកគេមានជាមួយនឹងកូនក្នុងកំឡុងពេលដែលពួកគេជាប់នៅក្នុងពន្ធនាគារ។ លើសពីនេះ

---

[៧០] *ភាគ៥.២នៃក្បួនប្រតិបត្តិការសុខភាពក៏ចែងដែរថាសម្ភារៈដែលរក្សាទុកក្នុងគ្លីនិកសុខភាពពន្ធនាគារត្រូវមានបរិមាណសមរម្យមួយហើយសមស្របតាមតំរូវការ( ទំព័រ ៨៥) ។*

[៧១] *ក្នុងផ្នែកក្បួនប្រតិបត្តិការសុខភាព ស្តីពីសម្ភារៈនិងបរិក្ខា ភាគ ៥.៥ និយាយថា "ចាក់ថ្នាំបង្ការ " និយាយថាទទួលការចាក់ថ្នាំបង្ការគឺជាតួនាទីគ្រូពេទ្យដែលអ្នកដឹកនាំគ្លីនិកពន្ធនាគារ ។ ការចាក់ថ្នាំបង្ការកុមារអាយុក្រោម ៦ឆ្នាំ គួរតែពិភាក្សាជាមួយគ្រូពេទ្យជំនាញកុមារមូលដ្ឋានគ្រប់កាលៈទេសៈ ។*

[៧២] *យោងតាមផ្នែកទី៦នៃភាគ ៣.១១ ទារកត្រូវតែចាក់ថ្នាំការពារភ្លាមៗក្រោយពេលកើតមុនត្រឡប់ចូលមកចូលមកពន្ធនាគារវិញ ( ទំព័រ ៥៥) ។*

[៧៣] *ស្សេរី ប្រោននិងសហការី "សិទ្ធិស្របច្បាប់នៃកុមារកម្ពុជា" ច្បាប់អន្តរជាតិនិងច្បាប់កម្ពុជា បញ្ញត្តិ និងការណែនាំ ស្តីពីកុមារ ។ ភ្នំពេញជំនួយផ្នែកច្បាប់កម្ពុជា ១៩៩៨ ទំព័រ ២៩០ ។*

ទៅទៀត កម្មវិធីក៏នូវបានធ្វើអោយគេយល់ដឹងអំពីការទទួលខុសត្រូវចំពោះកូនៗរបស់គេដែរ ក្នុងកំឡុងពេលនៃការជាប់ពន្ធនាគាររបស់ពួកគេ[៧៤] ។

- ***កែលំអបច្ចេកទេសមាតាបិតា*** ៖ កម្មវិធីមួយចំនួនមានគោលបំណងដើម្បីបង្កើនជោគជ័យរបស់អ្នកជាប់ពន្ធនាគារក្នុងនាមជាមាតាបិតា ដោយផ្តល់ការហ្វឹកហ្វឺនបច្ចេកទេសមាតាបិតា។ កម្មវិធីបែបនេះច្រើនតែជាសមាសភាគមួយក្នុងកម្មវិធីទូលំទូលាយជាច្រើនទៀតដូចបានរៀបរាប់អំពីការឃុំឃាំងក្នុងមណ្ឌលស្នាក់នៅដែលបានរៀបរាប់ខាងលើ។ ស្រដៀងគ្នានេះដែរមន្ទីរកែប្រែបេតហ្វតហ៊ីលនៅញូយ៉ក សហរដ្ឋអាមេរិក ដែលបើកអោយមានមតេយ្យកុមារនៅក្នុងពន្ធនាគារតាំងពីប្រហែល១០០ឆ្នាំមុនមកម្លេះ អនុវត្តកម្មវិធីដែលបញ្ចូលទំនាក់ទំនងទៅវិញទៅមករវាងមាតា-កូន ជាមួយនិង ជំនាញខាងមាតាបិតាហើយដូចជាការអប់រំជំនាញដែរ។ មន្ទីរឃុំឃាំងក៏បំពាក់អោយមានបន្ទប់លេងសំរាប់កុមារ ដែលមកសួរសុខទុក្ខម្តាយ ហើយបុគ្គលិកអនុវត្តកម្មវិធីលើកទឹកចិត្តអោយកូនៗអោយមកសួរសុខទុក្ខម្តាយអោយបានញឹកញាប់ ។ គេប្រើប្រាស់ការមកសួរសុខទុក្ខនេះ ព្រមទាំងវគ្គហ្វឹកហ្វឺនជាបទដ្ឋាន ទុកជាមធ្យោបាយក្នុងការអប់រំអ្នកជាប់ពន្ធនាគារអំពីតួនាទីនិងការទទួលខុសត្រូវរបស់ពួកគេក្នុងនាមជាមាតា ។ កម្មវិធីនេះត្រូវកត់សំគាល់អំពីជោគជ័យរបស់វាក្នុងការកាត់បន្ថយបានមួយកំរិតធំនូវអំពើប្រព្រឹត្តិបទល្មើសមិនរាងចាលក្នុងចំណោមអ្នកចូលរួមកម្មវិធីនោះ[៧៥] ។

## VIII- បញ្ហាប្រឈមមុខពេលអនាគត ៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ទោះជារបាយការណ៍នេះ និយាយយ៉ាងច្បាស់លាស់ចំពោះកុមារទាំងឡាយ ដែលរស់នៅក្នុងពន្ធនាគារជាមួយនឹងម្តាយរបស់គេបញ្ហាដែលបានលើកឡើងមកនេះ គឺជាបញ្ហាកើតឡើងតាមប្រព័ន្ធមួយនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ៖ ភាពក្រីក្រការខ្វះខាតការទទួលខុសត្រូវហេដ្ឋារចនាសម្ព័ន្ធសង្គមខ្សោយ និងប្រព័ន្ធតុលាការមិនត្រឹមត្រូវ ។ បញ្ហាទាំងនេះជ្រាបចូលក្នុងសង្គមកម្ពុជា ធ្វើអោយមិនមានយុត្តធម៌ និងចាំតែធ្វើតាម ។ កុមារទាំងឡាយដែលមិនបានអប់រំរួមទាំងកុមារដែលរស់នៅក្នុងមជ្ឈមណ្ឌលកែប្រែជាមួយនឹងឪពុកម្តាយជាប់គុក ឬ ឃុំខ្លួនបណ្តោះអាសន្នបន្តធ្វើអោយមានផលវិបាកដល់សង្គមកម្ពុជា ។ រដ្ឋអំណាចមិនអាចបន្តអោយកុមារទាំងនេះទទួលនូវបន្ទុកធ្ងន់ធ្ងរនៃប្រព័ន្ធដែលមិនបានការពារពួកគេ និងសិទ្ធិរបស់ពួកគេ

---

[៧៤] *ឯកសារដដែល ។*

[៧៥] *ឯកសារដដែល ។*

នោះទេ ។ សំណាងល្អបុគ្គល និងអង្គការមួយចំនួនបដិសេធន៏មិនទទួលយកនូវស្ថានភាពបែបនេះ និងបន្តប្រយុទ្ធដើម្បីទាមទារអោយមានការអភិវឌ្ឍន៏អោយបានខ្លាំងខ្លា និងកាន់តែត្រឹមត្រូវឡើង ។ ប្រជាជន និងភ្នាក់ងារទាំងនេះ គឺជាមនុស្សដែលត្រូវតែនាំមុខក្នុងការអនុវត្តវិធានការណ៍ ដើម្បីគោរពសិទ្ធិកុមារដែលរស់នៅជាមួយម្តាយរបស់គេក្នុងពន្ធាគារ ។ ទោះជាវិធានការណ៏នេះជះឥទ្ធិពលត្រឹមតែមនុស្សមួយក្រុមតូចក្នុងពេលបច្ចុប្បន្ននេះ ប្រជាជនទាំងនេះអាចពង្រីកការបង្កើតអោយមានសង្គមអាក្រក់មួយទៀត និងអនុញ្ញាតិអោយមានការបន្តការរំលោភសិទ្ធិ របស់កុមារប្រសិនបើមានការធ្វេសប្រហែស ។

ខាងក្រោមនេះ គឺជាអនុសាសន៏ទាំងឡាយដែលបានមកពីមូលដ្ឋានគ្រឹះនៃការសិក្សាស្រាវជ្រាវ និងរបកគំហើញទាំងឡាយ ។ ដោយអនុសាសន៏ភាគច្រើនតំរូវអោយមានការប្រឹងប្រែងយូរអង្វែង វាជាការចាំបាច់ ដែលបុគ្គលិកពន្ធនាគារ នាយកដ្ឋានពន្ធនាគារ និង/ឬ ភ្នាក់ងារផ្សេងៗទៀតដោះស្រាយបញ្ហាតំរូវការម្ហូបអាហារ និង សុខភាពរបស់ស្ត្រីមានផ្ទៃពោះមាតា និង កូនៗជាបន្ទាន់ ។ បន្ថែមពីលើអនុសាសន៏ទូទៅអនុសាសន៏ខាងក្រោម គឺជាអនុសាសន៏ សំរាប់រយៈពេលខ្លី ដោយរួមមានការចែកចាយម្ហូបអាហារ និងអាហារូបត្ថម្ភ និងការផ្តល់ថ្នាំសង្កូវអោយបានសមរម្យដល់ស្ត្រី និង កុមារទាំងនេះ ។

១- បង្កើតអនុគណកម្មការ ឬ ក្រុមកិច្ចការពិសេសមួយដែលស្ថិតក្រោមឱវាទក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលមានរួចមកហើយត្រូវមានសមាជិកតំណាងមកពីក្រសួងពាក់ព័ន្ធមកពីអង្គការជាតិ និង អង្គការអន្តរជាតិ ដែលមានគោលការណ៏ សំដៅដោះស្រាយបញ្ហាលើកឡើងក្នុងនេះដែរ ។ វិធីសាស្ត្រសំរាប់ការអនុវត្តន៏នេះ អាចតំរូវដូចខាងក្រោម :

ក-ការបង្កើតនូវមជ្ឈមណ្ឌលឃុំឃាំងមួយ សំរាប់ពិរុទ្ធជន និង ទណ្ឌិតទាំងអស់ដែលមានផ្ទៃពោះ និងមានកូននៅជាមួយ ។ នៅមជ្ឈមណ្ឌលឃុំឃាំងនេះ តំរូវអោយមានផ្តល់អាហារបរិភោគគ្រប់គ្រាន់ សេវាសុខភាព និង អប់រំ រៀបបំរុងសំរាប់បំពេញតំរូវការរបស់ស្ត្រីមានផ្ទៃពោះមាតានិងកូនៗ ព្រមទាំងការបង្កើតអោយមាននូវបរិយាកាសមួយដែលអាចទ្រទ្រង់ដល់ការលូតលាស់ និង អភិវឌ្ឍន៏របស់កុមារផង ។ លើសពីនេះទៅទៀត ការបង្កើតឡើងនូវមណ្ឌលឃុំឃាំងបែបនេះនឹងអាចកាត់បន្ថយនូវការធ្វើបាបកុមារពីសំណាក់អ្នកជាប់ពន្ធនាគារផ្សេងៗ ដោយត្រូវបំបែកមាតាដែលមានកូន ចេញពីអ្នកជាប់ពន្ធនាគារទាំងឡាយពិសេសគឺបំបែកចេញពីអ្នកទាំងឡាយណាដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋពាក់ព័ន្ធទៅនិងការធ្វើបាបកុមារកន្លងមក ។

ខ- បង្កើតវិធីចម្លាស់ផ្សេងៗជំនួសពន្ធនាគារ សំរាប់ជនល្មើសស្ត្រីដែលមិនហឹង្សា មានកូន ។ អាចយកគំរូតាមកម្មវិធីដែលទទួលបានជោគជ័យនៅប្រទេសផ្សេងៗវិធីចម្លាស់បែបនេះ អាចរួមមានការបំរើសហគមន៍ការបង្កើតនូវមណ្ឌលសំរាប់កម្មវិធីមាតា និងកូននៅក្នុងពន្ធនាគារឬបង្កើតអោយមានជាមន្ទីរឃុំឃាំងសុវត្ថិភាពមួយដែលមាតា និងកូនអាចរស់នៅជាមួយគ្នា ក្នុងបរិយាកាសរបៀបក្មេងមួយសំរាប់កុមារ ។

គ-ពិនិត្យសារជាថ្មី នូវយុទ្ធសាស្ត្រទាំងឡាយដើម្បីបំពេញបាននូវតំរូវការរបស់កុមារដោយផ្អែកទៅលើសេចក្តីត្រូវការជាក់លាក់ដូចជា ម្ហូបអាហារ និង ថ្នាំពេទ្យជាដើមរួមបញ្ចូលទាំងស្ត្រីមានផ្ទៃពោះនិងមាតាដែលកំពុងថែទាំកូនផង ។ ចំណុចនេះអាចតំរូវអោយមានការកែប្រែនូវថវិកាសំរាប់ម្ហូបអាហារសំរាប់អ្នកជាប់ពន្ធនាគារបច្ចុប្បន្នផង និង/ឬបង្កើតជាដៃគូជាមួយអង្គការ ដែលអាចជួយផ្តល់ម្ហូបអាហារ ឬការថែទាំ សុខភាព បន្ថែម។ វិធានការទាំងឡាយដែលចាត់ការគឺ រៀបចំបង្កើតនីតិវិធី និង/ឬច្បាប់ថ្មី ដោយក្រសួងមហាផ្ទៃដែលតំរូវអោយនាយកដ្ឋានពន្ធនាគារបង្កើននូវរបបអាហារដល់ស្ត្រីមានផ្ទៃពោះ និងមាតាដែលមានកូននៅជាមួយក្នុងពន្ធនាគារ ដោយមានការថែងជា គោលការណ៏ដូចខាងក្រោម :

*១- ត្រូវផ្តល់ម្ហូបអាហារបន្ថែមដល់ ស្ត្រីដែលបំបៅកូន ក្នុងបរិមាណមួយសមរម្យដើម្បីអោយពួកគេ អាចមានទឹកដោះគ្រប់គ្រាន់សំរាប់កូន ។*

*២- ត្រូវផ្តល់ទឹកដោះគោជាប្រចាំ ក៏ដូច ជាផ្តល់ថ្នាំវីតាមីនសំរាប់កូន ដល់មាតាណាដែល មិនមានលទ្ធភាពបំបៅដោះកូនបាន ។*

*៣-ត្រូវបែងចែកម្ហូបអាហារដាច់ដោយឡែកពីម្តាយ ចំពោះកូនណាដែលមករស់នៅជាមួយម្តាយក្នុងពន្ធនាគារ ហើយឈប់បៅដោះ ។*

ឃ- ពិនិត្យឡើងវិញនូវបទបញ្ញត្តិ និងនីតិវិធីបច្ចុប្បន្ន ដោយផ្តោតទៅលើការវិភាគ ថាតើច្បាប់ និងគោលនយោបាយបច្ចុប្បន្នសមរម្យនិងគ្រប់គ្រាន់តាមតំរូវការរបស់មាតាកូន និងស្ត្រីមានផ្ទៃពោះជាប់ពន្ធនាគារដែរឬទេ ។

២- ពង្រឹងច្បាប់ និង គោលនយោបាយជាតិទាំងឡាយដែលពាក់ព័ន្ធទៅនឹងស្ត្រី កុមារនិងស្ត្រីមានផ្ទៃពោះដែលរស់នៅក្នុងពន្ធនាគារ ។ មធ្យោបាយក្នុងការធ្វើដូច្នេះ រួមមានដូចខាងក្រោម :

ក- តាក់តែងបញ្ញត្តិដែលមានលក្ខណជាក់លាក់ខ្លាំងស្តីពីការអនុវត្តន៏ចំពោះមាតា កូននិងស្ត្រីមានផ្ទៃ

ពោះក្នុងពន្ធនាគារ ដោយរួមមានការបំភ្លឺនូវពាក្យពេចន៍ទាំងឡាយដែលប្រើនៅក្នុងច្បាប់នោះផង ។

ខ- កំណត់នូវបទដ្ឋានដែល :

១-អ្នកគ្រប់គ្រង និង ស្ថាប័នត្រូវអោយមាន "សមត្ថភាព " ដើម្បីកំណត់នូវអ្វីដែលជាប្រយោជន៍ដ៏ល្អបំផុតសំរាប់កុមារ

២- ភ្នាក់ងារដែលផ្តល់កន្លែងទទួលការថែទាំចម្លាស់សំរាប់កុមារត្រូវអោយមាន "សមត្ថភាព" ក្នុងការផ្តល់ការថែទាំគ្រប់គ្រាន់ដល់កុមារ

គ- កំណត់ជាបទដ្ឋានក្នុងការថែទាំមាតា កូន និង ស្ត្រីមានផ្ទៃពោះនៅគ្រប់ពន្ធនាគារទាំងអស់តាមរយៈការអនុវត្តន៍ និង ត្រួតពិនិត្យនូវបទបញ្ញត្តិ ។

ឃ-រុះរើប្រព័ន្ធកែប្រែ :

១- ដើម្បីធានាអោយមាតា កុមារ និងស្ត្រីមានផ្ទៃពោះមានមធ្យោបាយក្នុងការប្តឹង និង បញ្ចេញមតិលើកឡើងពីទុក្ខលំបាកដោយគ្មានការភ័យខ្លាច និង សងសឹកតបតវិញ ។

2- កំណត់អោយអ្នកគ្រប់គ្រងពន្ធនាគារ និង នាយកដ្ឋានពន្ធនាគារ ទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហាទាំងនេះទៅតាមពេលវេលា និង របៀបសមសមរម្យ ។

៣- បង្កើតអោយមាននីតិវិធី និង សម្ភារៈជាបទដ្ឋានសំរាប់អប់រំមាតា និង កុមារ (នៅទីណាដែលសមរម្យ) និងស្ត្រីមានផ្ទៃពោះអំពីសិទ្ធិរបស់គេក្នុងនាមជាពិរុទ្ធជន ទណ្ឌិតក៏ដូចជាសិទ្ធិកូនរបស់គេដោយយោង ទៅតាមច្បាប់ជាតិ និងអន្តរជាតិ ។

៤- បង្កើតអោយមានជាបទដ្ឋានមួយ ដែលពាក់ព័ន្ធទៅនិងភ្នាក់ងារ ឬ ជនណាដែលផ្តល់កន្លែងទទួលថែទាំចម្លាស់សំរាប់កុមារដែលជាកូនរបស់មាតាជាប់ពន្ធនាគារ ។ បទដ្ឋានបែបនេះនឹងជួយឱ្យរដ្ឋាភិបាល និង អ្នកគ្រប់គ្រង ផ្សេងៗទៀតក្នុងការ :

ក-កំណត់នូវភាពពេញច្បាប់ និង សមត្ថភាពរបស់ភ្នាក់ងារដែលបានលើកឡើងខាងលើ និងបុគ្គលហើយបញ្ជាក់អោយបានច្បាស់នូវតំរូវការចាំបាច់ក្នុងការផ្តល់ការថែទាំគ្រប់គ្រាន់ដល់កុមារ

ខ- ដាក់បទបញ្ញត្តិ និង ត្រួតពិនិត្យមើលភ្នាក់ងារ ឬ បុគ្គលដែលផ្តល់ការថែទាំចម្លាស់សំរាប់កុមារជំនួសពន្ធនាគារដើម្បីធានាអោយមានការការពារនូវសិទ្ធិរបស់កុមារ ។

គ- អនុម័តនូវនីតិវិធីឬ បទបញ្ញត្តិ ដែលបំភ្លឺ និងធានាសិទ្ធិរបស់មាតាក្នុងការអាចយកកូនបានមក

គ្រប់គ្រងវិញក្រោយពីបំរើទោសចប់ តែនឹងអាចអនុវត្តផ្ទុយពីនេះបាន បើសិនជាអាជ្ញាធរមានសមត្ថកិច្ចវិនិច្ឆ័យថាមាតានោះមិនមានសមត្ថភាពសមនឹងយកកូនវិញទេពេលបំរើទោសចប់នោះ ។

ឃ-តំរូវអោយភ្នាក់ងារ ឬបុគ្គលដែលផ្តល់កន្លែងទទួលការថែទាំកូនចម្លាស់ ជួយសម្របសម្រួលអោយមានទំនាក់ទំនងជាប្រចាំរវាងម្តាយនិងកូនអាចជារៀងរាល់សប្តាហ៍ ( ឬបើមិនអាចអាស្រ័យ ដោយចំងាយផ្លូវ អាចរៀងរាល់ខែ ) ដោយនាំកូនយកទៅសួរសុខទុក្ខម្តាយដោយផ្ទាល់ខ្លួន ។